# ប្រវត្តិព្រះអសីតិ
# មហាសាវ័ក
# ភាគទី ៧



ប្រមូលរៀបរៀងដោយ
ខ្ញុំព្រះករុណា
អាត្មាភាព **យង់ សុផាត**

# ប្រវត្តិព្រះអសីតិមហាសាវ័ក

## ភាគទី ៧

ប្រមូលរៀបរៀងដោយ
ខ្ញុំព្រះករុណា
អាត្មាភាព **យង់ សុផាត**

សម្រាប់ជាធម្មទាន

ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុផាត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ ៖ ២២២៥ សជណ

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១០

# ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
## ពិតថេរដីកា
## ព្រះតេជគុណ យង់ សុផាត ប្រធានសមាគមធម្មទានអរិយវង្ស យង់ សុផាត

**កម្មវត្ថុ** ៖ អំពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្សយង់ សុផាត*** នៅក្រសួងមហាផ្ទៃ។

**យោង** ៖ លិខិតលេខ***០១/១០ស.ធ.អ.យ.ផ*** ចុះថ្ងៃទី***២៣*** ខែ***តុលា*** ឆ្នាំ***២០០៩*** ស្តីពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្ស យង់ សុផាត*** ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំព្រះករុណាសូមពិតថេរដីកាព្រះតេជគុណប្រធានថា ក្រសួងមហាផ្ទៃយល់ព្រមចុះបញ្ជី***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ដែលមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលនៅភូមិ***រំចេក៣*** សង្កាត់***រតនៈ*** ក្រុង***បាត់ដំបង*** ខេត្ត***បាត់ដំបង*** នោះហើយ ។ ***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ត្រូវអនុវត្តតាមលក្ខន្តិកៈដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ និងធ្វើសកម្មភាពការងារក្នុងក្របខ័ណ្ឌជាសមាគមអព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើសកម្មភាពបម្រើឱ្យគណបក្សនយោបាយ និងមិនធ្វើជាឧបករណ៍គណបក្សនយោបាយ ។

ក្រោយពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមាន សមាគមធម្មទានអរិយវង្ស យង់ សុផាត ត្រូវដាក់ពាក្យសុំចុះបញ្ជីសាជាថ្មីអោយបានត្រឹមត្រូវតាមច្បាប់ ។

អាស្រ័យហេតុនេះ សូមព្រះតេជគុណប្រធានជ្រាបជាព័ត៌មាន ។
សូមព្រះតេជគុណប្រធាន ទទួលនូវការគោរពអំពីខ្ញុំព្រះករុណា ។

ស ខេង

**ចម្លងជូន ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- សាលាខេត្តបាត់ដំបង
  "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ

# អារម្ភកថា

សៀវភៅជីវប្រវត្តិព្រះអសីតិមហាសាវក ៨០ រូប ភាគ ៧ នេះ មានខ្លឹមសារជាប្រវត្តិរឿងរ៉ាវសាវកនាសម័យពុទ្ធកាល ដែលលោកបានទទួលតំណែងជាឯតទគ្គៈក៏មាន មិនបានទទួលតំណែងជាឯតទគ្គៈក៏មានដែរ ហើយមានឈ្មោះល្បីល្បាញនាសម័យនោះ ថែមទាំងជាអ្នកជួយផ្សព្វផ្សាយព្រះពុទ្ធសាសនា ឲ្យបានរុងរឿងចម្រើនដល់ពុទ្ធបរិស័ទនៅក្នុងសម័យនោះ ។

ក្នុងសម័យនោះ ពុទ្ធបរិស័ទដ៏ច្រើន សុទ្ធតែបានស្គាល់តំណែងឬភាពអស្ចារ្យ នៃព្រះថេរៈទាំងអស់នោះ ដោយថា អ្នកខ្លះ បានស្ដាប់ព្រះធម៌របស់លោក អ្នកខ្លះ បានធ្វើធម្មសាកច្ឆា អ្នកខ្លះ ក៏បានប្រគេនចង្ហាន់បិណ្ឌបាតដល់លោកជាដើម ។ ប៉ុន្តែ ឥឡូវនេះ ព្រះនាមរបស់ព្រះថេរៈខ្លះៗ ពុទ្ធបរិស័ទនាសម័យនេះ ស្ទើរតែលែងស្គាល់អស់ទៅហើយ ដោយសារហេតុនេះ សៀវភៅនេះនឹងបានជាពន្លឺជំនួយ ឲ្យដល់ពុទ្ធបរិស័ទ បានស្គាល់ច្បាស់នូវព្រះនាម គុណនាទី ចរិយា អធ្យាស្រ័យ

វត្តបដិបត្តិ និងការសម្ដែងព្រះធម៌ផ្សេងៗ របស់ព្រះថេរៈទាំងអស់នោះ ដែលមានសម្ដែងទុកនៅក្នុង **គម្ពីរថេរគាថា** និងក្នុង **គម្ពីរអបទាន** ជាដើម ព្រោះថា ព្រះពុទ្ធសាសនា ដែលរុងរឿងចម្រើន ក៏អាស្រ័យមានអ្នកចងចាំ បដិបត្តិតាម និងចេះសម្ដែងព្រះធម៌ ឲ្យដល់អ្នកដទៃបានស្ដាប់ មិនមែនដោយប្រការដទៃទេ ដូច្នេះ ព្រះថេរៈទាំងអស់នោះជាសក្ខីភាពបញ្ជាក់ថា ព្រះពុទ្ធសាសនា ដែលរុងរឿងនៅក្នុងសម័យនោះ ក៏ដោយសារលោកផងដែរ ទើបខ្ញុំព្រះករុណា អាត្មាភាព ខំប្រឹងប្រែងស្វែងរកក្បួនច្បាប់មកចងក្រងទុកជាពន្លឺដល់ពុទ្ធបរិស័ទក្នុងសម័យនេះ ។

សៀវភៅនេះ ខ្ញុំមិនអាចដាក់ភាសាបាលីផងបានទេ ព្រោះថាមានសេចក្ដីពិស្ដារពេក បើអ្នកសិក្សាត្រូវការភាសាបាលី ចូរតាមរកមើលក្នុង **គម្ពីរព្រះត្រៃបិដក** និង **អដ្ឋកថា** ក្នុងចំណុចដែលលើកឡើងមកនីមួយៗ ចុះ ព្រោះគ្រប់ចំណុច ដែលលើកឡើងមកនោះ សុទ្ធតែបានប្រាប់ពី **គម្ពីរ** ឬច្បាប់ដើម ជាមូលដ្ឋានរួចអស់ហើយ ។

ខ្ញុំសង្ឃឹមថា សៀវភៅនេះ នឹងបានជាប្រយោជន៍ ចំពោះបុគ្គលអ្នកប្រាថ្នាការចេះដឹងក្នុងព្រះពុទ្ធវចនៈ បើមិនក្រៃលែង ក៏ប្រសើជាងអត់

ផងដែរ ខ្ញុំ និងសព្រហ្មចារី ខំប្រឹងប្រែងអស់ពីកម្លាំងកាយ កម្លាំងចិត្ត ពិនិត្យផ្ទៀងផ្ទាត់យ៉ាងហ្មត់ចត់ ទោះបីយ៉ាងនោះក៏ដោយ ក៏គង់នៅមានខុសមិនខាន ដូនដោយចេះមិនដល់ ដូនដោយការភ្លេចភ្លាំង ជាពិសេសនោះគឺអក្ខរាវិរុទ្ធ ដូច្នេះ យើងខ្ញុំ សូមសង្ឃឹមនៅលើលោកអ្នកជាបណ្ឌិតជាសប្បុរស ជួយកែលម្អ ឲ្យដល់យើងខ្ញុំផង ដើម្បីជាប្រយោជន៍ដល់ជាតិ សាសនា របស់យើងទាំងអស់គ្នា ។

សូមអស់មិត្តអ្នកអាន បានទទួលនូវការចេះដឹង ជាគ្រឿងរំលឹកផ្ទាល់ខ្លួន ដើម្បីបានជាកិច្ចប្រតិបត្តិ ឬបានជាឧបនិស្ស័យប្រហារបង់នូវអាសវក្កិលេស បានចូលដល់សន្តិបទ គឺព្រះនិព្វាន ។

ចំពោះបុណ្យធម្មទាននេះ និងបុណ្យកុសលដទៃៗ ទៀត ដូចជាបុណ្យថ្នាក់ការសម្តែងព្រះធម៌ នៅក្នុងកម្មវិធីបុណ្យផ្សេងៗ ទៅតាមខេត្ត ក្រុង ជាច្រើន នៅក្នុងប្រទេសកម្ពុជានេះ ដោយខ្ញុំព្រះករុណាអាត្មាភាព បានសម្តែងព្រះធម៌ នៅកន្លែងណាៗ ក៏តែងតែបានទុកដាក់ប្រាក់បូជាព្រះធម៌ នៅកន្លែងនោះវិញ គ្រប់ៗ កន្លែង ដោយសរុបប្រាក់នៅក្នុង ព.ស. **២៥៥០ ប្រាក់ខ្មែរបាន ១៨.៤៩៥០០០ រៀល ( ១៨ លាន ៤**

**សែន ៩ ម៉ឺន ៥ ពាន់រៀល ) និងប្រាក់ដុល្លារ ៦៨៥ ដុល្លារសហរដ្ឋអាមេរិក ។** *នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង* **ប្រទេសឥណ្ឌា ដែលមានពុទ្ធបរិស័ទនៅប្រមាណ ៦៥ នាក់** *ក្នុងនោះ ក៏មាន* **ព្រះសង្ឃ ១០ ព្រះអង្គផងដែរ** *ដែលមានលោកគ្រូអគ្គបណ្ឌិត* **ប៊ុត សាវង្ស** *ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដោយទៅ* **ថ្វាយបង្គំបាន ៥១ កន្លែង** *បានការឧបត្ថម្ភអំពីឧបាសក* **ឡាយ ស្មុខុម** *និងឧបាសិកា* **ឌិម លក្ខណា** *នៅក្នុង* **ព.ស. ២៥៥០** *( ១០.០២.២០០៧ ) ។*

## **នឹកឃើញស្រុកព្រះ**

*នឹកឃើញស្រុកព្រះ   បានក្រាបសំពះ   អង្គព្រះសាស្ដា*
*សិរសោលំទោន   ទុកដូចឈូកផ្កា   បូជាសាស្ដា*
*ជ្រះថ្លាក្រៃលែង ។*
*៦៥ អង្គា   គាល់ព្រះកគវា   ៥១ កន្លែង*
*នៅស្រុកឥណ្ឌា   ចងចាំមិនលែង   សោមនស្សពន់ពេក*
*ក្នុង ព.ស.២៥៥០ ។*

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥១ ផ្នែកខាងសម្តែងព្រះធម៌ ដូចគ្នានឹង ព.ស. ២៥៥០ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. **២៥៥១ ប្រាក់ខ្មែរបាន ១៥.៨៣១០០០ រៀល ( ១៥ លាន ៨ សែន ៣ ម៉ឺន ១ ពាន់រៀល)** និង **ប្រាក់ដុល្លារ ៤៥ ដុល្លារ ។** នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសស្រីលង្កា** ដែលមានលោកគ្រូអគ្គបណ្ឌិត **ម៉ុត សារឧត្ត** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **១២១ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ៤ ព្រះអង្គផងដែរ** ដោយទៅថ្វាយបង្គំបាន **១៩ កន្លែង** បានការឧបត្ថម្ភមកអំពីឧបាសក **ឡាយ សុខុម** និងឧបាសក **សោម រតនៈ** ឧបាសិកា **ស៊ិម ចណ្ណា** នៅក្នុង **ព.ស. ២៥៥១** ( ០៤.០៤.២០០៨ ) ។

## នឹកឃើញលង្កា

| | | |
|---|---|---|
| នឹកឃើញលង្កា | នឹកឃើញកាលណា | ជ្រះថ្លាក្រៃលែង |
| នៅពុទ្ធស្ថាន | ១៩ កន្លែង | ដែលខ្ញុំបានស្វែង |
| | ទៅថ្វាយបង្គំ ។ | |

១២១ អង្គា គាល់ព្រះបាទា នាស្ថានមនោរម

លើសុមនកូដ ជេស្ដាឧត្ដម ជាកំពូលភ្នំ

ក្នុងប្រវត្តិពុទ្ធ ។

ទឹកដីលង្កា ទឹកដីអស្ចារ្យ ពេញពោរដោយឫទ្ធិ

នឹកឃើញកាលណា ជ្រះថ្លាក្រៃពិត ធម្មយាត្រាប្រណីត

ក្នុង ព.ស.២៥៥១ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥២ ផ្នែកខាងសម្ដែងព្រះធម៌ ដូចគ្នានឹង ព.ស. ២៥៥១ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. **២៥៥២ ប្រាក់ខ្មែរបាន ២៧.១២៨០០០ រៀល (២៧ លាន ១ សែន ២ ម៉ឺន ៨ ពាន់រៀល) និងប្រាក់ដុល្លារ ១៩៥ ដុល្លារ ។** នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសឥណ្ឌាជាលើកទីពីរ** ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** មានលោកគ្រូធម្មបណ្ឌិត **រស់ សុផាត** និងលោកគ្រូធម្មាចារ្យ **អឿ សៅ** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **៦៧ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ៥**

ព្រះអង្គផងដែរ បានការឧបត្ថម្ភមកអំពីឧបាសក ឃឹត សូណាត ឧបាសិកា ហ៊្វិន ម៉ារ៉ាវនី M. SU SOKUNORA et Mme INN VISAL + NARITA et RAKSA. ក្រោមការជ្រោមជ្រែងរបស់ឧបាសិកា អ៊ីច រិទ្ធារី ឧបាសិកា សួន គល្យាណ ឧបាសិកា សួន ចរណៃ នៅក្នុង ព.ស. ២៥៥២ ( ១៦.០២.២០០៩ ) ។

## ជ្រះថ្លាខ្លាំងណាស់

ជ្រះថ្លាខ្លាំងណាស់ ព្រះពុទ្ធជាម្ចាស់ គុណធំក្រៃលែង
ច្រើនពុទ្ធសករាជ សាសនាអង្វែង ល្អហួសការថ្លែង
ឱ! ព្រះសាសនា ។
នៅស្រុកឥណ្ឌា ៦៧ អង្គា រួមគ្នានមស្ការ
១០៩ ពុទ្ធស្ថាន ព្រមចិត្តផូផង់ថ្លា បីតិអស្ចារ្យ
ក្នុង ព.ស. ២៥៥២ ។

នៅមានបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថានផ្សេងៗ នៅក្នុង **ប្រទេសស្រីលង្កាជាលើកទីពីរ** ដែលមានលោកគ្រូធម្មបណ្ឌិត **រស់ សុធារត** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ

៣៦ នាក់ នៅក្នុងនោះទៀត ក៏មាន ព្រះសង្ឃ ៣ ព្រះអង្គផងដែរ បាន ការឧបត្ថម្ភមកអំពីឧបាសក ឆាយ អ៊ីចស៊ាង ឧបាសិកា ហុង គីមសៃ ក្រោមការជ្រោមជ្រែងរបស់ឧបាសក យន្ត សួន នៅក្នុង ព.ស. ២៥៥២ ( ១១.០៣.២០០៩ ) ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥៣ ផ្នែកខាងសម្តែងព្រះធម៌ ដូចគ្នានឹង ព.ស. ២៥៥២ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥៣ ប្រាក់ខ្មែរបាន ១៣.០៨០០០០ រៀល ( ១៣ លាន ០ សែន ៨ ម៉ឺន ) និងប្រាក់ដុល្លារ ២០៨ ដុល្លារ ។នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសលដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុងប្រទេសឥណ្ឌាជាលើកទី ៣ ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ ១១១ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ៦ ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន ៩៦ កន្លែង បានការជ្រោមជ្រែងពីឧបាសក ឡាយ សុខុម នៅក្នុង ព.ស. ២៥៥៣ ( ២៥.០១.២០១០ ) ។

## ស្រណោះស្រុកព្រះ

*ស្រណោះស្រុកព្រះ ធ្លាប់តែល្អល្អះ ឥឡូវអនិច្ចា !*
*យើងខ្ញុំទាំងឡាយ បានទៅនមស្ការ ស្ងប់ស្ងៀមអស្ចារ្យ*
*ឱះឱ! ពុទ្ធស្ថាន ។*
*នឹកឃើញកាលណា ចិត្តខ្ញុំជ្រះថ្លា គ្មានអ្វីប្រៀបបាន*
*១១១ អង្គា ៩៦ ពុទ្ធស្ថាន ព.ស.រាប់បាន*
*២៥៥៣ ។*

*នៅមានបុណ្យកុសលនៅក្នុង* **ព.ស. ២៥៥៤** *ផ្នែកខាងសម្តែងព្រះធម៌ ដូចគ្នានឹង* **ព.ស. ២៥៥៣** *ដែរ ដោយសរុបប្រាក់នៅក្នុង* **ព.ស. ២៥៥៤ ប្រាក់ខ្មែរបាន ៣១.៩៩០០០០ រៀល** *(* **៣១ លាន ៩ សែន ៩ ម៉ឺន** *)* **និងប្រាក់ដុល្លារ ៧២០ ដុល្លារ ។** *នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសលដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង* **ប្រទេសឥណ្ឌាជាលើកទី ៤** *ដែលមានលោកគ្រូអគ្គបណ្ឌិត* **ប៊ុត សាវង្ស** *ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ* **១១១ នាក់** *ក្នុងនោះ ក៏មាន* **ព្រះសង្ឃ ៥** *ព្រះអង្គផងដែរ ដោយទៅ*

ថ្វាយបង្គំបាន ៩៦ កន្លែង បានការជ្រោមជ្រែងពីឧបាសក ឡាយ សុខុម នៅក្នុង ព.ស. ២៥៥៤ ( ២៧.០២.២០១១ ) ។

## គួរឱ្យសង្វេគ

គួរឲ្យសង្វេគ ស្រណោះពន់ពេក ពេលឃើញពុទ្ធស្ថាន
ធ្លាប់តែរុងរឿង ចម្រើនថ្កើងថ្កាន ឥឡូវប្រែឋាន
ប្រៀបបានព្រៃស្ងាត់ ។
២៧៧ អង្គា ប្រណម្យវន្ទា បង្គំថ្វាយថ្វាត់
បូជនីយដ្ឋាន ១២ នាដែនពុទ្ធរដ្ឋ ធម្មយាត្រាកំណត់
ក្នុងពុទ្ធសករាជ ២៥៥៤ ។

ហេតុដូច្នេះ ដោយបុណ្យកុសលនេះ ខ្ញុំព្រះករុណា សូមឧទ្ទិសមហាកុសលទាំងអស់នេះ ជូនចំពោះញោមប្រុស យង់ សុខ ( ស្លាប់ ) និងញោមស្រី ឈឹម ហាយ ( ស្លាប់ ) ម្យ៉ាងទៀត ញាតិកានៅក្នុងសង្សារវដ្ត ជាពិសេសនោះ សូមលើកមហាកុសលទាំងអស់នេះ ជូនចំពោះលោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ម៉ុត សារឧឡ្សៃ លោកគ្រូធម្មបណ្ឌិត

របស់ ស្ងួនគ និងលោកគ្រូធម្មាចារ្យ គាំ ឡឹង ជាដើម សូមឲ្យបាននូវចំណែកបុណ្យកុសលនេះ ស្មើនឹងអាត្មាភាពផងដែរ **សូមអនុមោទនា !!!**
ក៏សូមឲ្យមិត្តអ្នកកំពុងតែកាន់សៀវភៅនេះអាន ឲ្យបានបុណ្យកុសលនៃធម្មទាននេះគ្រប់ៗ គ្នា សូមអនុមោទនានូវចំណែកនៃបុណ្យកុសលនេះ ឲ្យបានស្មើនឹងខ្ញុំព្រះករុណា អាត្មាភាពផងដែរ ។

ម្យ៉ាងទៀត ដោយអំណាចបុណ្យកុសលទាំងអស់នេះ ក៏សូមឲ្យបានជាឧបនិស្ស័យ ក្នុងការអស់ទៅនៃអាសវក្កិលេស នាកាលជាអនាគតកុំបីអាក់ខានឡើយ ( សូមឲ្យបានជាសាវកបារមីញាណ ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធអង្គណាទីមួយ ដែលជាឯតទគ្គៈផ្នែកខាងពហូសូត ១ មានសតិ ១ មានគតិ ១ មានធិតិ ១ ជាពុទ្ធុបដ្ឋាក ១ ) សូមឲ្យព្រះពុទ្ធសាសនារុងរឿងចម្រើន សូមឲ្យព្រះពុទ្ធសាសនាផ្សាយទូទៅពេញសកលលោក សូមឲ្យលោកទាំងមូល បានប្រកបដោយសន្តិភាព ព្រះសក្យមុនីទ្រង់ត្រាស់ថា **នត្ថិ សន្តិ បរំ សុខំ** ពុំមានសេចក្តីសុខដទៃ ក្រៅអំពីសេចក្តីស្ងប់ឡើយ ។

អាស្រមព្រះគន្ធកុដិ ថ្ងៃ ៨ កើត ខែពិសាខ ព.ស. ២៥៥៥

**ដោយប្រធានសមាគមធម្មទានអរិយទន្សាយចំស្ងួនគ**

# ឈ្មោះអ្នកជួយប្រែ និងពិនិត្យអក្ខរាវិរុទ្ធ

លោកអ្នកដ៏មានអាយុ ម៉ី សាលួន ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ សឿង គុសល ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ គឹម ម៉ានិត ជួយប្រែ

លោកអ្នកដ៏មានអាយុ ម៉ុន ប៊ូរា ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ អ៊ឹម សុជាន ជួយប្រែ

លោកអ្នកដ៏មានអាយុ មាន ចន្ធនា ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ ពេជ្រ ឧត្តម ជួយវាយកុំព្យូទ័រ

ឧបាសក អ៊ឹម វ៉ៃយ៉ា ជាទីប្រឹក្សាក្នុងកិច្ចការងារធម្មទាន

ឧបាសក សន ឈៀត ជួយប្រែ

ឧបាសក ឡាន សុខុម ជួយប្រែ

ឧបាសក បួ ស៊ីផួ ជួយពិនិត្យអក្ខរាវិរុទ្ធ

លោកគ្រូធម្មាចារ្យ គាំ អ៊ីច ជួយពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក ឌិម ជំនិត ជួយពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក រីម សុមេធ ជួយពិនិត្យអក្ខរាវិរុទ្ធ

ឱ

# សមាជិកសមាគមធម្មទានអរិយវង្សយង់ស៊ុនផាត

សម្ដេចព្រះសង្ឃរាជគណមហានិកាយ **នន្ទ ង៉ែត** ជាប្រធានកិត្តិយស

ភិក្ខុ អគ្គបណ្ឌិតោ **យង់ ស៊ុនផាត** ជាប្រធានសមាគម

លោកអភិបាលស្រុក ស្រេង ស្រ៊ាង ជាទីប្រឹក្សាសមាគម

ឧបាសក **អ៊ឹម អ៊ៃយ៉ា** ជាអនុប្រធានសមាគម

ឧបាសិកា **ង៉ែត យូអេង** ជាអនុប្រធានសមាគម

សាមណេរ **ម៉ី សាលួន** ជាលេខាធិការ

ឧបាសក **ឡាន ស៊ុខុម** ជាលេខាធិការរង

ឧបាសិកា **តាំង ប៉ោងជឹង** ជាហេរញ្ញិក

ឧបាសិកា **ជា នាង** ជាបេឡា

លោកគ្រូធម្មបណ្ឌិត **អឿ សៅ** សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក **ឡាយ ស៊ុខុម** សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា **អ៊ឹង រិទ្ធារី** សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា **ហោ នាព** សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា **គួ ម៉ិនគាង** សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា **ឈុំ ស៊ុធា** សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ម៉ែន រម្មណីយ៍ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ឌិម លក្ខណា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក អ៊ឹង ប៊ុនហួរ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា មួ ម៉ាឡា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក ប៊ុន ហេង សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ជុំ សុខុម សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ហេង ស្រីដា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ហេង ស្រីចន្ទ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ហេង គន្ធា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក ហេង សុភ័ក្រ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា តែង តល្យណា ជាសមាជិកសកម្ម

ឧបាសិកា ឡៀង ធីតា ជាសមាជិកសកម្ម

ឧបាសិកា ម៉ៅ នី ជាសមាជិកសកម្ម

ឧបាសិកា ហេង ចន្ទបុញ្ញាវតី ជាសមាជិកសកម្ម

ឧបាសក ហួង សុវណ្ណារិទ្ធ ជាសមាជិកសកម្ម

ឧបាសក ហួង សុវណ្ណារ៉ែត ជាសមាជិកសកម្ម

# មាតិការឿង

ល.រ ទំព័រ

១- ឈ្មោះរបស់ភិក្ខុ .................................................... ទ

២- ជីវប្រវត្តិរបស់ព្រះមហាចុន្ទត្ថេរ ................................ ១

លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវកផងដែរ

៣- ជីវប្រវត្តិរបស់ព្រះអជិតត្ថេរ ...................................... ៧១

លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវកផងដែរ

៤- ជីវប្រវត្តិរបស់ព្រះជោតកត្ថេរ .................................. ១១៩

លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវកផងដែរ

៥- ជីវប្រវត្តិរបស់ព្រះបុណ្ណកត្ថេរ .................................. ១៣៤

លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវកផងដែរ

៦- ជីវប្រវត្តិរបស់ព្រះឧបសីវត្ថេរ .................................. ១៤៨

លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវកផងដែរ

៧- ជីវប្រវត្តិរបស់ព្រះនន្ទកត្ថេរ .................................... ១៦៨

លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវកផងដែរ

៨- ជីវប្រវត្តិរបស់ព្រះហេមកត្ថេរ .................................. ១៨៤

លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវកផងដែរ

៩- ជីវប្រវត្តិរបស់ព្រះតោទេយ្យត្ថេរ .............................. ២០០

លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវកផងដែរ

១០- ជីវប្រវត្តិរបស់ព្រះកប្បត្ថេរ ................................... ២១៨

លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវកផងដែរ

១១- ជីវប្រវត្តិរបស់ព្រះជតុកណ្ណិត្ថេរ ............................. ២២៨

លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវកផងដែរ

១២- ជីវប្រវត្តិរបស់ព្រះភទ្រាវុធត្ថេរ .............................. ២៤៧

លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវកផងដែរ

១៣- ជីវប្រវត្តិរបស់ព្រះឧទយត្ថេរ ................................. ២៥៧

លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវកផងដែរ
១៤- ជីវប្រវត្តិរបស់ព្រះបោសាលត្ថេរ ............................ ២៦៨
លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវកផងដែរ
១៥- ជីវប្រវត្តិរបស់ព្រះបិង្គិយត្ថេរ ................................. ២៧៨
លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវកផងដែរ
១៦- ជីវប្រវត្តិរបស់ព្រះនាគិតត្ថេរ ................................. ២៩៥
លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវកផងដែរ
១៧- ជីវប្រវត្តិរបស់ព្រះនាលកត្ថេរ ................................ ៣១៧
លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវកផងដែរ

# ប្រវត្តិព្រះអសីតិមហាសាវ័ក ៨០ រូប

ព្រះថេរៈទាំង ៨០ រូប មានព្រះអញ្ញាកោណ្ឌញ្ញៈ ព្រះសារីបុត្រ ព្រះមហាមោគ្គល្លានជាដើម សុទ្ធសឹងតែជាមហាសាវ័កដែលមានជំនាញឯកទេស ដែលគ្មានអ្នកដទៃប្រដូចបាន បាលីហៅថា **ឯតទគ្គៈ** គឺបានដល់ភាពជាកំពូលរបស់ភិក្ខុមួយរូបៗ ដូចជាព្រះអញ្ញាកោណ្ឌញ្ញៈ ជាកំពូលផ្នែកខាងជាអ្នកបានបួសមុនគេ និងបានត្រាស់ដឹងព្រះធម៌មុនគេ ព្រះសារីបុត្រ ជាកំពូលផ្នែកខាង ជាអ្នកមានបញ្ញាគ្មានសាវ័កណាផ្ទឹមបាន ព្រះមហាមោគ្គល្លានជាកំពូលផ្នែកខាងឫទ្ធិ គ្មានសាវ័កណាស្មើផ្ទឹមបានដែរ យ៉ាងនេះជាដើម ។

ដូច្នេះ មហាសាវ័ករបស់ព្រះបរមគ្រូនៃយើងមាន ៨០ រូប ដូចមានព្រះនាមរបស់លោកខាងក្រោមនេះ គឺ

១- ព្រះអញ្ញាកោណ្ឌញ្ញៈ ២- ព្រះសារីបុត្រ

៣- ព្រះមោគ្គល្លាន ៤- ព្រះកស្សបៈ

៥- ព្រះអនុរុទ្ធ ៦-ព្រះភទ្ទិយកាឡិគោធាយបុត្រ

៧- ព្រះលកុណ្ដកភទ្ទិយៈ ៨- ព្រះបិណ្ឌោលភារទ្វាជៈ

៩- ព្រះបុណ្ណមន្តានីបុត្រ ១០- ព្រះមហាកច្ចាយនៈ

១១- ព្រះចូឡបន្ថកៈ ១២- ព្រះមហាបន្ថកៈ

១៣- ព្រះសុភូតិ ១៤- ព្រះរេវតខទិរវនិយៈ

១៥- ព្រះកង្ខារេវតៈ ១៦- ព្រះសោណកោលិវិសៈ

១៧- ព្រះសោណកុដិកណ្ណៈ ១៨- ព្រះសីវលី

១៩- ព្រះវក្កលិ ២០- ព្រះរាហុល

២១- ព្រះរដ្ឋបាល ២២- ព្រះកុណ្ឌធាន

២៣- ព្រះវង្គីសៈ ២៤- ព្រះឧបសេនវង្គន្តបុត្រ

២៥- ព្រះទព្វមល្លបុត្រ ២៦- ព្រះបិលិន្ទវច្ឆៈ

២៧- ព្រះពាហិយទារុចីរិយៈ ២៨- ព្រះកុមារកស្សបៈ

២៩- ព្រះមហាកោដ្ឋិតៈ ៣០- ព្រះអានន្ទ

៣១- ព្រះឧរុវេលកស្សបៈ ៣២- ព្រះកាឡុទាយី

៣៣- ព្រះពាកុលៈ ៣៤- ព្រះសោភិតៈ

៣៥- ព្រះឧបាលិ ៣៦- ព្រះនន្ទកៈ

| | |
|---|---|
| ៣៧- ព្រះនន្ទសក្យ: | ៣៨- ព្រះមហាកប្បិន |
| ៣៩- ព្រះសាគត: | ៤០- ព្រះរាធ: |
| ៤១- ព្រះមោឃរាជ | ៤២- ព្រះមហានាម |
| ៤៣- ព្រះអស្សជិ | ៤៤- ព្រះយស |
| ៤៥- ព្រះវិមល | ៤៦- ព្រះសុពាហុ |
| ៤៧- ព្រះបុណ្ណជិ | ៤៨- ព្រះគវម្បតិ |
| ៤៩- ព្រះនទីកស្សប: | ៥០- ព្រះគយាកស្សប: |
| ៥១- ព្រះកគ្គុ | ៥២- ព្រះកិម្ពិល: |
| ៥៣- ព្រះមហាចុន្ទ | ៥៤- ព្រះអជិត: |
| ៥៥- ព្រះតិស្សមេត្តេយ្យ | ៥៦- ព្រះបុណ្ណក: |
| ៥៧- ព្រះមេត្តគូ | ៥៨- ព្រះធោតក: |
| ៥៩- ព្រះឧបសីវ: | ៦០- ព្រះនន្ទកត្ថេរ |
| ៦១- ព្រះហេមក: | ៦២- ព្រះតោទេយ្យ |
| ៦៣- ព្រះកប្ប: | ៦៤- ព្រះជតុកណ្ណី |
| ៦៥- ព្រះភទ្រាវុធ | ៦៦- ព្រះឧទយត្ថេរ |

ប

៦៧- ព្រះបោសាលះ

៦៨- ព្រះបិង្គិយះ

៦៩- ព្រះនាគិតះ

៧០- ព្រះនាលកះ

៧១- ព្រះបុណ្ណះ

៧២- ព្រះមេឃិយះ

៧៣- ព្រះយសោជះ

៧៤- ព្រះសភិយះ

៧៥- ព្រះសេលះ

៧៦- ព្រះឧទាយី

៧៧- ព្រះឧបវាណះ

៧៨- ព្រះអង្គុលិមាល

៧៩- ព្រះវប្បះ

៨០- ព្រះភទ្ទិយះ ។

# ✍ ជីវប្រវត្តិរបស់ព្រះមហាចុន្ទត្ថេរ ✍

## " លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័កផងដែរ "

ព្រះមហាចុន្ទត្ថេរ លោកជាមហាសាវ័ក ដែលរាប់ចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័ក គឺជាសាវ័កធំ ៨០ រូប របស់ព្រះមុនីដែលជាអ្នកមាននូវឧបការគុណ ក្នុងការផ្សព្វផ្សាយព្រះធម៌វិន័យរបស់ព្រះពុទ្ធអង្គ មិនមែនត្រឹមតែប៉ុណ្ណោះ លោកក៏ធ្លាប់ជាពុទ្ធុបដ្ឋាករបស់ព្រះលោកនាយកផងដែរក្នុងកាលខ្លះ ទាំងនេះក៏ជាកិត្តិយសដ៏ខ្ពង់ខ្ពស់របស់លោកផងដែរ មានគម្ពីរខ្លះបានសម្ដែងថា លោកក៏ជាធម្មកថិកមួយរូបដ៏ឆ្នើម ក្នុងព្រះពុទ្ធសាសនានេះផងដែរ ។

ជីវប្រវត្តិបច្ចុប្បន្នជាតិនេះរបស់ព្រះមហាចុន្ទត្ថេរ មានសម្ដែងទុកនៅក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីព្រះបាលី **គម្ពីរខុទ្ទកនិកាយ ថេរគាថា** ដូចមានសេចក្ដីថា ៖

ព្រះមហាចុន្ទត្ថេរ កើតនៅក្នុងតំបន់នាលកៈ ឬនាលន្ទា ដែល

តាំងនៅមិនឆ្ងាយពីក្រុងរាជគ្រឹះ ដែលស្ថិតនៅក្នុងដែនមគធៈ បិតាឈ្មោះថា **វង្គន្តព្រាហ្មណ៍** មាតាឈ្មោះថា **នាងសារីព្រាហ្មណី** បិតារបស់លោកមានតំណែងជាមេស្រុកក្នុងតំបន់នោះ ឈ្មោះដើមរបស់លោកថា **ចុន្ទ** លោក គឺជាប្អូនប្រុសបង្កើតរបស់ព្រះសារីបុត្រ ។ ការចេញបួសរបស់ចុន្ទកុមារនេះ ព្រោះលោកចេញបួសតាមព្រះសារីបុត្រ ដែលជាបងប្រុសរបស់លោក ដោយមានព្រះអានន្ទ ជាព្រះឧបជ្ឈាយ៍ ( នេះពោលតាម **អដ្ឋកថាសាមគ្គាសូត្រ គម្ពីរបបញ្ចសូទនី** ) ។ កាលដែលលោកបួសរួចហើយ ភិក្ខុទាំងឡាយ និយមហៅលោកដោយពាក្យថា **មហា** នាំមុខឈ្មោះរបស់លោក ទើបមានឈ្មោះថា **មហាចុន្ទ** ។ សូម្បីរឿងរបស់លោក ដែលមានសម្តែងនៅក្នុងគម្ពីរផ្សេងៗ ក៏តែងតែនឹងប្រើពាក្យថា **អាយស្មា មហាចុន្ទោ** ប្រែថា ព្រះមហាចុន្ទដ៏មានអាយុ តែកន្លែងខ្លះហៅលោកថា **ចុន្ទសមណុទ្ទេស** ។ កាលព្រះមហាចុន្ទបានបួសរួចហើយ ក៏តាំងចិត្តប្រឹងប្រែងព្យាយាម ចម្រើនវិបស្សនាកម្មដ្ឋាន មិនយូរប៉ុន្មាន លោកក៏បានសម្រេចអភិញ្ញា ៦ ជា

ព្រះអរិយបុគ្គលមួយរូបក្នុងព្រះពុទ្ធសាសនានេះ បានសេចក្ដីថា លោកបានសម្រេចជាព្រះអរហន្ត តាំងពីនៅជាសាមណេរ មានអាយុ ៧ ខួបមកម៉្លេះ ។

កាលលោកបានសម្រេចអភិញ្ញាហើយ លោកមានបំណងចង់រស់នៅក្នុងទីស្ងប់ស្ងាត់ ដែលជាឧបនិស្ស័យនៃគុណសម្បត្តិ ដែលលោកបានមកហើយ ទើបបានពោលគាថាទុកពីរគាថា ដូចដែលមានសម្ដែងទុកនៅក្នុង គម្ពីរខុទ្ទកនិកាយ ថេរគាថា មានសេចក្ដីថា ៖

ការស្ដាប់ដោយល្អ ជាការចម្រើននៃអ្នកស្ដាប់ ការស្ដាប់ជាការចម្រើននៃបញ្ញា (ព្រោះ) បុគ្គល រមែងយល់សេចក្ដីបានដោយសារបញ្ញា សេចក្ដីដែលយល់ហើយ រមែងនាំសុខមកឲ្យ ។ បុគ្គលគួរសេពសេនាសនៈស្ងាត់ គួរប្រព្រឹត្តធម៌ ដែលជាហេតុរួចស្រឡះចាកសំយោជនៈ បើមិនបានសេចក្ដីត្រេកអរក្នុងទីស្ងាត់នោះទេ គប្បីជាអ្នកមានសតិ រក្សាខ្លួននៅក្នុងពួកចុះ ។

មានហេតុផលដែលសន្និដ្ឋានថា ព្រះមហាចុន្ទត្ថេរជាធម្មកថិក

នោះ មានសូត្រដែលគួរពិចារណាពីរសូត្រ គឺ **សល្លេខសូត្រ** ដែលជាព្រះសូត្រពោលដល់ការជុសខាត់កិលេស ១ និង **មហាចុន្ទសូត្រ** ដែលជាព្រះសូត្រសម្ដែងដល់អ្នកពេញចិត្តតិះដៀលគ្នានិងគ្នា ១ ។

ព្រះមហាចុន្ទ លោកធ្លាប់បានក្រាបទូលព្រះមានបុណ្យចំពោះពិធីដែលលះបង់ទិដ្ឋិ តាមដែលមានរឿងសម្ដែងប្រាកដនៅក្នុង **គម្ពីរមជ្ឈិមនិកាយ មូលបណ្ណាសកៈ** នៃ **សល្លេខសូត្រ** ថា ៖

សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រះមហាចុន្ទមានអាយុ ចេញអំពីទីពួនសំងំ ក្នុងសាយណ្ហសម័យ ហើយចូលទៅគាល់ព្រះមុនី លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះសាស្ដា ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះមហាចុន្ទមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះសុគតយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើនទិដ្ឋិទាំងឡាយ ( បានដល់មិច្ឆាទិដ្ឋិ ) ច្រើនប្រការណា ដែលជាទិដ្ឋិប្រកបដោយអត្តវាទខ្វះ ( ប្រកបដោយសក្កាយទិដ្ឋិ ២០ ) ប្រកប

ដោយលោកវាទខ្លះ ( ប្រកបដោយមិច្ឆាទិដ្ឋិ ៨ មានការឃើញថា ខ្លួនក្តី លោកក្តី ជារបស់ទៀងជាដើម ) កើតឡើងក្នុងលោក បពិត្រព្រះអង្គដ៏ចម្រើន កាលបើភិក្ខុធ្វើទុកក្នុងចិត្តជាដំបូង តើលះបង់ទិដ្ឋិទាំងនោះដោយឧបាយយ៉ាងនេះ ចោលទិដ្ឋិទាំងនោះ ដោយឧបាយយ៉ាងនេះបានឬទេ ? ព្រះអង្គត្រាស់តបថា ម្នាលចុន្ទ ទិដ្ឋិទាំងឡាយមានច្រើនប្រការ ដែលជាទិដ្ឋិប្រកបដោយអត្តវាទខ្លះ ប្រកបលោកវាទខ្លះ កើតឡើងក្នុងលោក ទិដ្ឋិទាំងឡាយនោះ កើតក្នុងបញ្ចក្ខន្ធណា ដេកសំងំនៅក្នុងបញ្ចក្ខន្ធណា ផុសផុលឡើងក្នុងបញ្ចក្ខន្ធណា កាលបើភិក្ខុឃើញច្បាស់នូវបញ្ចក្ខន្ធនោះ តាមសេចក្តីពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា នេះមិនមែនរបស់អញ នេះមិនមែនអញ នេះមិនមែនខ្លួនរបស់អញដូច្នេះ ការលះបង់នូវទិដ្ឋិទាំងឡាយនេះ គង់មានដោយឧបាយយ៉ាងនេះបាន ការលោះបង់ចោលនូវទិដ្ឋិទាំងឡាយនោះ គង់មានដោយឧបាយយ៉ាងនេះបាន ។

ម្នាលចុន្ទ ហេតុនេះ តែងមានជាប្រាកដ គឺភិក្ខុពួកខ្លះ ក្នុង

សាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយហើយ ចូលបឋមជ្ឈាន ប្រកបដោយវិតក្ក វិចារៈ មានបីតិនិងសុខដែលកើតអំពីវិវេក ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញ នៅដោយសេចក្តីផ្សួរផង់ដូច្នេះ ម្នាលចុន្ទ តែតថាគតមិនទាន់ឲ្យឈ្មោះធម៌ទាំងនោះ ថាជាសេចក្តីផ្សួរផង់ក្នុងវិន័យរបស់ព្រះ-អរិយៈទេ គ្រាន់តែឲ្យឈ្មោះធម៌ទាំងនោះថា ជាការនៅសប្បាយក្នុងបច្ចុប្បន្ន ក្នុងវិន័យរបស់ព្រះអរិយៈ ( ប៉ុណ្ណោះ )។ ម្នាលចុន្ទ ហេតុនេះតែងមានជាប្រាកដ គឺភិក្ខុពួកខ្លះ ក្នុងសាសនានេះ ចូលទុតិយ-ជ្ឈានដែលកើតក្នុងសន្តានខ្លួន ប្រកបដោយសេចក្តីជ្រះថ្លា គឺសទ្ធាមានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្ក មិនមានវិចារៈ មានបីតិ និងសុខកើតអំពីសមាធិ ព្រោះស្ងប់រម្ងាប់វិតក្ក និងវិចារៈ ភិក្ខុនោះ មានសេចក្តីសម្គាល់ថា អាត្មាអញនៅដោយសេចក្តីផ្សួរផង់ដូច្នេះ ម្នាលចុន្ទ តែថាតថាគតមិនទាន់ឲ្យឈ្មោះធម៌ទាំងនោះ ថាជាសេចក្តីផ្សួរ-ផង់ក្នុងអរិយវិន័យទេ គ្រាន់តែឲ្យឈ្មោះធម៌ទាំងនោះថា ជាការនៅ

សប្បាយក្នុងបច្ចុប្បន្ន ក្នុងអរិយវិន័យប៉ុណ្ណោះ ។ ម្នាលចុន្ទ ហេតុនេះ តែងមានជាប្រាកដ គឺភិក្ខុពួកខ្លះ ក្នុងសាសនានេះ មានចិត្តព្រងើយកន្តើយ ព្រោះនឿយណាយចាកបីតិ តែមានស្មារតីដឹងខ្លួនទទួលសេចក្តីសុខដោយនាមកាយ ព្រះអរិយៈទាំងឡាយ តែងតែសរសើរបុគ្គលប្រកបដោយតតិយជ្ឈាននោះថា បុគ្គលប្រកបដោយតតិយជ្ឈាន មានចិត្តព្រងើយកន្តើយ មានស្មារតីនៅជាសុខ ដូច្នេះដោយតតិយជ្ឈានណា ( ភិក្ខុនោះ ) បានចូលតតិយជ្ឈាននោះ ភិក្ខុនោះមានសេចក្តីសម្គាល់ថា អាត្មាអញនៅ ដោយសេចក្តីផូរផង់ដូច្នេះ ម្នាលចុន្ទ តែតថាគតមិនទាន់ឲ្យឈ្មោះធម៌ទាំងនោះ ថាជាសេចក្តីផូរផង់ក្នុងអរិយវិន័យនេះទេ គ្រាន់តែឲ្យឈ្មោះធម៌ទាំងនោះ ថាជាការនៅសប្បាយក្នុងបច្ចុប្បន្ន ក្នុងអរិយវិន័យប៉ុណ្ណោះ ។ ម្នាលចុន្ទ ហេតុនេះ តែងមានជាប្រាកដ គឺភិក្ខុពួកខ្លះក្នុងសាសនានេះ មានចិត្តព្រងើយកន្តើយ ព្រោះនឿយណាយចាកបីតិ មានស្មារតីរឭកដឹងខ្លួនទទួលសេចក្តីសុខដោយនាមកាយ ព្រះអរិយៈទាំងឡាយ តែងតែ

សរសើរបុគ្គលប្រកបដោយតតិយជ្ឈានទោះថា បុគ្គលប្រកបដោយតតិយជ្ឈាន មានចិត្តព្រងើយកន្តើយ មានស្មារតីនៅជាសុខដូច្នេះ ដោយតតិយជ្ឈានណា ( ភិក្ខុនោះ ) បានចូលតតិយជ្ឈាននោះ ភិក្ខុនោះ មានសេចក្តីសម្គាល់ថា អាត្មាអញនៅដោយសេចក្តីផូរផង់ដូច្នេះ ម្នាលចុន្ទ តែតថាគតមិនទាន់ឲ្យឈ្មោះធម៌ទាំងនោះ ថាជាសេចក្តីផូរផង់ ក្នុងអរិយវិន័យនេះទេ គ្រាន់តែឲ្យឈ្មោះធម៌ទាំងនោះ ថាជាការនៅសប្បាយក្នុងបច្ចុប្បន្ន ក្នុងអរិយវិន័យប៉ុណ្ណោះ ។ ម្នាលចុន្ទ ហេតុនេះ តែងមានជាប្រាកដ គឺភិក្ខុពួកខ្លះ ក្នុងសាសនានេះ ចូលចតុត្ថជ្ឈាន មានសតិដ៏បរិសុទ្ធ ដោយឧបេក្ខា មិនទុក្ខ មិនសុខ ព្រោះលះបង់នូវសេចក្តីសុខផង លះបង់នូវសេចក្តីទុក្ខផង វិនាសទៅនៃសោមនស្ស និងទោមនស្សទាំងឡាយ ក្នុងកាលមុនផង ភិក្ខុនោះមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញនៅដោយសេចក្តីផូរផង់ដូច្នេះ ម្នាលចុន្ទ តែតថាគតមិនទាន់ឲ្យឈ្មោះធម៌ទាំងនោះ ថាជាសេចក្តីផូរផង់ ក្នុងអរិយវិន័យនេះទេ គ្រាន់តែឲ្យឈ្មោះធម៌ទាំងនោះ

ថាជាការនៅសប្បាយក្នុងបច្ចុប្បន្ន ក្នុងអរិយវិន័យនេះប៉ុណ្ណោះ ។

ម្នាលចុន្ទ ភិក្ខុចូលអរូបឈាន ហើយនឹកថា យើងកំពុងតែជុសខាត់កិលេស ដូច្នេះ ក៏នៅមិនទាន់ហៅថា ជាការជុសខាត់កិលេសក្នុងអរិយវិន័យនេះ ហៅបានត្រឹមតែថា ធម៌ជាគ្រឿងស្ងប់រម្ងាប់ ។ ហើយទ្រង់ត្រាស់ណែនាំឲ្យជុសខាត់កិលេសតទៅទៀតថា អ្នកដទៃគេធ្វើអាក្រក់ យើងនឹងធ្វើអំពើល្អ ( ដោយទ្រង់បានសម្តែងការបៀតបៀននិងអកុសលកម្មបថ ១០ មានការសម្លាប់សត្វជាដើម និងមានការឃើញខុសចាកគន្លងធម៌ជាទីបំផុត មិច្ឆត្តៈ ( ការឃើញខុស ) ១០ យ៉ាង មានការឃើញខុសជាដើម មានការផុតស្រឡះដោយការខុសជាទីបំផុត និងទ្រង់សម្តែងទោសដទៃទៀត ដូចឧបក្កិលេសជាចំណែកអាក្រក់ ដែលផ្ទុយគ្នានឹងចំណែកល្អ រួមចំណែកនីមួយៗ ៤៤ ខ ) ។ ម្នាលចុន្ទ ដូចជាផ្លូវមិនស្មើ មានផ្លូវស្មើដទៃសម្រាប់ចៀសវាងផ្លូវមិនស្មើនោះ ម្នាលចុន្ទ ពុំនោះសោត ដូចកំពង់មិនស្មើ មានកំពង់ស្មើឯទៀត សម្រាប់ចៀសវាងកំពង់មិនស្មើនោះ មានឧបមាយ៉ាងណា

ម្នាលចុន្ទ ដូចការមិនបៀតបៀន ក៏ដើម្បីនឹងចៀសវាងអំពើអាក្រក់ មានការបៀតបៀនជាដើម ។

ម្នាលចុន្ទ អកុសលកម្មបថ មានការបៀតបៀនជាដើម មានការចុះអន់ថយទៅ កុសលធម៌ទាំងពួង មានការមិនបៀតបៀនជាដើម មានសភាពខ្ពស់ឡើង ។ ម្នាលចុន្ទ បុគ្គលដែលលិចទៅក្នុងភក់ នឹងបីត្រកងបុគ្គលដែលលិចទៅក្នុងភក់ផងគ្នាឡើងមកបាននោះ រមែងប្រព្រឹត្តទៅមិនបានទេ ( មិនមែនជាឋានៈដែលនឹងមាន ) បុគ្គលដែលមិនលិចទៅក្នុងភក់ ទើបនឹងបីត្រកងបុគ្គលលិចទៅក្នុងភក់ឲ្យឡើងមកបាន ម្នាលចុន្ទ បុគ្គលដែលមិនទូន្មានខ្លួន មិនបានណែនាំខ្លួន មិនបានធ្វើខ្លួនឲ្យរលត់ភាពក្តៅក្រហាយដោយខ្លួនឯង នឹងទូន្មានណែនាំបុគ្គលដទៃ ឲ្យរលត់ភាពក្តៅក្រហាយ រមែងប្រព្រឹត្តទៅមិនបានទេ តែបុគ្គលបានទូន្មាន បានណែនាំខ្លួន បានធ្វើខ្លួនឲ្យរលត់ភាពក្តៅក្រហាយដោយខ្លួនឯងហើយ ទើបនឹងទូន្មានណែនាំ បុគ្គលដទៃឲ្យរលត់ភាពក្តៅក្រហាយបាន សេចក្តីនេះយ៉ាងណា ការមិនបៀត

បៀនក៏មាន ទុកសម្រាប់រំលត់ការបៀតបៀន ការវៀរចាកសម្លាប់ជីវិតអ្នកដទៃមាន ទុកសម្រាប់រំលត់ការសម្លាប់ជីវិតអ្នកដទៃ ការវៀរចាកការកាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យមាន ទុកសម្រាប់រំលត់ការកាន់យកទ្រព្យ ដែលម្ចាស់គេមិនបានឲ្យនោះ រហូតដល់ការមិនប្រកាន់មាំនូវទិដ្ឋិមាន ទុកសម្រាប់រំលត់ការប្រកាន់មាំនូវទិដ្ឋិជាទីបំផុត ។ ម្នាលចុន្ទ ប្រការដែលតថាគតបានសម្តែងសល្លេខបរិយាយ គឺគ្រឿងជុសខាត់កិលេស ធ្វើការគិតឲ្យកើតឡើង ហេតុនៃការខ្ពស់ឡើង និងហេតុនៃការរលត់ ។ កាលព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ដូច្នេះហើយ ព្រះមហាចុន្ទត្ថេរមានសេចក្តីត្រេកអរចំពោះពុទ្ធភាសិតនោះយ៉ាងក្រៃលែង ។

មានរឿងដែលសម្តែងថា ព្រះមហាចុន្ទត្ថេរ បានឲ្យឱវាទដល់ភិក្ខុទាំងឡាយដោយត្រង់ ដែលរាប់ថាជាសេចក្តីល្អរបស់លោកមួយដែរ ដូចមានរឿងតំណាលទុកក្នុង **គម្ពីរអង្គុត្តរនិកាយ ឆក្កនិបាត** នៃ **មហាចុន្ទសូត្រ** ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះមហាចុន្ទដ៏មានអាយុ នៅក្នុងនិគមឈ្មោះសញ្ជាតិ ជិតដែនឈ្មោះ **ចេតី** ។ ក្នុងទីនោះ ព្រះមហាចុន្ទដ៏មានអាយុ មានថេរវាចាហៅភិក្ខុទាំងឡាយមកថា លោកអ្នកដ៏មានអាយុទាំងឡាយ ។ ភិក្ខុទាំងនោះបានទទួលស្តាប់ថេរវាចា ព្រះមហាចុន្ទដ៏មានអាយុថា អាវុសោ ដូច្នេះ ។ ព្រះមហាចុន្ទ មានថេរវាចាដូច្នេះថា លោកអ្នកដ៏មានអាយុទាំងឡាយ ពួកធម្មយោគភិក្ខុ ( ភិក្ខុអ្នកព្យាយាមក្នុងធម៌ ) ក្នុងសាសនានេះ បន្តុះបង្អាប់ពួកឈាយីភិក្ខុ ( ភិក្ខុអ្នកមានឈាន ) ថា ភិក្ខុទាំងនេះរិះគិតថា យើងជាអ្នកមានឈាន យើងជាអ្នកមានឈាន ចុះភិក្ខុទាំងនេះគិតអ្វី ភិក្ខុទាំងនេះគិតដើម្បីអ្វី ភិក្ខុទាំងនេះ គិតដោយហេតុអ្វី ។ បណ្តាភិក្ខុទាំងនោះ ឯពួកធម្មយោគភិក្ខុ ក៏មិនជ្រះថ្លា ពួកឈាយីភិក្ខុក៏មិនជ្រះថ្លា ទាំងមិនបានប្រតិបត្តិដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ជនច្រើន ដល់ទេវតា និងមនុស្សទាំងឡាយ ។ លោកអ្នកដ៏មាន

អាយុទាំងឡាយ ឯពួកឈាយីភិក្ខុក្នុងសាសនានេះ រមែងបន្ទុះបន្ទាប់ធម្មយោគភិក្ខុថា ភិក្ខុទាំងនេះ ជាអ្នកមានចិត្តប៉ោងឡើង មានចិត្តខ្ពស់ឡើង មានចិត្តឃ្លេងឃ្លោង មានមាត់រឹង មានវាចារោយរាយ មានសតិភ្លាំងភ្លាត់ មិនបានដឹងព្រម មានចិត្តមិនតម្កល់មាំ មានចិត្តរវើរវាយ មានឥន្ទ្រិយតាំងនៅជាប្រក្រតី គិតថា យើងជាអ្នកមានព្យាយាមក្នុងធម៌ ភិក្ខុទាំងនេះ ជាធម្មយោគៈអ្វី ភិក្ខុទាំងនេះជាធម្មយោគៈដើម្បីអ្វី ភិក្ខុទាំងនេះ ជាធម្មយោគៈដោយហេតុអ្វី បណ្ដាភិក្ខុទាំងនោះ ឯពួកឈាយីភិក្ខុ ក៏មិនជ្រះថ្លា ពួកធម្មយោគភិក្ខុ ក៏មិនជ្រះថ្លា ទាំងមិនបានប្រតិបត្តិដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ជនច្រើន ដល់ទេវតា និងមនុស្សទាំងឡាយ ។

លោកអ្នកដ៏មានអាយុទាំងឡាយ ពួកធម្មយោគភិក្ខុក្នុងព្រះសាសនានេះ រមែងនិយាយសរសើរ តែពួកភិក្ខុជាធម្មយោគៈដូចគ្នា មិននិយាយសរសើរពួកឈាយីភិក្ខុឡើយ ។ បណ្ដាភិក្ខុទាំងនោះ ឯ

ពួកធម្មយោគភិក្ខុ ក៏មិនជ្រះថ្លា ពួកឈាយីភិក្ខុ ក៏មិនជ្រះថ្លា ទាំងមិនបានប្រតិបត្តិ ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ជនច្រើន ដល់ទេវតា និងមនុស្សទាំងឡាយ ។ លោកអ្នកដ៏មានអាយុទាំងឡាយ ឯពួកឈាយីភិក្ខុ ក្នុងសាសនានេះ រមែងនិយាយសរសើរ តែពួកឈាយីភិក្ខុដូចគ្នា មិននិយាយសរសើរពួកធម្មយោគភិក្ខុឡើយ ។ បណ្តាភិក្ខុទាំងនោះ ឯពួកឈាយីភិក្ខុ ក៏មិនជ្រះថ្លា ពួកធម្មយោគភិក្ខុ ក៏មិនជ្រះថ្លា ទាំងមិនបានប្រតិបត្តិដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ជនច្រើន ដល់ទេវតា និងមនុស្សទាំងឡាយ ។ លោកអ្នកដ៏មានអាយុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គប្បីសិក្សាយ៉ាងនេះថា យើងជាធម្មយោគភិក្ខុ នឹងនិយាយសរសើរពួកឈាយីភិក្ខុ ។ លោកអ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ រឿង

នេះ ព្រោះហេតុអ្វី ? លោកអ្នកដ៏មានអាយុ ព្រោះថា បុគ្គលណា បានពាល់ត្រូវនូវធាតុ ឈ្មោះ **អមតៈ** ដោយនាមកាយហើយ បុគ្គលនោះជាបុគ្គលអស្ចារ្យ រកបានដោយកម្រក្នុងលោក ។ លោកអ្នកដ៏មានអាយុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរសិក្សាយ៉ាងនេះថា យើងជាពួកឈាយីភិក្ខុ នឹងនិយាយសរសើរពួកធម្មយោគភិក្ខុ ។ លោកអ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះចុះ ។ រឿងនោះ ព្រោះហេតុអ្វី ? លោកអ្នកដ៏មានអាយុទាំងឡាយ ព្រោះថា បុគ្គលណាត្រាស់ដឹង ឃើញនូវចំណែកនៃអត្ថដ៏ជ្រាលជ្រៅ ដោយប្រាជ្ញាហើយ បុគ្គលនោះជាបុគ្គលអស្ចារ្យ រកបានដោយក្រក្នុងលោក ។

ចប់រឿងក្នុង **មហាចុន្ទសូត្រ** ដែលចាត់ថា នេះជាសេចក្ដីល្អរបស់លោក ដែលលោកប៉ុនប៉ងអប់រំ ឲ្យភិក្ខុទាំងពីរចំណែកចេះពោលសរសើរដល់គ្នានិងគ្នា និងមិនឲ្យមើលងាយបុគ្គលដទៃទៀតផង ។ ព្រះមហាចុន្ទត្ថេរ លោកមានចំណេះចេះដឹងយ៉ាងជាក់ច្បាស់

បានយ៉ាងល្អ ក្នុងពោជ្ឈង្គ គឺអង្គនៃធម៌ជាគ្រឿងត្រាស់ដឹង មាន ៧ ប្រការ រហូតដល់លោកបានទទួលកិត្តិយសអំពីព្រះមហាវីរៈ ដោយលោកបានទទួលការអនុញ្ញាតពីព្រះពុទ្ធអង្គ ឲ្យសម្តែងពោជ្ឈង្គ ៧ ប្រការ ក្នុងគ្រាដែលព្រះមានព្រះភាគទ្រង់ប្រឈួន តាមដែលមានរឿងចារឹកទុកនៅក្នុង **គម្ពីរសំយុត្តនិកាយ មហាវារវគ្គ** នៃ **គិលានវគ្គ** ក្នុង **គិលានសូត្រ** ដូចមានសេចក្តីថា ៖

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ប្រថាប់នៅវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ ក៏ក្នុងសម័យនោះ ព្រះមានព្រះភាគ ទ្រង់មានអាពាធជាទម្ងន់ ។ គ្រានោះ ព្រះមហាចុន្ទត្ថេរ បានចូលទៅគាល់ព្រះសក្យមុនីដល់ទីគង់ប្រថាប់ ថ្វាយបង្គំព្រះសាស្តា រួចអង្គុយក្នុងទីដ៏សមគួរ ។ ពេលនោះ ព្រះជិនស្រី ទ្រង់ត្រាស់នឹងព្រះមហាចុន្ទត្ថេរថា ម្នាលចុន្ទ អ្នកចូរសម្តែងពោជ្ឈង្គ ៧ ប្រការ ឲ្យតថាគតបានស្តាប់ផងមើល ។ លំដាប់នោះ ព្រះមហាចុន្ទត្ថេរក្រាបទូលបង្គាញថា បពិត្រព្រះអង្គដ៏ចម្រើន ពោជ្ឈង្គ ៧ ប្រការទាំងនោះ

ដែលព្រះសយម្ភូទ្រង់បានសម្តែងទុកល្អហើយ ដែលបុគ្គលអប់រំល្អហើយ ធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីការដឹងដ៏ក្រៃលែង ដើម្បីការត្រាស់ដឹង ដើម្បីព្រះនិព្វាន ។ បពិត្រព្រះពុទ្ធអង្គដ៏ចម្រើន ពោជ្ឈង្គ ៧ ប្រការនោះ គឺអ្វី ? **១- សតិសម្ពោជ្ឈង្គ** អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង គឺសតិ ប្រែថា ការរឭក ។ **២- ធម្មវិចយសម្ពោជ្ឈង្គ** អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង គឺធម្មវិចយៈ ប្រែថា ការយកចិត្តទុកដាក់នូវធម៌ ។ **៣- វីរិយសម្ពោជ្ឈង្គ** អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង គឺវីរិយៈ ប្រែថា ការព្យាយាម ។ **៤- បីតិសម្ពោជ្ឈង្គ** អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង គឺបីតិ ប្រែថា ការឆ្អែតចិត្ត ។ **៥- បស្សទ្ធិសម្ពោជ្ឈង្គ** អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង គឺបស្សទ្ធិ ប្រែថា ការស្ងប់ចិត្ត ។ **៦- សមាធិសម្ពោជ្ឈង្គ** អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង គឺសមាធិ ប្រែថា ការតាំងចិត្តមាំ ។ **៧- ឧបេក្ខាសម្ពោជ្ឈង្គ** អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង គឺឧបេក្ខា ប្រែថា ការព្រងើយកន្តើយ ។

ពោជ្ឈង្គ ៧ ប្រការនេះឯង ដែលព្រះសម្ពុទ្ធទ្រង់សម្តែងទុក

ហើយ ដែលបុគ្គលអប់រំល្អហើយ ធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្ត ទៅដើម្បីការដឹងដ៏ក្រៃលែង ដើម្បីការត្រាស់ដឹង ដើម្បីព្រះនិព្វាន ។ គ្រានោះ ព្រះសក្យមុនី ទើបទ្រង់ត្រាស់ថា ម្នាលចុន្ទ ពោជ្ឈង្គទាំង ៧ ប្រការ រមែងមានយ៉ាងនេះឯង ។ កាលព្រះមហាចុន្ទត្ថេរ បាន សម្ដែងពោជ្ឈង្គ ៧ ប្រការដូច្នេះហើយ ព្រះបរមសាស្ដាទ្រង់សព្វ ព្រះទ័យ បាត់ពីប្រឈួននោះ ។ មានសេចក្ដីថា អាពាធនោះ ព្រះ លោកនាថ ទ្រង់លះបានហើយដោយប្រការដូច្នេះ ។

នៅមានសេចក្ដីល្អរបស់ព្រះមហាចុន្ទត្ថេរមួយរឿងទៀត ដែល ជាសេចក្ដីល្អ ធ្វើឲ្យបានដឹងនូវធម៌ ដើម្បីលះបង់នូវទិដ្ឋិផ្សេងៗ តាម ដែលមានសម្ដែងទុកនៅក្នុង **គម្ពីរមជ្ឈិមនិកាយ មូលបណ្ណាសកៈ** នៃ **សល្លេខសូត្រទី ៨** ដូចមានសេចក្ដីថា ៖

នៅមានសេចក្ដីល្អរបស់ព្រះមហាចុន្ទៈ ដែលជាសេចក្ដីដ៏សំខាន់ ក្រៃលែងដែលមានផលបន្តមកដល់ការធ្វើសង្គាយនាទៀតផង ដូចជា សេចក្ដីល្អរបស់លោក ដែលមានសម្ដែងនៅក្នុងសូត្រ រហូតដល់ពីរ

សូត្រនោះ គឺ **សាមគ្គាមសូត្រ** និង **បាសាទិកសូត្រ** ។

ព្រះមហាចុន្ទត្ថេរ លោកជាអ្នកមានការគិតឃើញ ចំពោះធម៌វិន័យថាមានប្រយោជន៍ តាមដែលមានរឿងពោលប្រាកដទុកនៅក្នុង **សាមគ្គាមសូត្រ** នៅក្នុង **គម្ពីរមជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ** ថា ៖

គ្រាមួយ ព្រះមានបុណ្យ ទ្រង់គង់ប្រថាប់នៅសាមគ្គាមៈ ក្នុងដែនសក្កៈ ។ ក្នុងគ្រានោះ និគណ្ឋនាដបុត្រ ( ម្ចាស់លទ្ធិអន្យតិរ្ថិយម្នាក់ក្នុងចំណោម ៦ នាក់ ) បានសម្លាប់ខ្លួនទៅថ្មីៗ នៅក្នុងក្រុងបាវា កាលនិគណ្ឋនាដបុត្រស្លាប់ទៅ ពួកនិគ្រន្ថដែលជាកូនសិស្សបានបែកគ្នាជាពីរពួក ថែមទាំងមានការកើតវិវាទដល់គ្នានិងគ្នា ព្រោះតែពាក្យណែនាំលទ្ធិរបស់ខ្លួនថា លោកមិនដឹងធម្មវិន័យនេះទេ ចំណែកយើងទើបជាអ្នកដឹងក្នុងធម្មវិន័យនេះ លោកដឹងធម្មវិន័យនេះ យ៉ាងណា លោកបដិបត្តិខុស យើងបដិបត្តិត្រូវ ពាក្យសម្តីរបស់យើងមានប្រយោជន៍ ឯពាក្យសម្តីរបស់លោកមិនមានប្រយោជន៍ ពាក្យដែលគួរពោលមុន លោកត្រឡប់យកមកពោលខាងក្រោយ ពាក្យដែលគួរ

ពោលខាងក្រោយ តែលោកត្រឡប់នាំមកពោលមុន លោកបានប្រព្រឹត្ត ខុសមកហើយ យើងមិនយកទោសលោកទេ លោកត្រូវគេសង្កត់សង្កិន ហើយ ចូរប្រព្រឹត្តដើម្បីដោះខ្លួនពីការពោលនោះ ចូរដកខ្លួនចេញ បើ លោកអាចធ្វើបាន ។ ពួកនិគ្រន្ថទាំងនោះ បានឈ្លោះប្រកែកគ្នាយ៉ាង នេះ ធ្វើឲ្យពួកគ្រហស្ថដែលស្លៀកស ជាសាវករបស់និគណ្ឋនាដបុត្រ ក៏មានការនឿយណាយចំពោះសេចក្តីគោរព ពួកនិគ្រន្ថទាំងនោះ ដូច គ្នានឹងបុគ្គលទាំងឡាយ ដែលនឿយណាយក្នុងធម្មវិន័យដែលពោល ទុកមិនល្អ ដែលមិនធ្វើឲ្យអស់ទុក្ខ មិនជួយឲ្យស្ងប់ មិនមែនជាពាក្យ ប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ដែលជាធម្មវិន័យ មិនអាចទីពឹង បាន ដូច្នោះ ។

ហេតុដែលពួកបរិវាររបស់និគណ្ឋនាដបុត្រ កើតវិវាទដល់គ្នា និងគ្នា រហូតធ្វើឲ្យបែកបាក់គ្នានោះ មានសម្តែងទុកនៅក្នុង **អដ្ឋកថា បរមត្ថទីបនី** នៃ **សាមគ្គាមសូត្រ** អធិប្បាយហេតុផលក្នុងរឿងនោះ ដូច មានសេចក្តីថា ៖

ក្នុងពេលដែលនិគណ្ឋនាដបុត្រ ដែលជាអាចារ្យជិតនឹងស្លាប់ គេគិតថា លទ្ធិរបស់យើងជាលទ្ធិមិនមែនជួយឲ្យសត្វអស់ទុក្ខបានទេ ជាលទ្ធិប្រាសចាកខ្លឹមសារ ខ្លួនយើងនេះជាអ្នកដល់នូវសេចក្ដីវិនាស ហើយ តែបើយើងប្រាប់ថា លទ្ធិរបស់យើងមិនមែនជួយឲ្យអស់ទុក្ខបានទេ ប្រាកដជាមិនមានបុគ្គលណាជឿ ក្រោយពីយើងស្លាប់ទៅហើយ ពួកគេប្រាកដជាបែកបាក់គ្នា នេះជាឧបាយមួយ ធ្វើឲ្យព្រះពុទ្ធជាម្ចាស់ទ្រង់បានឱកាសសម្ដែងធម៌ដល់ពួកគេ ពួកគេប្រាកដជាដឹងថា ព្រះពុទ្ធសាសនាទេ ទើបជាសាសនាដឹកនាំសត្វឲ្យរួចពីសេចក្ដីទុក្ខបាន ។ បន្ទាប់មក កូនសិស្សម្នាក់ៗ បានចូលទៅរកនិគណ្ឋនាដបុត្រ បានពោលអង្វរថា សូមលោកអាចារ្យ ប្រាប់កិច្ចដែលមានខ្លឹមសារ ក្នុងលទ្ធិរបស់លោកដល់ខ្ញុំផងចុះ ។ និគណ្ឋនាដបុត្រពោលតបថា កាលបើយើងស្លាប់ទៅហើយ សូមអ្នកទាំងអស់គ្នាប្រកាន់ថា ខ្លួនយើងជារបស់ទៀង ។ តមក មានកូនសិស្សម្នាក់ទៀត បានចូលទៅរកនិគណ្ឋនាដបុត្រៗ ទើបឲ្យសិស្សម្នាក់នោះរៀនឧច្ឆេទទិដ្ឋិ គឺឲ្យប្រកាន់ថា ខ្លួនស្លាប់ទៅហើយ

សូន្យ ហេតុដូច្នេះ ទើបធ្វើឲ្យកូនសិស្សបែកគ្នាជាពីរពួក ហើយគេក៏ស្លាប់ទៅ ។

គ្រានោះ ពួកកូនសិស្សនាំគ្នាធ្វើសរីរកិច្ចបូជាសពនិគណ្ឋនាដ-បុត្ររួចស្រេចហើយ មកប្រជុំសាកសួរគ្នាថា អាចារ្យបានប្រាប់កិច្ចដែលមានខ្លឹមសារដល់នរណាយ៉ាងណាខ្លះឬ ? ពេលនោះ មានសិស្សម្នាក់បានក្រោកឡើងពោលថា លោកអាចារ្យបានប្រាប់ខ្ញុំថា ខ្លួនយើងជារបស់ទៀង ។ ក៏មានសិស្សម្នាក់ទៀត ក្រោកឡើងពោលជំទាស់និងប្រាប់ថា លោកអាចារ្យបានប្រាប់ថា សត្វស្លាប់ទៅហើយសូន្យ ។ ក្នុងទីបំផុតសិស្សទាំងអស់នោះ ក៏កើតមានការឈ្លោះវិវាទគ្នានិងគ្នាដោយមិនព្រមស្តាប់គ្នា រហូតដល់បែកបាក់គ្នា ទៅកាន់ទិសផ្សេងៗ ។

ចំណែកសេចក្តីក្នុងព្រះបាលីនៃ **សាមគ្គាមសូត្រ** បានសម្តែងតទៅទៀតដូចមានសេចក្តីថា ៖

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងសាមគ្រាម ក្នុងដែនសក្កៈ ។ សម័យនោះឯង និគណ្ឋនាដបុត្រ ទើបតែនឹងធ្វើមរណកាល

ក្នុងដែនបាវា ។ ព្រោះកាលកិរិយានៃនិគណ្ឋនាដបុត្រនោះ ពួកនិគ្រន្ថ (ជាអន្តេវាសិក) ក៏បែកបាក់គ្នាជាពីរពួក កើតការប្រកួតប្រកាន់ ឈ្លោះទាស់ទែងគ្នា ចាក់ដោតគ្នានិងគ្នាដោយលំពែង គឺមាត់ថា អ្នកឯងមិនដឹងធម៌វិន័យនេះទេ យើងទើបដឹងធម៌វិន័យនេះ អ្នកឯងនឹងដឹងធម៌វិន័យនេះដូចម្តេចបាន អ្នកឯងប្រព្រឹត្តខុស យើងទើបបដិបត្តិត្រូវ ពាក្យរបស់យើងប្រកបដោយប្រយោជន៍ ពាក្យរបស់អ្នកឯង មិនប្រកបដោយប្រយោជន៍ទេ ពាក្យដែលគួរនិយាយមុន អ្នកឯងបែរជានិយាយក្រោយ ពាក្យដែលគួរនិយាយក្រោយ អ្នកឯងបែរជានិយាយមុន អ្នកឯងសន្សំតែវត្តដែលខុសៗ បើអ្នកឯងលើកវាទៈឡើង គេរមែងតិះដៀលបាន បើអ្នកឯងអាច ចូរប្រព្រឹត្តឲ្យរួចចាកវាទៈចុះ ។ ពួកនិគ្រន្ថទាំងនោះបានញុំាងនូវជម្លោះឲ្យដល់គ្នានិងគ្នាយ៉ាងនេះឯង ។ សេចក្តីស្លាប់តែម្នាក់តែហាក់ដូចជាប្រព្រឹត្តទៅក្នុងពួកនិគ្រន្ថ ជាអន្តេវាសិករបស់និគណ្ឋនាដបុត្រ ។ ពួកសាវករបស់និគណ្ឋនាដបុត្រណា ជាគ្រហស្ថស្លៀកពាក់សពួកសាវកទាំងនោះ មានសភាពនឿយណាយប្រាសចាកសេចក្តីត្រេកអរ

មានសភាពរួញរាក្នុងធម្មវិន័យ ដែលពួកនិគណ្ឋនាដបុត្រសម្តែងខុស ប្រកាសខុស មិនមែនជានិយ្យានិកធម៌ មិនមែនប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់ មិនមែនព្រះសម្មាសម្ពុទ្ធ សម្តែងជាស្តូបបែកធ្លាយ មិនមែនជាទីពំនាក់ឡើយ ។

គ្រានោះ សមណុទ្ទេស ឈ្មោះចុន្ទ នៅចាំវស្សាក្នុងដែនបាវា ចូលទៅរកព្រះអានន្ទមានអាយុ ដែលគង់នៅក្នុងសាមគ្រាម លុះចូលទៅដល់ហើយ ក៏អភិវាទព្រះអានន្ទមានអាយុ រួចអង្គុយក្នុងទីដ៏សមគួរ ។ កាលចុន្ទអង្គុយក្នុងទីដ៏សមគួរហើយ និយាយនឹងព្រះអានន្ទមានអាយុ ដូច្នេះថា បពិត្រលោកដ៏ចម្រើន និគណ្ឋនាដបុត្រ ទើបតែនឹងធ្វើមរណកាល ក្នុងដែនបាវា ព្រោះកាលកិរិយារបស់និគណ្ឋនាដបុត្រនោះ ពួកនិគ្រន្ថក៏បែកបាក់គ្នាជាពីរពួក ។ល។ ជាស្តូបបែកធ្លាយ មិនមែនជាទីពំនាក់ឡើយ ។កាលចុន្ទនិយាយយ៉ាងនេះហើយ ព្រះអានន្ទមានអាយុនិយាយនឹងចុន្ទយ៉ាងនេះថា លោកអ្នកដ៏មានអាយុ ចុន្ទ ពាក្យនេះជាពាក្យមានមូល គួរនឹងទៅគាល់ព្រះសម្ពុទ្ធ លោកអ្នកដ៏មានអាយុ ចុន្ទ

មកយើងនឹងចូលទៅគាល់ព្រះទសពល លុះចូលទៅដល់ហើយ នឹងក្រាបបង្គំទូលសេចក្តីនេះចំពោះព្រះមុនី ។ ចុន្ទក៏ទទួលពាក្យព្រះអានន្ទមានអាយុថា ព្រះករុណាលោកម្ចាស់ ។

លំដាប់នោះ ព្រះអានន្ទ និងចុន្ទបានចូលទៅគាល់ព្រះទសពល លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះសម្ពុទ្ធ ហើយអង្គុយក្នុងទីដ៏សមគួរ ។ កាលព្រះអានន្ទគង់ក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះជិនស្រីដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ចុន្ទនេះឯងបាននិយាយយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន និគណ្ឋនាដបុត្រ ទើបតែនឹងធ្វើមរណកាលក្នុងដែនបាវា ព្រោះកាលកិរិយារបស់និគណ្ឋនាដបុត្រនោះ ពួកនិគ្រន្ថក៏បែកបាក់គ្នាជាពីរពួក កើតទៅជាប្រកួតប្រកាន់ឈ្លោះទាស់ទែង ចាក់ដោតគ្នានិងគ្នាដោយលំពែង គឺមាត់ថា អ្នកឯងមិនដឹងធម៌វិន័យនេះទេ យើងទើបដឹងធម៌វិន័យនេះ ។ល។ ដូចជាស្តូបបែកធ្លាយមិនមែនជាទីពំនាក់ឡើយ បពិត្រព្រះមានព្រះភាគដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា អំណឹះឥតអំពីព្រះសាស្តាទៅ សូមកុំឲ្យ

វិវាទកើតឡើងក្នុងសង្ឃឡើយ ព្រោះថា វិវាទនោះ នឹងប្រព្រឹត្តទៅមិនដើម្បីជាគុណដល់ជនច្រើន មិនជាសុខដល់ជនច្រើន មិនជាប្រយោជន៍ មិនជាសេចក្តីចម្រើនដល់ជនច្រើន ជាទុក្ខដល់ទេវតា និងមនុស្សទាំងឡាយ ។ ព្រះលោកនាថទ្រង់ត្រាស់ថា ម្នាលអានន្ទ អ្នកយល់ឃើញសេចក្តីនោះដូចម្តេច ធម៌ទាំងឡាយ ដែលតថាគតត្រាស់ដឹងហើយសម្តែងហើយ ដល់អ្នកទាំងឡាយ ដូចជាសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គដ៏ប្រសើរ ប្រកបដោយអង្គ ៨ ម្នាលអានន្ទ អ្នកដែលឃើញភិក្ខុពីររូប មានវាទៈផ្សេងគ្នា ក្នុងធម៌ទាំងឡាយនេះដែរឬទេ ? បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយ ដែលព្រះលោកនាយកត្រាស់ដឹងហើយ សម្តែងហើយ ដល់ខ្ញុំព្រះអង្គទាំងឡាយ ដូចជាសតិប្បដ្ឋាន ៤ ជាដើម ខ្ញុំព្រះអង្គមិនដែលឃើញភិក្ខុពីររូបមានវាទៈផ្សេងគ្នា ក្នុងធម៌វិន័យនេះឡើយ បពិត្រព្រះអង្គដ៏ចម្រើន មានតែពួកបុគ្គលដែលជាអ្នកអែបអបព្រះមានបុណ្យទេ លុះអំណឹះឥតអំពីព្រះមានជោគទៅ នឹងញុំាងវិវាទឲ្យកើតឡើង ក្នុង

ព្រះសង្ឃ ព្រោះអាជីវៈជាហេតុខ្លះ ព្រោះអធិប្បាតិមោក្ខជាហេតុខ្លះ វិវាទនោះនឹងប្រព្រឹត្តទៅ ដើម្បីមិនជាគុណដល់ជនច្រើន មិនជាសុខដល់ជនច្រើន មិនជាប្រយោជន៍ មិនជាសេចក្តីចម្រើនដល់ជនច្រើន ជាទុក្ខដល់ទេវតា និងមនុស្សទាំងឡាយ ។ ម្នាលអានន្ទ ការវិវាទណាកើតឡើង ព្រោះអាស្រ័យអាជីពជាហេតុ ឬព្រោះអាស្រ័យអធិប្បា-តិមោក្ខជាហេតុ វិវាទនោះ គ្រាន់តែជាការបន្តិចបន្តួចទេ ម្នាលអានន្ទមួយទៀត កាលវិវាទណាកើតឡើងក្នុងសង្ឃ ព្រោះអាស្រ័យមគ្គ ឬអាស្រ័យបដិបទា វិវាទនោះនឹងប្រព្រឹត្តទៅ ដើម្បីមិនជាគុណដល់ជនច្រើន មិនជាសុខដល់ជនច្រើន មិនជាប្រយោជន៍ មិនជាសេចក្តីចម្រើនដល់ជនច្រើន ជាទុក្ខ ដល់ទេវតា និងមនុស្សទាំងឡាយ ។

ម្នាលអានន្ទ វិវាទមូលនោះមាន ៦ ប្រការ វិវាទមូល ៦ ប្រការដូចម្តេច ? ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ជាអ្នកច្រើនទៅដោយសេចក្តីក្រោធ ជាអ្នកច្រើនដោយការចងពៀរ ។ ម្នាលអានន្ទ ភិក្ខុណាជាអ្នកច្រើនដោយសេចក្តីក្រោធ ជាអ្នកច្រើនដោយការចងពៀរ ភិក្ខុ

នោះ ឈ្មោះថា មិនគោរព មិនកោតក្រែងចំពោះព្រះមានព្រះភាគផង មិនគោរព មិនកោតក្រែងចំពោះព្រះធម៌ផង ព្រះសង្ឃផង មិនធ្វើឲ្យពេញលេញក្នុងសិក្ខាផង ។ ម្នាលអានន្ទ ភិក្ខុណាមិនគោរព មិនកោតក្រែងចំពោះព្រះមានជោគ ចំពោះព្រះធម៌... មិនគោរព មិនកោតក្រែងចំពោះព្រះសង្ឃផង មិនធ្វើឲ្យពេញលេញក្នុងសិក្ខាផង ភិក្ខុនោះឈ្មោះថា បង្កើតវិវាទក្នុងសង្ឃ ។ វិវាទ ( ដែលកើតក្នុងសង្ឃ ) តែងប្រព្រឹត្តទៅដើម្បីមិនជាគុណដល់ជនច្រើន មិនជាសុខដល់ជនច្រើន មិនជាប្រយោជន៍ មិនជាសេចក្តីចម្រើនដល់ជនច្រើន ជាទុក្ខដល់ពួកទេវតានិងមនុស្សទាំងឡាយ ។ ម្នាលអានន្ទ បើអ្នកទាំងឡាយពិចារណាឃើញវិវាទមូល មានសភាពយ៉ាងនេះ ឰដ៏ខាងក្នុងក្តី ឰដ៏ខាងក្រៅក្តី ម្នាលអានន្ទ ក្នុងរឿងនោះ អ្នកទាំងឡាយ គួរព្យាយាមលះវិវាទមូលដ៏លាមកនោះចេញ ម្នាលអានន្ទ បើអ្នកទាំងឡាយពិចារណាមិនឃើញវិវាទមូលមានសភាពយ៉ាងនេះ ឰដ៏ខាងក្នុងក្តី ឰដ៏ខាងក្រៅក្តី ម្នាលអានន្ទ ក្នុងដំណើរនោះ អ្នកទាំងឡាយ គួរប្រតិបត្តិដើម្បីកុំឲ្យវិវាទមូល

ដ៏លាមកនោះឯង ហូរហៀរតទៅទៀត ការលះបង់វិវាទមូលដ៏លាមក នោះ រមែងមានដោយប្រការយ៉ាងនេះឯង ។

ម្នាលអានន្ទ មួយទៀត ភិក្ខុជាអ្នកច្រើនដោយការលុបគុណគេ ជាអ្នកច្រើនលើកខ្លួន... ជាអ្នកច្រើនច្រណែន ជាអ្នកកំណាញ់... ជាអ្នកអួតអាង ជាអ្នកមានមាយា... ជាអ្នកមានប្រាថ្នាដ៏លាមក ជាអ្នកមានសេចក្តីឃើញខុស... ជាអ្នកប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួន ជាអ្នកស្ទាបអង្អែល ( នូវសីល និងទិដ្ឋិ ) ជាអ្នកប្រកាន់មាំ ជាអ្នកលះបង់បានដោយកម្រ ។ ម្នាលអានន្ទ ភិក្ខុណាជាអ្នកប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួន ជាអ្នកស្ទាបអង្អែល ជាអ្នកប្រកាន់មាំ ជាអ្នកលះបង់បានដោយកម្រ ភិក្ខុនោះ ឈ្មោះថា មិនគោរព មិនកោតក្រែងចំពោះសាស្តាផង មិនគោរព មិនកោតក្រែងចំពោះព្រះធម៌ផង មិនកោតក្រែងចំពោះសង្ឃផង ជាអ្នកមិនធ្វើឲ្យពេញលេញក្នុងសិក្ខា ។ ម្នាលអានន្ទ ភិក្ខុណា មិនគោរព មិនកោតក្រែងចំពោះព្រះមានព្រះភាគ ព្រះធម៌... ព្រះសង្ឃ... ជាអ្នកមិនធ្វើឲ្យពេញលេញក្នុង

សិក្ខា ភិក្ខុនោះ ឈ្មោះថា បង្កើតវិវាទក្នុងសង្ឃ ។ វិវាទ (ដែលកើតឡើង) រមែងប្រព្រឹត្តទៅ ដើម្បីមិនជាគុណដល់ជនច្រើន មិនជាសុខដល់ជនច្រើន មិនជាប្រយោជន៍ មិនជាសេចក្ដីចម្រើនដល់ជនច្រើន ជាទុក្ខដល់ពួកទេវតា និងមនុស្សទាំងឡាយ ។ ម្នាលអានន្ទ បើអ្នកទាំង-ឡាយ ពិចារណាឃើញវិវាទមូល មានសភាពយ៉ាងនេះ ពួដ៏ខាងក្នុងក្ដី ពួដ៏ខាងក្រៅក្ដី ម្នាលអានន្ទ ក្នុងដំណើរនោះ អ្នកទាំងឡាយ គួរព្យាយាមលះបង់វិវាទមូលដ៏លាមកនោះចេញ ។ ម្នាលអានន្ទ បើអ្នកទាំងឡាយពិចារណាមិនឃើញវិវាទមូល មានសភាពយ៉ាងនេះ ពួដ៏ខាងក្នុងក្ដី ពួដ៏ខាងក្រៅក្ដី ម្នាលអានន្ទ ក្នុងដំណើរនោះ អ្នកទាំងឡាយគួរប្រតិបត្តិដើម្បីកុំឲ្យវិវាទមូលដ៏លាមកនោះឯង រាតត្បាតតទៅ ការលះបង់វិវាទដ៏លាមកនេះ រមែងមានដោយប្រការយ៉ាងនេះ ការមិនឲ្យវិវាទមូលដ៏លាមកនេះ រាតត្បាតតទៅ រមែងមានដោយប្រការយ៉ាងនេះ ។ ម្នាលអានន្ទ នេះឯងវិវាទមូល ៦ យ៉ាង ។

ម្នាលអានន្ទ អធិករណ៍នោះមាន ៤ យ៉ាង អធិករណ៍ ៤ យ៉ាង

ដូចម្ដេចខ្លះ អធិករណ៍ ៤ យ៉ាង គឺវិវាទាធិករណ៍ ១ អនុវាទាធិករណ៍ ១ អាបត្តាធិករណ៍ ១ កិច្ចាធិករណ៍ ១ ម្នាលអានន្ទ នេះឯងជាអធិករណ៍ ៤ យ៉ាង ។ ម្នាលអានន្ទ អធិករណសមថៈនេះ មាន ៧ យ៉ាង គឺសម្មុខាវិន័យ ១ សតិវិន័យ ១ អមូឡ្ហវិន័យ ១ បដិញ្ញាតករណៈ ១ យេភុយ្យសិកា ១ តស្សបាបិយសិកា ១ តិណវត្ថារកៈ ១ ដែលសង្ឃគប្បីឲ្យ ដើម្បីរម្ងាប់អធិករណ៍ដែលកើតឡើងហើយ ។ ម្នាលអានន្ទ ចុះសម្មុខាវិន័យតើដូចម្ដេច ? ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ជជែកគ្នាថា នេះជាធម៌ ឬថា នេះមិនមែនជាធម៌ ថានេះជាវិន័យ ឬថា នេះមិនមែនជាវិន័យ ។ ម្នាលអានន្ទ ភិក្ខុទាំងអស់នោះឯង គប្បីព្រមព្រៀងគ្នា ប្រជុំប្រៀបធៀបតាមបែបដែលជាធម៌ លុះប្រៀបធៀបតាមបែបដែលជាធម៌រួចហើយ គប្បីរម្ងាប់អធិករណ៍នោះ ដោយវិធីដែលឲ្យរម្ងាប់តាមបែបដែលជាធម៌នោះ ។ ម្នាលអានន្ទ សម្មុខាវិន័យយ៉ាងនេះឯង ។ ការរម្ងាប់អធិករណ៍ពួកខ្លះ ក្នុងសាសនានេះ រមែងមានដោយសម្មុខាវិន័យយ៉ាងនេះឯង ។

ម្នាលអានន្ទ ចុះយេភុយ្យសិកាតើដូចម្តេច ? ម្នាលអានន្ទ បើភិក្ខុទាំងនោះ មិនអាចរម្ងាប់អធិករណ៍នោះ ក្នុងអាវាសនោះបានទេ ។ ម្នាលអានន្ទ ក្នុងអាវាសណា មានភិក្ខុច្រើន ភិក្ខុទាំងនោះ គប្បីទៅកាន់អាវាសនោះ ។ ភិក្ខុទាំងអស់នោះ គួរមកប្រជុំគ្នាក្នុងអាវាសនោះ លុះមកប្រជុំគ្នាហើយ គួរប្រៀបធៀបតាមបែបដែលជាធម៌ លុះប្រៀបធៀបតាមបែបដែលជាធម៌ហើយ គប្បីរម្ងាប់អធិករណ៍នោះដោយវិធីដែលឲ្យរម្ងាប់តាមបែបដែលជាធម៌នោះ។ ម្នាលអានន្ទ យេភុយ្យសិកាយ៉ាងនេះឯង ។ ការរម្ងាប់អធិករណ៍ពួកខ្លះ ក្នុងសាសនានេះ រមែងមានដោយយេភុយ្យសិកាយ៉ាងនេះឯង ។

ម្នាលអានន្ទ ចុះសតិវិន័យតើដូចម្តេច ? ម្នាលអានន្ទ ក្នុងសាសនានេះ ភិក្ខុទាំងឡាយ ចោទភិក្ខុដោយគរុកាបត្តិ មានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី អាបត្តិរេងបារាជិកក្តីថា លោកមានអាយុ រឭកនូវគរុ-កាបត្តិមានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី អាបត្តិរេងបារាជិកក្តីដែលលោកត្រូវហើយ ឃើញឬទេ ? ភិក្ខុនោះ និយាយយ៉ាងនេះថា

ម្នាលអាវុសោ ខ្ញុំរឭកនូវគរុកាបត្តិមានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី អាបត្តិរេឯបារាជិកក្តី ដែលខ្ញុំត្រូវហើយ មិនឃើញទេ ។ ម្នាលអានន្ទ សតិវិន័យយ៉ាងនេះឯង ។ ការរម្ងាប់អធិករណ៍ ពួកខ្លះក្នុងសាសនានេះ រមែងមានដោយសតិវិន័យយ៉ាងនេះឯង ។

ម្នាលអានន្ទ អមូឡ្ហវិន័យ តើដូចម្តេច ? ម្នាលអានន្ទ ក្នុងសាសនានេះ ភិក្ខុទាំងឡាយ ចោទភិក្ខុដោយគរុកាបត្តិមានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី អាបត្តិរេឯបារាជិកក្តីថា លោកមានអាយុ រឭកនូវគរុកាបត្តិមានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី អាបត្តិរេឯបារាជិកក្តី ដែលលោកត្រូវហើយ ឃើញឬទេ ? ភិក្ខុនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំរឭកនូវគរុកាបត្តិមានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី អាបត្តិរេឯបារាជិកក្តី ដែលខ្ញុំត្រូវហើយ មិនឃើញទេ ។ ភិក្ខុនោះញ៉ាំងភិក្ខុនេះ ដែលកំពុងបណ្តោះបណ្តៃ មិនឲ្យបណ្តោះបណ្តៃបានថា លោកដ៏មានអាយុ ណ្ហើយ លោកចូរទទួលដឹងដោយស្រួលចុះ បើលោករឭកឃើញនូវគរុកាបត្តិមានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី អាបត្តិរេឯ

បារាជិកក្តី ដែលលោកត្រូវហើយ ។ ភិក្ខុនោះនិយាយយ៉ាងនេះថា ម្នាល អាវុសោ ខ្ញុំជាមនុស្សឆ្កួត មានចិត្តវិបល្លាសប្រែប្រួល កាលដែលខ្ញុំឆ្កួត មានចិត្តវិបល្លាសប្រែប្រួលនោះ បានប្រព្រឹត្តអនាចារ បានពោល បានព្យាយាមល្មើសនូវកិច្ច ដែលមិនមែនជារបស់សមណៈជាច្រើន ខ្ញុំរឭក មិនឃើញអំពើនោះទេ អំពើនោះខ្ញុំបានធ្វើដោយសេចក្តីវង្វេង ។ ម្នាល អានន្ទយ៉ាងនេះឯង សង្ឃគប្បីឲ្យអមូឡ្ហវិន័យដល់ភិក្ខុនោះ ។ ម្នាល អានន្ទ អមូឡ្ហវិន័យ យ៉ាងនេះឯង ។ ការរម្ងាប់អធិករណ៍ពួកខ្លះ ក្នុងសាសនានេះ រមែងមានដោយអមូឡ្ហវិន័យយ៉ាងនេះឯង ។

ម្នាលអានន្ទ ចុះបដិញ្ញាតករណៈ តើដូចម្តេច ? ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ត្រូវគេចោទក្តី មិនត្រូវគេចោទក្តី តែងរឭក តែងបើក តែងធ្វើឲ្យរាក់នូវអាបត្តិ ។ ម្នាលអានន្ទ ភិក្ខុនោះ គួរចូលមករកភិក្ខុចាស់ជាងខ្លួន ហើយធ្វើចីវរឆៀងស្មាម្ខាង ថ្វាយបង្គំបាទា អង្គុយប្រហោងផ្គងអញ្ជលីរួច គួរពោលយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន ខ្ញុំត្រូវអាបត្តិឈ្មោះនេះ ខ្ញុំសូមសម្តែងនូវអាបត្តិឈ្មោះនោះ ។ ភិក្ខុចាស់

នោះពោលយ៉ាងនេះថា លោកឃើញឬ ? ភិក្ខុនីឆ្លើយថា ខ្ញុំឃើញ ។ ភិក្ខុចាស់ពោលថា លោកត្រូវសង្រួមតទៅ ។ ភិក្ខុនីឆ្លើយថា ខ្ញុំនឹងសង្រួម ។ ម្នាលអានន្ទ បដិញ្ញាតករណៈយ៉ាងនេះឯង ។ ការរម្ងាប់អធិករណ៍ពួកខ្លះក្នុងសាសនានេះ រមែងមានដោយបដិញ្ញាតករណៈ យ៉ាងនេះឯង ។

ម្នាលអានន្ទ ចុះតស្សបាបិយសិកាតើដូចម្តេច ? ម្នាលអានន្ទ ក្នុងសាសនានេះ ភិក្ខុទាំងឡាយ ចោទភិក្ខុដោយគរុកាបត្តិ មានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី អាបត្តិរេផបារាជិកក្តីថា លោកដ៏មានអាយុ ចូររឭកនូវគរុកាបត្តិមានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី អាបត្តិរេផបារាជិកក្តី ដែលលោកត្រូវហើយ ។ ភិក្ខុនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំនឹកនូវគរុកាបត្តិមានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី អាបត្តិរេផបារាជិកក្តី ដែលខ្ញុំត្រូវហើយ មិនឃើញទេ ។ ភិក្ខុនោះញុំាងភិក្ខុនេះ ដែលកំពុងបណ្តោះបណ្តៃ មិនឲ្យបណ្តោះបណ្តៃបានថា ម្នាលលោកដ៏មានអាយុ ណ្ហើយ លោកចូរទទួលដឹងដោយស្រួលចុះ បើលោករឭកនូវគរុកាបត្តិមានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី

អាបត្តិរងបារាជិកក្តី ដែលលោកត្រូវហើយបាន ។ភិក្ខុនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំរឭកនូវគរុកាបត្តិមានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី អាបត្តិរងបារាជិកក្តី ដែលខ្ញុំត្រូវហើយ មិនឃើញទេ ម្នាលអាវុសោ តែខ្ញុំរឭកឃើញខ្លះ នូវអាបត្តិតិចតួច មានសភាពយ៉ាងនេះ ដែលខ្ញុំត្រូវហើយ ។ ភិក្ខុនោះញ៉ាំងភិក្ខុនេះ ដែលកំពុងបណ្តោះបណ្តៃ មិនឲ្យបណ្តោះបណ្តៃបានថា ម្នាលលោកមានអាយុ ណ្ហើយ លោកចូរទទួលដឹងដោយស្រួលចុះ បើលោករឭកនូវគរុកាបត្តិមានសភាពយ៉ាងនេះគឺអាបត្តិបារាជិកក្តីអាបត្តិរងបារាជិកក្តី ដែលលោកត្រូវហើយបាន ។ ភិក្ខុនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោ អម្បាលខ្ញុំ ត្រូវអាបត្តិបន្តិចបន្តួចប៉ុណ្ណោះ ដែលលោកមិនសួរសោះ ក៏គង់តទៅដឹងបាន ចំណង់បើខ្ញុំត្រូវគរុកាបត្តិមានសភាពយ៉ាងនេះគឺអាបត្តិបារាជិកក្តីអាបត្តិរងបារាជិកក្តី ដែលលោកសួរហើយ នឹងមិនទទួលដឹងដូចម្តេចបាន ។ភិក្ខុអ្នកចោទនោះ និយាយយ៉ាងនេះថា ម្នាលអាវុសោ អម្បាលលោកត្រូវអាបត្តិបន្តិចបន្តួចប៉ុណ្ណោះ ដែលខ្ញុំមិនសួរក៏នឹងមិនទទួលដឹង ចំណង់បើលោក

ត្រូវគរុកាបត្តិមានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី អាបត្តិវេ៍បារាជិកក្តី ដែលខ្ញុំមិនបានសួរ នឹងទទួលដឹងដូចម្តេចបាន ម្នាលលោកមានអាយុណេ្ហីយ លោកចូរទទួលដឹងដោយស្រួលចុះ បើលោករឭកនូវគរុកា-បត្តិមានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី អាបត្តិវេ៍បារាជិកក្តី ដែលត្រូវហើយបាន ។ ភិក្ខុនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំរឭកឃើញនូវគរុកាបត្តិ មានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី អាបត្តិវេ៍បារាជិកក្តី ដែលខ្ញុំត្រូវហើយ ពាក្យនេះខ្ញុំនិយាយលេងទេ ពាក្យនេះខ្ញុំនិយាយក្លែងទេ ខ្ញុំរឭកនូវគរុកាបត្តិមានសភាពយ៉ាងនេះគឺអាបត្តិបារាជិកក្តី អាបត្តិវេ៍បារាជិកក្តី ដែលខ្ញុំត្រូវហើយ មិនឃើញឡើយ ។ ម្នាលអានន្ទ តស្សបាបិយសិកាយ៉ាងនេះឯង ។ ការរម្ងាប់អធិករណ៍ពួកខ្លះក្នុងសាសនានេះ រមែងមានដោយតស្សបាបិយកាយ៉ាងនេះឯង ។

ម្នាលអានន្ទ ចុះតិណវត្ថារកៈតើដូចម្តេច ? ម្នាលអានន្ទ ក្នុងសាសនានេះ ភិក្ខុទាំងឡាយនាំគ្នាបង្កហេតុ ឈ្លោះទាស់ទែងគ្នា ហើយបានប្រព្រឹត្តអនាចារ បានពោល បានព្យាយាមល្មើស នូវកិច្ចមិនមែន

ជារបស់សមណៈជាច្រើន ម្នាលអានន្ទ ភិក្ខុទាំងអស់នោះឯង គប្បីព្រមព្រៀងប្រជុំគ្នា លុះប្រជុំគ្នាហើយ ភិក្ខុមួយរូបដែលជាអ្នកឈ្លាសជាងភិក្ខុដែលជាបក្ខពួកជាមួយគ្នា គប្បីក្រោកអំពីអាសនៈ ធ្វើចីវរឆៀងស្មាម្ខាង ប្រណម្យអញ្ជលីផ្ទៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្តាប់ខ្ញុំ យើងខ្ញុំទាំងឡាយក្នុងទីនេះ នាំគ្នាបង្កហេតុ ឈ្លោះទាស់ទែងគ្នា ហើយបានប្រព្រឹត្តអនាចារ បានពោល បានព្យាយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន បើកម្មមានកាលដ៏សមគួរដល់សង្ឃហើយ ខ្ញុំសូមសម្តែងអាបត្តិរបស់លោកអ្នកមានអាយុទាំងនេះផង អាបត្តិរបស់ខ្លួនខ្ញុំផង ដោយតិណវត្ថារកៈក្នុងកណ្តាលជំនុំសង្ឃ ជំនួសលោកមានអាយុទាំងឡាយនេះផង ដើម្បីខ្លួនខ្ញុំផង វៀរលែងតែអាបត្តិដែលមានទោសធ្ងន់ និងអាបត្តិដែលជាគិហិប្បដិសំយុត្ត ។ លំដាប់នោះ ភិក្ខុមួយរូប ជាអ្នកឈ្លាសជាងភិក្ខុទាំងឡាយដែលជាបក្ខពួកគ្នាដទៃទៀត គប្បីក្រោកអំពីអាសនៈ ធ្វើចីវរឆៀងស្មាម្ខាង ប្រណម្យអញ្ជលីផ្ទៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចម្រើន សូម

សង្ឃស្តាប់ខ្ញុំ យើងខ្ញុំទាំងឡាយក្នុងទីនេះ នាំគ្នាបង្កហេតុ ឈ្លោះទាស់ទែងគ្នា បានប្រព្រឹត្តអនាចារ បានពោល បានព្យាយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន បើកម្មមានកាលដ៏សមគួរដល់សង្ឃហើយ ខ្ញុំសូមសម្តែងអាបត្តិរបស់លោកមានអាយុទាំងឡាយនេះផង អាបត្តិរបស់ខ្ញុំផង ដោយតិណវត្ថារកៈ ក្នុងកណ្តាលជំនុំសង្ឃជំនួសលោកអ្នកមានអាយុទាំងឡាយនេះផង ដើម្បីខ្លួនខ្ញុំផង វៀរលែងតែអាបត្តិដែលមានទោសធ្ងន់ និងអាបត្តិជាគិហិប្បដិសំយុត្ត ។ ម្នាលអានន្ទ តិណវត្ថារកៈ យ៉ាងនេះឯង ។ ការរម្ងាប់អធិករណ៍ពួកខ្លះ ក្នុងសាសនានេះ រមែងមានដោយ តិណវត្ថារកៈ យ៉ាងនេះឯង ។

ម្នាលអានន្ទ ធម៌ ៦ ប្រការនេះ ជាសារាណីយធម៌ ( ធម៌នាំឲ្យរឭករកគ្នា ) ជាធម៌ធ្វើនូវសេចក្តីស្រឡាញ់ឲ្យដល់គ្នានិងគ្នា ជាធម៌ធ្វើសេចក្តីគោរពគ្នា ប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីសេចក្តីស្ងប់ស្ងាត់ ធម៌ ៦ ប្រការតើដូចម្តេចខ្លះ ? ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ បានតាំងកាយ-

កម្ម ប្រកបដោយមេត្តា ក្នុងពួកសព្រហ្មចារីបុគ្គល ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ នេះឯងឈ្មោះថា សារាណីយធម៌ ជាធម៌ធ្វើនូវសេចក្តីស្រឡាញ់ដល់គ្នានិងគ្នា ជាធម៌ធ្វើសេចក្តីគោរពគ្នា ប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីសេចក្តីស្ងប់ស្ងាត់ ១ ។ ម្នាលអានន្ទ មួយទៀត ភិក្ខុបានតាំងវចីកម្មប្រកបដោយមេត្តា ។ បេ ។ ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់ស្ងាត់ ១ ។ ម្នាលអានន្ទ មួយទៀត ភិក្ខុបានតាំងមនោកម្ម ប្រកបដោយមេត្តាក្នុងពួកសព្រហ្មចារីបុគ្គល ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ នេះឯងឈ្មោះថា សារាណីយធម៌ ជាធម៌ធ្វើនូវសេចក្តីស្រឡាញ់ឲ្យដល់គ្នានិងគ្នា ជាធម៌ធ្វើសេចក្តីគោរពគ្នា ប្រព្រឹត្តទៅដើម្បី សេចក្តីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីសេចក្តីស្ងប់ស្ងាត់ ១ ។ ម្នាលអានន្ទ មួយទៀត លាភទាំងឡាយណា ដែលប្រកបដោយធម៌ បានមកដោយធម៌ ដោយហោចទៅ សូម្បីត្រឹមតែអាហារបិណ្ឌបាត ភិក្ខុមិនជាអ្នកហួងហែង បរិភោគលាភមាន

សភាពដូច្នោះឡើយ ជាអ្នកបរិភោគជាសាធារណៈ ( ជាមួយ ) នឹងសព្រហ្មចារីបុគ្គល អ្នកមានសីលទាំងឡាយ នេះឯងឈ្មោះថា សារាណីយធម៌ ជាធម៌ធ្វើនូវសេចក្តីស្រឡាញ់ឲ្យដល់គ្នានិងគ្នា ជាធម៌ធ្វើសេចក្តីគោរពគ្នា ប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីសេចក្តីស្ងប់ស្ងាត់ ១ ។ ម្នាលអានន្ទ មួយទៀត សីលទាំងឡាយណា ដែលមិនដាច់ មិនធ្លុះ មិនពាល មិនពព្រុស ជាសីលដែលអ្នកប្រាជ្ញសរសើរ ជាសីលដែលតណ្ហានិងទិដ្ឋិមិនបានប៉ះពាល់ ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ភិក្ខុជាអ្នកមានសីលស្មើគ្នា ក្នុងសីលទាំងឡាយ មានសភាពដូច្នោះ ( ជាមួយ ) នឹងសព្រហ្មចារីបុគ្គល ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ នេះឯងឈ្មោះថា សារាណីយធម៌ ជាធម៌ធ្វើនូវសេចក្តីស្រឡាញ់ឲ្យដល់គ្នានិងគ្នា ជាធម៌ធ្វើសេចក្តីគោរពគ្នា ប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីសេចក្តីស្ងប់ស្ងាត់ ១ ។ ម្នាលអានន្ទ មួយវិញទៀត ទិដ្ឋិណាដ៏ប្រសើរ ជាទិដ្ឋិនាំសត្វ

ចេញចាកវដ្តៈ តែងដឹកនាំបុគ្គលអ្នកធ្វើតាមនោះ ឲ្យអស់នូវកងទុក្ខ ដោយប្រពៃ ភិក្ខុប្រកបដោយសេចក្តីយល់ឃើញស្មើគ្នា ដោយទិដ្ឋិ មានសភាពដូច្នោះ ( ជាមួយ ) នឹងសព្រហ្មចារីបុគ្គល ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ នេះឯងឈ្មោះថា សារាណីយធម៌ ជាធម៌ធ្វើនូវសេចក្តីស្រឡាញ់ដល់គ្នានិងគ្នា ជាធម៌ធ្វើសេចក្តីគោរពគ្នា ប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីសេចក្តីស្ងប់ស្ងាត់ ១ ។ ម្នាលអានន្ទ សារាណីយធម៌ ៦ ប្រការនេះឯង ជាធម៌ធ្វើនូវសេចក្តីស្រឡាញ់ឲ្យដល់គ្នានិងគ្នា ជាធម៌ធ្វើសេចក្តីគោរពគ្នា ប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីសេចក្តីស្ងប់ស្ងាត់ ។

ម្នាលអានន្ទ បើអ្នកទាំងឡាយ បានប្រព្រឹត្តសមាទាន នូវសារាណីយធម៌ ៦ ប្រការនេះ ឲ្យប្រពៃហើយ ម្នាលអានន្ទ តើអ្នកទាំងឡាយ មានដែលជួបគន្លងពាក្យ ជាពាក្យតូច ឬជាពាក្យថ្លោស ដែលគួរឲ្យអ្នកទាំងឡាយ អត់សង្កត់មិនបាន ដែរឬទេ ? បពិត្រព្រះ

អង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយ មិនដែលជួបពាក្យនោះទេ ។ ម្នាល អានន្ទ ព្រោះហេតុនោះ អ្នកទាំងឡាយ គួរតែប្រព្រឹត្តសមាទាននូវសារាណីយធម៌ទាំង ៦ ប្រការនេះ ឲ្យប្រពៃចុះ ព្រោះថាការប្រព្រឹត្តសមាទាននូវសារាណីយធម៌របស់អ្នកទាំងឡាយ នឹងមានប្រយោជន៍ មានសេចក្ដីសុខអស់កាលជាអង្វែង ។ លុះព្រះមានព្រះភាគ សម្ដែងព្រះសូត្រនេះចប់ហើយ ព្រះអានន្ទមានអាយុ ក៏មានចិត្តត្រេកអររីករាយ ចំពោះភាសិតរបស់ព្រះមហាមុនី ។

មានរឿងតំណាលអំពីព្រះមហាចុន្ទ បានពិចារណាមើលការស្ថិតនៅនៃព្រះសាសនា ក្នុងកាលជាអនាគត ដូចមានសម្ដែងនៅក្នុង **គម្ពីរទីឃនិកាយ បាដិកវគ្គ នៃបាសាទិកសូត្រ** មានសេចក្ដីថា ៖

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ប្រថាប់នៅក្នុងអម្ពវ័នរបស់ស្ដេចសក្យៈ ឈ្មោះថា វេធញ្ញៈ អ្នកជំនាញក្នុងវិជ្ជាបាញ់ព្រួញ ។ គ្រានោះ និគណ្ឋនាដបុត្រដែលជាម្ចាស់លទ្ធិរបស់ពួកនិគ្រន្ថ ទើបតែធ្វើមរណកាល នៅក្នុងក្រុងបាវា ហេតុក៏បានកើតឡើង ធ្វើឲ្យពួកនិគ្រន្ថ

ដែលជាបរិវារ កើតការបែកបាក់គ្នាជាពីរពួក ព្រោះតែការយល់ខុសគ្នា ។ ពេលនោះ ព្រះមហាចុន្ទត្ថេរ បានគង់ចាំវស្សានៅក្នុងក្រុងបាវា ក៏បានចូលទៅរកព្រះអានន្ទ ដែលលោកគង់នៅស្រុកសាមគ្រាម លុះចូលទៅដល់ហើយ ក៏បានតំណាលរឿងរបស់ពួកនិគ្រន្ថ ដែលបែកបាក់គ្នាឲ្យព្រះអានន្ទបានស្តាប់ថា ដោយហេតុមកពីធម៌វិន័យរបស់និគណ្ឋនាដបុត្រពោលទុកមិនល្អ ថែមទាំងមិនមែនជាធម៌វិន័យ ដែលនាំអ្នកបដិបត្តិចេញចាកទុក្ខបាន លំដាប់នោះ ទើបព្រះអានន្ទបបួលព្រះមហាចុន្ទត្ថេរចូលទៅគាល់ព្រះទសពល លុះចូលទៅដល់ហើយ ក៏បានក្រាបថ្វាយបង្គំ រួចក៏អង្គុយក្នុងទីដ៏សមគួរ ហើយក៏បានតំណាលរឿងទាំងនោះ ក្រាបទូលព្រះសម្ពុទ្ធឲ្យព្រះអង្គបានជ្រាប ។

គ្រានោះ ទើបព្រះសក្យមុនីត្រាស់ហេតុ ដែលធ្វើឲ្យបរិវារបែកបាក់គ្នាដូច្នេះថា មកពីសាស្តាមិនល្អ ធម៌វិន័យមិនល្អ និងសាវកមិនល្អ ហេតុទាំងបីនេះ បុគ្គលណាបដិបត្តិតាម រមែងមិនបានបុណ្យ ។ ប្រសិនបើសាស្តាមិនល្អ ធម៌វិន័យមិនល្អ តែសាវកល្អ ជាអ្នកបដិបត្តិ

តាម ថែមទាំងធ្វើសេចក្តីព្យាយាមតាម ក៏រមែងមិនបានបុណ្យ ។ តែថា សាស្តាល្អ ធម៌វិន័យល្អ ប៉ុន្តែសាវកមិនល្អ ចំពោះសាសនា និងធម៌វិន័យវិញ រមែងបានទទួលនូវការសរសើរ ចំណែកសាវកវិញ រមែងទទួលនូវការតិះដៀល បុគ្គលណាបដិបត្តិតាមសាសនា ធម៌វិន័យនោះ រមែងបានបុណ្យច្រើន ។ ប្រសិនបើសាស្តាក៏ល្អ ធម៌វិន័យក៏ល្អ សាវកក៏ល្អ រមែងបានទទួលនូវការសរសើរ បើបុគ្គលណាព្យាយាមបដិបត្តិតាម រមែងបានបុណ្យច្រើន ។ តែថា សាស្តាល្អហើយ ធម៌វិន័យល្អហើយ ចំណែកសាវកមិនយល់អត្ថន័យនៃធម៌ទាំងនោះ កាលសាស្តាស្លាប់ទៅហើយ សាវកទាំងនោះ ក៏រមែងមានការក្តៅក្រហាយក្នុងកាលជាខាងក្រោយ ។

ពេលនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងតទៅទៀតថា ម្នាលចុន្ទ ប្រសិនបើព្រហ្មចរិយធម៌ ប្រកបដោយអង្គទាំងនុ៎ះហើយ សាស្តាមិនមែនជាថេរៈ ជាអ្នកដឹងរាត្រីយូរ ជាអ្នកបួសយូរ តាំងនៅជាអង្វែង ជាអ្នកចម្រើនវ័យដោយលំដាប់ទេ ព្រហ្មចរិយធម៌នោះ

ឈ្មោះថា មិនបរិបូណ៌ដោយអង្គនោះ យ៉ាងនេះឡើយ ។ ម្នាលចុន្ទ បើព្រហ្មចរិយធម៌ប្រកបដោយអង្គយ៉ាងនេះហើយ ទាំងសាស្តាក៏ជាថេរៈ ជាអ្នកដឹងរាត្រី បួសយូរ តាំងនៅជាអង្វែង ចម្រើនវ័យដោយលំដាប់ ក្នុងកាលណាហើយ ព្រហ្មចរិយធម៌នោះ ទើបឈ្មោះថា បរិបូណ៌ដោយ អង្គនោះ យ៉ាងនេះ ក្នុងកាលនោះ ។

ម្នាលចុន្ទ ប្រសិនបើព្រហ្មចរិយធម៌ ប្រកបដោយអង្គទាំងនុ៎ះ ទាំងសាស្តាក៏ជាថេរៈ ជាអ្នកដឹងរាត្រីយូរ ជាអ្នកបួសយូរ តាំងនៅជាអង្វែង ជាអ្នកចម្រើនវ័យដោយលំដាប់ហើយ តែមិនមានពួកភិក្ខុជាសាវ័ករបស់សាស្តានោះ ជាថេរៈ ជាអ្នកឈ្លាសវៃ ដឹកនាំក្មៀវក្លា បានដល់ធម៌ក្សេមចាកយោគៈ អាចនឹងប្រាប់នូវព្រះសទ្ធម្មបាន អាចសង្កត់សង្កិននូវបរប្បវាទដែលកើតឡើងហើយ ឲ្យជាពាក្យដែលខ្លួនសង្កត់សង្កិនរៀបរយ ដោយពាក្យប្រកបដោយធម៌ ហើយសម្តែងធម៌ព្រមទាំងបាដិហារិយ៍ ព្រហ្មចរិយធម៌នោះ ឈ្មោះថា មិនបរិបូណ៌ដោយអង្គនោះ យ៉ាងនេះ ។ ម្នាលចុន្ទ បើព្រហ្មចរិយធម៌ប្រកបដោយអង្គ

ទាំងនុ៎ះ ទាំងសាស្តាក៏ជាថេរៈ ជាអ្នកដឹងរាត្រីយូរ ជាអ្នកបួសយូរ តាំងនៅជាអង្វែង ជាអ្នកចម្រើនវ័យដោយលំដាប់ហើយ ទាំងពួកភិក្ខុជាសាវករបស់សាស្តានោះ ក៏ជាថេរៈ ជាអ្នកឈ្លាសវៃ ដឹកនាំក្មៀវក្លាបានដល់ធម៌ក្សេមចាកយោគៈ អាចនឹងប្រាប់នូវព្រះសទ្ធម្មបាន អាចសង្កត់សង្កិននូវបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាពាក្យដែលខ្លួនសង្កត់សង្កិនរៀបរយ ដោយពាក្យប្រកបដោយធម៌ ហើយសម្តែងធម៌ព្រមទាំងបាដិហារិយ៍ក្នុងកាលណា ព្រហ្មចរិយធម៌នោះ ទើបឈ្មោះថា បរិបូណ៌ដោយអង្គនោះ យ៉ាងនេះ ក្នុងកាលនោះ ( បើចង់បានសេចក្តីពិស្តារក្នុងរឿងនេះតទៅទៀតនោះ សូមមើលនៅក្នុង **គម្ពីរទីឃនិកាយ បាដិកវគ្គ** ភាគ ១៨ ទំព័រ ២៤៩ ទៀតចុះ )។

លំដាប់នោះ ព្រះសម្ពុទ្ធបានត្រាស់ណែនាំព្រះមហាចុន្ទត្ថេរ ឲ្យប្រៀបធៀបធម៌ ដែលព្រះអង្គឃើញហើយ ដោយបញ្ញាដ៏ប្រពៃ គឺពិចារណាអត្ថ ដើម្បីធ្វើឲ្យព្រហ្មចរិយធម៌តាំងនៅស្ថិតស្ថេរ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ និងសេចក្តីសុខដល់ពួកជនច្រើន គឺដើម្បីអនុគ្រោះ

ដល់ទេវតា និងមនុស្សទាំងឡាយ ។ ហើយព្រះអង្គទ្រង់ពន្យល់ទៀតថា ធម៌ដែលព្រះអង្គសម្តែងហើយ ដោយបញ្ញាដ៏ប្រពៃនោះ មានសតិប្បដ្ឋាន ៤ ជាដើម មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ជាទីបំផុតទុក្ខ ។ ព្រះអង្គបានត្រាស់ណែនាំឲ្យសិក្សាពោធិបក្ខិយធម៌ទាំង ៣៧ ប្រការទាំងនេះ ដោយការព្រមព្រៀងគ្នា មិនឈ្លោះវិវាទគ្នា ហើយទ្រង់ត្រាស់វិធីសាកសួរព្រះធម៌ កាលបើព្រះសង្ឃ ឬមិត្តសព្រហ្មចារីដែលជាអ្នកសម្តែងព្រះធម៌ ។

១- កាលបើដឹងថា ប្រកាន់យកអត្ថខុស លើកព្យញ្ជនៈខុស ដែលមិនអាចយល់បាន ឬគប្បីពោលជំទាស់ដល់អ្នកសម្តែង ព្រមដោយព្យញ្ជនៈនេះ និងព្យញ្ជនៈមួយទៀតរបស់អត្ថនេះ និងអត្ថនេះ ឬអត្ថមួយទៀតរបស់ព្យញ្ជនៈនេះ យ៉ាងណានីមួយដោយត្រឹមត្រូវ បើអ្នកសម្តែងនោះពោលថា ព្យញ្ជនៈនេះ អត្ថនេះ ត្រឹមត្រូវហើយ ក៏មិនគប្បីពោលជំទាស់ និងកាន់យកដោយអត្ថ និងព្យញ្ជនៈនោះៗ ( ពាក្យថា ព្យញ្ជនៈ សំដៅដល់ តួអក្សរ ឬពាក្យ, ពាក្យថា អត្ថ សំដៅដល់

សេចក្ដីរបស់តួអក្សរ ឬពាក្យ ) ។

២- បើដឹងថា កាន់យកអត្ថខុស លើកព្យញ្ជនៈត្រូវ ក៏គប្បីសាកសួរអត្ថរបស់ព្យញ្ជនៈទាំងពីរចំណែក ថាចំណែកណាទីមួយត្រូវជាង ហើយពិចារណាដូចគ្នានឹងខ.ទី ១ ចុះ ។

៣- បើដឹងថា កាន់យកអត្ថត្រូវ លើកព្យញ្ជនៈខុស ក៏គប្បីសាកសួរអត្ថរបស់ព្យញ្ជនៈទាំងពីរចំណែករបស់អត្ថនោះ ថាចំណែកណាទីមួយត្រូវជាង ហើយពិចារណាដូចគ្នានឹងខ.ទី ១ ចុះ ។

៤- បើដឹងថា កាន់យកអត្ថត្រូវ លើកព្យញ្ជនៈត្រូវ ក៏គប្បីអនុមោទនា ហើយត្រាស់ថា ទ្រង់មិនបានសម្ដែងធម៌ដើម្បីសង្រួមអាសវៈ ( កិលេសដែលដេកត្រាំនៅក្នុងសន្ដាន ) បច្ចុប្បន្ន ឬដើម្បីឲ្យទម្លាយអាសវៈក្នុងកាលជាអនាគតយ៉ាងណាទីមួយប៉ុណ្ណោះ តែដើម្បីទាំងពីរចំណែក និងការដែលទ្រង់សម្ដែងការអនុញ្ញាតបច្ច័យ ៤ ថាក៏ដើម្បីបំបាត់បង់ភាពក្ដៅ និងត្រជាក់ ដើម្បីញុំាងជីវិតិន្ទ្រិយឲ្យប្រព្រឹត្តទៅបានស្រួលជាដើម ។

ព្រះអង្គបានបង្រៀនពីការឆ្លើយឆ្លង ជាមួយនឹងម្ចាស់លទ្ធិដទៃ ដូចមានសេចក្តីថា ម្នាលចុន្ទ បើអ្នកបួសក្នុងលទ្ធិដទៃ បានពោលជាមួយសមណសក្យបុត្រ ជាអ្នកប្រកបខ្លួនឲ្យសើម នៅដោយសេចក្តីសុខ អ្នកគប្បីសួរថា ប្រកបខ្លួនបែបណា បើមានច្រើន គឺ

១- មនុស្សខ្លះសម្លាប់សត្វ

២- មនុស្សខ្លះលួចទ្រព្យ

៣- មនុស្សខ្លះនិយាយកុហក

៤- មនុស្សខ្លះបម្រើខ្លួនដោយកាមគុណ ( គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ) ដែលគួរប្រាថ្នាស្រឡាញ់ពេញចិត្តយ៉ាងនេះ ឈ្មោះថាប្រកបខ្លួនឲ្យសើម នៅដោយសេចក្តីសុខបែបអ្នកស្រុក មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ។

បើអ្នកបួសក្នុងលទ្ធិដទៃសួរអ្នកថា សមណសក្យបុត្រប្រកបខ្លួនឲ្យសើម នៅដោយសេចក្តីសុខ ៤ យ៉ាង ដូចដែលពោលមកហើយនោះ ក៏គប្បីបដិសេធថា មិនជាការពិតឡើយ ហើយទ្រង់សម្តែងការប្រកប

ខ្លួនឲ្យសើម នៅដោយសេចក្ដីសុខ ដែលប្រព្រឹត្តទៅដើម្បីព្រះនិព្វានថា បានដល់ សេចក្ដីសុខក្នុងឈាន ៤ ។ បើអ្នកបួសក្នុងលទ្ធិដទៃពោលថា សមណសក្យបុត្រ ប្រកបខ្លួនឲ្យសើម នៅដោយសេចក្ដីសុខក្នុងឈាន ៤ យ៉ាងនោះ ក៏គប្បីពោលជានាថា ត្រឹមត្រូវ ។

បើអ្នកបួសក្នុងលទ្ធិដទៃសួរដល់ផល និងអានិសង្ស ដែលអ្នកប្រកបខ្លួនឲ្យសើម នៅដោយសេចក្ដីសុខក្នុងឈាន ៤ យ៉ាងនោះ តើគប្បីសង្ឃឹមបានអ្វី គប្បីតបថា មាន ៤ យ៉ាង គឺ

១- ជាព្រះសោតាបន្ន ២- ជាព្រះសកទាគាមី

៣- ជាព្រះអនាគាមី ៤- ធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្ត ។

ម្នាលចុន្ទ បើអ្នកបួសក្នុងលទ្ធិដទៃសួរថា សមណសក្យបុត្រមានធម៌ដែលមិនតាំងមាំ គប្បីពន្យល់ថា ធម៌ដែលព្រះមានព្រះភាគទ្រង់ត្រាស់ដល់សាវក មិនឲ្យឈានកន្លងរហូតដល់អស់ជីវិត មាននៅទៀត បានដល់ភិក្ខុដែលជាព្រះអរហន្តអស់អាសវៈហើយ នឹងមិនឈានកន្លងឋានៈ ៩ យ៉ាង រហូតដល់អស់ជីវិត គឺ

១- មិនសម្លាប់សត្វដោយការតាំងចិត្ត

២- មិនលួចទ្រព្យគេ

៣- មិនសេពមេថុនធម្ម

៤- មិននិយាយកុហកទាំងដែលកំពុងដឹងខ្លួន

៥- មិនសន្សំអាហារទុកបរិភោគ ដូចមនុស្សដែលធ្លាប់ជាអ្នកគ្រប់គ្រងផ្ទះ ឬឃ្លាំង

៦- មិនលំអៀងព្រោះស្រឡាញ់ ( ឆន្ទាគតិ )

៧- មិនលំអៀងព្រោះស្អប់ ( ទោសាគតិ )

៨- មិនលំអៀងព្រោះវង្វេង ( មោហាគតិ )

៩- មិនលំអៀងព្រោះខ្លាច ( ភយាគតិ ) ។

ម្នាលចុន្ទ បើអ្នកបួសក្នុងលទ្ធិដទៃសួរអ្នកថា សមណសក្យបុត្របញ្ញត្តញាណទស្សនៈ ( គឺការឃើញដោយបញ្ញា ) ដែលមិនមានព្រំដែន រាប់រយៈពេលយូរ ដែលជាអតីត មិនប្រារព្ធរយៈពេលយូរដែលជាអនាគត គប្បីពន្យល់ថា ញាណប្រឈមមុខដឹងការប្រព្រឹត្តទៅ

ក្នុងជាតិមុនៗ ប្រារព្ធអតីតកាលយូររបស់ព្រះតថាគតមាន ប្រាថ្នានឹងរឭកប៉ុនណា ក៏រឭកបានប៉ុណ្ណោះ ។

ចំណែកញាណ ដែលកើតពីបញ្ញាត្រាស់ដឹង ដែលប្រារព្ធអនាគតកាលយូរអង្វែងបាន រមែងកើតឡើងដល់ព្រះតថាគតថា ជាតិនេះជាជាតិចុងក្រោយ ។ ម្នាលចុន្ទ អតីត អនាគត បច្ចុប្បន្ន ដែលមិនពិត មិនប្រាកដ មិនមានប្រយោជន៍ តថាគតក៏មិនព្យាករដែរ ។ អតីត អនាគត បច្ចុប្បន្ន ដែលពិត ដែលប្រាកដ ដែលមានប្រយោជន៍ តថាគតរមែងដឹងកាល ហើយរមែងតបបញ្ហាក្នុងរឿងនោះ ។ តថាគតជាអ្នកពោលឲ្យសមរម្យដល់កាល ពោលការពិត ពោលសេចក្តីដែលពិត ពោលសេចក្តីដែលមានប្រយោជន៍ ពោលជាធម៌ ពោលជាវិន័យក្នុងធម៌ទាំងឡាយ ដែលជាអតីត អនាគត និងបច្ចុប្បន្ន ព្រោះដូច្នោះជនក្នុងលោកទើបហៅថា **តថាគត** ។ តថាគតជាអ្នកត្រាស់ដឹងដោយប្រពៃ ដឹងនូវកិច្ចទាំងពួងរបស់ទេវតា មារ ព្រហ្ម ព្រមទាំងសមណ-ព្រាហ្មណ៍ ដែលសម្រេចហើយ និងមិនសម្រេច ព្រោះដូច្នោះ ទើប

ហៅថា **តថាគត** ។ តថាគតបានត្រាស់សម្តែងនូវកិច្ចណា ក្នុងរវាង ដែលត្រាស់ដឹង នូវអនុត្តរសម្មាសម្ពោធិញ្ញាណ រហូតដល់បរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ កិច្ចនោះរមែងមានយ៉ាងនោះទាំងអស់ មិនមានជាយ៉ាងដទៃ ដូច្នោះ ទើបហៅថា **តថាគត** ។ តថាគតបាន ពោលយ៉ាងណា បានធ្វើយ៉ាងនោះ បានធ្វើយ៉ាងណា បានពោលយ៉ាង នោះ ព្រោះដូច្នោះ ទើបហៅថា **តថាគត** ។ តថាគតជាធំ មិនមានអ្នក ដទៃធំជាង ជាអ្នកឃើញតាមសេចក្តីពិត ថែមទាំងជាអ្នកមានអំណាច ក្នុងមនុស្សលោក ទេវលោក មារលោក ព្រហ្មលោក និងក្នុងពួកសព្វ សត្វទាំងអស់ ព្រោះដូច្នោះ ទើបជនក្នុងលោកហៅថា **តថាគត** ។

ម្នាលចុន្ទ បើអ្នកបួសក្នុងលទ្ធិដទៃសួរថា សត្វស្លាប់ហើយ កើត ឬមិនកើត ឬថាទាំងកើតទាំងមិនកើត ឬថាកើតក៏មិនមែន មិន កើតក៏មិនមែន គប្បីតបថា សេចក្តីនោះ ព្រះលោកនាយកទ្រង់មិនបាន ព្យាករទុកទេ ។ បើអ្នកបួសក្នុងលទ្ធិដទៃសួរថា ហេតុដូចម្តេច ទើបព្រះ សម្ពុទ្ធទ្រង់មិនព្យាករសេចក្តីនោះ ? គប្បីតបថា ព្រោះមិនប្រកបដោយ

ប្រយោជន៍ មិនប្រកបដោយធម៌ មិនជាខាងដើមនៃព្រហ្មចរិយធម៌ មិនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដើម្បីលះបង់នូវតម្រេក ដើម្បីការរលត់ទុក្ខ ដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងដ៏ក្រៃលែង ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ។ បើគេសួរថា ព្រោះហេតុអ្វី ទើបព្រះអង្គព្យាករ ? គប្បីឆ្លើយថា ទុក្ខ ហេតុឲ្យកើតទុក្ខ ការរំលត់ទុក្ខ និង១.បដិបត្តិឲ្យដល់ទីរំលត់ទុក្ខ បើមានគេសួរថា ហេតុអ្វីទើបព្រះអង្គទ្រង់ព្យាករចំពោះអរិយសច្ចៈ ៤ នោះ ? គប្បីតបថា ព្រោះប្រកបដោយប្រយោជន៍ ប្រកបដោយធម៌ ប្រព្រឹត្តទៅដើម្បីព្រះនិព្វានតែមួយចំណែកប៉ុណ្ណោះ ។

គ្រានោះ ព្រះសយម្ភូ ទ្រង់ត្រាស់នឹងព្រះមហាចុន្ទតទៅទៀតថា ម្នាលចុន្ទ ទិដ្ឋិ ( ការឃើញ ) ដែលតថាគតព្យាករ ក៏ទ្រង់ព្យាករ មិនគួរព្យាករ ក៏ទ្រង់មិនព្យាករ ហើយទ្រង់សម្តែងទិដ្ឋិដែលប្រកបដោយចំណែកខាងដើម ទាំងទិដ្ឋិដែលប្រកបដោយចំណែកខាងចុង និងត្រាស់ថា ទ្រង់មិនអនុមតិតាមពាក្យពោលរបស់ពួកសមណព្រាហ្មណ៍

ទាំងនោះ ព្រោះកាលដែលពួកសមណព្រាហ្មណ៍ ពោលអះអាងទៅផ្សេងៗ គ្នាថា ខ្លួន និងលោកទៀង ខ្លួន និងលោកមិនទៀង ខ្លួន និងលោកទៀងក៏មាន មិនទៀងក៏មាន ខ្លួន និងសត្វលោកកើតឯងៗ ខ្លួន និងលោកមានអ្នកដទៃធ្វើឲ្យ ខ្លួន និងលោកមិនមាននរណាធ្វើឲ្យ តែកើតឡើងឯងៗ សុខ និងទុក្ខទៀង សុខ និងទុក្ខមិនទៀងជាដើម ។ រហូតដល់សុខ និងទុក្ខមិនមាននរណាធ្វើឲ្យ តែកើតឡើងឯងៗ ។ ម្នាលចុន្ទ ពួកសមណៈ ឬព្រាហ្មណ៍បានពោលអះអាងទៅផ្សេងៗ គ្នាថា កាលបើស្លាប់ហើយ ខ្លួនមានរូបមិនមានរោគ, កាលបើស្លាប់ហើយ ខ្លួនមិនមានរូប, ខ្លួនមានរូបក៏មាន មិនមានរូបក៏មាន, ខ្លួនមានរូបក៏មិនមាន មិនមានរូបក៏មិនមាន, កាលបើស្លាប់ហើយ ខ្លួនមានសញ្ញា ខ្លួនមិនមានសញ្ញាជាដើម រហូតដល់ខ្លួនរមែងដាច់សូន្យ ។

ហេតុផលដែលព្រះលោកវិទូ ទ្រង់មិនអនុមតិតាមពាក្យពោលអះអាងរបស់សមណព្រាហ្មណ៍ទាំងនោះ ព្រោះនៅមានប្រភេទសត្វដទៃទៀត ដែលមានសភាពជាយ៉ាងដទៃ មិនបានស្លាប់ខ្លួន ដូចពាក្យ

ដែលសមណព្រាហ្មណ៍បានពោលអះអាងទាំងនោះ ។ ព្រះភគវា ទ្រង់សម្តែងសតិប្បដ្ឋានទាំង ៤ ដើម្បីឲ្យលះបង់ ឬឈានកន្លងនូវទិដ្ឋិទាំងពីរប្រភេទនោះ បានដល់ ទិដ្ឋិដែលប្រកបដោយចំណែកខាងដើម និងទិដ្ឋិដែលប្រកបដោយចំណែកខាងចុង ។ ពេលនោះ ព្រះឧបាទនៈដែលនៅឈរបក់ផ្លិតថ្វាយព្រះមហាមុនីនៅពីក្រោយ ក៏បានពោលសរសើរព្រះធម៌ទេសនានោះថា គួរឲ្យអស្ចារ្យ គួរឲ្យជ្រះថ្លាក្រៃលែង ធម្មបរិយាយនោះមានឈ្មោះអ្វីព្រះអង្គ ? ព្រះមានបុណ្យត្រាស់ថា ម្នាលឧបាទនៈ អ្នកចូរទ្រទ្រង់ចាំនូវធម្មបរិយាយនេះទុកថា **បាសាទិកៈ** ប្រែថា នាំមកនូវសេចក្តីជ្រះថ្លា ។

សមត្ថភាពផ្នែកខាងមានឫទ្ធិ របស់ព្រះមហាចុន្ទក៏មានដែរ ដូចដែលមានរឿងតំណាលទុកនៅក្នុង **អដ្ឋកថាធម្មបទ** នៃ **ពុទ្ធវគ្គ** ក្នុងរឿងយមកប្បាដិហារិយ៍ ដូចមានសេចក្តីថា ៖

ក្នុងបណ្តាពុទ្ធបរិស័ទ បានក្រាបទូលសូមធ្វើនូវឥទ្ធិបាដិហារិយ៍ជំនួសព្រះវិជិតមារក្នុងចំនួនពុទ្ធបរិស័ទទាំងអស់ ក៏មានព្រះមហាចុន្ទ

មួយរូបដែរ កាលនោះលោកនៅជាសាមណេរមានអាយុ ៧ ខួប តែបានជាព្រះខីណាស្រពហើយ ជាអ្នកដល់ព្រមដោយបដិសម្ភិទាទៀតផង ក៏បានចូលទៅក្រាបទូលនឹងព្រះភគវាថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមធ្វើបាដិហារិយ៍ជំនួសព្រះអង្គវិញ ។ ពេលនោះ ព្រះមុនីត្រាស់សួរថា អ្នកធ្វើយ៉ាងណាចុន្ទ សាមណេរចុន្ទ ក្រាបទូលថា ខ្ញុំព្រះអង្គនឹងអង្រួនដើមព្រីងធំ ដែលជាទង់នៃជម្ពូទ្វីបឲ្យញាប់ញ័រ ហើយនាំយកផ្លែព្រីងធំឲ្យមហាជន ដែលប្រជុំគ្នាក្នុងទីនេះបានបរិភោគ និងនាំយកផ្កាបារិជាត ( ផ្កាឋានសួគ៌ ) មកហើយ ថ្វាយព្រះអង្គ ។ លំដាប់នោះ ព្រះមានព្រះភាគត្រាស់ថា តថាគតជ្រាបដល់អានុភាពរបស់អ្នកហើយ តែតថាគតមិនអនុញ្ញាតឲ្យធ្វើបាដិហារិយ៍នោះឡើយ ។

គទៅនឹងនាំយករឿងរបស់ព្រះមហាចុន្ទត្ថេរ ដែលមានសេចក្ដីទាក់ទងនឹងការបរិនិព្វានរបស់ព្រះធម្មសេនាបតីសារីបុត្រ ព្រោះលោកជាបងប្រុសបង្កើតរបស់ព្រះចុន្ទ តាមដែលមានរឿងពោលទុកនៅក្នុងគម្ពីរសំយុត្តនិកាយ មហាវារវគ្គ នៃ នាលន្ទាវគ្គ ក្នុង ចុន្ទសូត្រ ថា ៖

សម័យមួយ ព្រះមហាវីរៈ ទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពន ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះសារីបុត្រ កើតមានអាពាធជាទម្ងន់នៅក្នុងស្រុកនាលន្ទា ក្នុងដែនមគធៈ ដែលជាស្រុកកំណើតរបស់លោក ។ ពេលនោះ ព្រះចុន្ទសមណុទ្ទេសជាអ្នកបដិបត្តិព្រះសារីបុត្រ ( ដោយការចាត់ចែងទឹកលុបមុខ ឈើស្ទន់ បោសសម្អាតបរិវេណ គក់ប្របាច់ រៀបចំបាត្រ និងចីវរឲ្យ ) ។

សេចក្តីនៅក្នុង **អដ្ឋកថាគម្ពីរសារត្ថប្បកាសិនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលី **គម្ពីរសំយុត្តនិកាយ** ដូចមានសេចក្តីថា ៖

ព្រះមហាចុន្ទ បានទិមន្តជាប់តាមព្រះសារីបុត្រ នៅចាំប្រតិបត្តិនៅស្រុកនាលន្ទានោះ ក្នុងពេលដែលព្រះសារីបុត្តត្ថេរជិតបរិនិព្វាន ។ ព្រះសារីបុត្របានសួរព្រះមហាចុន្ទត្ថេរថា នែចុន្ទ ពេលនេះ ជាពេលថ្មើរណា ។ ព្រះមហាចុន្ទ មានថេរវាចាតបថា ជាពេលទៀបភ្លឺហើយ ព្រះសារីបុត្តត្ថេរបានប្រាប់ព្រះមហាចុន្ទត្ថេរថា ចូរឲ្យប្រជុំភិក្ខុសង្ឃ កាលដែលភិក្ខុសង្ឃមកជុំគ្នាអស់ហើយ ព្រះមហាចុន្ទត្ថេរមានថេរវាចាថា

ព្រះភិក្ខុសង្ឃនិមន្តមកជុំគ្នាអស់ហើយ ទើបលោកប្រាប់ថា នែចុន្ទ អ្នកចូរជួយគ្រាហ៍ខ្ញុំក្រោកឡើងបន្តិចមើល៍ ។

ព្រះមហាចុន្ទត្ថេរ បានជួយគ្រាហ៍លោកឲ្យក្រោកឡើងអង្គុយ ហើយព្រះសារីបុត្រ បានសូមខមាទោសចំពោះភិក្ខុដែលជាបរិវារទាំងនោះ ព្រមទាំងអត់ទោសឲ្យដល់ភិក្ខុជាបរិវារទាំងនោះផងដែរ បន្ទាប់មកលោកក៏សិងផ្អៀងខាងស្តាំ យកចីវរបិទមុខ និងបានបរិនិព្វានក្នុងពេលចេញចាកចតុត្ថជ្ឈានហើយ ។ចំណែកមហាជន បានរួមគ្នាលេងសាធុកីឡា ប្រគំតន្ត្រី បុណ្យសពនៅរហូត ៧ ថ្ងៃ ៧ យប់ ហើយទើបធ្វើឈាបនកិច្ចសព របស់ព្រះសារីបុត្រនៅលើជើងថ្ករឈើក្រអូបខ្ពស់ដល់ ៩៩ ហត្ថ ។

ព្រះមហាចុន្ទ បានរក្សាអដ្ឋិធាតុព្រះសារីបុត្រ ដាក់ក្នុងសំពត់តម្រងទឹក ហើយគិតថា យើងមិនគួរនៅក្នុងទីនេះយូរពេកទេ យើងគួរប្រញាប់ទៅក្រាបបង្គំទូលព្រះមានព្រះភាគ ឲ្យទ្រង់ជ្រាបនូវការបរិនិព្វានរបស់ព្រះធម្មសេនាសារីបុត្រ គិតឃើញដូច្នេះហើយ ទើបកាន់យក

កញ្ចប់អដ្ឋិធាតុ ព្រមទាំងបាត្រ និងចីវរ របស់ព្រះសារីបុត្រទៅកាន់ក្រុងសាវត្ថី ។

រឿងនៅក្នុង ព្រះបាលីចុន្ទសូត្រ មានពោលដូចតទៅថា

ព្រះមហាចុន្ទ បាននាំយកបាត្រ និងចីវរ ព្រមទាំងអដ្ឋិធាតុរបស់ព្រះសារីបុត្រទៅដល់វត្តជេតពនមហាវិហារ បានចូលទៅរកព្រះអានន្ទត្ថេរ ថ្វាយបង្គំហើយ អង្គុយចុះ និងមានថេរវាចាថា បពិត្រព្រះអានន្ទដ៏ចម្រើន ព្រះសារីបុត្របរិនិព្វានទៅហើយ នេះបាត្រចីវររបស់លោក ។ ព្រះអានន្ទក៏ពោលថា នៃចុន្ទ រឿងដែលអ្នកនាំមកប្រាប់នេះ ជារឿងដែលគួរនាំចូលទៅគាល់ព្រះមានព្រះភាគ ហើយនាំគ្នាទៅគាល់ព្រះមានជោគ ក្រាបទូលក្នុងរឿងនេះឲ្យព្រះអង្គបានជ្រាប ។ ព្រះមហាចុន្ទតបទទួលថា ល្អហើយ លោកម្ចាស់អានន្ទ ។

កាលបើព្រះអានន្ទ និងព្រះមហាចុន្ទនាំគ្នាទៅដល់កន្លែងគាល់ហើយ ថ្វាយបង្គំរួច ក៏អង្គុយនៅក្នុងទីដ៏សមគួរ តពីនោះ ព្រះអានន្ទបានក្រាបទូលរឿងនោះថា បពិត្រព្រះមានព្រះភាគ ព្រះសារីបុត្តត្ថេរ

បរិនិព្វានហើយ ព្រះចុន្ទសមណុទ្ទេសប្រាប់ខ្ញុំព្រះអង្គថា នេះជាបាត្រ ចីវរ និងអដ្ឋិធាតុរបស់លោក រាងកាយរបស់ខ្ញុំព្រះអង្គ ដូចជាត្រូវចាក់ដោយលំពែង សូម្បីទិសទាំងឡាយមិនប្រាកដដល់ខ្ញុំព្រះអង្គ ( ផងឹត ៨ ទិស ) ធម៌ទាំងឡាយក៏មិនប្រាកដដល់ខ្ញុំព្រះអង្គ កាលបានស្តាប់ពាក្យថា ព្រះសារីបុត្របរិនិព្វានហើយ ព្រះអង្គ ។

កាលដែលព្រះមហាចុន្ទ ជាអ្នកនាំដំណឹងការបរិនិព្វានរបស់ព្រះសារីបុត្រមកប្រាប់ រហូតមានផលដោយសារតែឲ្យព្រះសារីបុត្របានទទួលការលើកទូលកិត្តិយស ពីព្រះមានព្រះភាគជាម្ចាស់ មានរឿងពោលទុកនៅក្នុង **អដ្ឋកថាសុមង្គលវិលាសិនី** ដូចមានសេចក្តីថា ៖

ព្រះអានន្ទ បានក្រាបទូលព្រះមានព្រះភាគជាម្ចាស់ ឲ្យទ្រង់ជ្រាបការបរិនិព្វានរបស់ព្រះសារីបុត្រ ទើបក្រាបទូលថ្វាយថា នេះជាបាត្រចីវរ និងកញ្ចប់អដ្ឋិធាតុរបស់ព្រះសារីបុត្រ ព្រះអង្គ ។ ព្រះមុនីទ្រង់លាព្រះហស្តចេញ ទទួលកញ្ចប់អដ្ឋិធាតុរបស់ព្រះថេរៈ និងទ្រង់ដាក់កញ្ចប់អដ្ឋិធាតុលើព្រះហស្ត ហើយត្រាស់សរសើរព្រះសារីបុត្រ

ថា ជាអ្នកទ្រទ្រង់គុណ និងអង់អាច ស្រស់ស្រទន់ ស្រដៀងគ្នានឹងតថាគត និងត្រាស់ឲ្យកសាងស្តូប បញ្ចុះអដ្ឋិធាតុរបស់ព្រះថេរៈនៅជិតខ្លោងទ្វារវត្តជេតពនមហាវិហារ ជិតក្រុងសាវត្ថី ។ ចំណែកក្នុងបាលីក្នុងចុន្ទសូត្រនេះ មានពោលដល់ព្រះមានព្រះភាគជាម្ចាស់ថា ព្រះអង្គទ្រង់បានសម្តែងធម៌ ឲ្យដល់បុគ្គលមានខ្លួនជាកោះ មានខ្លួនជាទីពឹង គឺចូរមានខ្លួនជាកោះ មានធម៌ជាទីពឹង មិនឲ្យសង្ឃឹមលើវត្ថុដទៃទេ និងអ្នកប្រាថ្នាយកចិត្តទុកដាក់ក្នុងការសិក្សា នឹងបានសម្រេចផលដ៏ប្រសើរ ។

ការប្រព្រឹត្តទៅក្នុងអតីតជាតិរបស់ព្រះមហាចុន្ទត្ថេរ តាមដែលពោលទុកនៅក្នុង **អដ្ឋកថាបរមត្ថទីបនី** ដូចមានសេចក្តីថា ៖

ព្រះមហាចុន្ទត្ថេរ ធ្លាប់បានធ្វើបុណ្យកុសលទុកក្នុងសម្នាក់នៃព្រះពុទ្ធទាំងឡាយ ក្នុងអតីតជាតិកន្លងមកហើយ តែក្នុងពេលដែលលោកកើតឡើងដើម្បីកសាងបុណ្យកុសលក្នុងភពផ្សេងៗ នោះ ជាតិមួយលោកបានទៅកើតនៅក្នុងត្រកូលនាយសូនផ្កាំងក្នុងក្រុងពន្ធុមតីដែលត្រូវនឹងពុទ្ធកាលរបស់ព្រះវិបស្សីសម្មាសម្ពុទ្ធ លោកបានទ្រទ្រង់

ជីវិត រស់នៅដោយការធ្វើថ្នាំផលក់ តាមវង្សត្រកូល ។ ក្នុងថ្ងៃមួយ លោកបានថ្វាយបាត្រដីដល់ព្រះវិបស្សីសម្ពុទ្ធ ដោយសេចក្តីជ្រះថ្លា និង ដោយអានិសង្សដែលបានថ្វាយបាត្រដីនោះ កាលបើលោកអស់ជីវិត អំពីជាតិនោះហើយ បានមកកើតជាមនុស្ស និងទេវលោកអស់កាល ដ៏យូរអង្វែង ។ រហូតមកដល់ពុទ្ធកាលនៃព្រះសមណគោតមបរមគ្រូ នៃយើងនេះ លោកបានមកកើតជាប្អូនប្រុសរបស់ព្រះសារីបុត្រ និងបាន ចូលមកបួសក្នុងព្រះពុទ្ធសាសនានេះ ដូចដែលបានពោលមកហើយ ក្នុងវគ្គខាងដើម ។

ម្យ៉ាងទៀត ជីវប្រវត្តិរបស់ព្រះមហាចុន្ទត្ថេរ ដែលបានពោល ទាំងអតីតជាតិ និងបច្ចុប្បន្នជាតិនោះ មានសម្តែងប្រាកដនៅក្នុង **គម្ពីរ ខុទ្ទកនិកាយ អបទាន** នៃ **ចុន្ទថេរអបទាន** ដែលលោកតំណាល ជីវប្រវត្តិដោយខ្លួនឯងមួយវគ្គ តែជាការពោលក្រោយអំពីលោក បាន សម្រេចជាព្រះអរហន្តហើយ ដូចមានសេចក្តីថា ៖

ខ្ញុំធ្វើចេតិយ ស្រោបដោយផ្កាម្លិះទាំងឡាយ បូជាចំពោះព្រះ

មានព្រះភាគ ព្រះនាមសិទ្ធត្ថ ជាចម្បងក្នុងលោក ទ្រង់មិនញាប់ញ័រ ដោយលោកធម៌ ។ លុះខ្ញុំរៀបចំស្រេចហើយ ទើបបង្អោនថ្វាយផ្កានោះ ចំពោះព្រះពុទ្ធ ហើយយកផ្កាដ៏សេសបង្អោនថ្វាយទៀត ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ នាំយកចេតិយផ្កាទៅថ្វាយ ចំពោះព្រះពុទ្ធ ជាអគ្គនាយកក្នុងលោក ព្រះអង្គប្រាកដស្មើដោយចេតិយមាស ។ ព្រះសម្ពុទ្ធ មានសេចក្តីសង្ស័យកន្លងបង់ហើយ មានពួកព្រះខីណាស្រព ដែលមានអន្លង់ធ្លងផុតចោមរោមហើយ ព្រះអង្គគង់នៅក្នុងចំណោមភិក្ខុសង្ឃ ហើយសម្តែងនូវគាថាទាំងនេះថា ។

កុលបុត្រណា បានថ្វាយដល់តថាគត នូវចេតិយដែលធ្វើដោយផ្កា មានក្លិនដូចជាទិព្វផ្សាយទៅ តថាគតនឹងសម្តែងសរសើរនូវកុលបុត្រនោះ អ្នកទាំងឡាយចូរស្តាប់តថាគតសម្តែងចុះ ។ បុរសនេះ លុះចុតិចាកអត្តភាពនេះទៅ នឹងទៅកើតក្នុងទេវលោក មានពួកទេវតាចោមរោម ជាអ្នកបរិបូណ៌ដោយផ្កាម្ទិះ ។ ទីនៅរបស់កុលបុត្រនោះ ដ៏ខ្ពស់ជាវិការនៃមាស និងកែវមណី ប្រាសាទទាំងឡាយ ដែល

បុញ្ញកម្មតាក់តែងហើយ នឹងកើតប្រាកដ ។ កុលបុត្រនោះ នឹងសោយទេវរាជ្យ នឹងសោយទិព្វសម្បត្តិ មានពួកស្រីអប្សរចោមរោម អស់ ៧៤ ដង ។ នឹងបានសោយរាជសម្បត្តិលើផែនដី គ្រប់គ្រងផែនដីអស់ ៣០០ ដង នឹងបានជាស្ដេចចក្រពត្តិអស់ ៧៥ ដង ។ កុលបុត្រនោះ នឹងកើតជាក្សត្រ ជាអធិបតីនៃមនុស្ស មាននាមថា **ទុជ្ជយៈ** អាស្រ័យនូវបុញ្ញកម្មរបស់ខ្លួន ហើយសោយនូវផលបុណ្យនោះ ។ កុលបុត្រនោះ នឹងមិនទៅកាន់កំណើតជាវិនិបាតឡើយ កាន់យកអត្តភាពតែជាមនុស្ស កុលបុត្រនោះ បានសន្សំប្រាក់ទុកច្រើនរាប់រយកោដិ ។ កុល-បុត្រនោះ នឹងកើតក្នុងកំណើតជាព្រាហ្មណ៍ ជាអ្នកចេះដឹង មានប្រាជ្ញា ជាឱរសជាទីស្រឡាញ់នៃវង្គន្តព្រាហ្មណ៍ និងនាងសារីព្រាហ្មណី ។ លុះកាលជាខាងក្រោយ កុលបុត្រនោះមាននាមថា **ចុល្លចុន្ទ** និងបានបួសក្នុងសាសនារបស់ព្រះសម្ពុទ្ធ ជាអង្គីរស នឹងបានជាសាវករបស់ព្រះមានជោគ ។ ចូល្លចុន្ទនោះ ជាសាមណេរ មានសន្ដានស្ងប់ស្ងាត់ បានជាព្រះខីណាស្រព កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមាន

អាសវៈ និងបរិនិព្វាន ។

ខ្ញុំបានបម្រើព្រះសម្ពុទ្ធ មានព្យាយាមធំផង បម្រើពួកភិក្ខុអ្នកមានសីលជាទីស្រឡាញ់ដទៃច្រើនអង្គផង បម្រើព្រះថេរៈជាបងនៃខ្ញុំផង ដើម្បីសម្រេចប្រយោជន៍ ដ៏ខ្ពង់ខ្ពស់ ។ ខ្ញុំបម្រើព្រះថេរៈជាបងរបស់ខ្ញុំរួចហើយ រើសព្រះធាតុដាក់ក្នុងបាត្រ នាំមកថ្វាយដល់ព្រះមុនីជាចម្បងក្នុងលោក ប្រសើរជាងនរៈ ។ ព្រះពុទ្ធ (ព្រះអង្គប្រសើរ) ក្នុងលោក ព្រមទាំងទេវលោក ទ្រង់ទទួលដោយព្រះហស្តទាំងពីរ ហើយបង្ហាញនូវព្រះធាតុនោះដល់ភិក្ខុសង្ឃ ។ ឯចិត្តរបស់ខ្ញុំរួចស្រឡះហើយ សទ្ធារបស់ខ្ញុំតម្កល់ខ្ជាប់ហើយ ខ្ញុំកំណាត់ដឹងនូវអាសវៈទាំងពួងជាអ្នកមិនមានអាសវៈ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះសម្ពុទ្ធដ៏មានសិរី ខ្ញុំក៏បានប្រតិបត្តិហើយ ។

ម្យ៉ាងទៀត ព្រះមហាចុន្ទត្ថេរ បានធ្វើនាទីឧបដ្ឋាកព្រះសម្ពុទ្ធ

ជារឿយៗ ក្រៅពីលោកអស់ការៈទៅបដិបត្តិ ចំពោះព្រះសារីបុត្រហើយ លោកក៏បានត្រឡប់មកជួយព្រះអានន្ទ ក្នុងការឧបដ្ឋាកព្រះមានបុណ្យជាបន្តទៅទៀត ។

ដូចមានរឿងដែលពោលទាក់ទង ធ្វើនាទីជាឧបដ្ឋាករបស់ព្រះមហាចុន្ទត្ថេរ ចំពោះព្រះមហាមុនី ដែលមានសម្តែងទុកនៅក្នុង **គម្ពីរទីឃនិកាយ មហាវគ្គ** នៃ **មហាបរិនិព្វានសូត្រ** ដូចមានសេចក្តីថា ៖

គ្រាមួយ ព្រះសាស្តាត្រាស់ជាមួយនឹងព្រះអានន្ទត្ថេរ ដែលជាឧបដ្ឋាកថា ម្នាលអានន្ទ ថ្ងៃនេះឯងតថាគតនឹងបរិនិព្វានក្នុងចន្លោះដើមសាលព្រឹក្សទាំងគូ នៅក្នុងសាលវ័នឧទ្យាន នៃមល្លក្សត្រ ក្បែរក្រុងកុសិនារា មកអានន្ទ យើងនាំគ្នាទៅកាន់ស្ទឹងកកុធានទីនោះសិន ។ គ្រានោះ ព្រះអានន្ទទទួលព្រះពុទ្ធដីកាថា ព្រះករុណាព្រះអង្គ ។ កាលព្រះវិជិតមារជាម្ចាស់ ព្រមទាំងភិក្ខុសង្ឃជាច្រើន ដែលមានរួមទាំងព្រះចុន្ទត្ថេរផងដែរ កាលបើស្តេចយាងទៅដល់ស្ទឹងកកុធានទី ទើប

ស្តេចយាងចុះទៅស្រង់ទឹក រួចស្រេចហើយស្តេចយាងត្រឡប់ឡើងមកវិញ ហើយស្តេចយាងទៅគង់ប្រថាប់នៅក្នុងអម្ពវនឧទ្យាន ក៏បានត្រាស់ជាមួយនឹងព្រះមហាចុន្ទត្ថេរថា ម្នាលចុន្ទ ចូរអ្នកប្រញាប់ទៅក្រាលសំពត់សង្ឃដី ៤ ជាន់ឲ្យតថាគត ព្រោះតថាគតល្ហិតល្ហៃណាស់ តថាគតចង់សិងសម្រាក ។ គ្រានោះ ព្រះចុន្ទទទួលព្រះពុទ្ធដីកាថា ព្រះករុណាព្រះអង្គ ហើយក៏ប្រញាប់ប្រញាល់ទៅក្រាលសំពត់សង្ឃដី ៤ ជាន់ថ្វាយព្រះពុទ្ធអង្គ ។ ពេលដែលក្រាលរួចហើយ ព្រះមានជោគទ្រង់ទៅផ្ទុំដោយសីហសេយ្យាស៍ ( សិងផ្អៀងខាងស្តាំ ) ទ្រង់តម្រួតព្រះបាទលើព្រះបាទ មានសតិសម្បជញ្ញៈ ។ ចំណែកព្រះមហាចុន្ទត្ថេរក៏បានអង្គុយគាល់នៅខាងមុខព្រះភក្ត្ររបស់ព្រះសាស្តា ដោយមិនបាននិមន្តគេចទៅទីណាឡើយ ។

រឿងទាំងអស់នេះ ដែលពោលឲ្យឃើញថា ក្រៅអំពីព្រះមហាចុន្ទត្ថេរជាឧបដ្ឋាកព្រះសម្ពុទ្ធហើយ ក៏សម្តែងឲ្យឃើញថា លោកមាន

អាយុវែងរហូតដល់ព្រះមានព្រះភាគ ស្តេចរំលត់ខន្ធបរិនិព្វាន ។ កាល
តមក គឺក្រោយពីព្រះទសពលស្តេចរំលត់ខន្ធបរិនិព្វានទៅហើយនោះ
លោកបានទ្រទ្រង់នូវអាយុសង្ខារ មកដល់កាលដ៏សមគួរហើយ ទើប
លោករំលត់ខន្ធចូលកាន់អមតមហានិព្វានទៅហោង ។៚

( ជីវប្រវត្តិរបស់ព្រះមហាចុន្ទត្ថេរ ចប់ )

888888888888888888888888888888888888

# ✍ ជីវប្រវត្តិរបស់ព្រះអជិតត្ថេរ ✍

## “ លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័កផងដែរ ”

ព្រះអជិតត្ថេរ លោកជាព្រះអរិយមហាសាវក នៅក្នុងគណៈសោឡសភិក្ខុ និងបានទទួលការលើកតម្កើងឲ្យចូលនៅក្នុងចំណោមព្រះអសីតិមហាសាវក គឺជាសាវកធំរបស់ព្រះពុទ្ធជាម្ចាស់ ៨០ រូប ចំណែកជីវប្រវត្តិរបស់លោកវិញ ក៏មានសម្តែងទុកទាំងក្នុងអតីតជាតិ និងបច្ចុប្បន្នជាតិផងដែរ ។

ជីវប្រវត្តិក្នុងអតីតជាតិរបស់ព្រះអជិតត្ថេរ ដែលមានសម្តែងទុកនៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** បានសម្តែងដល់ការកសាងសន្សំបុណ្យកុសល និងសេចក្តីល្អផ្សេងៗ ទុកថា ៖

ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ជាលោកនាយក ទ្រង់ដល់នូវត្រើយ នៃធម៌ទាំងពួង ស្តេចចូលទៅក្នុងព្រៃហិមពាន្ត ហើយគង់នៅ ។ ខ្ញុំមិនធ្លាប់ស្គាល់ព្រះសម្ពុទ្ធ ទាំងមិនធ្លាប់ឮសូរស័ព្ទគេប្រាប់អំពីព្រះអង្គ

ខ្ញុំកំពុងដើរស្វែងរកកិច្ចា ក្នុងព្រៃដើម្បីខ្លួនខ្ញុំ ។ ខ្ញុំបានឃើញព្រះសម្ពុទ្ធ ទ្រង់មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ក្នុងព្រៃនោះ លុះឃើញហើយ ក៏មានសេចក្ដីត្រិះរិះថា បុរសនេះ ជាអ្វីហ្ន៎ ។ ខ្ញុំខំពិនិត្យមើលលក្ខណៈទាំងឡាយ ក៏បាននឹកឃើញ នូវវិជ្ជារបស់ខ្ញុំថា សុភាសិតនេះ ខ្ញុំបានឮមកពីសម្នាក់ នៃព្រះពុទ្ធជាអ្នកប្រាជ្ញ ។ បុរសនេះ ជាក់ជាព្រះពុទ្ធ សមដូចពាក្យនៃព្រះពុទ្ធទាំងនោះ បើដូច្នោះ អាត្មាអញគប្បីធ្វើសក្ការៈចំពោះព្រះអង្គ ព្រះអង្គនឹងញុំាងគតិរបស់អញឲ្យស្អាត ។ ខ្ញុំបានត្រឡប់មកកាន់អាស្រម ដោយរួសរាន់ ហើយកាន់យកទឹកឃ្មុំ ប្រេង និងថ្នាំង ដើរចូលទៅជិតព្រះលោកនាយក ។ ខ្ញុំបានកាន់យកឈើ ៣ កំណាត់ មកតម្កល់ទុកក្នុងទីវាល ហើយអុជប្រទីប ថ្វាយបង្គំអស់ ៨ លើក ។ ព្រះមានជោគជាបុរសដ៏ឧត្ដម ជាលោកនាយក ទ្រង់គង់អស់ ៧ យប់ ៧ ថ្ងៃ លំដាប់អំពីនោះមក ទ្រង់ក្រោកចាកអាសនៈ ក្នុងវេលាជាទីអស់នៃរាត្រី ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ អស់យប់ និងថ្ងៃទាំងអស់ ខ្ញុំមានចិត្តជ្រះថ្លា ថ្វាយប្រទីបដល់

ព្រះពុទ្ធ ដោយដៃរបស់ខ្លួន ។ គ្រឿងក្រអូបទាំងពួង ដែលកើតក្នុងព្រៃ មាននៅលើភ្នំគន្ធមាទន៍ ក៏មកក្នុងសម្នាក់នៃព្រះពុទ្ធ ដោយអានុភាពនៃព្រះពុទ្ធ ។ ឈើណាមួយ ដែលមានផ្ការីក ហើយមានផ្កាក្រអូប ឈើទាំងអស់នោះ ប្រជុំគ្នាហើយក្នុងកាលនោះ ដោយអានុភាពនៃព្រះពុទ្ធ ។ នាគ និងគ្រុឌទាំងឡាយ ទាំងអម្បាលម៉ាន (ដែលនៅ) ក្នុងព្រៃហិមពាន្ត សត្វទាំងពីរពួកនោះ មានប្រាថ្នាដើម្បីស្តាប់ធម៌ បាននាំគ្នាមកក្នុងសម្នាក់នៃព្រះពុទ្ធ ។ សមណៈឈ្មោះទេវលៈ ជាអគ្គសាវ័កនៃព្រះពុទ្ធ បានចូលមកកាន់សម្នាក់នៃព្រះពុទ្ធ ជាមួយនឹងភិក្ខុមួយសែនអង្គ ដែលជាអ្នកស្ទាត់ក្នុងឈាន ។ ព្រះបទុមុត្តរៈ ទ្រង់ជាក់ច្បាស់នូវត្រៃលោក ទ្រង់គួរទទួលនូវការបូជា ទ្រង់គង់នៅក្នុងកណ្តាលនៃពួកភិក្ខុ ហើយបានត្រាស់គាថាទាំងនេះថា

បុរសណាជ្រះថ្លា ហើយញ៉ាំងប្រទីបឲ្យភ្លឺ ដោយដៃរបស់ខ្លួន ដើម្បីតថាគត តថាគតនឹងសរសើរ នូវបុរសនោះ អ្នកទាំងឡាយចូរប្រុងស្តាប់ នូវពាក្យរបស់តថាគតដែលនឹងសម្តែងចុះ ។ បុរសនេះ

នឹងរីករាយក្នុងទេវលោកអស់ ៦ ម៉ឺនកប្ប នឹងបានសោយរាជ្យ ជាស្តេចចក្រពត្តិអស់មួយពាន់ដង ។ បុរសនេះ នឹងបានជាធំជាងទេវតា នឹងសោយរាជ្យក្នុងទេវលោកអស់ ៣៦ ដង នឹងសោយរាជ្យ ដ៏ធំទូលាយលើផែនដីអស់ ៧ រយដង ។ នឹងបានសោយប្រទេសរាជ ដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យកប្ប នឹងបានជាអ្នកមានចក្ខុជាទិព្វ ដោយផលនៃប្រទីបនេះ ។ បុរសនេះ នឹងមើលឃើញ អស់ទីកន្លះក្រោសជុំវិញ សព្វកាល កាលបើបុរសនេះ ច្យុតចាកទេវលោក ហើយមកកើត ( ក្នុងមនុស្សលោក ) នឹងមានគេទ្រទ្រង់ប្រទីបឲ្យ ទាំងយប់ទាំងថ្ងៃ ។ កាលបើបុរសអ្នកប្រកបដោយបុញ្ញកម្មនេះ កើតឡើង ទីក្រុងត្រឹមណា នឹងភ្លឺរន្ទាលត្រឹមនោះ ។ បុរសនេះ ចាប់កំណើតណា ទោះជាទេវតា ឬជាមនុស្ស ជនទាំងឡាយ នឹងបម្រើបុរសនេះ ដោយអំណាចនៃទីបទាននោះផង ដោយផលនៃប្រទីប ៨ ផង នេះជាផលនៃទីបទាន ។កន្លងទៅមួយសែនកប្បទៀត ព្រះសាស្តា ព្រះនាមគោតម ទ្រង់នឹងសម្ភពក្នុងត្រកូលនៃស្តេចឱក្កាកៈ នឹងត្រាស់

ដឹងក្នុងលោក បុរសនេះ ជាអ្នកទទួលមត៌កក្នុងធម៌ របស់ព្រះគោតម នោះ ជាឱរសដែលធម៌និម្មិត នឹងកំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នក មិនមានអាសវៈ នឹងបរិនិព្វាន ។ បុរសនេះ នឹងបានជាសាវកនៃព្រះ សាស្តា ឈ្មោះអជិតៈ នឹងញ៉ាំងព្រះសម្ពុទ្ធ ព្រះនាមគោតម ជាសក្យៈ ដ៏ប្រសើរ ឲ្យត្រេកអរ ។

ខ្ញុំត្រេកអរហើយ ក្នុងទេវលោកអស់ ៦ ម៉ឺនកប្ប ខ្ញុំមានប្រទីប ចំនួនមួយរយ តែងភ្លឺរុងរឿង អស់កាលជានិច្ចក្នុងទីនោះ ។ រស្មីរបស់ ខ្ញុំ តែងផ្សាយទៅ ក្នុងទេវលោក ឬក្នុងមនុស្សលោក ខ្ញុំរឭកឃើញ នូវព្រះពុទ្ធដ៏ប្រសើរ ហើយញ៉ាំងសេចក្តីរីករាយដ៏ក្រៃលែងឲ្យកើត ឡើង ។ ខ្ញុំច្យុតចាកឋានតុសិតមកកាន់ផ្ទៃនៃមាតា កាលខ្ញុំកំពុងកើត ពន្លឺដ៏ធំទូលាយកើតប្រាកដឡើង ។ ខ្ញុំចេញចាកផ្ទះ ចូលទៅកាន់ផ្នួស រួចចូលទៅរកពាវរីព្រាហ្មណ៍ ហើយដល់នូវភាពជាសិស្សនៃព្រាហ្មណ៍ នោះ ។ កាលខ្ញុំនៅក្នុងព្រៃហិមពាន្ត បានឮនូវព្រះលោកនាយក កាល ខ្ញុំស្វែងរកប្រយោជន៍ដ៏ឧត្តម បានចូលទៅគាល់ព្រះលោកនាថ ។ ព្រះ

សម្មាសម្ពុទ្ធទ្រង់ជាអ្នកទូន្មាន បានទូន្មានខ្ញុំហើយ ទ្រង់ចូងឱយៈ មិនមាន ឧបធិក្កិលេស ព្រះសម្ពុទ្ធទ្រង់សម្តែងព្រះនិព្វាន ជាធម៌ញុំាំងសត្វឲ្យ រួចចាកទុក្ខទាំងពួង ។ ដំណើរមករបស់ខ្ញុំនោះ ស្រេចហើយ ខ្ញុំបាន ញុំាំងព្រះភគវា ឲ្យត្រេកអរហើយ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា នៃព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ ក្នុងកប្បទីមួយសែនអំពីកប្បនេះ ក្នុង កាលនោះ ព្រោះហេតុដែលខ្ញុំបានឲ្យប្រទីប ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃទីបទាន ។ កិលេសទាំងឡាយ ខ្ញុំដុតចោលហើយ ភព ទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចដំរីកាត់ទន្លីង ។ ឱហ្ន៎ ដំណើរដែលខ្ញុំមក ក្នុងសម្នាក់នៃព្រះពុទ្ធ របស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិ-សម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំក៏បានធ្វើឲ្យជាក់ច្បាស់ ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានបដិបត្តិហើយ ។

ជីវប្រវត្តិក្នុងអតីតជាតិរបស់ព្រះអជិតត្ថេរ ក្នុងជាតិតមក មាន រឿងពោលទុកនៅក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយ

សេចក្តីបាលី **គម្ពីរខុទ្ទកនិកាយ ថេរគាថា** ដូចមានសេចក្តីថា ៖

ក្នុងកប្បទី ៩១ ដោយរាប់ថយក្រោយទៅពីកប្បនេះ ព្រះអជិតៈ បានកើតឡើងត្រូវនឹងពុទ្ធកាលនៃព្រះវិបស្សីសម្ពុទ្ធ ។ ថ្ងៃមួយលោកបានឃើញព្រះវិបស្សីជាម្ចាស់ ស្តេចកំពុងតែត្រាច់ចារិកបិណ្ឌបាត ក៏កើតសទ្ធាជ្រះថ្លា ទៅនាំយកផ្លែក្តិដ្ឋ យកមកដាក់បាត្រ កាលតមកបានធ្វើបុណ្យផ្សេងៗ ទៀតជាច្រើន លុះអស់ជីវិតអំពីជាតិនោះហើយបានស្លាប់កើតៗ ក្នុងមនុស្ស និងទេវតាអស់កាលដ៏យូរអង្វែង ។

ចំណែកជីវប្រវត្តិអតីតជាតិរបស់ព្រះអជិតត្ថេរ ដែលពោលដល់ការកសាងសន្សំបុណ្យបារមី រួមគ្នាជាមួយនឹងពាវរីព្រាហ្មណ៍ និងមាណព ១៥ នាក់ទៀត នៅក្នុងពុទ្ធកាលនៃព្រះកស្សបសម្ពុទ្ធ ដូចមានរឿងប្រាកដនៅក្នុង **អដ្ឋកថាបរមត្ថជោតិកា** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីក្នុង **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** ដូចមានសេចក្តីថា ៖

ក្នុងអតីតកាល នាពុទ្ធសម័យរបស់ព្រះកស្សបសម្ពុទ្ធជាម្ចាស់ ព្រះអជិតត្ថេរ បានកើតនៅក្នុងក្រុងពារាណសី ដោយបានជាកូនសិស្ស

ប្រធានមេជាងឈើម្នាក់ ដែលជាអ្នកមានចំណេះដឹងផ្នែកខាងជាង ឈើមិនមាននរណាៗ ប្រៀបផ្ទឹមបានជាគម្រប់ពីរ ប៉ុន្តែមេជាងនោះ មានកូនសិស្ស ១៦ នាក់ ក្នុងសិស្សម្នាក់ៗ មានកូនសិស្សម្នាក់ៗ ១ ពាន់នាក់ រាប់រួមទាំងកូនសិស្ស និងអាចារ្យ មាន ១ ម៉ឺន ៦ ពាន់ ១៧ នាក់ ។ បណ្តាជាងឈើទាំងអស់នោះ បានធ្វើការរកស៊ីចិញ្ចឹមជីវិតនៅក្នុងក្រុងពារាណសី ដោយប្រកបមុខរបរជាជាងឈើទាំងអស់ ដោយពួកគេនាំគ្នាទៅតាមទីជិតភ្នំ ដើម្បីរកកាប់ឈើមកធ្វើជាប្រាសាទក្នុងរូបភាពផ្សេងៗ និងរៀបចំឲ្យរួចស្រេចរៀបរយល្អហើយ នៅក្នុងស្ថានទីនោះ ហើយរុះរើចេញនាំយកមកដាក់ផ្ទុកលើផែ រួចបណ្តែតចុះយកមកលក់ នៅក្នុងក្រុងពារាណសី ប្រសិនបើព្រះរាជា ទ្រង់ត្រូវការប្រាសាទ ១ ជាន់ ឬ ៧ ជាន់ ពួកគេនឹងជួយគ្នាកសាងថ្វាយ តែបើព្រះរាជាទ្រង់មិនប្រាថ្នាទេ ពួកគេនឹងលក់ឲ្យដល់បុគ្គលដទៃទៀត ដើម្បីនាំយកមាសប្រាក់មកចិញ្ចឹមបុត្រភរិយា ។

ថ្ងៃមួយ អាចារ្យរបស់ពួកជាងឈើទាំងនោះគិតថា យើងមិន

អាចចិញ្ចឹមជីវិត ដោយអាជីពជាជាងឈើនេះបានជានិច្ចទេ ពីព្រោះថា បើយើងចាស់ទៅ កិច្ចការងារជាជាងឈើនេះ មិនអាចប្រព្រឹត្តទៅបាន ព្រោះជាកិច្ចការងារធ្ងន់ ដែលធ្វើបានដោយលំបាក កាលបើគិតឃើញដូច្នេះហើយ ទើបហៅពួកកូនសិស្សទាំងនោះមកប្រាប់ថា ពួកអ្នកទាំងអស់គ្នា ពួកយើងចូរនាំគ្នាទៅរកឈើដែលមិនមានខ្លឹម មានដើមល្វាជាដើមមក ។ គ្រានោះ ពួកកូនសិស្សក៏ទទួលយល់ព្រមថា បាទ បាទ ហើយនាំគ្នាចូលទៅរកឈើដែលមិនមានខ្លឹមមក ។ មេជាងឈើដែលជាអាចារ្យ បាននាំយកឈើទាំងនោះមកធ្វើជាសត្វ និងធ្វើជាគ្រឿងយន្តទុកក្នុងតួសត្វទាំងនោះ ។ សត្វឈើនោះ ពេលហើរឡើងលើអាកាស មានលក្ខណៈដូចគ្នានឹងស្តេចហង្ស ហើយហើរចុះទៅក្នុងព្រៃដែលជាទីបរិវេណរបស់ពួកសិស្សទាំងនោះ ។ ពេលនោះ មេជាងឈើដែលជាអាចារ្យ បានប្រាប់ដល់ពួកសិស្សទាំងនោះថា ពួកយើងអាចធ្វើពាហនៈសត្វឈើបែបនេះ ហើយដើម្បីបានជាកម្លាំងទៅ រឹបអូសយករាជសម្បត្តិនៅក្នុងជម្ពូទ្វីបទាំងអស់ឲ្យបាន ដូច្នេះពួកយើងចូរនាំគ្នា

ជួយធ្វើសត្វពាហនៈយ៉ាងនេះឲ្យបានច្រើន ដើម្បីទៅរឹបអូសយករាជសម្បត្តិក្នុងនគរដទៃៗ ព្រោះការចិញ្ចឹមជីវិត ដោយការងារជាជាងឈើនេះ លំបាកណាស់ ។

ពួកកូនសិស្សទាំងនោះ បាននាំគ្នាធ្វើតាមពាក្យណែនាំរបស់អាចារ្យ កាលធ្វើរួចស្រេចហើយ ក៏បានជម្រាបរឿងរ៉ាវទាំងអស់នោះឲ្យអាចារ្យបានជ្រាប ។ ចំណែកអាចារ្យបានសួរកូនសិស្សថា តើពួកយើងទៅរឹបអូសយករាជសម្បត្តិក្នុងនគរណាមុនទើបជាការល្អ ។ ពួកកូនសិស្សឆ្លើយប្រាប់ថា ពួកយើងគួរទៅរឹបអូសយករាជសម្បត្តិ នៅក្នុងក្រុងពារាណសីមុនទើបជាការល្អ ។ គ្រានោះ លោកអាចារ្យបានពោលហាមថា កុំឲ្យសោះពួកអ្នកទាំងអស់គ្នា ពួកអ្នកទាំងអស់គ្នា កុំពេញចិត្តក្នុងការរឹបអូសយករាជសម្បត្តិ នៅក្នុងក្រុងពារាណសីឡើយ កាលបើពួកយើងរឹបអូសយករាជសម្បត្តិ នៅក្នុងក្រុងពារាណសីបានហើយ ពាក្យថា ជាងឈើ នឹងមានដល់ពួកយើងទៅហើយ ប្រាកដជាជនដ៏ច្រើននាំគ្នាហៅយើងថា ព្រះរាជាជាងឈើ ដូច្នេះ អ្នកទាំងឡាយ

ចូរនាំគ្នាទៅរឹបអូសយករាជសម្បត្តិនៅនគរដទៃសិនចុះ ។

ពេលនោះ ពួកជាងឈើទាំងនោះក៏បានព្រមព្រៀងគ្នារួចស្រេចហើយ ទើបនាំបុត្រ និងភរិយាឡើងជិះពាហនៈសត្វឈើ ព្រមដោយអាវុធគ្រប់ដៃ ហើយនាំគ្នាឆ្ពោះមុខទៅកាន់ព្រៃហិមពាន្ត និងបានចូលទៅកាន់ក្រុងមួយដែលនៅជិតគ្នានឹងព្រៃហិមពាន្តនោះ ហើយបានចូលទៅសម្រាកក្នុងព្រះរាជនិវេសន៍ ។ ពួកគេបានរឹបអូសយករាជសម្បត្តិក្នុងក្រុងនោះបានហើយ ទើបអភិសេកអាចារ្យដែលជាមេជាងឈើឲ្យឡើងជាព្រះរាជា មាននាមប្រាកដថា **ព្រះរាជាកដ្ឋវាហនៈ** ប្រែថា ព្រះរាជាពាហនៈឈើ ក្រុងនោះមានឈ្មោះថា ក្រុងកដ្ឋវាហនៈ ដោយកាន់យកព្រះនាមព្រះរាជាជាគោល ។ ព្រះរាជាកដ្ឋវាហនៈ ទ្រង់ជាអ្នកតាំងនៅក្នុងរាជធម៌ ទាំងឧបរាជ ឬរាជទាហានក៏ដូចគ្នា ។ ចំណែកកូនសិស្សទាំង ១៦ នាក់នោះ ឲ្យទទួលតំណែងជាអាមាត្យនៅក្នុងរាជសម្នាក់ ។

**រាជធម៌** បានដល់ ធម៌សម្រាប់ស្ដេចអ្នកគ្រប់គ្រងផែនដី សំដៅ

ដល់គុណសម្បត្តិរបស់អ្នកគ្រប់គ្រងដ៏ល្អ អាចគ្រប់គ្រងនូវផែនដីបាន ដោយធម៌ និងញ៉ាំងប្រយោជន៍ ព្រមទាំងសេចក្ដីសុខឲ្យដល់ប្រជាជន រហូតបានទទួលការសរសើរថា ព្រះរាជាប្រកបដោយទសពិធរាជធម៌ ទសពិធរាជធម៌នោះ មាន ១០ ប្រការគឺ ១-ទាន ២-សីល ៣-បរិច្ចាគ ៤- អាជ្ជវៈ ( ការទៀងត្រង់ ) ៥- មទ្ទវៈ ( ភាពទន់ភ្លន់ ) ៦- តបៈ ៧- អក្កោធៈ ៨- អវិហិង្សា ៩- ខន្តី ១០- អវិរោធនៈ ( ការមិនឃ្លាតចាកធម៌ ) ។

កាលព្រះរាជាទ្រទ្រង់ទសពិធរាជធម៌នេះហើយ ក៏បានសង្គ្រោះមហាជនដោយសង្គហវត្ថុដទៃទៀត ដោយយកចិត្តទុកដាក់ទំនាក់ទំនងប្រជាជន មាន ៤ ប្រការ គឺ

**១- សស្សមេធៈ** ការឆ្លាតក្នុងការបម្រុងធញ្ញាហារឲ្យបរិបូណ៌ ដោយទ្រង់គាំទ្រផ្នែកកសិកម្ម ។

**២- បុរិសមេធៈ** ការឆ្លាតក្នុងការបម្រុងអ្នករាជការ និងទ្រង់លើកទឹកចិត្ត គាំទ្រមនុស្សល្អ ដែលមានចំណេះចេះដឹង និងមាន

សមត្ថភាពក្នុងកិច្ចការងារ ។

៣- **សម្មាបាសៈ** ទ្រង់បំបាត់ទុក្ខ បម្រុងសុខដល់រាស្ត្រ ដោយទ្រង់គាំទ្រអាជីពរបស់ប្រជាជន ។

៤- **វាចាបេយ្យៈ ឬ វាជបេយ្យៈ** ត្រាស់វាចាពីរោះផ្អែមល្ហែមជាមួយនឹងប្រជាជនគ្រប់ជាន់ថ្នាក់ ។ ដោយទ្រង់មានព្រះរាជតម្រាស់ពាក្យណាដែលមានប្រយោជន៍ និងឲ្យមានសាមគ្គីភាព ។

ដោយព្រះរាជាទ្រង់មានព្រះរាជធម៌ ទើបជួយឲ្យប្រទេសជាតិសម្បូណ៌សប្បាយមិនមានទុក្ខភ័យ អន្តរាយណាៗ កើតឡើងឡើយ ដូច្នេះ ទើបធ្វើឲ្យអ្នកក្រុង និងអ្នកជនបទ តែងតែមានចិត្តកក្តីគោរពរាប់អានចំពោះព្រះរាជាកប្លវាហនៈ រហូតដល់រាជបរិវារពោលថា ពួកយើងបានព្រះរាជាដែលលោកទ្រទ្រង់នូវធម៌ ចំណែករាជបរិវារវិញ ក៏មានគុណធម៌ដូចគ្នាដែរ ។ នៅថ្ងៃមួយ មានពួកឈ្មួញនាំទំនិញមកពីក្រុងពារាណសី ដែលជាក្រុងនៅក្នុងមជ្ឈិមប្រទេស មកកាន់ក្រុងកប្លវាហនៈ ហើយនាំយកគ្រឿងបណ្ណាការចូលទៅថ្វាយដល់ព្រះរាជា

កប្ផវាហនៈ ។ គ្រានោះ ព្រះរាជាទ្រង់ត្រាស់សួរថា ពួកអស់លោកមកអំពីទីណា ? ពេលនោះ ពួកឈ្មួញក្រាបបង្គំទូលថា សូមតេជះតម្កល់លើត្បូង ទូលបង្គំទាំងឡាយ មកពីក្រុងពារាណសី ព្រះករុណាថ្លៃវិសេស ។

ព្រះរាជាទ្រង់សាកសួរដល់ការមករបស់ពួកឈ្មួញ និងត្រាស់ថា ពួកលោកចូរធ្វើជាមិត្តមេត្រីភាពរបស់ខ្ញុំ និងព្រះរាជារបស់ពួកលោក ។ លំដាប់នោះ ពួកឈ្មួញមានសេចក្តីត្រេកអរណាស់ ក៏បានក្រាបបង្គំទូលទទួលនូវភាព ជាមិត្តមេត្រីភាពនោះថា ព្រះករុណាថ្លៃវិសេស ។ ព្រះរាជាកប្ផវាហនៈ ទ្រង់សព្វព្រះទ័យនឹងពួកឈ្មួញទាំងនោះ ដោយទ្រង់ត្រាស់ឲ្យព្រះរាជទានស្បៀង និងអាហារដល់ពួកឈ្មួញទាំងនោះ ក្នុងពេលដែលពួកឈ្មួញក្រាបបង្គំលាត្រឡប់ទៅវិញទ្រង់បានប្រាស្រ័យដោយភាពអើពើម្តងទៀត ធ្វើឲ្យពួកឈ្មួញទាំងនោះមានសេចក្តីពេញចិត្ត ក្នុងការដែលទ្រង់មានទឹកចិត្តល្អ ។ លុះកាលពួកឈ្មួញត្រឡប់មកដល់ក្រុងពារាណសីវិញហើយ បានចូលទៅគាល់

ក្រោបបង្គំព្រះបាទពារាណសីឲ្យទ្រង់ជ្រាប ក្នុងការទ្រង់មានមិត្តមេត្រីភាពនឹងព្រះរាជាកដ្ឋវាហនៈ ។ ព្រះបាទពារាណសី ទ្រង់ជ្រាបដូច្នោះហើយ ទើបទ្រង់ត្រាស់ឲ្យវាយស្គរប្រកាសឡើងថា ចាប់អំពីថ្ងៃនេះតទៅ ចូរលើកលែងការយកពន្ធដារពួកឈ្មួញ ដែលមកពីដែនកដ្ឋវាហនៈ ពីព្រោះព្រះរាជាកដ្ឋវាហនៈ ទ្រង់បានជាមិត្តរបស់ខ្ញុំ ។

មានសេចក្តីថា ព្រះរាជាទាំងពីរអង្គនោះ ទ្រង់បានជាសម្លាញ់នឹងគ្នា ដោយទ្រង់មិនធ្លាប់បានជួបឃើញគ្នាសោះ ដោយទ្រង់អាស្រ័យពួកឈ្មួញដឹកនាំចងសម្ពន្ធមេត្រីភាពឲ្យ ។ ចំណែកព្រះរាជាកដ្ឋវាហនៈក៏បានត្រាស់បញ្ជាឲ្យវាយស្គរ ប្រកាសដូចព្រះបាទពារាណសីដែរ ។ ចំណែកខាងព្រះបាទពារាណសី ទ្រង់មានព្រះរាជសារបញ្ជូនទៅថ្វាយដល់ព្រះរាជាកដ្ឋវាហនៈថា បើមានវត្ថុណានីមួយដែលជាវត្ថុអស្ចារ្យសមគួរមើល ឬសមគួរស្តាប់កើតឡើងក្នុងស្រុក ឬនៅក្នុងក្រុងរបស់ព្រះអង្គ សូមឲ្យខ្ញុំព្រះអង្គបានមានឱកាសមើល ឬស្តាប់ផង ។ ចំណែកព្រះរាជាកដ្ឋវាហនៈក៏ទ្រង់តបព្រះរាជសារទៅថ្វាយវិញ ដោយសេចក្តី

ដូចគ្នាដែរ ។ សេចក្ដីពិស្ដារវរាងព្រះរាជាកដ្ឋវាហនៈ និងព្រះបាទពា-រាណសី ក្នុងរឿងនេះសូមមើលនៅក្នុងជីវប្រវត្តិរបស់ព្រះមោឃរាជ ។

ក្នុងរឿងដែលពួកកូនសិស្សរបស់ពាវរីព្រាហ្មណ៍ បានចូលទៅគាល់ព្រះមានបុណ្យ ដើម្បីក្រាបបង្គំទូលសួរបញ្ហានោះ មានសម្ដែងនៅក្នុង **គម្ពីរខុទ្ទកនិកាយ ចូឡនិទ្ទេស** នៃ **បារាយនវគ្គ** ថា ៖

ក្នុងពេលដែលពួកកូនសិស្សទាំងនោះ ចូលទៅដល់បាសាណកចេតិយហើយ ក្នុងខណៈពេលនោះ ព្រះមានជោគទ្រង់បរិបូណ៌ដោយព្រះគុណចំពោះសព្វសត្វទាំងពួង ទ្រង់មានភិក្ខុសង្ឃនៅជុំវិញ ទ្រង់កំពុងសម្ដែងព្រះធម៌ដល់ពួកភិក្ខុសង្ឃទាំងឡាយ ដោយអាការអង់អាចដូចគ្នានឹងរាជសីហ៍ ដែលបន្លឺសំឡេងនៅក្នុងព្រៃ ដូច្នោះ ។

គ្រានោះ អជិតមាណព បានក្រឡេកឃើញព្រះភគវាជាម្ចាស់ទ្រង់មានព្រះរស្មីដូចដួងព្រះអាទិត្យ ឬដួងព្រះចន្ទក្នុងថ្ងៃ ១៥ កើត ក៏មានចិត្តរីករាយត្រេកអរ និងក្រាបទូលសួរបញ្ហាឡើងថា សូមព្រះអង្គទ្រង់ប្រាប់ជាតិត្រកូល ព្រមទាំងលក្ខណៈ និងការសម្រេចក្នុងមន្ត

ទាំងឡាយរបស់ពាវរីព្រាហ្មណ៍ដល់ខ្ញុំព្រះអង្គផងចុះ តើពាវរីព្រាហ្មណ៍មានកូនសិស្សប៉ុន្មាននាក់ព្រះអង្គ ? កាលអជិតមាណពក្រាបទូលសួរបញ្ហាដូច្នេះហើយ ទើបព្រះទសពលទ្រង់ដោះស្រាយថា ពាវរីព្រាហ្មណ៍មានអាយុ ១២០ ឆ្នាំ ដែលឈ្មោះថាពាវរីជាឈ្មោះតាមគោត្រ កើតនៅក្នុងត្រកូលព្រាហ្មណ៍ ។ ពាវរីព្រាហ្មណ៍មានលក្ខណៈមហាបុរស ៣ ប្រការនៅក្នុងខ្លួន ជាអ្នកសម្រេចវិជ្ជាត្រៃវេទ ជាអ្នកសម្រេចក្នុងគម្ពីរលក្ខណៈព្យាករសាស្ត្រ និងគម្ពីរឥតិហាសៈ ឬគម្ពីរនិឃណ្ឌុ និងគម្ពីរកេដុភៈ ថែមទាំងមានកូនសិស្ស ៥០០ នាក់ ។ កាលបើអជិតមាណពបានស្តាប់ការបកស្រាយដូច្នេះហើយ ក៏ទូលសួរបញ្ហាតទៅទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គជាអ្នកខ្ពង់ខ្ពស់បំផុត ក្នុងមនុស្សទាំងពួង ខ្ញុំព្រះអង្គមិនដែលរមិលមើលលក្ខណៈរបស់អាចារ្យខ្ញុំព្រះអង្គទេ ដូច្នេះ សូមព្រះអង្គទ្រង់កាត់នូវសេចក្តីសង្ស័យរបស់ខ្ញុំព្រះអង្គ កុំឲ្យខ្ញុំព្រះអង្គមានសេចក្តីសង្ស័យតទៅទៀតថា តើអាចារ្យពាវរីព្រាហ្មណ៍របស់ខ្ញុំព្រះអង្គនោះ មានលក្ខណៈមហាបុរស ៣ ប្រការ

នោះបានដល់អ្វីខ្លះ ព្រះអង្គ ? ពេលនោះ ព្រះវិជិតមារ ត្រាស់តបថា ពាវរីព្រាហ្មណ៍មានអណ្តាតវែងធំ អាចលៀនអណ្តាតបិទមុខបាន ១ មានរោមសវែង សរសៃតូចឆ្មារ វិលដូចជាក្រយៅដៃដុះឡើង នៅត្រង់ចន្លោះចិញ្ចើម ១ មានរបស់អាថ៌កំបាំងនៅក្នុងស្រោម ១ អ្នកចូរដឹងយ៉ាងនេះចុះ ។

គ្រានោះ ពួកមហាជនទាំងឡាយមិនបានឮពាក្យទូលសួរបញ្ហាទេ បានឮតែព្រះពុទ្ធដីកា ដែលព្រះអង្គទ្រង់ដោះស្រាយបញ្ហានោះប៉ុណ្ណោះ ក៏បានធ្វើឲ្យកើតភាពអស្ចារ្យក្នុងចិត្ត មហាជនទាំងនោះ ម្នាក់ៗក៏បានប្រណម្យដៃធ្វើអញ្ជលីកម្ម ។ លំដាប់នោះ អជិតមាណព បានក្រាបទូលសរសើរឡើងថា លោកអ្នកនេះជាទេវតា ជាព្រហ្ម ឬព្រះឥន្ទ្រ យ៉ាងណាហ្ន៎ ទើបទ្រង់ដឹងច្បាស់នូវបញ្ហាដែលយើងនឹកទូលសួរដោយចិត្តបាន ហើយនឹកទូលសួរបញ្ហាតទៅទៀតថា អាចារ្យពាវរីរបស់ខ្ញុំ លោកផ្ញើទូលសួរបញ្ហាដោយសិរសា និងវត្ថុដែលធ្វើឲ្យសិរសាដាច់ធ្លាក់ចុះ ហេតុដូច្នេះ សូមទ្រង់កែខៃឲ្យខ្ញុំព្រះអង្គអស់សេចក្តីសង្ស័យ

ផងចុះ ? ពេលនោះ ព្រះមហាវីរៈទ្រង់ដោះស្រាយបញ្ហានោះដូច្នេះថា អ្នកចូរដឹងដូច្នេះថា សិរសានោះបានដល់អវិជ្ជា គឺការមិនដឹង និងវត្ថុដែលធ្វើឲ្យសិរសាដាច់ធ្លាក់ចុះនោះ បានដល់ វិជ្ជា គឺការដឹង ដែលប្រកបដោយសទ្ធា សតិ សមាធិ ឆន្ទៈ និងវីរិយៈ ។ កាលបើអជិតមាណពបានស្តាប់នូវការបកស្រាយដូច្នេះហើយ ក៏ដកដង្ហើមធំៗឡើង ប្រកបដោយបីតិសោមនស្សរីករាយយ៉ាងខ្លាំង ក៏បានធ្វើសំពត់ស្បែកខ្លាធៀងស្មាម្ខាង ក្រាបចុះទៀបព្រះយុគលបាទរបស់ព្រះសម្ពុទ្ធ និងក្រាបបង្គំទូលថា បពិត្រព្រះអង្គទ្រង់និរទុក្ខ ទ្រង់មានព្រះចក្ខុញ្ញាណ ពាវរីព្រាហ្មណ៍ ព្រមដោយកូនសិស្សទាំងអស់មានចិត្តត្រេកអររីករាយណាស់ ហេតុដូច្នេះ សូមក្រាបថ្វាយបង្គំព្រះយុគលបាទទាំងគូរបស់ព្រះអង្គ ដោយសេចក្តីគោរព និងដោយចិត្តជ្រះថ្លា ។

គ្រានោះ ព្រះសាស្តា ទ្រង់ត្រាស់ប្រទានពរថា ពាវរីព្រាហ្មណ៍ ព្រមទាំងកូនសិស្សទាំងអស់ ចូរមានសេចក្តីសុខ និងអាយុយឺនយូរ ។ ហើយព្រះអង្គទ្រង់ត្រាស់អនុញ្ញាតថា តថាគតឲ្យឱកាសដល់អ្នកទាំង

ឡាយដើម្បីសួរបញ្ហា ប្រសិនបើចង់សួរដល់សេចក្ដីសង្ស័យទាំងពួង របស់ពាវរី និងរបស់អ្នក ឬបុគ្គលទាំងឡាយ ចូរអ្នកសួរតាមសេចក្ដីប្រាថ្នាចុះ បើអ្នកមានសេចក្ដីឆ្ងល់ក្នុង១.ណា ចូរសួរក្នុង១.នោះមកចុះ ។

លំដាប់នោះឯង អជិតមាណព ក្រោយពីការបានទទួលនូវការប្រទានវរោកាសពីព្រះសម្ពុទ្ធជាម្ចាស់ហើយ ក៏បានក្រាបទូលសួរបញ្ហាមុនដំបូងគេ ចំពោះព្រះលោកនាយកនោះថា ក៏ក្នុងបញ្ហាដែលអជិតៈលើកឡើងយកមកសួរជាលំដាប់លំដោយ មានសេចក្ដីតទៅថា

( អជិតមាណពដ៏មានអាយុ ទូលសួរថា ) សត្វលោកត្រូវអ្វីបិទបាំង រមែងមិនជាក់ច្បាស់ ព្រោះអ្វី ព្រះអង្គត្រាស់ថា អ្វីជាគ្រឿងប្រឡាក់ អ្វីជាភ័យធំ របស់សត្វលោកនោះ ?

( ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ម្នាលអជិតៈ ) សត្វលោកត្រូវអវិជ្ជាបិទបាំង រមែងមិនជាក់ច្បាស់ ព្រោះសេចក្ដីកំណាញ់ និងសេចក្ដីប្រមាទ តថាគតពោលថា តណ្ហាជាគ្រឿងប្រឡាក់ ទុក្ខជាភ័យធំ របស់សត្វលោកនោះ ។

ចំពោះពាក្យថា លោកក្នុងទីនេះ បើតាមសេចក្តីក្នុងព្យញ្ជនៈ ប្រែបានពីរន័យ **ន័យទី ១** លោក ប្រែថា ភពដែលឃើញ បានដល់ ទឹកដីដែលប្រាកដដល់សត្វលោក ។ **ន័យទី ២** លោក ប្រែថា សភាពដែលបែកធ្លាយទៅ ។ ពាក្យថា **លោក** ពោលដោយអត្ថ បាន ដល់ សភាវៈដែលមានការកើតឡើងពីខាងដើម និងមានការរលត់ទៅ វិញនៅខាងចុង ។

សេចក្តីរបស់ពាក្យថាលោកនេះ តាមដែលមានមកប្រាកដនៅ ក្នុង **គម្ពីរសំយុត្តនិកាយ សឡាយតនវគ្គ** ព្រះអានន្ទត្ថេរបានក្រាបទូល សួរព្រះបរមសាស្តាថា ៖

បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលហៅថា **លោកៗ** នោះ ហៅ ដោយហេតុត្រឹមណា ព្រះអង្គ ? គ្រានោះ ព្រះលោកនាយកត្រាស់តប ថា ម្នាលអានន្ទ សភាវៈណាមានការបែកធ្លាយជាធម្មតា សភាវៈ នោះហៅថាលោកក្នុងអរិយវិន័យនេះ ។ ម្យ៉ាងទៀត ពាក្យថា លោក នេះ មានសម្តែងទុកនៅក្នុង **ចុល្លនិទ្ទេស** ដែលជាពាក្យអធិប្បាយ

របស់ព្រះសារីបុត្តត្ថេរថា លោក បានដល់ លោកនរក លោកតិរច្ឆាន លោកប្រេតវិស័យ លោកមនុស្ស លោកទេវតា លោកខន្ធ ធាតុ អាយតនៈ លោកនេះ លោកដទៃ ព្រហ្មលោក និង ទេវលោក ។

ចំណែកនៅក្នុង **អដ្ឋកថាបបញ្ចសូទនី ទុតិយភាគ** ដែលសម្តែងដល់លោក សំដៅយកទីអាស្រ័យ ៣ ប្រការ គឺ

មនុស្សលោក ១ ទេវលោក ១ ព្រហ្មលោក ១ ។

ប៉ុន្តែពាក្យថា លោកដែលមានប្រាកដក្នុង **គម្ពីរវិសុទ្ធិមគ្គ** និង **ព្រះអដ្ឋកថាចារ្យ** បានសម្តែងទុកមាន ៣ ប្រការដែរនោះ គឺ

**១- សង្ខារលោក** លោក គឺសង្ខារ សំដៅដល់សភាវៈដែលតាក់តែងឡើង ប៉ុន្តែក្នុង **គម្ពីរអង្គុត្តរនិកាយ ចតុក្កនិបាត** ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា សង្ខារលោក គឺតួខ្លួនយើងនេះ ដែលមានបណ្តោយប្រមាណមួយព្យាម ទទឹងប្រមាណមួយហត្ថ ។

**២- សត្វលោក** លោក គឺពួកសត្វ សំដៅដល់មនុស្ស ទេវតា និងសត្វតិរច្ឆានដែលជាប់ជំពាក់នៅក្នុងលោកនេះ ។

៣- **ឱកាសលោក** លោក គឺផែនដី សំដៅដល់ទីនៅនៃពួកសត្វ ប៉ុន្តែក្នុង **អដ្ឋកថា** បានសម្តែងថា ចក្កវាឡលោក លោក គឺចក្រវាល បានដល់ បរិមណ្ឌលធំទូលាយមិនមានទីបំផុត ។

ព្រះពុទ្ធដីកា នៃព្រះសក្យមុនី ទ្រង់ដោះស្រាយថា លោកត្រូវអវិជ្ជាគ្របដណ្តប់ (បង់រឹត) ពាក្យថា អវិជ្ជា ប្រែថា ការមិនដឹង ។

ការមិនដឹង មានពាក្យអធិប្បាយទុកនៅក្នុង **គម្ពីរខុទ្ទកនិកាយ ចូឡនិទ្ទេស** និងក្នុង **គម្ពីរធម្មសង្គណី** នៃ **ព្រះអភិធម្មបិដក** បានសម្តែងរហូតមានដល់ ៨ ប្រការ គឺ

១- ការមិនដឹងក្នុងទុក្ខ

២- ការមិនដឹងក្នុងតណ្ហាជាហេតុឲ្យកើតទុក្ខ

៣- ការមិនដឹងក្នុងកិរិយារំលត់ទុក្ខ

៤- ការមិនដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរំលត់ទុក្ខ

៥- ការមិនដឹងក្នុងទីបំផុតខាងដើម

៦- ការមិនដឹងក្នុងទីបំផុតខាងចុង

៧- ការមិនដឹងក្នុងទីបំផុតខាងដើម និងទីបំផុតខាងចុង

៨- ការមិនដឹងក្នុងធម៌ដែលកើតឡើងហើយ អាស្រ័យធម៌នេះជាបច្ច័យ កិរិយាមិនដឹង ការមិនឃើញ ការមិនត្រាស់ដឹងជាដើម ។

ម្យ៉ាងទៀត អវិជ្ជា គឺការមិនដឹង បើនឹងបែងចែកក៏នឹងមាន ២ ប្រការ គឺ

**១- អវិជ្ជាផ្លូវលោក** សំដៅដល់ការមិនដឹងសន្មតិ និងការមិនដឹងបញ្ញត្តិ ដែលជនក្នុងលោកនិយមប្រើ ។

**២- អវិជ្ជាផ្លូវធម៌** សំដៅដល់ ការមិនដឹងតាមសេចក្តីពិត ឬដឹងតែមិនជាក់ច្បាស់ ដឹងមិនសព្វគ្រប់ ឬដឹងខុស ដឹងទុក្ខ ថាជាសុខ ដឹងហេតុឲ្យកើតទុក្ខ ថាជាហេតុឲ្យកើតសុខជាដើម ។

អវិជ្ជាផ្លូវលោក និងផ្លូវធម៌ ជាគ្រឿងគ្របដណ្តប់ ឬចងរឹតសត្វលោក ។ ដូចអវិជ្ជាផ្លូវលោក អាចគ្របដណ្តប់ ឬចងរឹត មិនឲ្យរីកចម្រើនទៅមុខបាន ដូចតួយ៉ាង អ្នកសិក្សា ឬអ្នករៀនសូត្រនៅក្នុងសាលា បើនៅរៀនសូត្រមិនមានចំណេះចេះដឹងតាមកំណត់របស់

ថ្នាក់រៀន ក៏មិនបានឡើងថ្នាក់ ការមិនដឹងខ្លួននឹងត្រូវរៀនសូត្រ នៅតែជាគ្រឿងគ្របដណ្តប់ ឬចងរឹតដដែល ។ ចំណែកអវិជ្ជាផ្លូវធម៌ ក៏មានអំណាចគ្របដណ្តប់ ឬចងរឹតសត្វលោក ឲ្យនៅមានសភាពដដែល គឺមិនឲ្យរួចផុតចាកលោកនេះទៅបានឡើយ ឬចាកភាពជាសត្វលោកទៅបានដែរ ឲ្យមានការវិលវល់ត្រាច់រង្គាត់នៅក្នុងវដ្តសង្សារ ថែមទាំងបានទទួលនូវសេចក្តីទុក្ខជាច្រើនប្រការ នេះជាច្បាប់របស់សត្វលោក ។ អវិជ្ជាជាបច្ច័យឲ្យកើតសង្ខារ សង្ខារជាបច្ច័យឲ្យកើតវិញ្ញាណ ជាដើម នេះបង្ហាញឲ្យឃើញថា ព្រោះមានអវិជ្ជាជាហេតុ ។

បុគ្គលធ្វើខុស ព្រោះមានរាគៈ ឬមានលោភៈជាដើមហេតុខ្លះ ព្រោះមានទោសៈជាដើមហេតុខ្លះ ហេតុនៃការធ្វើខុសដែលពិតប្រាកដនោះ ព្រោះមានអវិជ្ជាជាដើមហេតុ ជាដែនកើត សរុបឲ្យខ្លីមកនៅត្រង់អវិជ្ជា ដោយអវិជ្ជាជាបច្ច័យឲ្យកើតរាគៈ ឬលោភៈ ទោសៈ មោហៈទៀត ការវិលវល់យ៉ាងនេះ ជាកិលេសវដ្តៈនោះឯង ។ កាលមានកិលេស កិលេសក៏ជាបច្ច័យឲ្យកើតកម្ម កម្មក៏ជាបច្ច័យឲ្យកើត

វិបាក ( ផលរបស់កម្ម ) វិបាកក៏ជាបច្ច័យឲ្យកើតកិលេស មានការវិលវល់តជាប់គ្នាទៅយ៉ាងនេះ ទាំងនេះ ក៏បង្ហាញឲ្យឃើញថា អវិជ្ជាបិទបាំងលោក ។

ចំណែកក្នុង **គម្ពីរអង្គុត្តរនិកាយ ទសកនិបាត** បានពោលដល់សំយោជនៈ គឺជាគ្រឿងចងរឹត សំដៅយកកិលេសដែលចងសត្វលោកទុកក្នុងវដ្តសង្សារ មាន ១០ ប្រការ គឺ

១-សក្កាយទិដ្ឋិ ២-វិចិកិច្ឆា ៣-សីលព្វតបរាមាសៈ ៤-កាមរាគៈ ៥-បដិឃៈ ៦-រូបរាគៈ ៧-អរូបរាគៈ ៨- មានះ ៩- ឧទ្ធច្ចៈ ១០- អវិជ្ជា ។កិលេសទាំងនេះសុទ្ធតែជាគ្រឿងបិទបាំង ឬចងចិត្តរបស់សត្វលោកឲ្យជាប់នៅក្នុងលោកនេះ តែគ្រប់ៗនីមួយៗ ក្នុងកិលេសទាំងនោះ សុទ្ធតែមានអវិជ្ជាជាប្រធាន ឬជាឫសគល់ បើមិនមានអវិជ្ជាទេ កិលេសទាំងនោះក៏គ្មានដែរ ។

នៅក្នុង **គម្ពីរខុទ្ទកនិកាយ ចុល្លនិទ្ទេស** បានពោលថា

អជិតមាណពក្រាបទូលសួរបញ្ហាៗទី ២ តទៅទៀតថា បពិត្រ

ព្រះមានព្រះភាគ លោកមិនភ្លឺស្វាងព្រោះហេតុអ្វី ? គ្រានោះ ព្រះពុទ្ធអង្គទ្រង់ត្រាស់តបថា ម្នាលអជិតៈ លោកត្រូវអវិជ្ជាបិទបាំង លោកមិនភ្លឺស្វាង ព្រោះសេចក្តីប្រាថ្នាផ្សេងៗ និងសេចក្តីប្រមាទ ឬក៏ការធ្វេសប្រហែស ។ ពាក្យថា **វេវិច្ឆា** មានសេចក្តីថា ការគិតចង់ឲ្យសម្បត្តិរបស់អ្នកដទៃ ដល់នូវការវិនាសបាត់បង់ទៅ គឺគិតថា សូមឲ្យមានតែយើងម្នាក់មានទ្រព្យសម្បត្តិ អ្នកដទៃកុំមានដូចយើងឡើយ ។

ម្យ៉ាងទៀត នៅក្នុង **គម្ពីរខុទ្ទកនិកាយ ចុល្លនិទ្ទេស** ពោលថា វេវិច្ឆា បានដល់ មច្ឆរិយៈ គឺសេចក្តីកំណាញ់ មាន ៥ ប្រការ គឺ

១ កំណាញ់អាវាស ២ កំណាញ់ត្រកូល ៣ កំណាញ់លាភ ៤ កំណាញ់វណ្ណៈ ៥ កំណាញ់ធម៌ ។ **បមាទា** ឬ **បមាទ** គឺការប្រមាទនោះ មានពាក្យអធិប្បាយថា ការមួម៉ៅ ការវង្វេង ការខ្វះសតិគិតគូរ ការបណ្តោយចិត្តឲ្យត្រេកអរ ឬមានតម្រេកក្នុងអារម្មណ៍ផ្សេងៗ ដែលជាទីតាំងនៃសេចក្តីតម្រេក និងមានការថ្នាំងថ្នាក់នៅក្នុងអារម្មណ៍ដែលជាទីតាំងនៃការថ្នាំងថ្នាក់ មានការភ្លើតភ្លើនក្នុងអារម្មណ៍ដែលជា

ទីតាំងនៃការកើតកើន មានការវង្វេងក្នុងអារម្មណ៍ ដែលជាទីតាំងនៃការវង្វេង ភ្លេចចាស់ ភ្លេចឈឺ ភ្លេចស្លាប់ ថែមទាំងមានចិត្តស្វាហាប់ ធ្វើតែអំពើអាក្រក់ ទាំងផ្លូវកាយ វាចា និងចិត្ត វង្វេងគិតតែនៅក្នុងកាមគុណ ៥ ជាដើមហេតុរបស់អកុសលធម៌ទាំងពួង ទាំងនេះ ជាដំណើរផ្លូវទៅរកសេចក្តីស្លាប់ ។ ព្រោះដូច្នោះ លោក មិនភ្លឺស្វាង ព្រោះតែសេចក្តីកំណាញ់ និងការប្រមាទ ។

ដែលអជិតមាណព ក្រាបទូលសួរបញ្ហាថា អ្វីជាគ្រឿងប្រឡាក់លោក ព្រះអង្គ ? ព្រះមុនីត្រាស់ថា តណ្ហាជាគ្រឿងប្រឡាក់លោក ។

ពាក្យថា **តណ្ហា** ប្រែថា សេចក្តីប្រាថ្នា ក៏សេចក្តីប្រាថ្នានោះមាន ៣ ប្រការ គឺ

១ កាមតណ្ហា ២ ភវតណ្ហា ៣ វិភវតណ្ហា ។ តណ្ហាហៅថា ជប្បា មានពាក្យអធិប្បាយតាមនិទ្ទេសថា បានដល់ រាគៈ គឺតម្រេកត្រេកអរ **សរាគៈ** គឺតម្រេកត្រេកអរច្រើន **អនុស័យ** គឺការដេកត្រាំ **អនុរោធៈ** គឺការចាក់ដោត **នន្ទិ** គឺការកើតកើន **នន្ទិរាគៈ** គឺការ

ត្រេកត្រអាលដោយការក្ដៅក្រហាយ **ចិត្តរាគៈ** គឺតម្រេកត្រេកអររបស់ចិត្ត **ឥច្ឆា** គឺការប្រាថ្នា **មុច្ឆា** គឺការខ្វល់ខ្វាយ **អជ្ឈោសនា** គឺការប្រឈមចុះ និងមានឈ្មោះហៅច្រើនយ៉ាងទៀត ។

ម្យ៉ាងទៀត ដែលហៅថា **តណ្ហាជប្បា** ព្រោះជប្បាជាកិលេសគ្រឿងក្រសោបចិត្ត សំដៅដល់បរិយុដ្ឋាន បានដល់ កិលេសដែលអណ្ដែតឡើង ចូលដល់ចិត្តគ្រប់ប្រការហើយ រួមទាំងរាគៈ ទោសៈ មោហៈ ។ ព្រោះពួកកិលេសទាំងនេះមានរាគៈ កាលបើកើតឡើងហើយ រមែងចូលទៅក្រសោបចងចិត្តទុកបាន ថែមទាំងឲ្យវង្វេងស្រឡាញ់រាក់ទាក់ ចាំគាំទ្រថា វត្ថុនេះគួរដល់លោក លោកអាចធ្វើបាន បើលោកបានមកហើយ នឹងជាគ្រឿងលើកមុខមាត់យ៉ាងនោះ ។ ចំណែកកិលេសពួកទោសៈ ខណៈដែលកើតឡើងហើយ ក៏បានចូលទៅក្រសោបចិត្តឲ្យតស៊ូ និងនៅចាំជាស់តឿនជានិច្ចថា គេនឹងធ្វើដល់យើងយ៉ាងនេះយ៉ាងនោះ យើងក៏ជាមនុស្សម្នាក់ មិនគួរបណ្ដោយឲ្យគេមើលងាយមើលថោកដល់យើងដែរ ។ ចំណែកកិលេសពួកមោហៈ

វិញ កាលកើតឡើងហើយ ក៏បានចូលទៅក្រសោបចិត្តឲ្យវង្វេង ក្តៅក្រហល់ក្រហាយ ខ្វាចក្រែងថា នឹងចោលអ្វីៗ ផ្សេងៗ ទៅ អធិប្បាយថា យើងគួរមានមុខមានមាត់ឡើង ទាំងនេះ ជាការពិតណាស់ គិតរហូតដល់បរិភោគមិនបាន សម្រាន្តមិនលក់ កាលនឹងធ្វើកិច្ចការអ្វីៗ រមែងខិតខំទៅក្នុងផ្លូវវង្វេង ។ កិលេសផ្សេងៗ សុទ្ធតែជាគ្រឿងលាបលោក ជាគ្រឿងតោងលោក ជាគ្រឿងធ្វើលោកឲ្យសៅហ្មងទាំងអស់ ។

ដែលអជិតមាណព ក្រាបទូលសួរបញ្ហាថា អ្វីជាភ័យធំរបស់លោកនោះ ?

ព្រះមានជោគត្រាស់តបថា ទុក្ខ បានដល់ សភាពដែលទ្រាំបានដោយកម្រ មាន ២ ប្រភេទ គឺ

១- ទុក្ខប្រចាំ ហៅថា **សភាវទុក្ខ** បានដល់ កើត ចាស់ ឈឺ ស្លាប់ ស្រេក ឃ្លាន ។

២- ទុក្ខចរ ហៅថា **អាគន្តុកទុក្ខ** បានដល់ សោកៈ បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ ។ ទុក្ខទាំងនេះ រមែងគ្របសង្កត់លោក

ដោយមានឧបមាថា ជាតិទុក្ខ ជរាទុក្ខ មរណទុក្ខ ។ កាលបើលោកត្រូវសភាវទុក្ខ គ្របសង្កត់សព្វៗ កាលហើយ បុគ្គលទើបត្រូវការដោះស្រាយទុក្ខគ្មានពេលដាច់ ដូចដេក ដើរ ឈរ អង្គុយ បរិភោគអាហារ និងត្រូវបន្ទោបង់ជាដើម ទាំងនេះដើម្បីដោះស្រាយទុក្ខ តែក៏នៅមិនអាចដោះស្រាយបាន មិនចេះចប់មិនចេះហើយ ព្រោះទុក្ខទាំងឡាយ មិនធ្លាប់ខ្លាចបុគ្គល គ្រប់ជាតិ-វណ្ណៈណាឡើយ ។

កាលអជិតមាណព បានស្តាប់ព្រះពុទ្ធដីកានេះហើយ បានក្រាបទូលសួរបញ្ហាតទៅទៀតថា

( អជិតមាណពដ៏មានអាយុ ទូលសួរថា ) **ខ្សែតណ្ហា រមែងហូរទៅក្នុងអាយតនៈទាំងពួង អ្វីជាគ្រឿងទប់ខ្សែតណ្ហាទាំងឡាយ សូមព្រះអង្គត្រាស់ប្រាប់នូវធម៌ ជាគ្រឿងរាំងនូវខ្សែតណ្ហាទាំងឡាយ ខ្សែតណ្ហាទាំងឡាយ ត្រូវបិទដោយអ្វី ?**

( ព្រះមានព្រះភាគដោះស្រាយថា ម្នាលអជិតៈ ) **សតិ ជាគ្រឿងទប់ខ្សែតណ្ហាទាំងឡាយនោះ ដែលមាននៅក្នុងលោក តថាគត**

ពោលថា សតិជាគ្រឿងរាំងខ្សែតណ្ហាទាំងឡាយ បុគ្គលគប្បីបិទខ្សែតណ្ហាទាំងនោះដោយបញ្ញា ។

មានពាក្យអធិប្បាយថា សតិជាគ្រឿងរាំងនូវក្រសែទាំងពួងនោះ គឺថាគតពោលនូវធម៌ជាគ្រឿងរាំងក្រសែទាំងឡាយថា បានដល់សតិ ក្រសែទាំងនោះ នឹងបិទរាំងទៅបានដោយបញ្ញា ។ ពាក្យថា **សោតា** ប្រែថា ក្រសែ ជាពាក្យកណ្តាលៗ អាចរួមគ្នានឹងពាក្យដែលមានសេចក្តីល្អ ក៏ជាគ្រឿងប្រាប់លក្ខណៈល្អ ដូចសោតាបន្នដែលជាពាក្យសម្រាប់ប្រើហៅ ព្រះអរិយបុគ្គលថ្នាក់ដំបូង ដោយប្រែថា អ្នកដល់ក្រសែនៃធម៌ ឬក្រសែនៃព្រះនិព្វាន ។ ប៉ុន្តែ បើនាំយកទៅតនឹងសព្ទដែលមានសេចក្តីមិនល្អ ក៏ក្លាយជាគ្រឿងបង្ហាញលក្ខណៈដែលមិនល្អ ដូចពាក្យថា **តណ្ហាសោតា** ប្រែថា ក្រសែនៃតណ្ហា ឬតណ្ហាដែលហូរមក ។ ចំណែកក្នុងទីនេះ ក្រសែ សំដៅយកផ្នែកមិនល្អដោយអធិប្បាយតាមនិទ្ទេសថា ក្រសែនោះបានដល់ តណ្ហា ទិដ្ឋិ កិលេស ទុច្ចរិត អវិជ្ជា ដែលមាននៅក្នុងអបាយលោក មនុស្សលោក ទេវលោក

ខន្ធលោក ធាតុលោក អាយតនលោក ទើបឈ្មោះថា ក្រសែទាំងឡាយ រមែងហូរទៅ ។

ចំណែកក្នុងពាក្យថា ក្នុងទីទាំងពួង បានដល់ អាយតនៈទាំងអស់ ។ រមែងហូរទៅនោះ បានដល់ កើតឡើង ហូរទៅជាប់ជានិច្ចមិនដាច់ខ្សែ ។ កាលបើភ្នែកឃើញរូប តណ្ហាអាស្រ័យរូប ក៏ហូរចូលមកតាមផ្លូវភ្នែក, ត្រចៀកឮសំឡេង តណ្ហាអាស្រ័យសំឡេងនោះ ក៏ហូរចូលមកតាមផ្លូវត្រចៀក, ច្រមុះបានធុំក្លិន តណ្ហាអាស្រ័យក្លិននោះ ក៏ហូរចូលមកតាមច្រមុះ, អណ្តាតបានដឹងរស តណ្ហាអាស្រ័យរសនោះ ក៏ហូរចូលមកតាមផ្លូវអណ្តាត, កាយដឹងផោដ្ឋព្វៈ តណ្ហាអាស្រ័យផោដ្ឋព្វៈនោះ ក៏ហូរចូលមកតាមផ្លូវកាយ, ចិត្តដឹងធម្មារម្មណ៍ តណ្ហាអាស្រ័យនូវធម្មារម្មណ៍នោះ ក៏ហូរមកតាមផ្លូវចិត្ត ។ កាលតណ្ហាហូរចូលមកហើយ ក៏កើតអាសវក្កិលេសដេកត្រាំនៅក្នុងចិត្ត ហើយបង្គាប់ចិត្តឲ្យជាទាសៈ ក៏បានធ្លាក់ទៅក្នុងអំណាចរបស់តណ្ហា គឺការខ្វល់ខ្វាយចំណង់ក៏រមែងកើតឡើង រមែងធ្វើបុគ្គលនោះឲ្យអស់ឥស្សរភាព ឬក៏

ធ្វើឲ្យបុគ្គលនោះ មិនមានសេរីភាពចំពោះខ្លួនឯងជាដើម ។ គ្រឿងរាំង ក្រសែទាំងនោះ ព្រះពុទ្ធអង្គត្រាស់ថា បានដល់ សតិ ។

សេចក្តីរបស់សតិបែងចែកទៅ រមែងមានលក្ខណៈ ២ គឺ

**១- អាការរបស់សតិ** បានដល់ អាការដែលរឭកបាន ចាំបាន កំណត់បាន ។

**២- តួសតិ** បានដល់ ជាគរតា គឺការដឹងខ្លួន ឬការភ្ញាក់ដែល ផុយគ្នាពីការដេកលក់ ឬការវង្វេង ។

ដែលថា សតិ ជាគ្រឿងរាំងក្រសែទាំងនោះ សតិការរឭក បាន កាលមានអារម្មណ៍ទាំងឡាយមកប៉ះខ្ទប់ បើបុគ្គលមានសតិរឭក បានថា នេះជារបស់ខាងក្រៅ កើតឡើងហើយរលត់ទៅវិញ មកប៉ះខ្ទប់ តែមួយរយៈប៉ុណ្ណោះ ហើយក៏បាត់ទៅវិញ ឬដូចគ្នានឹងយើងអង្គុយ នៅលើយានពាហនៈ បានក្រឡេកឃើញវត្ថុផ្សេងៗ ដែលមើលឃើញ តាមក្រសែភ្នែករបស់ខ្លួន លុះធ្លងផុតហើយ ក៏បាត់អស់ទៅ យ៉ាង ណាមិញ រូបដែលឃើញ ក៏មានសភាពជារូបនៅខាងក្រៅ សំឡេង

ក៏មានសភាពនៅខាងក្រៅដូច្នោះដែរ ចំណែកបុគ្គលដែលប្រមូលយកមកនឹកគិតនោះ ក៏មិនមែនជាតួខ្លួនដែលជាអ្នកនឹកគិតដែរ ត្រឹមតែជាស្រមោលនៃអារម្មណ៍ខាងក្រៅតែប៉ុណ្ណោះ ។

កាលបុគ្គលរឭកដឹងបានដូច្នេះហើយ ក្រសែតណ្ហាទាំងឡាយក៏ហូរចូលមកមិនបាន កិលេសផ្សេងៗ ដូចជាបុគ្គលអាក្រក់ បើម្ចាស់របស់ភ្ញាក់ទាន់ នឹងមិនហ៊ានតស៊ូទល់មុខ តែបើភ្លាំងភ្លាត់សតិ កិលេសផ្សេងៗ ក៏នឹងហូរចូលមក ដូចគ្នានឹងម្ចាស់របស់ដែលដេកលក់ ត្រូវចោរលួចយករបស់របរទៅ ។ ព្រោះដូច្នោះ យើងនឹងត្រូវដាក់សតិឲ្យនៅចាំយាមទ្វារ គឺទ្វារទាំងឡាយទុកចាំដើម្បីការពារកិលេសតណ្ហា ដូចយើងជួលឲ្យមនុស្សមកជួយយាមរក្សាត្រង់ទ្វារផ្ទះ ឬកន្លែងធ្វើការដើម្បីការពារបុគ្គលអាក្រក់ មិនឲ្យចូលមកលួចរបស់របរ ឬបង្កភាពចលាចលកុំឲ្យកើតឡើង ។ សតិជាគ្រឿងរាំងក្រសែទាំងឡាយបានមួយរយៈ ប្រៀបដូចបុគ្គលដែលផ្អាប់ថ្មសង្កត់ស្មៅដូច្នោះឯង បើបុគ្គលធ្វេសប្រហែសភ្លេចសតិហើយ ក្រសែទាំងឡាយនឹងហូរចូលមកទៀតបាន ។

ពិធីដែលនឹងមិនឲ្យក្រសែទាំងឡាយ បានដល់កិលេសតណ្ហាហូរចូលមកបាននោះ ត្រូវអាស្រ័យនូវបញ្ញា ការដឹងទាន់មួយប្រការទៀត តែបញ្ញាដែលកើតឡើងបាន ក៏ព្រោះការមានសតិ ។ បញ្ញាជាគ្រឿងបិទរាំងក្រសែទាំងឡាយ បានដោយដាច់ខាតនោះ ក៏ត្រូវអាស្រ័យបញ្ញាថ្នាក់ខ្ពស់ អាចដឹងច្បាស់ចាក់ធ្លុះបានក្នុងហេតុផល ដឹងទាន់ហេតុការណ៍ ដូចដឹងល្អក៏ដឹងថាល្អ អាក្រក់ក៏ដឹងថាអាក្រក់ បានត្រឹមត្រូវតាមសភាពពិត មិនវង្វេងល្ងង់ល្ងីល្ងើយល់ខុស ប្រកាន់យកត្រូវមកជាខុស យកខុសទៅជាត្រូវ ។ បញ្ញាការដឹងយ៉ាងខ្ពស់ ដែលប្រព្រឹត្តទៅក្នុងគោលធម៌ត្រៃលក្ខណ៍ គឺលក្ខណៈ ៣ ឃើញច្បាស់លាស់យល់ថា សង្ខារទាំងឡាយមិនទៀង សង្ខារទាំងឡាយជាទុក្ខ ធម៌ទាំងឡាយជាអនត្តា ។

បញ្ញាអាចឲ្យដឹងយល់ថា អវិជ្ជាជាបច្ច័យឲ្យកើតសង្ខារ សង្ខារជាបច្ច័យឲ្យកើតវិញ្ញាណ វិញ្ញាណជាបច្ច័យឲ្យកើតនាមរូប នាមរូបជាបច្ច័យឲ្យកើតសឡាយតនៈ សឡាយតនៈជាបច្ច័យឲ្យកើតផស្សៈ

ផស្សៈជាបច្ច័យឲ្យកើតវេទនា វេទនាជាបច្ច័យឲ្យកើតតណ្ហា តណ្ហាជាបច្ច័យឲ្យកើតឧបាទាន ឧបាទានជាបច្ច័យឲ្យកើតភព ភពជាបច្ច័យឲ្យកើតជាតិ ជាតិជាបច្ច័យឲ្យកើតជរា និងមរណៈ ។ បញ្ញាឲ្យយល់ដឹងថា អវិជ្ជារលត់ធ្វើឲ្យសង្ខាររលត់ សង្ខាររលត់ធ្វើឲ្យវិញ្ញាណរលត់ វិញ្ញាណរលត់ធ្វើឲ្យនាមរូបរលត់ នាមរូបរលត់ធ្វើឲ្យសឡាយតនៈរលត់ សឡាយតនៈរលត់ធ្វើឲ្យផស្សៈរលត់ ផស្សៈរលត់ធ្វើឲ្យវេទនារលត់ វេទនារលត់ធ្វើឲ្យតណ្ហារលត់ តណ្ហារលត់ធ្វើឲ្យឧបាទានរលត់ ឧបាទានរលត់ធ្វើឲ្យភពរលត់ ភពរលត់ធ្វើឲ្យជាតិរលត់ ជាតិរលត់ធ្វើឲ្យជរា និងមរណៈរលត់ ។ បញ្ញាយល់ដឹងទៀតថា សភាវៈនេះជាទុក្ខ សភាវៈនេះជាហេតុនាំឲ្យកើតទុក្ខ សភាវៈនេះជាទីរលត់ទុក្ខ សភាវៈនេះជាផ្លូវទៅកាន់ទីរលត់ទុក្ខ ។ ក្រសែ គឺកិលេសតណ្ហា នឹងបិទរាំងឲ្យបានដាច់ខាតនោះ ដោយបញ្ញាថ្នាក់អរិយមគ្គ ។

( អជិតមាណពដ៏មានអាយុ ទូលសួរថា ) បពិត្រព្រះអង្គនិទ្ទុក្ខ បញ្ញាផង សតិផង នាម និងរូបផង ធម៌ទាំះ ដែលខ្ញុំព្រះអង្គសួរ

ហើយ សូមព្រះអង្គសម្តែង តើធម៌ទាំងនុ៎ះ រលត់ទៅក្នុងទីណា ?

ម្នាលអជិតៈ អ្នកបានសួរនូវបញ្ហាណា ចំពោះតថាគតៗ នឹងសម្តែងនូវបញ្ហានោះដល់អ្នក នាម និងរូប រលត់មិនសល់ក្នុងទីណា សតិ និងបញ្ញានេះ ក៏រលត់ទៅក្នុងទីនោះ ព្រោះរលត់វិញ្ញាណ ។

ពាក្យថា នាម បានដល់ វេទនា សញ្ញា សង្ខារ វិញ្ញាណ និងរួមទាំងអសង្ខតធាតុ ( ធាតុដែលបច្ច័យតាក់តែងមិនបាន ) ។ ពាក្យថា រូប បានដល់ មហាភូតរូប និងឧបាទាយរូប ។ ប៉ុន្តែ រូបដោយសេចក្តីថា គឺសភាពដែលមានការបែកធ្លាយទៅដោយត្រជាក់ និងក្តៅជាដើម ។ **បញ្ញា** ប្រែថា ការដឹងទូទៅ គឺដឹងហេតុផល ដែលកំពុងប្រាកដ ។ **សតិ** ប្រែថា ការរឭក គឺការភ្ញាក់ ឬការដឹងខ្លួន ។ នាមរូប និងសតិបញ្ញារលត់ទៅ ព្រោះវិញ្ញាណរលត់ទៅនោះឯង គឺបានដល់បុគ្គលចម្រើនធម៌ រហូតចូលដល់ភាពស្ងប់ស្ងាត់ ចាកអារម្មណ៍ទាំងឡាយ នៅសល់តែការដឹង ដែលជាបញ្ញាដឹងច្បាស់ចាក់ធ្លុះនូវសភាវធម៌នោះ តាមសេចក្តីពិត ។

សភាវធម៌ពួកណាកើតឡើងក្នុងសង្សារវដ្ត គឺការកើតស្លាប់នៅក្នុងលោកផ្សេងៗ ដែលរកខាងដើម និងខាងចុងគ្មានទីបំផុត បិទបាំងកំណើតទាំង ៧ ចេញ ( សោតាបន្នបុគ្គល មានកំណើតយ៉ាងច្រើន ៧ ជាតិទៀត ) នាម និងរូបរមែងរលត់ទៅក្នុងទីនោះ គឺដល់នូវភាពតាំងនៅក្នុងទីនោះមិនបាន ព្រោះការរលត់ទៅនៃអភិសង្ខារវិញ្ញាណ ដោយសោតាបត្តិមគ្គញ្ញាណ ។ សភាវៈពួកណាកើតឡើងក្នុងកំណើត ៥ លើកលែងតែកំណើត ២ ចេញ ( សកទាគាមីមកកាន់លោកនេះម្តងទៀត ) នាម និងរូបរមែងរលត់ទៅក្នុងទីនោះ គឺដល់នូវការតាំងនៅមិនបាន ព្រោះការរលត់ទៅនៃអភិសង្ខារវិញ្ញាណ ដោយសកទាគាមិមគ្គញ្ញាណ ។ ធម៌ពួកណា គឺនាម និងរូបដែលកើតឡើងក្នុងនាមធាតុ រូបធាតុ អរូបធាតុ លើកលែងតែកំណើត ១ ចេញ នាម និងរូបរមែងរលត់ទៅក្នុងទីនោះ គឺដល់នូវការតាំងនៅមិនបាន ព្រោះការរលត់ទៅនៃអភិសង្ខារវិញ្ញាណ ដោយអនាគាមិមគ្គញ្ញាណ ។ ធម៌ពួកណា គឺនាម និងរូបដែលកើតឡើង ហើយរមែងរលត់ទៅ គឺដល់នូវការតាំងនៅមិនបាន ព្រោះការ

រលត់ទៅនៃអភិសង្ខារវិញ្ញាណ ដោយអរហត្តមគ្គញ្ញាណ ។ កាលព្រះអរហន្តបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ គឺការរលត់ដោយមិនមានចំណែកសេសសល់ ។ កាលវិញ្ញាណចាស់រលត់ទៅ សតិ និងបញ្ញា និងនាមរូបរមែងរលត់ទៅ គឺដល់នូវការតាំងនៅមិនបាន ។

បញ្ហាដែលអជិតមាណពក្រាបទូលសួរ និងពុទ្ធព្យាករណ៍ដែលទ្រង់ដោះស្រាយរួចមកហើយនោះ សុទ្ធតែជាធម្មាធិដ្ឋាន និងឆ្លើយជាធម៌សុទ្ធៗ មិនបានពោលដល់បុគ្គលឡើយ អជិតមាណពត្រូវការនឹងដឹងលក្ខណៈរបស់បុគ្គលទៀត ទើបក្រាបទូលសួរព្រះមានព្រះភាគ ជាបុគ្គលាធិដ្ឋានតទៅទៀតថា

ពួកអសេក្ខបុគ្គល អ្នកមានធម៌ពិចារណាហើយ និងពួកសេក្ខ-បុគ្គលជាច្រើនណា ក្នុងសាសនានេះ បពិត្រព្រះអង្គនិទ្ទុក្ខ ខ្ញុំព្រះអង្គសួរនូវសេចក្តីប្រព្រឹត្តទៅនៃបុគ្គលទាំងនោះ ព្រះអង្គមានបញ្ញាចាស់ក្លាសូមសម្តែងប្រាប់ដល់ខ្ញុំព្រះអង្គ ។

បុគ្គលមិនគប្បីជាប់ជំពាក់ ក្នុងកាមទាំងឡាយ គប្បីជាអ្នក

មានចិត្តមិនល្អក់ ជាអ្នកឈ្លាសវៃ ចំពោះធម៌ទាំងអស់ ជាភិក្ខុមានសតិ គប្បីវៀរស្រឡះ ( ចាកកាមទាំងឡាយ ) ។ ព្រះអរហន្ត ឬព្រះអសេក្ខបុគ្គល ជាបុគ្គលអស់អាសវក្កិលេសហើយ ជាអ្នកជាក់ច្បាស់នូវធម៌ទាំងពួងថា សង្ខារទាំងឡាយមិនទៀង សង្ខារទាំងឡាយជាទុក្ខ ធម៌ទាំងឡាយជាអនត្តា ថែមទាំងដឹងច្បាស់ទៀតថា អវិជ្ជាជាបច្ច័យឲ្យកើតសង្ខារជាដើម ដឹងច្បាស់ទៀតថា សភាវធម៌ណានីមួយ មានការកើតឡើងជាធម្មតា សភាវធម៌ទាំងនោះ ក៏មានការរលត់ទៅវិញជាធម្មតាដែរ ។

ម្យ៉ាងទៀត ព្រះអរហន្តសាវកទាំងនោះ ដឹងច្បាស់នូវខន្ធ ធាតុ អាយតនៈ គតិ ឧប្បត្តិ បដិសន្ធិ ភព សង្សារ វដ្ដៈ ។ ព្រះអរហន្តសាវកទាំងនោះ តាំងនៅក្នុងទីបំផុតនៃខន្ធ អាយតនៈ គតិ ភព សង្សារ វដ្ដៈ តាំងនៅក្នុងទីបំផុតនៃភពហើយ ក្នុងអត្តភាពចុងក្រោយ ដោយមិនមានការកើតជាបន្តទៀត ទើបហៅថា បុគ្គលមានធម៌បរិបូណ៌ហើយ ។ ចំណែកព្រះសេក្ខបុគ្គល គឺបុគ្គលដែលត្រូវសិក្សាជាបន្ត

ទៀតនោះ បានដល់ ការសិក្សាក្នុងអធិសីលសិក្ខា អធិចិត្តសិក្ខា និង អធិប្បញ្ញាសិក្ខា ។ ពាក្យថា **អធិសីលសិក្ខា** ប្រែថា ការសិក្សាក្នុង អធិសីល បានដល់ ការសង្រួមក្នុងព្រះបាតិមោក្ខ គឺការបរិបូណ៌ដោយ អាចារ និងគោចរ ការសម្លឹងឃើញភ័យក្នុងទោស សូម្បីត្រឹមតែបន្តិច បន្តួច ក៏សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ គឺសីលក្ខន្ធទាំងតូច ទាំងធំ សីលជាទីពឹង ជាគ្រឿងរាំង ជាការសង្រួមរាំង ជាប្រធាន នៃកុសលធម៌ទាំងឡាយ ។ ពាក្យថា **អធិចិត្តសិក្ខា** ប្រែថា ការសិក្សា ក្នុងអធិចិត្ត បានដល់ ភិក្ខុក្នុងធម្មវិន័យនេះ ជាអ្នកទំនេរចាកកាម ទំនេរ ចាកអកុសលធម៌ បានសម្រេចបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន និងចតុត្ថជ្ឈាន ។ ពាក្យថា **អធិប្បញ្ញាសិក្ខា** ប្រែថា ការសិក្សាក្នុង អធិប្បញ្ញា បានដល់ បញ្ញាដែលធ្វើឲ្យដឹងការកើត និងការរលត់ ជា បញ្ញាដ៏បរិសុទ្ធ ជាបញ្ញាដែលទម្លាយកិលេសបាន ជាបញ្ញាដែលធ្វើឲ្យ អស់ទុក្ខបាន ជាបញ្ញាដែលដឹងច្បាស់ក្នុងអរិយសច្ចៈទាំង ៤ បាន ។

ព្រះលោកនាថ ទ្រង់ត្រាស់ទៀតថា ម្នាលអជិតៈ ភិក្ខុមិនគប្បី

ជាប់ចិត្តក្នុងកាមទាំងឡាយ ជាបុគ្គលមានចិត្តមិនល្អក់កករ ជាបុគ្គលឆ្លាតក្នុងធម៌ទាំងឡាយ គួរជាបុគ្គល មានសតិលះបង់នូវកាមារម្មណ៍ទាំងឡាយ ។

ពាក្យថា **កាម** សំដៅដល់ការប្រាថ្នា បើពោលទៅដោយមាតិកាមាន ២ ប្រការ គឺ

**១- កិលេសកាម** ប្រែថា កិលេសជាហេតុធ្វើឲ្យកើតសេចក្ដីប្រាថ្នា បានដល់ ឆន្ទៈ រាគៈ លោភៈ ឥច្ឆា តណ្ហា ជាដើម ។

**២- វត្ថុកាម** ប្រែថា វត្ថុដែលគួរប្រាថ្នា បានដល់ កាមគុណ ៥ គឺរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ( វត្ថុដែលពាល់ត្រូវដោយកាយ ដែលគួរប្រាថ្នា គួរពេញចិត្ត ពោលរួម សំដៅដល់មនុស្សសត្វ ទ្រព្យ ) ។

បុគ្គលមានចិត្តមិនល្អក់កករ សំដៅដល់មនោសុចរិត គឺមានចិត្តមិនមានអភិជ្ឈា មិនមានព្យាបាទ មិនមានមច្ឆរិយៈ ។ ពាក្យថា **មនោ** ប្រែថា ចិត្ត មានឈ្មោះហៅច្រើនយ៉ាងទៀត ដូចជាចិត្ត មនៈ

មានសៈ ហទយៈ អាយតនៈ វិញ្ញាណ ជាដើម ។ សេចក្តីដែលថា ជាបុគ្គលឆ្លាតក្នុងធម៌ទាំងពួង គឺជាបុគ្គលដែលចេះជ្រាលជ្រៅ ក្នុងធម៌ដែលជាលោកិយ និងលោកុត្តរៈ ។ ពាក្យថា **ភិក្ខុ** ប្រែថា បុគ្គលដែលឃើញភ័យនៃក្រសែការវិលវល់របស់លោក ឬអ្នកសូម ។

សេចក្តីដែលថា **ភិក្ខុគួរមានសតិនោះ** គឺគួរមានសតិដោយហេតុ ៤ ប្រការ ដែលហៅថាសតិប្បដ្ឋាន សំដៅដល់ធម៌ដែលជាទីតាំងនៃសតិ មាន ៤ ប្រការ គឺ

កាយានុបស្សនាសតិប្បដ្ឋាន ១ វេទនានុបស្សនាសតិប្បដ្ឋាន ១ ចិត្តានុបស្សនាសតិប្បដ្ឋាន ១ ធម្មានុបស្សនាសតិប្បដ្ឋាន ១ ឬគួរមានសតិដោយហេតុ ១០ ប្រការ មានពុទ្ធានុស្សតិ គឺការរឭកដល់គុណព្រះពុទ្ធជាម្ចាស់ជាដើម និងឧបសមានុស្សតិ គឺការរឭកដល់គុណព្រះនិព្វាន ដែលរម្ងាប់កិលេស និងកងទុក្ខទាំងពួង ។ ចំណែកសេចក្តីដែលថា ភិក្ខុគួរមានសតិលះបង់វៀរដោយជុំវិញនោះ គឺមានសតិ

សព្វៗ កាល គ្រប់ឥរិយាបថទាំង ៤ ដោយមានសតិនៅជាមួយខ្លួនជានិច្ច មិនថានៅពេលធ្វើ ឬនិយាយ និងនឹកគិតអ្វីៗ ទេ ។

ក្នុងពេលដែលចប់ព្រះគាថា គឺព្រះពុទ្ធដីកា ដែលព្រះពុទ្ធជាម្ចាស់ត្រាស់តបបញ្ហានោះ ធម្មចក្ខុ បានដល់ ភ្នែក គឺបញ្ញាដែលដឹងឃើញ ( ឬហៅថាសោតាបត្តិមគ្គ ដែលប្រាសចាកធូលី ឬមន្ទិល ក៏បានកើតឡើងដល់ទេវតា និងមនុស្សជាច្រើន ដែលជាអ្នកមានឆន្ទៈពេញចិត្តក្នុងធម៌ដូចគ្នា មានអជិតមាណពជាដើមថា សភាវធម៌ណានីមួយមានការកើតឡើងជាធម្មតា សភាវធម៌នោះ មានការរលត់ទៅវិញជាធម្មតា ។ គ្រានោះ ចិត្តរបស់អជិតមាណព ក៏បានផុតស្រឡះចាកអាសវក្កិលេសទាំងឡាយ ព្រោះមិនមានឧបាទាន គឺអស់នូវការប្រកាន់មាំ និងព្រមគ្នាកាលដែលអជិតមាណព បានសម្រេចជាព្រះអរហន្តនោះ ស្បែកខ្លា ឬបរិក្ខារជារបស់តាបស និងពុកមាត់ពុកចង្កាបាត់ទៅមួយរំពេច បានប្រាកដឡើងនូវបរិក្ខារទាំង ៨ ដែលជាបរិក្ខាររបស់ភិក្ខុ ហើយក៏ចូលទៅថ្វាយបង្គំព្រះមហាវីរៈ ដោយប្រកាសថា

បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គជាសាស្តារបស់ខ្ញុំព្រះអង្គ ចំណែកខ្ញុំព្រះអង្គជាសាវករបស់ព្រះអង្គ ។

ប៉ុន្តែ នៅក្នុងអដ្ឋកថាបានពោលតទៅទៀតថា ក្នុងពេលដែលចប់ព្រះធម៌ទេសនា អជិតមាណព ព្រមទាំងអន្តេវាសិក ១.០០០ នាក់នោះ បានសម្រេចព្រះអរហត្តផល ។ ចំណែកធម្មចក្ខុ បានកើតឡើងដល់ទេវតា និងមនុស្សជាច្រើន ។ ក្នុងទីបំផុតនៃសោឡសបញ្ហា ដែលព្រះមានជោគ ទ្រង់ដោះស្រាយដល់អជិតមាណព ព្រមដោយមាណពទាំង ១៥ នាក់ទៀត និងបរិវារទាំងអស់ ថែមទាំងនាំគ្នាក្រាបទូលសូមបព្វជ្ជា និងឧបសម្បទាក្នុងធម្មវិន័យនេះ ព្រះអង្គក៏ទ្រង់ត្រាស់អនុញ្ញាត ការបួសជាភិក្ខុក្នុងព្រះសាសនានេះ របស់ពួកគេទាំងនោះ ដោយវិធីឯហិភិក្ខុឧបសម្បទា ។

ជីវប្រវត្តិរបស់ព្រះអជិតត្ថេរ មានសម្តែងប្រាកដនៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ដោយលោកបានតំណាលដល់ជីវប្រវត្តិខ្លួនឯងទុក ក្នុងការបានសម្រេចគុណធម៌ ឬក្នុងដំណើរជីវិតចុងក្រោយនេះដោយ

ការអស់ជាតិកំណើតតទៅទៀតថា ៖

កាលដែលខ្ញុំព្រះអង្គចូលទៅគាល់ព្រះមានព្រះភាគ ទ្រង់ជាអ្នកប្រាជ្ញហើយ ធ្វើឲ្យខ្ញុំប្រសព្វនឹងផលល្អ គឺខ្ញុំបានសម្រេចវិជ្ជា ៣ ថែមទាំងបានធ្វើតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធហើយទៀតផង ។ ដោយអានិសង្សដែលខ្ញុំដុតប្រទីបបូជាព្រះបទុមុត្តរៈ ក្នុងកប្បទីមួយសែនអំពីកប្បនេះ កាលនោះព្រោះហេតុដែលខ្ញុំបានឲ្យប្រទីប ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃទីបទាន ។ កិលេសទាំងឡាយ ខ្ញុំដុតចោលហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចដំរីកាត់ទន្ទឹង ឱហ្ន៎! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនានៃព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយដែរ ។

ចំណែកផលបុណ្យរបស់ព្រះអជិតៈ បើនឹងពិចារណាដល់រយៈពេលដែលលោកចូលមកបួសជាភិក្ខុ និងបានសម្រេចជាព្រះអរហន្ត

ហើយ នៅក្នុងរវាងបឋមពោធិកាល និងប្រកបផ្សំនឹងលោកជាអ្នកមាន ឈ្មោះល្បាញល្បីមកពីមុននោះ ថែមទាំងមានបរិវារជាច្រើនទៀតផង គង់ជាហេតុជួយឲ្យបុគ្គលទាំងឡាយធ្លាប់ស្គាល់ច្បាស់ ឬអ្នកធ្លាប់បាន ឮកិត្តិគុណរបស់លោកហើយ ក៏កើតជំនឿ ដោយការដឹងថា លោកបាន សម្រេចអរិយធម៌ថ្នាក់ខ្ពស់បំផុតហើយ ថែមទាំងលោកជួយប្រកាស ធម៌វិន័យរបស់ព្រះបរមសាស្តា ឲ្យមហាជនបានទទួលនូវអចលនបទ ជាច្រើន ទាំងនេះក៏ជាចំណែកបុណ្យមួយផ្នែក របស់លោកដែរ ។

ចំណែកជីវប្រវត្តិ ដែលទាក់ទងនឹងការរំលត់ខន្ធបរិនិព្វានរបស់ លោក មិនឃើញមានសម្តែងទុកក្នុងទីណាទេ ៕

( ជីវប្រវត្តិរបស់ព្រះអជិតត្ថេរ ចប់ )

8888888888888888888888888888888

# ✍ ជីវប្រវត្តិរបស់ព្រះធោតកត្ថេរ ✍

## " លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័កផងដែរ "

ព្រះធោតកត្ថេរ លោកដឹងច្បាស់លាស់ ចាក់ធ្លុះរហូតដល់គុណធម៌ថ្នាក់លោកុត្តរៈ លោកក៏ជាអ្នកទទួលនូវកិត្តិយសដ៏ប្រសើរផងដែរ ជាពិសេសនោះ លោកបានសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័កមួយរូបដែរ លោកក៏ជាអ្នកនៅក្នុងក្រុមនៃមាណពទាំង ១៦ នាក់ ដែលជាកូនសិស្សរបស់អាចារ្យពាវរីព្រាហ្មណ៍ ដែលរៀនសម្រេចមន្តទាំងឡាយ ក្នុងលទ្ធិរបស់ព្រាហ្មណ៍ដូចគ្នានឹងសិស្សច្បងដែរ ទាំងលោកក៏មានបរិវារ ១.០០០ នាក់ទៀត ហើយលោកក៏បានទទួលការយកចិត្តទុកដាក់ពីអាចារ្យពាវរីព្រាហ្មណ៍ ដោយឲ្យនាំយកបញ្ហាទៅក្រាបទូលសួរព្រះបរមសាស្តា រួមជាមួយនឹងមាណពដែលជាកូនសិស្សច្បងទាំងឡាយ ។

ជីវប្រវត្តិក្នុងបច្ចុប្បន្នជាតិរបស់ព្រះធោតកត្ថេរ មានសម្តែងទុក

នៅក្នុង អដ្ឋកថាសុត្តនិបាត នៃ បារាយនវគ្គ និងក្នុង គម្ពីរខុទ្ទកនិកាយ ចូឡនិទ្ទេស តែក្នុងទីនេះសូមលើកតែសាច់រឿងពីព្រះបាលីថា ៖

ព្រះជោតកៈ ជាបុត្ររបស់ព្រាហ្មណ៍ម្នាក់នៅក្នុងក្រុងសាវត្ថី កាលចម្រើនវ័យធំដឹងក្តីឡើង ក៏បានចូលទៅថ្វាយខ្លួនធ្វើជាកូនសិស្ស របស់អាចារ្យពាវរីព្រាហ្មណ៍ ដើម្បីសូមការសិក្សាសិល្បវិជ្ជា ។ កាលដែលជោតកមាណព ស្ម័គ្រចិត្តព្រមធ្វើជាកូនសិស្ស របស់អាចារ្យពាវរីនោះ ពីព្រោះអាចារ្យពាវរី ជាអ្នកចេះដឹងសព្វគ្រប់ក្នុងវិជ្ជាត្រៃវេទ និងមានលក្ខណៈពិសេសរបស់មហាបុរស ៣ ប្រការ ទាំងជាព្រះរាជបុរោហិត របស់ព្រះបាទបសេនទិកោសលទៀតផង ។ កាលជាខាងក្រោយមក អាចារ្យពាវរី ក៏មានការនឿយណាយក្នុងភាពជាឃរាវាស ទើបក្រាបទូលលាព្រះបាទបសេនទិកោសលចេញទៅបួស ក៏បានតាំងអាស្រមនៅក្បែរឆ្នេរនៃស្ទឹងគោធាវរី ដែលជាព្រំដែន នៃអស្សកៈ និងដែនមូឡកៈ តាំងចិត្តបំពេញផ្នួស និងជាគណាចារ្យបានបង្រៀនមន្តផ្សេងៗ ដល់សិស្ស ។

ជោតកមាណព ព្រមដោយមាណពដែលជាកូនសិស្សដទៃៗ និងកូនសិស្សរបស់ខ្លួន ក៏បាននាំគ្នាចេញបួសតាមអាចារ្យពាវរីដែរ ។ កាលអាចារ្យពាវរីព្រាហ្មណ៍ ចូលទៅតាំងអាស្រមនៅទីកន្លែងនោះ ក្នុងក្រុង និងបរិវេណទាំងនោះ ក៏សម្បូរសប្បាយរុងរឿងឡើង ឯអាចារ្យពាវរីវិញ ក៏បានទទួលអំណោយអំពីពពួកអ្នកស្រុកទាំងនោះ ហើយទើបបានយកទៅបរិច្ចាគទានជាប្រចាំជារៀងរាល់ឆ្នាំ ។ ថ្ងៃមួយ អាចារ្យពាវរីបានបរិច្ចាគទានរួចហើយ ក៏ត្រឡប់មកកាន់អាស្រមវិញ គ្រានោះ មានព្រាហ្មណ៍ចាស់ជរាម្នាក់ មានខ្លួនប្រឡាក់ស្រមកដោយធូលី ដើរធ្វើញ័រៗ ចូលទៅរកពាវរីព្រាហ្មណ៍ ហើយក៏និយាយសុំទ្រព្យ ៥០០ កហាបណៈ ។ចំណែកអាចារ្យពាវរី កាលបើបានឃើញព្រាហ្មណ៍ នោះហើយ ក៏អញ្ជើញឲ្យអង្គុយលើអាសនៈ រួចក៏បានប្រាស្រ័យសាកសួរសុខទុក្ខ ហើយឆ្លើយប្រាប់ថា យើងអស់ទ្រព្យហើយ ពីព្រោះយើងបានបរិច្ចាគទានទើបតែរួចដែរ ។ គ្រានោះ ព្រាហ្មណ៍នោះក៏ខឹងឡើង ទើបគិតក្លែងជារឿងបោកបញ្ឆោត គំរាមកំហែងឡើងថា បើអ្នកមិន

ឲ្យទ្រព្យដល់យើងទេ រយៈពេល ៧ ថ្ងៃទៀត ក្បាលរបស់លោក ត្រូវបែកជា ៧ ភាគ ។ អាចារ្យពាវរីបានស្តាប់ពាក្យរបស់ព្រាហ្មណ៍ចាស់នោះហើយ ក៏ភ័យខ្លាច រហូតដល់បរិភោគមិនបានសម្រាន្តមិនលក់ ធ្វើឲ្យរាងកាយស្គាំងស្គម ។

ពេលនោះ មានទេវតាមួយអង្គ ជាអ្នកមានបំណងល្អក្នុងហេតុទាំងនោះ ទើបចូលទៅរកពាវរី ហើយពោលដាស់តឿនឲ្យមានសតិថា ព្រាហ្មណ៍ចាស់ជរានោះ ជាអ្នកពោលកុហកបោកបញ្ឆោតទេតើ គេមិនដឹងថា អ្វីជាក្បាល អ្វីជាធម៌ ដែលជាហេតុធ្វើឲ្យក្បាលបែកជា ៧ ភាគនោះទេ ។ លំដាប់នោះ ពាវរីត្រិះរិះគិតថា ទេវតានេះគង់ដឹងក្នុងរឿងនេះហើយ ទើបសួរឡើងថា អ្វីជាក្បាល អ្វីដែលជាធម៌ នាំឲ្យក្បាលដាច់ធ្លាក់ចុះ ?

គ្រានោះ ទេវតាក៏ឆ្លើយថា សូម្បីខ្ញុំក៏មិនដឹងថា អ្វីជាក្បាល អ្វីជាធម៌ ដែលជាហេតុធ្វើឲ្យក្បាលដាច់ធ្លាក់ចុះដូចគ្នាដែរ តែក្នុងរឿងនេះ មានតែព្រះលោកវិទូទេ ទ្រង់ជាព្រះរាជឱរសរបស់សក្យរាជ នៃ

រាជវង្សរបស់ព្រះបាទឱក្កាករាជ ព្រះអង្គប្រាកដជាប្រាកដក្នុងរឿងនេះ ហើយ តែឥឡូវនេះ ព្រះពុទ្ធអង្គទ្រង់គង់ប្រថាប់នៅក្នុងរាជវាំង នៃព្រះបាទកោសល ក្នុងក្រុងសាវត្ថីឯណោះ ។ ពាវរីបានឮដូច្នោះហើយ ក៏មានចិត្តរីករាយឡើងវិញ ក៏បានរំសាយភាពកើតទុក្ខទាំងនោះ ទើបបានហៅកូនសិស្សដែលសម្រេចមន្តមកប្រាប់ឲ្យដឹងថា ឥឡូវនេះ ព្រះសម្ពុទ្ធ ទ្រង់ជាអ្នកខ្ពង់ខ្ពស់បំផុត ជាងសព្វសត្វទាំងពួង ឥឡូវស្ដេចឧប្បត្តិឡើងហើយក្នុងលោក ពួកអ្នកចូរទៅស៊ើបដំណឹងមើលដើម្បីឲ្យដឹងការពិត ។ ពួកកូនសិស្សទាំងនោះ សួរពាវរីថា បពិត្រលោកអាចារ្យ ពួកខ្ញុំនឹងដឹងថាព្រះពុទ្ធដោយឧបាយយ៉ាងណាទៅ ? អាចារ្យពាវរីក៏បានពោលពន្យល់មាណពទាំងនោះ ឲ្យមើលទៅនៅក្នុងតម្រាលក្ខណៈព្យាករណ៍សាស្ត្រ ពួកអ្នកនឹងដឹងថា ព្រះភគវាមានលក្ខណៈប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ តាមដែលមានពោលទុកក្នុងមន្តទាំងឡាយ យ៉ាងជាក់ច្បាស់ហើយ ។ បើព្រះអង្គនៅគ្រប់គ្រងផ្ទះ ព្រះអង្គនឹងបានជាស្ដេចចក្រពត្តិ ជាអ្នកឈ្នះសត្រូវក្នុងទិស

ទាំងពួង ទ្រង់គ្រប់គ្រងប្រកបដោយធម៌ មិនប្រើអាជ្ញា និងអាវុធ ។ បើព្រះអង្គចេញទៅបួសវិញ នឹងបានសម្រេចជាព្រះសម្មាសម្ពុទ្ធ ទ្រង់ជាសាស្តាឯកក្នុងលោក ។ ប៉ុន្តែមួយទៀត បើចង់ដឹង ចូរនឹកទូលសួរបញ្ហាដោយចិត្ត ៣ ១. ព្រះអង្គប្រាកដជាត្រាស់ តបបញ្ហានោះដោយវាចាដ៏ស្រទន់ តាមដែលចិត្តនឹកគិតទូលសួរ ។ ពេលដែលអាចារ្យពាវរីពោលប្រាប់វិធីនេះដូច្នេះហើយ ទើបចងបញ្ហាឲ្យមាណពទាំង ១៦ នាក់នោះ ដែលបានចេញទៅស៊ើបមើលដំណឹង រកព្រះលោកនាថ កាលបើឃើញហើយ ចូរសួរបញ្ហានេះផង ។

ដោតកមាណព ជាមាណពម្នាក់ ក្នុងចំណោមមាណពទាំង ១៦នាក់នោះ បានធ្វើដំណើរទៅស៊ើបមើលដំណឹងព្រះមានព្រះភាគរហូត ទៅដល់បាសាណកចេតិយ នៃដែនមគធៈ និងបានជាអ្នកក្រាបទូលសួរបញ្ហាជាលំដាប់ទី ៥ កាលដោតកៈ បានទទួលពុទ្ធានុញ្ញាតហើយ ទើបក្រាបទូលសួរបញ្ហាឡើងថា

( ដោតកមាណពដ៏មានអាយុទូលសួរថា ) បពិត្រព្រះសម្ពុទ្ធ

ខ្ញុំព្រះអង្គក្រាបទូលសួរព្រះអង្គ សូមព្រះអង្គសម្ដែងសេចក្ដីនោះដល់ខ្ញុំព្រះអង្គ បពិត្រព្រះអង្គស្វែងរកគុណដ៏ធំ ខ្ញុំព្រះអង្គប្រាថ្នា ( ស្ដាប់ ) ព្រះវាចារបស់ព្រះអង្គ បានស្ដាប់ព្រះពុទ្ធដីកា ជាសុរសីហនាទរបស់ព្រះអង្គហើយ នឹងសិក្សាធម៌ជាគ្រឿងរំលត់កិលេសរបស់ខ្ញុំ ។

( ព្រះសាស្ដា ទ្រង់ដោះស្រាយថា ម្នាលធោតកៈ ) បើដូច្នោះ អ្នកចូរជាបុគ្គលមានបញ្ញាខ្ជាប់ខ្ជួន មានសតិ ធ្វើសេចក្ដីព្យាយាមក្នុងសាសនានេះចុះ បុគ្គលបានស្ដាប់ពាក្យអំពីសម្នាក់នៃតថាគតនេះហើយ គប្បីសិក្សាធម៌ជាគ្រឿងរំលត់កិលេសរបស់ខ្លួន ។

ខ្ញុំព្រះអង្គបានឃើញព្រះអង្គ ជាព្រាហ្មណ៍ ឥតមានកង្វល់ត្រាច់ទៅក្នុងទេវលោក និងមនុស្សលោក បពិត្រព្រះអង្គមានចក្ខុជុំវិញ ខ្ញុំព្រះអង្គសូមនមស្ការព្រះអង្គ បពិត្រព្រះអង្គជាសក្យពង្ស សូមព្រះអង្គដោះខ្ញុំព្រះអង្គ ចេញចាកសេចក្ដីសង្ស័យទាំងឡាយ ។

ម្នាលធោតកៈ តថាគតមិនអាចដើម្បីនឹងដោះអ្នកណាមួយក្នុងលោក ដែលមានសេចក្ដីសង្ស័យបានទេ ប៉ុន្តែកាលបើអ្នកដឹងធម៌ដ៏

ប្រសើរយ៉ាងនេះ នឹងឆ្លងឱឃៈនេះបាន ។

បពិត្រព្រះអង្គ ជាព្រហ្ម សូមព្រះអង្គទ្រង់ព្រះករុណាប្រៀនប្រដៅវិវេកធម៌ឲ្យដល់ខ្ញុំព្រះអង្គដឹងច្បាស់ ដើម្បីខ្ញុំព្រះអង្គមិនទើសទាក់ដូចអាកាស ជាអ្នកស្ងប់ មិនអាស្រ័យដោយកិលេសក្នុងពេលនេះ ។

( ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលធោតកៈ ) បុគ្គលមានសតិ គួរដឹងច្បាស់នូវសន្តិបទណា ហើយឆ្លងតណ្ហា ដែលផ្សាយទៅក្នុងលោកបាន តថាគតនឹងសម្តែងនូវសន្តិបទនោះ ដែលតថាគតជាក់ច្បាស់ក្នុងខ្លួន ក្នុងបច្ចុប្បន្ន ដល់អ្នក ។

បពិត្រព្រះអង្គអ្នកស្វែងរកនូវគុណដ៏ធំ បុគ្គលមានសតិ គួរដឹងច្បាស់នូវសន្តិបទណា ហើយឆ្លងតណ្ហា ដែលផ្សាយទៅផ្សេងៗក្នុងលោកបាន ខ្ញុំព្រះអង្គត្រេកអរ ចំពោះសន្តិបទដ៏ស្ងប់ឧត្តមនោះ ។

( ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ម្នាលធោតកៈ ) អ្នកដឹងច្បាស់អារម្មណ៍ណានីមួយ ក្នុងចំណែកខាងលើ ( អនាគត ) ក្នុងចំណែកខាងក្រោម ( អតីត ) និងក្នុងចំណែកទទឹង ឬកណ្តាល

( បច្ចុប្បន្ន ) ដឹងច្បាស់ថា ជាអារម្មណ៍ជាប់ជំពាក់ នៅក្នុងលោកយ៉ាងនេះហើយ អ្នកកុំធ្វើតណ្ហាក្នុងភពតូចភពធំទៀតឡើយ ។

ក្នុងកាលចប់នៃព្រះគាថា ដែលជាព្រះពុទ្ធដីកា ត្រាស់តបបញ្ហារបស់ព្រះមានបុណ្យនោះ ធម្មចក្ខុ ភ្នែក គឺបញ្ញា ដែលដឹងធម៌តាមសេចក្តីពិតនោះ បានកើតឡើងដល់មនុស្ស និងទេវតាជាច្រើន ដោយពិចារណាឃើញថា សភាវធម៌ណានីមួយ មានការកើតឡើងជាធម្មតា សភាវធម៌នោះ ក៏មានការរលត់ទៅវិញជាធម្មតាដែរ និងមាណពដែលជាបរិវាររបស់ធោតកមាណព ក៏ដូចគ្នាដែរ ក៏ដោយការអប់រំវាសនាដូចគ្នានឹងធោតកមាណព ចិត្តរបស់ជនទាំងនោះ ក៏ផុតស្រឡះចាកអាសវក្កិលេសទាំងឡាយ ព្រោះអស់ការប្រកាន់មាំចំពោះសង្ខារទៀតហើយ ។ ព្រមគ្នានឹងការបានសម្រេចជាព្រះអរហន្តនោះ បរិក្ខាររបស់តាបស មានស្បែកខ្លាជាដើម ពុកមាត់ ពុកចង្កា បានបាត់ទៅមួយរំពេចក្នុងពេលនោះឯង ។ បរិក្ខារទាំង ៨ បានមកប្រាកដដល់ធោតកមាណពមានភាវៈជាភិក្ខុ ហើយក្រាបទូលឡើងថា

បពិត្រព្រះមានជោគ ព្រះអង្គជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវករបស់ព្រះអង្គ ។ ការដែលព្រះទសពល ត្រាស់តបសោឡសចប់ហើយ ជោតកមាណព ព្រមដោយមាណព ១៥ នាក់ទៀត និងបរិវារទាំងអស់ បានក្រាបទូលសូមបព្វជ្ជាឧបសម្បទា ក្នុងព្រះពុទ្ធសាសនានេះ ព្រះអង្គក៏ទ្រង់ត្រាស់អនុញ្ញាត ការបព្វជ្ជាឧបសម្បទាដោយវិធីឯហិភិក្ខុឧបសម្បទា ។

ព្រះជោតកត្ថេរ កាលបានជាព្រះអរហន្តហើយ លោកបានពោលតំណាលអំពីជីវប្រវត្តិរបស់លោកទុក តាមដែលមានសម្តែងប្រាកដនៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ដូចមានសេចក្តីថា ៖

ទឹកស្ទឹងឈ្មោះភាគីរសី ហូរចេញមកអំពីព្រៃហិមពាន្ត ហើយហូរទៅតាមទ្វារក្រុងហង្សវតី ក្នុងគ្រានោះ ។ អារាមឈ្មោះសោភិតៈដែលគេសាងល្អហើយ នៅក្បែរឆ្នេរនៃស្ទឹងគង្គា ព្រះពុទ្ធអង្គព្រះនាមបទុមុត្តរៈ ជាលោកនាយក ស្តេចប្រថាប់នៅក្នុងអារាមនោះ ។ ព្រះមានព្រះភាគ មានពួកមនុស្សចោមរោមហើយ ដូចជាព្រះឥន្ទ្រ មាន

ពួកទេវតាចោមរោម ស្តេចគង់នៅក្នុងអារាមនោះ ដូចជាកេសរ-រាជសីហ៍ ដែលឥតមានសេចក្តីតក់ស្លុត ។ ខ្ញុំកើតជាព្រាហ្មណ៍ មាននាមថា ធម្មុគ្គៈ នៅក្នុងនគរហង្សវតី បពិត្រព្រះមហាមុនី ខ្ញុំឈ្មោះយ៉ាងនេះ។ កាលនោះ ពួកសិស្សចំនួន ១៨ រយនាក់ តែងចោមរោមខ្ញុំ ខ្ញុំព្រមព្រៀងដោយពួកសិស្សទាំងនោះ ក៏ចូលទៅកាន់ឆ្នេរស្ទឹងគង្គា ។ ខ្ញុំកំពុងឆ្លងស្ទឹងភាគីរសី បានឃើញពួកសមណៈ ជាបុគ្គលមិនកុហក ជាអ្នកបន្សាត់បង់នូវបាប ត្រង់ឆ្នេរស្ទឹងគង្គានោះ ហើយខ្ញុំគិតយ៉ាងនេះ ក្នុងខណៈនោះថា ពួកសមណៈជាពុទ្ធបុត្រ មានយសធំទាំងនេះ ឆ្លងស្ទឹងទៅទាំងល្ងាច ទាំងព្រឹក នាំឲ្យខ្លួនលំបាក ខ្លួនសមណៈទាំងនោះ ក៏នឿយហត់ ។ ព្រះពុទ្ធ អ្នកផងតែងពោលថាជាកំពូលរបស់សត្វលោក ព្រមទាំងទេវលោក ឯអាត្មាអញ មិនទាន់មានគ្រឿងសក្ការៈ គឺការជម្រះផ្លូវសម្រាប់ដើរទៅ ចំពោះទក្ខិណេយ្យបុគ្គលនៅឡើយ ។ បើដូច្នេះ គួរតែអាត្មាអញ ញ៉ាំងជនឲ្យធ្វើស្ពានត្រង់ស្ទឹងគង្គា ថ្វាយព្រះពុទ្ធដ៏ប្រសើរ លុះអាត្មាអញ ឲ្យគេធ្វើស្ពាន

នេះរួចហើយ ឈ្មោះថា អាត្មាអញ បានធ្វើននូវកពនេះ ។ ខ្ញុំបាន ចំណាយទ្រព្យរាប់រយរាប់ពាន់ ឲ្យគេធ្វើស្ពាន ខ្ញុំជឿថាសក្ការៈដែល ខ្ញុំធ្វើហើយ ( នេះ ) នឹងមានផលធំទូលាយ ។ លុះខ្ញុំឲ្យគេធ្វើស្ពាន នោះរួចហើយ ក៏ចូលទៅគាល់ព្រះលោកនាយក ធ្វើអញ្ជលីកម្មលើ ក្បាល ហើយក្រាបបង្គំទូលពាក្យនេះថា បពិត្រព្រះមហាមុនី ខ្ញុំព្រះ អង្គចំណាយទ្រព្យរាប់រយរាប់ពាន់ ឲ្យគេធ្វើស្ពាននេះ ដើម្បីប្រយោជន៍ ដល់ព្រះអង្គ សូមព្រះអង្គទទួលយក នូវស្ពានដ៏ធំនេះចុះ ។ ព្រះមុនី ព្រះនាមបទុមុត្តរៈ ព្រះពុទ្ធអង្គជ្រាបច្បាស់ ទ្រង់គួរទទួលគ្រឿងបូជា ទ្រង់គង់នៅកណ្ដាលភិក្ខុសង្ឃ ហើយត្រាស់គាថាទាំងនេះថា បុគ្គល ណាជ្រះថ្លា បានឲ្យគេធ្វើស្ពានដោយដៃខ្លួនឯង ដើម្បីតថាគត។ នឹង សរសើរបុគ្គលនោះ អ្នកទាំងឡាយ ចូរស្តាប់តថាគត។ នឹងសម្ដែង ដូចតទៅនេះ ។

បុគ្គលនេះ បើទុកជាធ្លាក់ទៅក្នុងជ្រោះ ឬធ្លាក់អំពីភ្នំ ឬដើម ឈើក្តី ច្យុតហើយក្តី រមែងបាននូវទីឈរ នេះជាផលនៃការឲ្យស្ពាន។

សត្រូវទាំងឡាយ មិនគ្របសង្កត់ ( នូវបុគ្គលនេះបាន ) ដូចជាខ្យល់ មិនអាចគ្របសង្កត់ដើមជ្រៃ ដែលមានឫសដុះមាំ នេះជាផលនៃការ ឲ្យស្ពាន ។ ចោរទាំងឡាយ មិនអាចនឹងគ្របសង្កត់បុគ្គលនេះបានទេ ពួកក្សត្រក៏មិនមើលងាយបានដែរ ( បុគ្គលនេះ ) នឹងឆ្លងផុតសត្រូវ ទាំងពួង នេះជាផលនៃការឲ្យស្ពាន ។ បុគ្គលប្រកបដោយបុញ្ញកម្ម នេះ បើទុកជានៅក្នុងទីវាល ដែលហាលដោយកម្ដៅថ្ងៃដ៏ខ្លាំងក្លា ក៏ នឹងមិនមានវេទនាឡើយ ។ យានដ៏រី ដែលបុញ្ញកម្ម និម្មិតល្អហើយ ក្នុងទេវលោក ឬក្នុងមនុស្សលោក ក៏នឹងកើតឡើងក្នុងខណៈនោះ ព្រោះដឹងនូវសេចក្ដីត្រិះរិះរបស់បុគ្គលនោះ ។ សេះសិន្ធពមួយពាន់ មានសន្ទុះលឿនដូចជាខ្យល់ ជាពាហនៈដ៏រហ័ស នឹងចូលទៅបម្រើ ( បុគ្គល ) ទាំងព្រឹកទាំងល្ងាច នេះជាផលនៃការឲ្យស្ពាន ។ បុគ្គល នេះ លុះមកកាន់អត្តភាពជាមនុស្ស នឹងបានសេចក្ដីសុខ មួយទៀត យានដ៏រីនឹងកើតដល់បុគ្គលនេះ ដែលកើតជាមនុស្សក្នុងលោកនេះ ។ កន្លងទៅមួយសែនកប្បទៀត នឹងមានព្រះបរមសាស្ដា ទ្រង់ព្រះនាម

គោតម កើតក្នុងត្រកូល ព្រះបាទឱក្កាករាជ ត្រាស់ឡើងក្នុងលោក បុគ្គលនេះ នឹងបានទទួលមរតក ក្នុងធម៌របស់ព្រះពុទ្ធអង្គនោះ ជាឱរស ដែលធម៌និម្មិតហើយ នឹងកំណត់ដឹងអាសវៈទាំងពួង ជាអ្នកមិនមាន អាសវៈ នឹងបរិនិព្វាន ។

ឱហ្ន៎ ! អំពើដែលខ្ញុំធ្វើល្អហើយ ចំពោះព្រះសម្មាសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ខ្ញុំធ្វើគ្រឿងសក្ការៈ ចំពោះព្រះពុទ្ធអង្គនោះហើយ ក៏បានដល់នូវការអស់ទៅនៃអាសវៈ ។ ខ្ញុំមានចិត្តបញ្ជូនទៅកាន់សេចក្ដីព្យាយាម ជាអ្នកស្ងប់រម្ងាប់ មិនមានឧបក្កិលេស មិនមានអាសវៈ ដូចដំរីកាត់ផ្ដាច់នូវទន្ទឹង ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញ បោលហើយ ភពទាំងពួង ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គល មិនមានអាសវៈ ដូចដំរីកាត់ផ្ដាច់នូវទន្ទឹង ។ ឱហ្ន៎ ! ដំណើរដែលខ្ញុំមក ក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជាទាំង ៣ ខ្ញុំបាន ដល់ហើយដោយលំដាប់ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់

ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ចំណែកជីវប្រវត្តិរបស់ព្រះជោតកត្ថេរ ដែលទាក់ទងនឹងការធ្វើកុសលកម្មក្នុងអតីតជាតិ ដូចគ្នាជាមួយនឹងអាចារ្យពាវរីព្រាហ្មណ៍ និងមាណពដទៃទៀតនោះដែរ មានសម្តែងប្រាកដនៅក្នុង **អដ្ឋកថាបរមត្ថជោតិកា** ដែលបានពោលរួចមកហើយ នៅក្នុងជីវប្រវត្តិរបស់ព្រះអជិតត្ថេរ ។ ចំណែកនៅក្នុងរឿង ដែលទាក់ទងនឹងកិច្ចការធ្វើជាបុណ្យកុសលរបស់លោកវិញ ក៏គង់នឹងមិនផុត ព្រះធម្មចារឹក គឺអ្នកជួយប្រកាសសាសនធម៌ឲ្យដល់មហាជន នាសម័យនោះដែរ ។

ព្រះជោតកត្ថេរ លោកទ្រទ្រង់អាយុសង្ខារ មកដល់កាលដ៏សមគួរហើយ លោកក៏បានរំលត់ខន្ធបរិនិព្វានទៅហោង ។ល។

( ជីវប្រវត្តិរបស់ព្រះជោតកត្ថេរ ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះបុណ្ណកត្ថេរ ✍

## " លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័កផងដែរ "

ព្រះបុណ្ណកត្ថេរ លោកបានសម្រេចដល់ធម៌ទីបំផុត នៅក្នុងព្រះពុទ្ធសាសនានេះ ថែមទាំងបានទទួលការលើកតម្កើងសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័ក គឺជាសាវ័កធំរបស់ព្រះពុទ្ធ ៨០ រូប លោកក៏ជាបុគ្គលម្នាក់ក្នុងបណ្តាមាណព ១៦ នាក់ ដែលជាសិស្សរបស់អាចារ្យពាវរីព្រាហ្មណ៍ ដែលបានរៀនចប់វិជ្ជាត្រៃវេទ ក្នុងលទ្ធិរបស់ព្រាហ្មណ៍មុនមកបួស ។

ជីវប្រវត្តិក្នុងបច្ចុប្បន្នរបស់ព្រះបុណ្ណកត្ថេរ មានសម្តែងប្រាកដនៅក្នុង **អដ្ឋកថាបរមត្ថជោតិកា** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីក្នុងព្រះបាលី **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** នៃ **បារាយនវគ្គ** និងក្នុង **គម្ពីរខុទ្ទកនិកាយ ចូឡនិទ្ទេស** តែក្នុងទីនេះនឹងសូមនាំយកមកចំពោះតែសាច់រឿងក្នុងព្រះបាលី ដូចមានសេចក្តីថា ៖

ព្រះបុណ្ណកៈ ជាបុត្ររបស់ព្រាហ្មណ៍ម្នាក់ នៅក្នុងក្រុងសាវត្ថី កាលចម្រើនវ័យធំដឹងក្តីឡើងហើយ បានចូលទៅថ្វាយខ្លួនជាសិស្ស ក្នុងសម្នាក់របស់អាចារ្យពាវរីព្រាហ្មណ៍ ។ កាលដែលបុណ្ណកៈស្ម័គ្រចិត្ត ព្រមធ្វើជាកូនសិស្សរបស់អាចារ្យពាវរីព្រាហ្មណ៍នោះ ក៏ព្រោះអាចារ្យពាវរីព្រាហ្មណ៍ជាអ្នកដឹងអ្វីៗ គ្រប់យ៉ាងក្នុងវិជ្ជាត្រៃវេទ ថែមទាំងជាអ្នកមានលក្ខណៈនៃរាងកាយពិសេសរបស់មហាបុរស ៣ប្រការ ទាំងជារាជបុរោហិត របស់ព្រះបាទបសេនទិកោសលទៀតផង ។ ជាខាងក្រោយមក អាចារ្យពាវរីព្រាហ្មណ៍មានការនឿយណាយ ក្នុងជីវិតជាឃរាវាស គឺការគ្រប់គ្រងផ្ទះ ទើបក្រាបបង្គំទូលលាព្រះបាទបសេនទិកោសលទៅបួសជាតាបស ទៅតាំងអាស្រមនៅឆ្នេរនៃស្ទឹងគោធាវារី ដែលជាព្រំដែននៃដែនអស្សកៈ និងដែនមូឡកៈ ហើយតាំងចិត្តបំពេញផ្នួស និងជាគណាចារ្យបានបង្រៀនសិស្សដោយមន្តផ្សេងៗ ។

បុណ្ណកៈ ព្រមដោយមាណពដែលជាកូនសិស្សដទៃៗ និងកូនសិស្សទាំងឡាយរបស់ខ្លួន បាននាំគ្នាចេញបួសតាមពាវរីព្រាហ្មណ៍ ។

កាលពាវរីព្រាហ្មណ៍ទៅនៅអាស្រ័យទីកន្លែងនោះហើយ ស្រុក និង បរិវេណទាំងនោះ ក៏បានរីកចម្រើនជាច្រើន ចំណែកអាចារ្យពាវរីវិញ ក៏បានទទួលផលប្រយោជន៍អំពីអ្នកស្រុកទាំងនោះ ដោយបានទទួល អំណោយផ្សេងៗ ដូច្នេះហើយ ទើបធ្វើឲ្យអាចារ្យពាវរីព្រាហ្មណ៍បាន បរិច្ចាគមហាទានជាប្រចាំរៀងរាល់ឆ្នាំ ។ ថ្ងៃមួយ អាចារ្យពាវរីបាន បរិច្ចាគទានរួចហើយ ក៏បានត្រឡប់ចូលទៅកាន់អាស្រមវិញ គ្រានោះ ក៏មានព្រាហ្មណ៍ចាស់ជរាម្នាក់ទៀត ជាអ្នកធ្វើជាពិការដៃជើង ព្រម ទាំងខ្លួនប្រាណប្រឡាក់ស្រមកទៅដោយធូលី ថែមទាំងដើរធ្វើញ័រៗ ចូល ទៅរកអាចារ្យពាវរីដោយនិយាយសុំទ្រព្យ ៥០០ កហាបណៈ ។ ចំណែក អាចារ្យពាវរីព្រាហ្មណ៍វិញ បានឃើញព្រាហ្មណ៍ចាស់នោះហើយ ក៏ បានអញ្ជើញឲ្យទៅអង្គុយលើអាសនៈ និងបានប្រាស្រ័យចរចាសួរដល់ សេចក្ដីសុខ និងទុក្ខ រួចហើយ ក៏ឆ្លើយប្រាប់ថា ទ្រព្យរបស់យើង អស់ទៅហើយ ព្រោះយើងទើបតែបរិច្ចាគទានរួចហើយដែរ ។

គ្រានោះ ព្រាហ្មណ៍អ្នកសុំក៏មានការខឹង ទើបរកឧបាយធ្វើជា

រឿងដើម្បីបោកបញ្ឆោតគំរាមកំហែងឡើងថា កាលដែលយើងនិយាយសុំយ៉ាងនេះហើយ បើលោកមិនព្រមឲ្យទ្រព្យនោះដល់យើងទេ រយៈពេល ៧ ថ្ងៃទៀត ក្បាលរបស់លោកនឹងត្រូវបែកជា ៧ ភាគ ។ ពេលដែលអាចារ្យពាវរីព្រាហ្មណ៍ បានស្តាប់ឮពាក្យគំរាមកំហែងយ៉ាងនេះហើយ ក៏កើតការភ័យខ្លាច រហូតដល់បរិភោគមិនបាន សម្រាន្តមិនលក់ ថែមទាំងធ្វើឲ្យរាងកាយមានសភាពស្ងួកស្គាំងទៀតផង ។ គ្រានោះ មានទេវតាជាអ្នកមានបំណងល្អ ដឹងនូវហេតុទាំងនោះ ទើបចូលទៅរកអាចារ្យពាវរីព្រាហ្មណ៍ ហើយដាស់តឿនថា អ្នកចូរមានសតិឡើង ព្រាហ្មណ៍នោះជាមនុស្សពោលកុហកបោកបញ្ឆោតទេ គេក៏មិនដឹងក្បាល មិនដឹងធម៌ ដែលជាក្បាល ទាំងមិនដឹងធម៌ ដែលជាហេតុធ្វើឲ្យក្បាលដាច់ធ្លាក់ចុះដែរ ។ ពេលនោះ ពាវរីព្រាហ្មណ៍ត្រិះរិះគិតថា ទេវតានេះ ប្រាកដជាមិនពោលកុហកយើងក្នុងរឿងនេះទេ ហើយទើបពោលអង្វរថា សូមលោកជួយប្រាប់ក្បាល និងធម៌ដែលធ្វើឲ្យក្បាលដាច់ធ្លាក់ចុះដល់ខ្ញុំផងចុះ ។

លំដាប់នោះ ទេវតាឆ្លើយថា សូម្បីខ្ញុំក៏មិនដឹងថា អ្វីជាក្បាល អ្វីជាធម៌ ដែលជាហេតុធ្វើឲ្យក្បាលដាច់ធ្លាក់ចុះដូចគ្នាដែរ តែក្នុងរឿងនេះ មានតែព្រះលោកវិទូទេ ទ្រង់ជាព្រះរាជឱរសរបស់សក្យរាជនៃរាជវង្សរបស់ព្រះបាទឱក្កាករាជ ព្រះអង្គប្រាកដជាជ្រាបក្នុងរឿងនេះហើយ តែឥឡូវនេះ ព្រះពុទ្ធអង្គទ្រង់គង់ប្រថាប់នៅក្នុងរាជវាំងនៃព្រះបាទកោសល ក្នុងក្រុងសាវត្ថីឯណោះ ។ អាចារ្យពាវរីព្រាហ្មណ៍បានឮដូច្នោះហើយ ក៏មានចិត្តរីករាយឡើងវិញ បានរំសាយភាពកើតទុក្ខទាំងនោះ ទើបបានហៅកូនសិស្ស ដែលសម្រេចមន្តមកប្រាប់ឲ្យដឹងថា ឥឡូវនេះ ព្រះសម្ពុទ្ធ ទ្រង់ជាអ្នកខ្ពង់ខ្ពស់បំផុតជាងសព្វសត្វទាំងពួង ឥឡូវនេះស្តេចឧប្បត្តិឡើងហើយក្នុងលោក ពួកអ្នកចូរទៅស៊ើបដំណឹងមើលដើម្បីឲ្យដឹងការពិត ។ ពួកកូនសិស្សទាំងនោះ បានសួរអាចារ្យពាវរីព្រាហ្មណ៍ថា បពិត្រលោកអាចារ្យ ពួកខ្ញុំនឹងដឹងថាព្រះពុទ្ធដោយឧបាយយ៉ាងណាទៅ ? អាចារ្យពាវរីព្រាហ្មណ៍ក៏បានពោលពន្យល់មាណពទាំងនោះ ឲ្យមើលទៅនៅក្នុងតម្រាលក្ខណៈព្យាករណ៍

សាស្ត្រ ពួកអ្នកនឹងដឹងថា ព្រះមានព្រះភាគ មានលក្ខណៈប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ តាមដែលមានពោលទុកក្នុងមន្តទាំងឡាយយ៉ាងជាក់ច្បាស់ហើយ ។ បើព្រះអង្គនៅគ្រប់គ្រងផ្ទះ ព្រះអង្គនឹងបានជាស្តេចចក្រពត្តិ ជាអ្នកឈ្នះសត្រូវក្នុងទិសទាំងពួង ទ្រង់គ្រប់គ្រងប្រកបដោយធម៌ មិនប្រើអាជ្ញា និងអាវុធ ។ បើព្រះអង្គចេញទៅបួសវិញ នឹងបានសម្រេចជាព្រះសម្មាសម្ពុទ្ធ ទ្រង់ជាសាស្តាឯកក្នុងលោក ។ ប៉ុន្តែមួយទៀត បើចង់ដឹង ចូរនឹកទូលសួរបញ្ហាដោយចិត្ត ៣ ១. ព្រះមានព្រះភាគប្រាកដជាត្រាស់តបបញ្ហានោះ ដោយវាចាដ៏ស្រទន់ តាមដែលចិត្តនឹកគិតទូលសួរ ។ ពេលដែលពាវរីព្រាហ្មណ៍ពោលប្រាប់វិធីនេះដូច្នេះហើយ ទើបចងបញ្ហាឲ្យមាណពទាំង ១៦ នាក់នោះ ដែលបានចេញទៅស៊ើបមើលដំណឹងរកព្រះលោកនាយក កាលបើឃើញហើយ ចូរសួរបញ្ហានេះផង ។

បុណ្ណកមាណព ជាមាណពម្នាក់នៅក្នុងបណ្តាមាណពទាំង ១៦ នាក់នោះ ក៏បានឱកាសធ្វើដំណើររួមទៅស៊ើបមើល ឬទៅរកព្រះមុនី

កាលទៅដល់បាសាណកចេតិយ ក្នុងដែនមគធៈ និងបានជាអ្នកក្រាបទូលសួរបញ្ហាជាលំដាប់ទី ៣ បុណ្ណកៈ កាលបានទទួលពុទ្ធានុញ្ញាតហើយ ទើបបានក្រាបទូលសួរបញ្ហាថា

( បុណ្ណកមាណពដ៏មានអាយុទូលសួរថា ) ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយបញ្ហា ទើបមកសាកសួរព្រះអង្គ អ្នកមិនញាប់ញ័រ ទ្រង់ឃើញនូវធម៌ជាឫសគល់ ពួកមនុស្សជាច្រើនក្នុងលោកនេះ គឺឥសី ក្សត្រ ព្រាហ្មណ៍ អាស្រ័យនូវអ្វី ទើបរៀបចំនូវយញ្ញដល់ពួកទេវតា ខ្ញុំព្រះអង្គទូលសួរនូវដំណើរនោះ សូមព្រះអង្គត្រាស់ប្រាប់សេចក្ដីនោះដល់ខ្ញុំព្រះអង្គឲ្យទាន ។

( ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ) ម្នាលបុណ្ណកៈ ពួកមនុស្សទាំងនេះ ជាច្រើនក្នុងលោកនេះ គឺឥសី ក្សត្រ ព្រាហ្មណ៍បានរៀបចំនូវយញ្ញ ដល់ពួកទេវតា ម្នាលបុណ្ណកៈ ពួកមនុស្សទាំងនេះកាលប្រាថ្នានូវភាពនៃហេតុនេះៗ សុទ្ធតែអាស្រ័យនូវធម៌ ដែលទ្រុឌទ្រោម ទើបបានរៀបចំយញ្ញ ។

( បុណ្ណកមាណពដ៏មានអាយុទូលសួរថា ) ពួកមនុស្សជាំពូកខ្លះជាច្រើន ក្នុងលោកនេះ គឺឥសី ក្សត្រ ព្រាហ្មណ៍ បានរៀបចំនូវយញ្ញ ដល់ទេវតា បពិត្រព្រះអង្គនិទ្ទុក្ខ ពួកមនុស្សអម្បាលនោះ បើមិនប្រមាទ ( ក្នុងគន្លងនៃយញ្ញ ) តើបានឆ្លងផុតជាតិ និងជរាដែរឬ ខ្ញុំព្រះអង្គសូមទូលសួរដំណើរនោះ សូមព្រះអង្គត្រាស់ប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គឲ្យទាន ។

( ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ) ម្នាលបុណ្ណកៈ ពួកមនុស្សអម្បាលនោះ ប្រកបក្នុងការបូជា ត្រេកអរដោយអំណាចនៃភវរាគៈ ទើបប៉ុនប៉ង សរសើរ ( ជាប់ជំពាក់ ) បូជា ជ្រុលជ្រប់ក្នុងកាមព្រោះអាស្រ័យលាភ តថាគតពោលថា អ្នកបូជាយញ្ញអម្បាលនោះ មិនបានឆ្លងផុតជាតិ និងជរាទៅបានឡើយ ។

( បុណ្ណកមាណពដ៏មានអាយុទូលសួរថា ) បពិត្រព្រះអង្គនិទ្ទុក្ខ អ្នកបូជាយញ្ញទាំងនោះ ឆ្លងជាតិជរា ដោយយញ្ញទាំងឡាយមិនរួចទេ ដូច្នេះ តើនរណាក្នុងទេវលោក មនុស្សលោក ទើបឆ្លង

ជាតិ និងជរាទៅបាន បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទូលសួរដំណើរ នោះ សូមព្រះអង្គត្រាស់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គឲ្យទាន ?

( ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ) ម្នាលបុណ្ណកៈ បុគ្គលណាមិនមានកិលេសជាតគ្រឿងញាប់ញ័រ ក្នុងលោកណាមួយ ព្រោះពិចារណាឃើញនូវធម៌ដ៏ខ្ពស់ និងទាប ក្នុងលោក តថាគតពោលថា បុគ្គលនោះ ជាអ្នកស្ងប់ ប្រាសចាកផ្សែង គឺទុច្ចរិត មិនមានសេចក្តីតានតឹង មិនមានសេចក្តីប្រាថ្នា តែងឆ្លងជាតិ និងជរាផុតបាន ។

កាលបើព្រះមហាវីរៈ ទ្រង់ដោះស្រាយបញ្ហាទាំងនោះចប់ហើយ ទេវតា និងមនុស្សជាច្រើន បានសម្រេចនូវធម្មចក្ខុ ជាអ្នកមិនមាននូវមន្ទិល ហើយបានពិចារណាឃើញថា សភាវធម៌ណានីមួយ មានការកើតឡើងជាធម្មតា សភាវធម៌ទាំងនោះ ក៏មានការរលត់ទៅវិញជាធម្មតាដែរ ។ ចំណែកបុណ្ណកមាណព កាលបានសម្រេចជាព្រះអរហន្តហើយ គ្រឿងបរិក្ខាររបស់តាបស មានស្បែកខ្លាជាដើម បាន

បាត់ទៅអស់ បរិក្ខារទាំង ៨ របស់សមណៈ ក៏មកប្រាកដឡើងមួយរំពេចពេលនោះឯង ហើយឈរប្រណម្យដៃក្រាបទូលឡើងថា បពិត្រព្រះលោកនាថ ព្រះអង្គជាសាស្តារបស់ខ្ញុំព្រះអង្គ ចំណែកខ្ញុំព្រះអង្គវិញជាសាវករបស់ព្រះអង្គ ។ ការបព្វជ្ជាឧបសម្បទា របស់បុណ្ណក-មាណពកើតព្រមគ្នាជាមួយនឹងមាណព ១៥ នាក់ទៀត និងបរិវារទាំងអស់ គឺកាលព្រះមានជោគ ទ្រង់ត្រាស់ឆ្លើយសោឡសបញ្ហាចប់មាណពទាំងអស់គ្នាបានក្រាបទូលសូមបព្វជ្ជាឧបសម្បទា ក្នុងសម្នាក់របស់ព្រះអង្គ ហើយព្រះជិនស្រីទ្រង់ត្រាស់អនុញ្ញាត ឲ្យបព្វជ្ជាឧប-សម្បទាជាភិក្ខុ ដោយឯហិភិក្ខុឧបសម្បទា ។

ជីវប្រវត្តិរបស់ព្រះបុណ្ណកត្ថេរ ក្រោយពីលោកបានសម្រេចអរិយធម៌ថ្នាក់ខ្ពស់បំផុត ដោយលោកបានសម្រេចព្រះអរហន្តហើយលោកក៏បានពោលអំពីជីវប្រវត្តិអតីតជាតិរបស់ខ្លួនឯងផ្ទាល់ ដូចមានសម្តែងនៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ដូចមានសេចក្តីថា ៖

ព្រះពុទ្ធ ជាសយម្ភូ ទ្រង់ឈ្មះមារ គង់នៅក្នុងចន្លោះភ្នំ ដែលនៅអែបចុងញក ព្រះអង្គមានអាពាធ ក្នុងទីនោះ ។ កាលព្រះពុទ្ធអង្គ ស្តេចបរិនិព្វានហើយ សំឡេងគឹកកង កើតមានជុំវិញអាស្រមរបស់ខ្ញុំ ក្នុងខណៈនោះ ពន្លឺក៏កើតឡើងក្នុងវេលានោះដែរ ។ ពួកសត្វសាហាវទាំងពួង គឺខ្លាឃ្មុំ ឆ្កែព្រៃ ខ្លារខិន និងកេសររាជសីហ៍ ក្នុងដងព្រៃទាំងអម្បាលម៉ាន ក៏បន្លឺសំឡេងឡើង ក្នុងខណៈនោះដែរ ។ ខ្ញុំបានឃើញសេចក្តីអស្ចារ្យនុ៎ះកើតហើយ ក៏ចូលទៅកាន់ញកភ្នំ បានឃើញព្រះសម្ពុទ្ធ ទ្រង់ឈ្នះមារ ស្តេចបរិនិព្វានហើយ ត្រង់ញកភ្នំនោះ ។ ( លុះខ្ញុំឃើញ ) នូវព្រះសម្មាសម្ពុទ្ធ ទ្រង់ឈ្នះមារ ដែលបរិនិព្វានហើយ ទ្រង់ដូចជាសាលរាជព្រឹក្ស ដែលមានផ្ការីក ឬដូចជាព្រះអាទិត្យ ដែលទើបនឹងរះឡើង ពុំនោះសោត ដូចជារងើកភ្លើងដែលឥតមានអណ្តាត ។ ខ្ញុំបានធ្វើជើងថ្ករ បំពេញស្មៅ និងឧសក្នុងទីនោះ លុះខ្ញុំធ្វើជើងថ្ករដ៏វិចិត្ររួចហើយ ក៏បូជាសរីរសព ។ លុះខ្ញុំ

បូជាសរីរសេពរួចហើយ ក៏ស្រោចស្រពនូវទឹកអប់លើព្រះធាតុ ខណៈនោះ ទេវតា ដែលស្ថិតនៅឰដ៏អាកាស កាន់យកនូវឈ្មោះ ( ខ្ញុំ ) ថា អ្នកបំពេញកិច្ចនោះ ចំពោះព្រះសយម្ភូ ទ្រង់ស្វែងរកនូវគុណដ៏ធំហើយ អ្នកនៅក្នុងសម្នាក់នៃព្រះមុនី ក្នុងកាលណា អ្នកនឹងបានឈ្មោះថា បុណ្ណកៈ ក្នុងកាលនោះ ។ លុះខ្ញុំច្យុតចាកកាយនោះហើយ ក៏បានទៅកើតក្នុងទេវលោក ក្លិនជាទិព្វបង្អុរចុះពីអាកាស ត្រង់កន្លែងដែលខ្ញុំនៅនោះ ។ កាលនោះ ឈ្មោះរបស់ខ្ញុំថា បុណ្ណកៈ ក្នុងទីនោះ ខ្ញុំកើតជាទេវតា ឬជាមនុស្ស តែងបំពេញសេចក្តីបំណងបាន ។ នេះសរីរៈជាទីបំផុតរបស់ខ្ញុំ ភពជាទីបំផុត កំពុងប្រព្រឹត្តទៅ សូម្បីក្នុងអត្តភាពនេះ គង់អ្នកផងប្រកាសនាម ( របស់ខ្ញុំ ) ថា បុណ្ណកៈ ។ ខ្ញុំបានញុំាងព្រះពុទ្ធ ព្រះនាមគោតម ជាសក្យៈដ៏ប្រសើរ ឲ្យត្រេកអរ ខ្ញុំកំណត់ដឹងអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលនោះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំ

មិនដែលស្គាល់ទុគ្គតិឡើយ នេះជាផលនៃការបូជាសិរីសេពន៍ុះឯង ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំគាស់រំលើងចោលហើយ ជាអ្នកមិនមានអាសវៈ ដូចដំរីផ្តាច់ខ្សែទន្ទីង ។ ឱហ្ន៎ ! ដំណើរដែលខ្ញុំមក ក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ ទាំងសាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

រឿងក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** តាមដែលពោលរួចមកហើយនេះ ជារឿងដែលសម្តែងដល់ការកសាងបុណ្យបារមីក្នុងអតីត-ជាតិ និងបុណ្យបារមីមួយទៀត ដែលបានធ្វើរួមជាមួយនឹងមាណពដទៃទៀត ដូចមានសម្តែងទុកនៅក្នុង **អដ្ឋកថាបរមត្ថជោតិកា** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីក្នុង **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** ដែលបាននាំយកមកពោលរួចមកហើយ នៅក្នុងរឿងជីវប្រវត្តិរបស់

ព្រះអជិតត្ថេរទុំះឯង ។

ចំណែកផលបុណ្យរបស់ព្រះបុណ្ណកត្ថេរនេះ គង់នឹងប្រព្រឹត្ត ទៅដូចគ្នានឹងព្រះថេរៈរួមគណៈរបស់លោក ដែលថាបុណ្យដ៏សំខាន់ នោះ គឺបុណ្យដែលលោកជួយផ្សព្វផ្សាយសីលធម៌ ឲ្យដល់មហាជន ដោយទំនងបែបនេះជាប់តគ្នា រហូតដល់លោករំលត់ខន្ធបរិនិព្វាន ។

ឯការរំលត់ខន្ធបរិនិព្វានរបស់លោកវិញ ក៏មិនបានឃើញថា លោកបរិនិព្វាននៅក្នុងទីកន្លែងណាទីមួយនោះទេ ។៚

( ជីវប្រវត្តិរបស់ព្រះបុណ្ណកត្ថេរ ចប់ )

888888888888888888888888888888888888888888888

# ✍ ជីវប្រវត្តិរបស់ព្រះឧបសីវត្ថេរ ✍

## " លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័កផងដែរ "

*ព្រះឧបសីវត្ថេរ លោកជាអ្នកទ្រទ្រង់នៅក្នុងគុណ ផ្នែកខាងអសេក្ខធម៌ ជាព្រះអរហន្តសាវ័ក ដែលមានសមត្ថភាពល្អ ហើយក៏បានសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័កផងដែរ បានដល់សាវ័កធំរបស់ព្រះពុទ្ធជាម្ចាស់ ៨០ រូប លោកក៏ជាមាណពម្នាក់នៅក្នុងចំណោមមាណព ដែលមានកិត្តិយសដ៏ខ្ពង់ខ្ពស់ ១៦ នាក់ ដែលជាកូនសិស្សរបស់អាចារ្យពាវរីព្រាហ្មណ៍ ថែមទាំងជាអ្នកបានរៀនចប់មន្តទាំងឡាយ នៅក្នុងសម្នាក់របស់អាចារ្យពាវរី កាលដែលលោកចូលមកបួសជាភិក្ខុនៅក្នុងព្រះពុទ្ធសាសនានេះ ក៏បានជាកម្លាំងដ៏សំខាន់ ក្នុងការប្រកាសព្រះធម៌វិន័យនៃព្រះពុទ្ធសាសនា ឲ្យដល់មហាជនជាច្រើនបានយល់ដឹង ឲ្យបានទទួលប្រយោជន៍ និងសេចក្ដីសុខអស់កាលដ៏យូរ ។*

ជីវប្រវត្តិក្នុងបច្ចុប្បន្នជាតិរបស់ព្រះឧបសីវត្ថេរ មានសម្តែងប្រាកដនៅក្នុង **អដ្ឋកថាបរមត្ថជោតិកា** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីក្នុង **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** នៃ **បារាយនវគ្គ** និងក្នុង **គម្ពីរខុទ្ទកនិកាយ ចូឡនិទ្ទេស** តែក្នុងទីនេះ នឹងសូមនាំយកតែសាច់រឿងពីព្រះបាលី ដូចមានសេចក្តីថា ៖-

ព្រះឧបសីវៈ ជាបុត្ររបស់ព្រាហ្មណ៍ម្នាក់ នៅក្នុងក្រុងសាវត្ថី កាលចម្រើនវ័យធំដឹងក្តីឡើងហើយ បានចូលទៅថ្វាយខ្លួនជាសិស្សរបស់អាចារ្យពាវរីព្រាហ្មណ៍ ដើម្បីសុំការសិក្សាសិល្បវិជ្ជា ។ កាលដែលឧបសីវមាណព ស្ម័គ្រចិត្តព្រមធ្វើជាកូនសិស្ស របស់អាចារ្យពាវរីព្រាហ្មណ៍នោះ ពីព្រោះអាចារ្យពាវរីព្រាហ្មណ៍ ជាអ្នកចេះដឹងសព្វគ្រប់ក្នុងវិជ្ជាត្រៃវេទ និងមានលក្ខណៈពិសេសរបស់មហាបុរស ៣ ប្រការ ទាំងជាព្រះរាជបុរោហិតរបស់ព្រះបាទបសេនទិកោសលទៀតផង ។ កាលជាខាងក្រោយមក អាចារ្យពាវរីព្រាហ្មណ៍ក៏មានការនឿយណាយនៅក្នុងភាពជាយរាវាស ទើបក្រាបទូលលាព្រះបាទ

បសេនទិកោសលចេញទៅបួស ក៏បានតាំងអាស្រមនៅក្បែរឆ្នេរនៃស្ទឹងគោធាវារី ដែលជាព្រំដែននៃដែនអស្សកៈ និងដែនមូឡកៈ តាំងចិត្តបំពេញផ្នួស និងជាគណាចារ្យ បានបង្រៀនមន្តផ្សេងៗ ដល់កូនសិស្សទាំងឡាយ ។

ឧបសីវមាណព ព្រមដោយមាណពដែលជាកូនសិស្សដទៃៗ និងកូនសិស្សរបស់ខ្លួន ក៏បាននាំគ្នាចេញបួស ទៅតាមអាចារ្យពាវរីផងដែរ ។ កាលអាចារ្យពាវរីព្រាហ្មណ៍ ចូលទៅតាំងអាស្រមនៅទីកន្លែងនោះ ក្នុងក្រុង និងបរិវេណទាំងនោះ ក៏សម្បូរសប្បាយរុងរឿងឡើង ឯអាចារ្យពាវរីព្រាហ្មណ៍វិញ បានទទួលនូវអំណោយអំពីពពួកអ្នកស្រុកទាំងនោះ ហើយទើបបានយកទៅបរិច្ចាគទាន ជាប្រចាំរៀងរាល់ឆ្នាំ ។ ថ្ងៃមួយ អាចារ្យពាវរីព្រាហ្មណ៍បានបរិច្ចាគទានរួចហើយ ក៏ត្រឡប់មកកាន់អាស្រមវិញ គ្រានោះ មានព្រាហ្មណ៍ចាស់ជរាម្នាក់ មានខ្លួនប្រឡាក់ស្រមកដោយធូលី ដើរធ្វើញ័រៗ ចូលទៅរកអាចារ្យពាវរីព្រាហ្មណ៍ ហើយក៏បាននិយាយសុំទ្រព្យ ៥០០ កហាបណៈ ។

ចំណែកអាចារ្យពាវរីព្រាហ្មណ៍ កាលបើបានឃើញព្រាហ្មណ៍នោះមកហើយ ក៏អញ្ជើញឲ្យអង្គុយលើអាសនៈ រួចបានប្រាស្រ័យសាកសួរសុខទុក្ខ ហើយឆ្លើយប្រាប់ថា យើងអស់ទ្រព្យហើយ ពីព្រោះយើងបានបរិច្ចាគទានទើបតែរួចដែរ ។ ពេលនោះ ព្រាហ្មណ៍នោះក៏ខឹងឡើងទើបគិតក្លែងជារឿងបោកបញ្ឆោតគំរាមកំហែងឡើងថា បើអ្នកមិនឲ្យទ្រព្យដល់យើងទេ រយៈពេល ៧ ថ្ងៃទៀត ក្បាលរបស់លោកត្រូវបែកជា ៧ ភាគ ។ អាចារ្យពាវរីព្រាហ្មណ៍ បានស្តាប់ពាក្យរបស់ព្រាហ្មណ៍ចាស់នោះហើយ ក៏ភ័យខ្លាច រហូតដល់បរិភោគមិនបានសម្រាន្តមិនលក់ធ្វើឲ្យរាងកាយស្គាំងស្គម ។

គ្រានោះ មានទេវតាមួយអង្គ ជាអ្នកមានបំណងល្អក្នុងហេតុទាំងនោះ ទើបចូលទៅរកអាចារ្យពាវរីព្រាហ្មណ៍ ហើយពោលដាស់តឿនឲ្យមានសតិថា ព្រាហ្មណ៍ចាស់ជរានោះ ជាអ្នកពោលកុហកបោកបញ្ឆោតទេតើ គេមិនដឹងថា អ្វីជាក្បាល អ្វីជាធម៌ ដែលជាហេតុធ្វើឲ្យក្បាលបែកជា ៧ ភាគនោះទេ ។ ពេលនោះ អាចារ្យពាវរីត្រិះរិ

ះគិតថា ទេវតានេះគង់នឹងដឹងក្នុងរឿងនេះហើយ ទើបសួរឡើងថា អ្វីជាក្បាល អ្វីដែលជាធម៌ នាំឲ្យក្បាលដាច់ធ្លាក់ចុះ ?

លំដាប់នោះ ទេវតាឆ្លើយថា សូម្បីខ្ញុំក៏មិនដឹងថា អ្វីជាក្បាល អ្វីជាធម៌ ដែលជាហេតុធ្វើឲ្យក្បាលដាច់ធ្លាក់ចុះដូចគ្នាដែរ តែក្នុងរឿងនេះមានតែព្រះលោកវិទូទេ ទ្រង់ជាព្រះរាជឱរសរបស់សក្យរាជនៃរាជវង្សរបស់ព្រះបាទឱក្កាករាជ ព្រះអង្គប្រាកដជាជ្រាបក្នុងរឿងនេះហើយ តែឥឡូវនេះ ព្រះពុទ្ធអង្គទ្រង់គង់ប្រថាប់នៅក្នុងរាជវាំងនៃព្រះបាទបសេនទិកោសល នៅក្នុងក្រុងសាវត្ថីឯណោះ ។ អាចារ្យពាវរីបានឮដូច្នោះហើយ ក៏មានចិត្តរីករាយឡើងវិញ ក៏បានរំសាយភាពកើតទុក្ខទាំងនោះ ទើបបានហៅកូនសិស្ស ដែលសម្រេចមន្តមកប្រាប់ឲ្យដឹងថា ឥឡូវនេះ ព្រះមានជោគទ្រង់ជាអ្នកខ្ពង់ខ្ពស់បំផុត ជាងសព្វសត្វទាំងពួង ឥឡូវស្តេចឧប្បត្តិឡើងហើយក្នុងលោក ពួកអ្នកចូរទៅស៊ើបដំណឹងឲ្យដឹងការពិតមើល ។ ពួកកូនសិស្សទាំងនោះ សួរអាចារ្យពាវរីព្រាហ្មណ៍ថា បពិត្រលោកអាចារ្យ ពួកខ្ញុំនឹងដឹងថា ព្រះ

ពុទ្ធដោយឧបាយយ៉ាងណាទៅ ? អាចារ្យពាវរីព្រាហ្មណ៍ បានពោលពន្យល់មាណពទាំងនោះ ឲ្យមើលទៅនៅក្នុងតម្រាលក្ខណព្យាករណ៍សាស្ត្រ ពួកអ្នកនឹងដឹងថា ព្រះមានព្រះភាគ មានលក្ខណៈប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ តាមដែលមានពោលទុកនៅក្នុងមន្តទាំងឡាយយ៉ាងជាក់ច្បាស់ហើយ ។ បើព្រះអង្គនៅគ្រប់គ្រងផ្ទះ ព្រះអង្គនឹងបានជាស្តេចចក្រពត្តិ ជាអ្នកឈ្នះសត្រូវក្នុងទិសទាំងពួង ទ្រង់គ្រប់គ្រងប្រកបដោយធម៌ មិនប្រើអាជ្ញា និងអាវុធ ។ បើព្រះអង្គចេញទៅបួសវិញ នឹងបានសម្រេចជាព្រះសម្មាសម្ពុទ្ធ ទ្រង់ជាសាស្តាឯកក្នុងលោក ។ ប៉ុន្តែមួយទៀត បើចង់ដឹងចូរនឹកទូលសួរបញ្ហាដោយចិត្ត ៣ ខ ព្រះមានព្រះភាគប្រាកដជាត្រាស់តបបញ្ហានោះដោយព្រះវាចាដ៏ស្រទន់ តាមដែលចិត្តនឹកគិតទូលសួរហើយនោះ ។ ពេលដែលអាចារ្យពាវរីព្រាហ្មណ៍ ពោលប្រាប់វិធីយ៉ាងនេះ ដូច្នេះហើយ ទើបចងបញ្ហាឲ្យមាណពទាំង ១៦ នាក់នោះ ដែលបានចេញទៅស៊ើបដំណឹងរកព្រះលោកនាថ កាលបើឃើញហើយ ចូរអ្នកទាំង

អស់គ្នាសួរបញ្ហានេះផង ។

ឧបសីវមាណព ជាមាណពម្នាក់ ក្នុងចំណោមមាណព ១៦ នាក់នោះ បានធ្វើដំណើរទៅស៊ើបដំណឹងរកព្រះមានព្រះភាគ រហូតទៅដល់បាសាណកចេតិយ នៃដែនមគធៈ និងបានជាអ្នកក្រាបទូលសួរបញ្ហាជាលំដាប់ទី ៦ កាលឧបសីវៈបានទទួលពុទ្ធានុញ្ញាតហើយ ទើបក្រាបទូលសួរបញ្ហាឡើងដូច្នេះថា

( ឧបសីវមាណពដ៏មានអាយុ ទូលសួរថា ) បពិត្រព្រះអង្គជាសក្យពង្ស ខ្ញុំព្រះអង្គម្នាក់ឯង មិនអាស្រ័យ ( ធម៌ ឬបុគ្គល ) ទើបមិនអាចឆ្លងឱឃៈដ៏ធំបាន បពិត្រព្រះអង្គមានចក្ខុជុំវិញ សូមព្រះអង្គសម្តែងនូវអារម្មណ៍ គឺនិស្ស័យ ដែលនាំឲ្យខ្ញុំព្រះអង្គអាស្រ័យហើយឆ្លងឱឃៈនេះ ។

( ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ) ម្នាលឧបសីវៈ អ្នកចូរមានសតិសម្លឹងអាកិញ្ចញ្ញាយតនជ្ឈាន អាស្រ័យដោយបរិកម្មថា មិនមានៗ ហើយឆ្លងឱឃៈចុះ អ្នកចូរលះកាមទាំងឡាយ វៀរចាក

សេចក្តីសង្ស័យចេញ ចូរពិចារណាធម៌ ជាទីអស់ទៅនៃតណ្ហា ទាំងយប់ ទាំងថ្ងៃចុះ ។

( ឧបសីវមាណពដ៏មានអាយុ ទូលសួរថា ) អ្នកណាប្រាសចាកតម្រេក ក្នុងកាមទាំងឡាយទាំងពួង លះបង់ឈានដទៃ អាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ អ្នកនោះមិនសាបសូន្យ ស្ថិតនៅក្នុងអាកិញ្ចញ្ញាយតនៈនោះបានដែរឬ ?

( ព្រះមានព្រះភាគត្រាស់ថា ) ម្នាលឧបសីវៈ អ្នកណាប្រាសចាកតម្រេកក្នុងកាមទាំងឡាយទាំងពួង លះឈានដទៃ អាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ បុគ្គលនោះ ជាអ្នកមិនសាបសូន្យ គប្បីស្ថិតនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈានបាន ។

បពិត្រព្រះអង្គមានចក្ខុជុំវិញ បើអ្នកនោះជាអ្នកមិនសាបសូន្យ គប្បីស្ថិតនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះ អស់ប្រជុំនៃឆ្នាំជាច្រើន អ្នកនោះជាអ្នកមានចិត្តចុះស៊ប់ ត្រជាក់ ក្នុងអាកិញ្ចញ្ញាយតនជ្ឈាន

ឬវិញ្ញាណរបស់បុគ្គលមានសភាពដូច្នោះ គប្បីឃ្លាតទៅឬ ?

( ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ) ម្នាលឧបសីវៈ អណ្តាតភ្លើងដែលត្រូវកម្លាំងខ្យល់បក់ រមែងរលត់ទៅ មិនដល់នូវការរាប់ ( ថាទៅក្នុងទីណាទេ ) យ៉ាងណាមិញ មុនីរួចស្រឡះហើយចាកនាមកាយ រមែងរលត់ទៅ មិនដល់នូវការរាប់ ( ថាទៅក្នុងទីណា ) យ៉ាងនោះដែរ ។

បុគ្គលនោះរលត់ទៅ លែងមាន ឬថា ឥតមានមោះមៃ ដោយការតាំងនៅទៀងទាត់ សូមព្រះមុនីសម្តែងសេចក្តីនោះដល់ខ្ញុំព្រះអង្គ ព្រោះថា ធម៌នោះព្រះអង្គជាក់ច្បាស់ហើយ ។

( ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ) ម្នាលឧបសីវៈ បុគ្គលដែលរលត់ទៅហើយ នឹងប្រមាណពុំបានទេ ពួកជនពោលចំពោះបុគ្គលនោះ ព្រោះកិលេសណា កិលេសនោះរបស់បុគ្គលនោះមិនមានទេ កាលធម៌ទាំងឡាយ ដែលបុគ្គលនោះកម្ចាត់អស់ហើយ សូម្បីគន្លងនៃពាក្យទាំងអស់ ក៏បុគ្គលនោះកម្ចាត់អស់ហើយ ។

ក្នុងកាលចប់នៃព្រះគាថា ដែលជាព្រះពុទ្ធតម្រាស់ត្រាស់តបបញ្ហានោះហើយ ធម្មចក្ខុ បានដល់ ភ្នែក គឺបញ្ញាដែលឃើញធម៌ទៅតាមសេចក្ដីពិត បានកើតឡើងដល់មនុស្ស និងទេវតាជាច្រើន ដោយពិចារណាឃើញថា សភាវធម៌ណានីមួយមានការកើតឡើងជាធម្មតា សភាវធម៌នោះ ក៏មានការរលត់ទៅវិញជាធម្មតាដែរ មាណពទាំងអស់ដែលជាបរិវាររបស់ឧបសីវមាណព ដោយការបានអប់រំវាសនាបារមីមកដូចគ្នានឹងឧបសីវៈនោះ ក៏មានចិត្តរួចផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនមានការប្រកាន់មាំតទៅទៀត ។ ព្រមគ្នានឹងការបានសម្រេចជាព្រះអរហន្តនោះ បរិក្ខារទាំងអស់របស់តាបស ដែលមានស្បែកខ្លាជាដើម និងពុកមាត់ពុកចង្កា ក៏បានបាត់ទៅមួយរំពេចក្នុងពេលនោះឯង ។ ឧបសីវមាណព កាលមានភាវៈជាភិក្ខុហើយបានពោលឡើងថា បពិត្រព្រះលោកនាថ ព្រះអង្គជាសាស្ដា របស់ខ្ញុំព្រះអង្គ ចំណែកខ្ញុំព្រះអង្គវិញ ជាសាវករបស់ព្រះអង្គ ។ កាលព្រះមានព្រះភាគត្រាស់តបសោឡសបញ្ហាចប់ហើយ ឧបសីវមាណព

ព្រមដោយមាណព ១៥ នាក់ទៀត និងបរិវារទាំងអស់ បានក្រាបទូលសូមបព្វជ្ជាឧបសម្បទា នៅក្នុងព្រះពុទ្ធសាសនានេះ ព្រះបរមសាស្តាក៏ទ្រង់ត្រាស់អនុញ្ញាតឲ្យបព្វជ្ជាឧបសម្បទាជាភិក្ខុ ដោយវិធីឯហិភិក្ខុ-ឧបសម្បទាទៅ ។

ព្រះឧបសីវត្ថេរ កាលបានជាព្រះអរហន្តហើយ លោកក៏បានពោលតំណាលអំពីជីវប្រវត្តិរបស់ខ្លួនឯងទុក តាមដែលមានសម្តែងប្រាកដនៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ដូចមានសេចក្តីថា ៈ-

មានភ្នំមួយឈ្មោះអនោមៈ នៅជិតនឹងព្រៃហិមពាន្ត អាស្រមរបស់ខ្ញុំធ្វើល្អហើយ បណ្ណសាលា ខ្ញុំក៏បានកសាងល្អហើយដែរ ។ មានស្ទឹងមួយ មានកំពង់រាបល្អ គួរជាទីរីករាយនៃចិត្ត តែងហូរចុះទៅក្នុងទីនោះ មានឈូក និងឧប្បលជាច្រើន ដុះនៅតាមកំពង់ ជាលំដាប់ ។ ឯត្រីស្លាត ត្រីក្បក ត្រីក្រាញ់ ត្រីសណ្តាយ ត្រីឆ្តិន ( មានក្នុងកំពង់នោះ ) ទឹកស្ទឹងដ៏ជ្រៅច្រើនដោយត្រី និងអណ្តើក ក៏រមែងហូរទៅក្នុងកាលនោះ ។ ក្នុងទីនោះ មានតិមិរព្រឹក្ស មានផ្ការីក ដើមអសោកមាន

ផ្កាតូចៗ ទាំងក្រុបធ្នារ និងក្រុបក្លា ទោរទៅកាន់អាស្រមរបស់ខ្ញុំ ។ ក្នុងទីនោះ មានដើមខ្វែងគង់ និងព្រៃម្ទិះរូត មានផ្ការីក ដើមរាំង ដើមស្រល់ និងដើមចម្ប៉ាជាច្រើន មានផ្ការីក ក្នុងទីនោះដែរ ។ ដើមអង្គ្រែង ដើមរំដួល ដើមចម្បក់ ដើមធ្នង់ និងដើមចេកទុំ មានផ្ការីក ពួកឈើទាំងនោះសុទ្ធតែមានផ្ការីកហើយ នៅជិតអាស្រមរបស់ខ្ញុំ ។ ដើមរាជព្រឹក្សដើមប្រទៀង ដើមយុត្កា និងដើមប្រយង្គុ ស្អឹកដ៏ដេរដាសដោយវល្លិ៍បាសអស់កន្ទះយោជន៍ជុំវិញ ។ ដើមមាតករព្រឹក្ស ម្ទិះរូត ប្រទៀង ឈើក្លើងអង្កោល និងតាលកុជព្រឹក្ស ជាច្រើនក្នុងទីនោះ សុទ្ធតែជាឈើ មានផ្ការីក ។ ស្មៅក្រវាញជ្រុកជាច្រើន សុទ្ធតែជាស្មៅ មានផ្ការីក ក្បែរអាស្រមរបស់ខ្ញុំនោះ បណ្តាឈើមានផ្ការីកទាំងនោះ ពួកឈើច្រើនសុទ្ធតែល្អៗ ។ ដើមសម៉ កន្ទួតព្រៃ ស្វាយ ព្រីង និងសម៉ពិភេទក៍ផ្សាយក្លិននោះ ជុំវិញអាស្រមខ្ញុំ ។ ដើមពុទ្រា ដើមរាក់ខ្មៅ ដើមញ៉ៅដើមម៉ាក់ ប្រាង ទន្ទាប់ ទ្រយឹង ស្រគាំ ពង្រ ។ ដើមខ្នុរសម្ង ខ្នុរណាំងចេក ដើមច័ន ក៏មានក្នុងទីនោះ ដើមម្កាក់ និងដើមគុយ ក៏មានច្រើន

ក្នុងទីនោះដែរ ។ ដើមគូលេន អាលកព្រឹក្ស និងសណ្តែកព្រៃ សុទ្ធតែជាឈើមានផ្លែ នៅជិតអាស្រមរបស់ខ្ញុំ តពីនោះទៅ មានផ្លែសាវម៉ាវជាច្រើន ។ អវជព្រឹក្សពេញដោយផ្លែទុំ ដើមមិលក្ខុព្រឹក្ស ដើមឧទុម្ពរជាច្រើន ខ្លះផ្លែទុំ ខ្លះផ្លែខ្ចី ដើមឈើក្រៅអំពីនេះជាច្រើន សុទ្ធតែជាឈើមានផ្លែ ជិតអាស្រមរបស់ខ្ញុំ ។ សូម្បីឈើមានផ្កាជាច្រើន គឺដើមកន្ទួំ ដើមកុម្ភ និងដើមពុកឆ្មា មានផ្ការីក នៅជិតអាស្រមរបស់ខ្ញុំ ។ អាលកព្រឹក្ស និងតាលកព្រឹក្ស មាននៅជិតអាស្រមរបស់ខ្ញុំ មានជាតស្រះធំមួយ នៅជិតអាស្រមរបស់ខ្ញុំ ។ ស្រះនោះ មានទឹកថ្លា មានទឹកត្រជាក់ មានកំពង់ល្អ គួរជាទីរីករាយនៃចិត្ត មានទាំងឈូកក្រហម និងឧប្បលជាច្រើន លាយចម្រុះដោយឈូកស នៅក្នុងស្រះនោះ ទាំងដេរជាសដោយព្រលិតសាយកាយ ដោយក្លិនផ្សេងៗ ដើមឈូកកំពុងចាប់ផ្លែ (ក្រពុំ) ពួកដើមកេសរ ឯទៀតៗ កំពុងរីក ផ្កាឈូក និងផ្កាកណិការជាច្រើន មានត្របកផ្កា សំយុងចុះក្រោម មានទឹកហូរចេញអំពីក្រអៅឈូក ផ្អែមដូចទឹកឃ្មុំ មានទឹកហូរចេញអំពីមើមឈូក ឆ្ងាញ់ដូចទឹក

ដោះស្រស់ និងទឹក ដោះថ្លា ផ្កាកុមុទ ស្វាយក្រអូប ផ្កានយិតាព្រឹក្ស ជាច្រើន ប្រកបដោយក្លិនផ្សេងៗ រមែងប្រាកដដោយក្លិននោះជុំវិញ ។ ធ្លេរជាតស្រះ មានដើមកាកេតជាច្រើន មានផ្ការីក ដើមកុលាបមាន ផ្កាល្អ ឈូកស មានក្លិនក្រអូប ។ ក្រពើ ក្រពាជាសត្វចាប់គេស៊ី ក៏កើតនៅក្នុងស្រះនោះ ពស់ថ្លាន់ ជាសត្វរបរិតក៏មានច្រើន ក្នុងស្រះ នោះដែរ ។ មានត្រីស្វាត ត្រីក្បក ត្រីក្រាញ់ ត្រីសណ្តាយ និងត្រីឆ្ពិន ដ៏ជេរជាសដោយត្រី និងអណ្តើក ដោយកន្ទេនដែលធ្លាប់អាស្រ័យនៅ ។ ព្រាប ប្រវឹក ខ្វែក ក្អែកទឹក ត្រដេវវិច ចាក្រពាក ចង្អៀលខ្យង ព្រហីត ។ មានពួកសត្វកង្កែន លលក ខ្វែង ជាសត្វហើរដ៏ច្រើន ក្អែចចក កូនសេក ក្តាន់ ទ្រាយ ជាច្រើន ។ ពួកម្រឹគ គឺកាសេនិយម្រឹគ និងតិលកម្រឹគ សីហៈ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ឆ្កែព្រៃ ខ្លាត្រី ចូលទៅ អាស្រ័យទីងស្រះនោះ ។ ពួកស្វា ពួកកិន្នរ ក៏ប្រាកដជិតអាស្រមរបស់ ខ្ញុំ ខ្ញុំស្រង់ទឹកនៅក្នុងស្រះនោះ ហើយបរិភោគផ្លែឈើទាំងឡាយ ។ ខ្ញុំផឹកទឹកក្រអូប នៅក្នុងអាស្រមរបស់ខ្ញុំ មានម្រឹគទ្រាយ ជ្រូក ប្រើស

និងពួកសត្វមានរូបតូចៗ ។ភ្លើងមានពន្លឺដ៏រុងរឿង នៅជិតអាស្រមរបស់ខ្ញុំ ពួកសត្វហង្ស ក្រៀល ក្ងោក និងតាវ៉ៅ ជាសត្វមានប្រយោជន៍តែងអាស្រ័យនៅក្បែរអាស្រមរបស់ខ្ញុំដែរ ។ ក្នុងទីនេះ មានធ្មា ខ្លែងស្រាក កេងកង ជាច្រើន និងបិសាច អសុរ កុម្ភណ្ឌ និងអារក្ស ជាច្រើន ។ ពួកគ្រុឌ នាគ និងពួកឥសីមានអានុភាពច្រើន មានចិត្តស្ងប់តម្កល់មាំ នៅជិតអាស្រមរបស់ខ្ញុំ ។ពួកឥសីទាំងអស់ ទ្រទ្រង់នូវកន្ទីទឹកស្មៀក សំពត់ស្បែកខ្លា ពេញដោយភារៈគឺផ្នួងសក់ នៅជិតអាស្រមរបស់ខ្ញុំ ។ ពួកឥសីទាំងនោះ ក្រឡេកមើលប្រមាណមួយជួរនឹម ជាបុគ្គលមានប្រាជ្ញា មានកិរិយាប្រព្រឹត្តស្ងប់ជាប្រក្រតី ជាអ្នកត្រេកអរតាមមានតាមបាន នៅជិតអាស្រមរបស់ខ្ញុំ ។ពួកឥសីទាំងនោះរលាស់សំពត់សម្បកឈើ ដណ្តប់នូវស្បែកខ្លា ជាអ្នករឹងប៉ឹងដោយកម្លាំងរបស់ខ្លួន ទៅឰដ៏អាកាស ក្នុងកាលនោះ ។ ពួកឥសីទាំងនោះ នាំមកនូវទឹកថ្មីៗ ឈើ និងឱសថចូលទៅប្រកបដោយខ្លួនឯង នេះជាផលនៃសប្បាដិហារិយៈ ។ពួកឥសីទាំងនោះកាន់យកស្នូកលោបជាតិ នៅក្នុងកណ្តាលព្រៃ

ដូចជាដំរីដ៏ប្រសើរ ឬដូចជាកេសររាជសីហ៍ មិនមានសេចក្ដីតក់ស្លុតឡើយ ។ ពួកឥសីខ្លះទៅកាន់អមរគោយានទ្វីប ខ្លះទៅកាន់បុព្វវិទេហទ្វីប ខ្លះទៅកាន់ឧត្តរកុរុទ្វីប ដោយមិនអើពើនឹងសំពត់កម្ពលរបស់ខ្លួន ។ ពួកឥសីទាំងនោះ នាំយកបិណ្ឌបាតអំពីទ្វីបនោះៗ មកឆាន់ជាមួយគ្នា កាលបើពួកឥសីទាំងអស់ មានតេជះដ៏ខ្ពង់ខ្ពស់ ប្រកបដោយតាទិគុណ ចៀសចេញទៅហើយ ព្រៃក៏លាន់ឮកងរំពងឡើង ដោយសំឡេងនៃស្បែកខ្លា ក្នុងកាលនោះ ។ បពិត្រព្រះអង្គមានព្យាយាមធំ ពួកសិស្សរបស់ខ្ញុំទាំងនោះ ប្រាកដបែបនេះ សុទ្ធតែជាអ្នកមានតបៈដ៏ខ្ពង់ខ្ពស់ ខ្ញុំមានពួកសិស្សទាំងនោះ ចោមរោមហើយ នៅក្នុងអាស្រមរបស់ខ្ញុំ ។ ពួកសិស្សទាំងនោះដែលមកប្រជុំគ្នា ជាអ្នកត្រេកអរដោយកុសលកម្មរបស់ខ្លួន មានខ្លួនទូន្មានហើយ ជាអ្នកមានសេចក្ដីប្រាថ្នា ចំពោះកុសលកម្មរបស់ខ្លួន មានសីល មានប្រាជ្ញាចាស់ ជាអ្នកឈ្លាសវៃ ក្នុងអប្បមញ្ញាទាំងឡាយ ធ្វើឲ្យខ្ញុំរីករាយ ។ ព្រះសម្មាសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ព្រះអង្គជ្រាបច្បាស់ត្រៃលោក គួរទទួលនូវគ្រឿងបូជា ជាអ្នកដឹកនាំ

សត្វលោក មានព្យាយាម មានប្រាជ្ញាចាស់ ជាអ្នកប្រាជ្ញ ទ្រង់ប្រាប ច្បាស់នូវសម័យ ស្តេចយាងចូលមកជិត ព្រះសម្ពុទ្ធ ទ្រង់កាន់បាត្រ ស្តេចចូលមកដើម្បីភិក្ខា ។ ( ខ្ញុំបានឃើញ ) នូវព្រះសម្ពុទ្ធ ព្រះនាម បទុមុត្តរៈ មានព្យាយាមធំ ទ្រង់ស្តេចចូលមកហើយ ក៏ក្រាលកម្រាល ស្មៅ ហើយរោយរាយដោយផ្កាឈើ ។ ខ្ញុំមានចិត្តរំភើប មិនអាចតាំង នៅបាន ក៏និមន្តព្រះសម្ពុទ្ធឲ្យគង់ ហើយឡើងភ្នំយ៉ាងឆាប់ កាន់យកនូវ ខ្ទឹមក្រស្នា ។ ខ្ញុំបានបេះយកផ្លែខ្នុរប៉ុនឆ្នាំង មានក្លិនក្រអូប ជាទីរីករាយ នៃទេវតា ហើយលើកលីនាំចូលទៅថ្វាយព្រះលោកនាយក ។លុះខ្ញុំថ្វាយ ផ្លែខ្នុរចំពោះព្រះពុទ្ធរួចហើយ លាបនូវខ្ទឹមក្រស្នា ខ្ញុំមានចិត្តជ្រះថ្លា មាន ចិត្តរីករាយ បានថ្វាយបង្គំព្រះពុទ្ធដ៏ប្រសើរ ។ព្រះសម្មាសម្ពុទ្ធ ព្រះនាម បទុមុត្តរៈព្រះពុទ្ធអង្គជ្រាបច្បាស់នូវត្រៃលោកគួរទទួលនូវគ្រឿងបូជា ទ្រង់គង់ក្នុងកណ្តាលពួកឥសី ហើយត្រាស់គាថាទាំងនេះថា ។

បុគ្គលណាបានឲ្យផ្លែខ្នុរ ខ្ទឹមក្រស្នា និងអាសនៈ ដល់តថាគតៗ នឹងសរសើរបុគ្គលនោះ អ្នកទាំងឡាយចូរស្តាប់ តថាគតនឹងសម្តែង

ដូចតទៅនេះ បុគ្គលនេះកាលនៅក្នុងស្រុកក្តី ក្នុងព្រៃក្តី ក្នុងញកភ្នំក្តី ក្នុងគុហាក្តី ភោជននឹងកើតឡើង ព្រោះដឹងចិត្តរបស់បុគ្គលនេះ នរៈនេះ បើទៅកើតក្នុងទេវលោក ឬមនុស្សលោក នឹងឆ្អែតស្កប់ស្កល់ ដោយភោជនផង ដោយសំពត់ផង នរៈនេះ បើអន្ទោលទៅកាន់កំណើតណា ទោះជាទេវតា ឬជាមនុស្ស នឹងជាអ្នកមានភោគៈ មិនរំកើបញាប់ញ័រ ។ នឹងត្រេកអរក្នុងទេវលោក អស់ ៣ ម៉ឺនកប្ប នឹងបានជាស្តេចចក្រពត្តិ ១០០០ ដង ។ នឹងបានសោយរាជ្យជាស្តេចទេវតា ៧១ ដង នឹងបានសោយប្រទេសរាជដ៏ធំទូលាយរាប់បានមួយអសង្ខេយ្យកប្បកន្លងទៅមួយសែនកប្ប នឹងមានព្រះសាស្តា ព្រះនាមគោតម កើតក្នុងត្រកូលព្រះបាទឱក្កាករាជ ត្រាស់ដឹងនៅក្នុងលោក នរៈនេះនឹងបានទទួលមរតិកក្នុងធម៌របស់ព្រះពុទ្ធនោះ ជាឱរសដែលធម៌និម្មិតហើយ មាននាមថាឧបសីវៈ នឹងបានជាសាវកនៃព្រះសាស្តា នរៈនេះនឹងមិនមានអាសវៈ ព្រោះកំណត់ដឹងអាសវៈទាំងពួង ។

លាភដែលត្រូវបានដោយល្អ ខ្ញុំបានហើយ ព្រោះខ្ញុំបានជួបនឹង

ព្រះលោកនាថ ។ វិជ្ជា ៣ ខ្ញុំបានដល់ហើយ ដោយលំដាប់សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើរួចហើយ ។ ខ្ញុំ ( កាលទៅ ) ក្នុងស្រុកក្តី ក្នុងព្រៃក្តី ក្នុងញកភ្នំក្តី ក្នុងគុហាក្តី ភោជនរមែងកើតឡើងដល់ខ្ញុំ ព្រោះដឹងនូវសេចក្តីត្រេះរិះរបស់ខ្ញុំ ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង ។ ឱហ្ន៎ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ ដោយលំដាប់ ទាំងសាសនារបស់ព្រះសម្ពុទ្ធ ខ្ញុំក៏បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

មួយទៀតការសន្សំបុណ្យបារមីរបស់ព្រះឧបសីវត្ថេរ ដែលបានធ្វើរួមជាមួយនឹងអាចារ្យពាវរី និងមាណពដទៃទៀតនោះ តាមដែលបានពោលរួចមកហើយ នៅក្នុងជីវប្រវត្តិរបស់ព្រះអជិតត្ថេរ ។

ព្រះឧបសីវត្ថេរ លោកទ្រទ្រង់អាយុសង្ខារ មកដល់កាលដ៏សម

គួរហើយ លោកក៏បានរំលត់ខន្ធបរិនិព្វានទៅហោង ។

ការបរិនិព្វានរបស់លោក មិនឃើញមានសម្តែងទុកក្នុង **គម្ពីរ** ណាថា លោកបរិនិព្វានក្នុងទីណា ឬកន្លែងណានីមួយឡើយ ៕៚

( ជីវប្រវត្តិរបស់ព្រះឧបសីវត្ថេរ ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះនន្ទកត្ថេរ ✍

**“ លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័កផងដែរ ”**

ព្រះនន្ទកត្ថេរ ជាព្រះអរិយមហាថេរៈ ដែលជាអ្នកទ្រទ្រង់នូវអរិយគុណ គឺព្រះអរហត្តផល លោកក៏បានចាត់ចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័ក ដែលជាបុគ្គលបានសន្សំបុណ្យបារមីរួចមកហើយ លោកក៏ជាកូនសិស្សរបស់អាចារ្យពាវរីព្រាហ្មណ៍ ជាអ្នករៀនចប់វិជ្ជាត្រៃវេទក្នុងលទ្ធិព្រាហ្មណ៍ និងជាអ្នកនាំបញ្ហាមកក្រាបទូលសួរព្រះលោកនាយក ដើម្បីពិសោធការពិតថា ព្រះពុទ្ធអង្គជាព្រះពុទ្ធមែន ឬក៏មិនមែន ។

ជីវប្រវត្តិក្នុងបច្ចុប្បន្នជាតិ របស់ព្រះនន្ទកត្ថេរ មានសម្ដែងប្រាកដនៅក្នុង **អដ្ឋកថាបរមត្ថជោតិកា** ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីនៃព្រះបាលីក្នុង **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** នៃ **បារាយនវគ្គ** និងក្នុង **គម្ពីរខុទ្ទកនិកាយ ចូឡនិទ្ទេស** តែក្នុងទីនេះនឹងសូមនាំយក

សាច់រឿងពីព្រះបាលីមក ដូចមានសេចក្តីថា ៖-

ព្រះនន្ទកៈ ជាបុត្ររបស់ព្រាហ្មណ៍ម្នាក់ នៅក្នុងក្រុងសាវត្ថី កាលចម្រើនវ័យធំដឹងក្តីឡើងហើយ បានចូលទៅថ្វាយខ្លួនជាសិស្ស របស់អាចារ្យពាវរីព្រាហ្មណ៍ ដើម្បីសូមការសិក្សាសិល្បវិជ្ជា ។ កាលដែលនន្ទកមាណពស្ម័គ្រចិត្តព្រមធ្វើជាកូនសិស្ស របស់អាចារ្យពាវរីនោះ ពីព្រោះអាចារ្យពាវរីជាអ្នកចេះសព្វគ្រប់ ក្នុងវិជ្ជាត្រៃវេទ ជាពិសេសនោះ ក្នុងរាងកាយរបស់អាចារ្យពាវរី មានលក្ខណៈវិសេសរបស់មហាបុរស ៣ ប្រការ និងជាព្រះរាជបុរោហិត របស់ព្រះបាទបសេនទិកោសលទៀតផង ។

កាលជាខាងក្រោយមក អាចារ្យពាវរី ក៏មានការនឿយណាយនៅក្នុងភាពជាឃរាវាស ទើបក្រាបទូលលាព្រះបាទបសេនទិកោសលចេញទៅបួស ក៏បានតាំងអាស្រមនៅក្បែរឆ្នេរនៃស្ទឹងគោធាវារី ដែលជាព្រំដែននៃដែនអស្សកៈ និងដែនមូឡកៈតាំងចិត្តបំពេញផ្នួស និងជាគណាចារ្យ បានបង្រៀនមន្តផ្សេងៗ ដល់កូនសិស្សទាំងឡាយ ។

នន្ទកមាណព ព្រមដោយមាណព ដែលជាកូនសិស្សដទៃៗ និងកូនសិស្សរបស់ខ្លួន ក៏បាននាំគ្នាចេញបួសតាមអាចារ្យពាវរីដែរ ។ កាលអាចារ្យពាវរីព្រាហ្មណ៍ ចូលទៅតាំងអាស្រមនៅទីកន្លែងនោះ ក្នុងស្រុក និងបរិវេណទាំងនោះ ក៏សម្បូរសប្បាយរុងរឿងឡើង ឯអាចារ្យពាវរីវិញ បានទទួលអំណោយអំពីពពួកអ្នកស្រុកទាំងនោះ ហើយក៏បានយកទៅបរិច្ចាគទាន ជាប្រចាំរៀងរាល់ឆ្នាំ ។ ថ្ងៃមួយ អាចារ្យពាវរីបានបរិច្ចាគទានរួចហើយ ក៏ត្រឡប់មកកាន់អាស្រមវិញ គ្រានោះ មានព្រាហ្មណ៍ចាស់ជរាម្នាក់ មានខ្លួនប្រឡាក់ស្រមកដោយធូលី ដើរធ្ញើញ័រៗ ចូលទៅរកអាចារ្យពាវរី ហើយក៏និយាយសុំទ្រព្យ ៥០០ កហាបណៈ ។ ចំណែកអាចារ្យពាវរីព្រាហ្មណ៍ កាលបើបានឃើញព្រាហ្មណ៍នោះមកហើយ អញ្ជើញឲ្យអង្គុយលើអាសនៈ រួចក៏បានប្រាស្រ័យសាកសួរសុខទុក្ខ ហើយឆ្លើយប្រាប់ថា យើងអស់ទ្រព្យហើយ ពីព្រោះយើងបានបរិច្ចាគទានទើបតែរួចដែរ ។ ពេលនោះ ព្រាហ្មណ៍នោះក៏ខឹងឡើង ទើបគិតក្លែងជារឿងបោកបញ្ឆោត

គំរាមកំហែងឡើងថា បើអ្នកមិនឲ្យទ្រព្យដល់យើងទេ រយៈពេល ៧ ថ្ងៃទៀត ក្បាលរបស់អ្នកត្រូវបែកជា ៧ភាគ ។ អាចារ្យពាវរីបាន ស្ដាប់ឮពាក្យរបស់ព្រាហ្មណ៍ចាស់នោះហើយ ភ័យខ្លាច រហូតដល់ បរិភោគមិនបាន សម្រាន្តមិនលក់ ធ្វើឲ្យរាងកាយស្គាំងស្គម ។

គ្រានោះ មានទេវតាមួយអង្គ ជាអ្នកមានបំណងល្អក្នុងហេតុ ទាំងនោះ ទើបចូលទៅរកអាចារ្យពាវរីព្រាហ្មណ៍ ហើយពោលដាស់ តឿនឲ្យមានសតិថា ព្រាហ្មណ៍ចាស់ជរានោះ ជាអ្នកពោលកុហក បោកបញ្ឆោតទេតើ គេមិនដឹងថា អ្វីជាក្បាល អ្វីជាធម៌ ដែលជាហេតុ ធ្វើឲ្យក្បាលបែកជា ៧ ភាគនោះទេ ។ គ្រានោះ អាចារ្យពាវរីត្រិះរិះ គិតថា ទេវតានេះគង់នឹងដឹង ក្នុងរឿងនេះហើយ ទើបសួរឡើងថា អ្វីជាក្បាល អ្វីដែលជាធម៌ នាំឲ្យក្បាលដាច់ធ្លាក់ចុះ ?

លំដាប់នោះ ទេវតាឆ្លើយថា សូម្បីខ្ញុំក៏មិនដឹងថា អ្វីជាក្បាល អ្វីជាធម៌ ដែលជាហេតុធ្វើឲ្យក្បាលដាច់ធ្លាក់ចុះដូចគ្នាដែរ តែក្នុងរឿង នេះ មានតែព្រះលោកវិទូទេ ទ្រង់ជាព្រះរាជឱរសរបស់សក្យរាជនៃ

រាជវង្សរបស់ព្រះបាទឱក្កាករាជ ព្រះអង្គប្រាកដជាជ្រាបក្នុងរឿងនេះហើយ តែឥឡូវនេះ ព្រះមានព្រះភាគទ្រង់គង់ប្រថាប់នៅក្នុងរាជវាំងនៃព្រះបាទបសេនទិកោសល ក្នុងក្រុងសាវត្ថីឯណោះ ។ អាចារ្យពាវរីព្រាហ្មណ៍បានឮដូច្នោះហើយក៏មានចិត្តរីករាយឡើងវិញ បានរំសាយភាពកើតទុក្ខទាំងនោះ ទើបបានហៅកូនសិស្សដែលសម្រេចមន្តមកប្រាប់ឲ្យដឹងថា ឥឡូវនេះ ព្រះសម្ពុទ្ធទ្រង់ជាអ្នកខ្ពង់ខ្ពស់បំផុតជាងសព្វសត្វទាំងពួង ឥឡូវស្ដេចឧប្បត្តិឡើងហើយក្នុងលោក ពួកអ្នកចូរទៅស៊ើបដំណឹង ឲ្យបានដឹងមើល ។ ពួកកូនសិស្សទាំងនោះ សួរអាចារ្យពាវរីព្រាហ្មណ៍ថា បពិត្រលោកអាចារ្យ ពួកខ្ញុំនឹងដឹងថា ព្រះពុទ្ធដោយឧបាយយ៉ាងណាទៅ ។ អាចារ្យពាវរីព្រាហ្មណ៍ក៏បានពោលពន្យល់មាណពទាំងនោះ ឲ្យមើលទៅនៅក្នុងតម្រាលក្ខណព្យាករណ៍សាស្ត្រ ពួកអ្នកនឹងដឹងថា ព្រះមានជោគ មានលក្ខណៈប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ តាមដែលមានពោលទុកក្នុងមន្តទាំងឡាយយ៉ាងជាក់ច្បាស់ហើយ ។ បើព្រះអង្គនៅគ្រប់គ្រងផ្ទះ ព្រះអង្គ

នឹងបានជាស្តេចចក្រពត្តិ ជាអ្នកឈ្នះសត្រូវក្នុងទិសទាំងពួង ទ្រង់គ្រប់គ្រងប្រកបដោយធម៌ មិនប្រើអាជ្ញា និងអាវុធ ។ បើព្រះអង្គចេញទៅបួសវិញ នឹងបានសម្រេចជាព្រះសម្មាសម្ពុទ្ធ ទ្រង់ជាសាស្តាឯកក្នុងលោក ។ ប៉ុន្តែមួយទៀត បើចង់ដឹង ចូរនឹកទូលសួរនូវបញ្ហាដោយចិត្ត ៣ ខ ព្រះអង្គប្រាកដជាត្រាស់តបបញ្ហានោះ ដោយព្រះវាចាដ៏ស្រទន់តាមដែលចិត្តនឹកគិតទូលសួររបស់ពួកអ្នក ។ ពេលដែលអាចារ្យពាវរីព្រាហ្មណ៍ ពោលប្រាប់វិធីនេះ ដូច្នេះហើយ ទើបចងបញ្ហាឲ្យមាណពទាំង ១៦ នាក់នោះ ដែលបានចេញទៅស៊ើបមើលដំណឹងរកព្រះពុទ្ធកាលបើឃើញហើយ ចូរសួរនូវបញ្ហានេះផង ។

នន្ទកមាណព ជាមាណពម្នាក់ ក្នុងចំណោមមាណព ១៦ នាក់នោះ បានធ្វើដំណើរទៅស៊ើបមើលដំណឹងព្រះមានព្រះភាគ រហូតទៅដល់បាសាណកចេតិយ នៃដែនមគធៈ និងបានជាអ្នកក្រាបទូលសួរបញ្ហាជាលំដាប់ទី ៧ កាលនន្ទកៈ បានទទួលពុទ្ធានុញ្ញាតហើយ ទើបក្រាបទូលសួរបញ្ហាឡើងថា

( នន្ទកមាណពដ៏មានអាយុ ទូលសួរថា ) ជនទាំងឡាយតែងពោលថា ពួកមុនី រមែងមាននៅក្នុងលោក ដំណើរនោះតើយ៉ាងណា ជនទាំងនោះ ហៅបុគ្គលដែលប្រកបដោយញាណថា មុនី ឬហៅបុគ្គលដែលប្រកបដោយការចិញ្ចឹមជីវិត ថាជាមុនី ?

( ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ) ម្នាលនន្ទកៈ ពួកជនអ្នកឈ្លាសវៃ ក្នុងលោកនេះ មិនហៅថា មុនី ព្រោះការឃើញ ព្រោះការស្តាប់ ព្រោះការដឹង ឬព្រោះសីល និងវត្ត តែប៉ុណ្ណោះទេ ជនទាំងឡាយណា ធ្វើខ្លួនឲ្យប្រាសចាកមារសេនា ជាអ្នកមិនតានតឹង មិនមានសេចក្តីប្រាថ្នា តថាគតហៅជនទាំងនោះថា មុនី ។

( នន្ទកមាណពដ៏មានអាយុទូលសួរថា ) សមណព្រាហ្មណ៍ពួកខ្លះទាំងនេះ តែងពោលសេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញខ្លះ ដែលស្តាប់ខ្លះ ពោលសេចក្តីបរិសុទ្ធ ព្រោះសីលវត្តខ្លះ ពោលសេចក្តីបរិសុទ្ធ ព្រោះវិធីច្រើនយ៉ាងខ្លះ ។ ( ព្រះសម្ពុទ្ធ ) អ្នកនិរទុក្ខ ពួកសមណព្រាហ្មណ៍ទាំងនោះ កាលបើប្រព្រឹត្តក្នុងវត្ត

ដែលឃើញថា ជាគ្រឿងបរិសុទ្ធនោះ តើបានឆ្លងជាតិ និងជរាបាន ដែរឬ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមសួរព្រះអង្គ សូមព្រះអង្គសម្តែងប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ?

( ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ) ម្នាលនន្ទកៈ សមណព្រាហ្មណ៍ទាំងឡាយពួកខ្លះទាំងនេះពោលថា សេចក្តីបរិសុទ្ធ ព្រោះអារម្មណ៍ដែលឃើញ និងអារម្មណ៍ដែលស្តាប់ខ្លះ ពោលថា សេចក្តីបរិសុទ្ធព្រោះសីល និងវត្តខ្លះ ពោលថាសេចក្តីបរិសុទ្ធ ព្រោះវិធីជាច្រើនយ៉ាងខ្លះ សមណព្រាហ្មណ៍ទាំងនោះ រមែងប្រព្រឹត្តទៅក្នុងវត្ត ដែលឃើញថាជាគ្រឿងបរិសុទ្ធនោះ ក៏ពិតមែនហើយ ប៉ុន្តែតថាគតពោលថា សមណព្រាហ្មណ៍ទាំងនោះ មិនបានឆ្លងផុតជាតិ និងជរាបានឡើយ ។

( នន្ទកមាណពដ៏មានអាយុទូលសួរទៀតថា ) សមណព្រាហ្មណ៍ទាំងឡាយ ពួកខ្លះទាំងនេះពោលថា សេចក្តីបរិសុទ្ធព្រោះអារម្មណ៍ ដែលឃើញ និងអារម្មណ៍ដែលស្តាប់ខ្លះ ពោលថា សេចក្តីបរិសុទ្ធ

ព្រោះសីល និងវត្តខ្លះ ពោលថា សេចក្តីបរិសុទ្ធ ព្រោះវិធីជាច្រើន យ៉ាងនេះ បពិត្រព្រះអង្គ ជាព្រះលោកនាយក បើព្រះអង្គត្រាស់ថា សមណព្រាហ្មណ៍ទាំងនោះ ឆ្លងឱឃៈមិនបានទេ បពិត្រព្រះអង្គ និរទុក្ខ កាលបើដូច្នេះ តើនរណាក្នុងទេវលោក ឬមនុស្សលោក ទើបឆ្លងផុតជាតិ និងជរាទៅបាន បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ សូមទូលសួរព្រះអង្គ សូមព្រះអង្គសម្តែងប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ?

( ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ម្នាលនន្ទកៈ ) តថាគតមិនបានពោលថា ពួកសមណព្រាហ្មណ៍ទាំងអស់ ត្រូវជាតិជរាគ្របសង្កត់ទេ តថាគតពោលថា ពួកសមណព្រាហ្មណ៍ណា ក្នុងលោកនេះលះអារម្មណ៍ដែលខ្លួនបានឃើញ បានឮ បានប៉ះពាល់ និងសីលវត្ត លះបង់វិធីជាច្រើនទាំងអស់ចេញ ឬពួកសមណព្រាហ្មណ៍ណា កំណត់ដឹងនូវតណ្ហា មិនមានអាសវៈ ពួកជននោះឯង ឈ្មោះថា ឆ្លងផុតឱឃៈបាន ។

ខ្ញុំព្រះអង្គត្រេកអរចំពោះព្រះវាចានោះរបស់ព្រះអង្គអ្នកស្វែងរកគុណដ៏ធំ បពិត្រព្រះគោតម ព្រះនិព្វានដែលមិនមានឧបធិ ដែលព្រះអង្គបានសម្តែងទុកល្អហើយ ព្រះអង្គពោលថា កាលពពួកនៃសមណព្រាហ្មណ៍ណាលះអារម្មណ៍ដែលខ្លួនបានឃើញ បានឮ បានប៉ះពាល់ និងសីលវត្ត លះបង់វិធីជាច្រើនយ៉ាង ទាំងអស់ចេញ ឬពួកជនណា កំណត់ដឹងនូវតណ្ហា មិនមានអាសវៈ ទើបតថាគតពោលថា ជនទាំងនោះ ឆ្លងផុតឱឃៈបាន ។

ក្នុងពេលដែលចប់នូវព្រះគាថា ដែលជាព្រះពុទ្ធតម្រាស់ត្រាស់តបបញ្ហារបស់ព្រះមានព្រះភាគនោះ ធម្មចក្ខុ បានដល់ ភ្នែក គឺបញ្ញាដែលបានឃើញធម៌ទៅតាមសេចក្តីពិត បានកើតឡើងដល់ទេវតានិងមនុស្សជាច្រើន ដោយពិចារណាឃើញថា សភាវធម៌ណានីមួយមានការកើតឡើងជាធម្មតា សភាវធម៌នោះ ក៏មានការរលត់ទៅវិញជាធម្មតាដែរ ព្រមទាំងមាណពដែលជាបរិវាររបស់នន្ទកៈ ដែលមានការអប់រំវាសនាបារមី រួមគ្នាជាមួយនឹងនន្ទកៈនោះមក ក៏មានចិត្តរួចផុត

ស្រឡះចាកអាសវក្កិលេសទាំងឡាយ ដោយមិនមានការប្រកាន់មាំត ទៅទៀត ។ព្រមគ្នានឹងការបានសម្រេចជាព្រះអរហន្តនោះបរិក្ខាររបស់ តាបស ដែលមានស្បែកខ្លាជាដើម និងពុកមាត់ ពុកចង្កាក៏បាត់ទៅមួយ រំពេចក្នុងពេលនោះឯង ក៏ប្រាកដឡើងមកវិញ ជាសំពត់កាសាវៈមួយ រំពេចនោះឯង ។នន្ទកៈ កាលមានការៈជាភិក្ខុហើយ ក៏បានពោលឡើង ថា បពិត្រព្រះសយម្ភូ ព្រះអង្គជាសាស្ដារបស់ខ្ញុំព្រះអង្គ ចំណែកខ្ញុំ ព្រះអង្គវិញ ជាសាវ័ករបស់ព្រះអង្គ ។ កាលព្រះសម្ពុទ្ធ ទ្រង់ត្រាស់ តបសោឡសបញ្ហានេះចប់ហើយ នន្ទកៈ ព្រមដោយមាណព ១៥ នាក់ ទៀត និងបរិវារទាំងអស់ នាំគ្នាក្រាបទូលសូមបព្វជ្ជាឧបសម្បទា ក្នុង ព្រះពុទ្ធសាសនានេះ ព្រះមានព្រះភាគទ្រង់ត្រាស់អនុញ្ញាត ការបព្វជ្ជ ឧបសម្បទា ដោយវិធី ឯហិភិក្ខុឧបសម្បទា ។

ព្រះនន្ទកៈ ក្រោយពីបានសម្រេចជាព្រះអរហន្តហើយ លោក បានពោលតំណាលអំពីជីវប្រវត្តិរបស់ខ្លួនលោកទុក តាមដែលមាន សម្ដែងនៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ដូចមានសេចក្ដីថា ៖-

ក្នុងភពមុន ខ្ញុំកើតជាព្រានម្រឹគ នៅក្នុងព្រៃធំ កំពុងស្វែងរកម្រឹគប្រើស ស្រាប់តែបានជួបព្រះសយម្ភូ ។ គ្រានោះ ព្រះមានជោគព្រះនាមអនុរុទ្ធ ទ្រង់ឈ្នះមារ ព្រះអង្គជាអ្នកប្រាជ្ញ ទ្រង់ប្រាថ្នានូវទីដ៏ស្ងប់ស្ងាត់ ស្តេចយាងចូលទៅក្នុងព្រៃ ។ ខ្ញុំយកឈើ ៤ កំណាត់មកបញ្ឈរទុកក្នុងទីជា ៤ ធ្វើបារាំដ៏វិចិត្រយ៉ាងល្អ ប្រក់ដោយផ្កាឈូកទាំងឡាយ ។ ខ្ញុំប្រក់បារាំរួចហើយ ក៏ថ្វាយបង្គំព្រះសយម្ភូ គ្រវែងធ្នូចោលក្នុងទីនោះ ហើយចូលទៅកាន់ផ្នួស ។ កាលខ្ញុំទើបតែនឹងបួស ខ្ញុំក៏មានព្យាធិកើតឡើង ខ្ញុំនឹកឃើញនូវបុព្វកម្ម ហើយធ្វើមរណកាលក្នុងទីនោះ ។ ខ្ញុំប្រកបដោយបុព្វកម្ម បានទៅកើតក្នុងស្ថានតុសិត វិមានជាវិការនៃមាស កើតឡើងតាមសេចក្តីប្រាថ្នាក្នុងទីនោះ ខ្ញុំអធិដ្ឋាននូវវាហនៈ ដែលទឹមដោយសេះមួយពាន់ ជាយានទិព្វ ខ្ញុំឡើងកាន់យាននោះ ហើយទៅតាមសេចក្តីប្រាថ្នា ។ កាលបើខ្ញុំ ដែលបុញ្ញកម្មនាំអំពីទីនោះមក ខ្ញុំបានកើតជាទេវតា បារាំបិទបាំងខ្ញុំ អស់ទីមួយរយយោជន៍ជុំវិញ ។ ខ្ញុំនោះ ដេកលើដំណេកដោយរួសរាន់ ដែលគេមិនបានប្រក់

ហើយ គ្រាន់តែក្រាលដោយផ្កា ស្រាប់តែផ្កាឈូក ធ្លាក់ចុះមកអំពីអាកាស មកបិទបាំង អស់កាលជានិច្ច ។ កាលថ្ងៃបណ្តើរកូនកំពុងញាប់ញ័រ កាលកម្តៅ ថ្ងៃកំពុងក្តៅ កម្តៅថ្ងៃឥតក្តៅដល់ខ្ញុំឡើយ នេះជាផលនៃការឲ្យបាពំ ។ ខ្ញុំបានកន្លងផុតទុគ្គតិ អបាយទាំងឡាយខ្ញុំបានបិទហើយ កម្តៅក្នុងបាពំក្តី ទៀបគល់នៃឈើក្តី ឥតមានដល់ខ្ញុំឡើយ ។ ខ្ញុំអធិដ្ឋានទឹកសមុទ្រ ឲ្យទៅជាផែនដី ហើយឆ្លងនូវទឹកប្រៃព្រោះអំពើដែលខ្ញុំ បានធ្វើល្អហើយនោះ នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំធ្វើផ្លូវព្ធដ៏អាកាស ហើយទៅកាន់ព្ធដ៏អាកាសបាន ឱហ្ន៎ ! អំពើដែលខ្ញុំធ្វើល្អហើយ នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំដឹងខន្ធរបស់ខ្លួន និងសត្វដទៃដែលអាស្រ័យនៅក្នុងកាលមុន ទិព្វចក្ខុ ខ្ញុំបានជម្រះហើយ អាសវៈទាំងឡាយរបស់ខ្ញុំ អស់រលីងហើយ នេះជាផលនៃពុទ្ធបូជា ។ ជាតិខាងមុខ ខ្ញុំបានលះបង់ហើយ ខ្ញុំបានជាឱរសនៃព្រះពុទ្ធ ជាអ្នកទទួលមត៌ក ក្នុងព្រះសទ្ធម្ម នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំបានញុំាំងព្រះសុគតព្រះនាមគោតម ជាសក្យៈដ៏ប្រសើរ ឲ្យប្រោសប្រាណ ជាអ្នកទ្រទ្រង់

ធម៌ ជាអ្នកទទួលមត៌កក្នុងធម៌ នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំបានបម្រើព្រះមានជោគ ព្រះនាមគោតម ជាសក្យៈដ៏ប្រសើរ ហើយបានក្រាបទូលសួរផ្លូវ ដែលគប្បីទៅកាន់ត្រើយ គឺព្រះនិព្វាន ចំពោះព្រះមុនី ។ ព្រះពុទ្ធដែលខ្ញុំអារាធនាហើយ ទ្រង់សម្តែងនូវបទ គឺព្រះនិព្វាន ជាគុណជាតដ៏ល្អិតជ្រាលជ្រៅ ខ្ញុំលុះបានស្តាប់ធម៌ របស់ព្រះពុទ្ធនោះហើយ ក៏បានដល់នូវការអស់ទៅនៃអាសវៈ ។ ឱហ្ន៎ ! អំពើល្អ ខ្ញុំបានធ្វើហើយ ខ្ញុំបានរួចស្រឡះចាកជាតិហើយ មានអាសវៈទាំងពួងអស់រលីងហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង ។ ឱហ្ន៎ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធ របស់ខ្ញុំល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា

៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

រឿងរបស់ព្រះនន្ទកត្ថេរនេះ ជារឿងដែលបង្ហាញឲ្យឃើញថា ការធ្វើសេចក្តីល្អ ចំពោះខ្លួនរបស់លោក ។ ចំណែករឿងដែលធ្វើសេចក្តីល្អ ជាមួយនឹងអាចារ្យពាវរីព្រាហ្មណ៍ និងមាណពជទៃនោះ មានសម្តែងយ៉ាងជាក់ច្បាស់ហើយ ក្នុងជីវប្រវត្តិរបស់ព្រះអជិតត្ថេរ បើលោកអ្នក ប្រាថ្នាចង់ដឹងសេចក្តីពិស្តារនោះ ចូរទៅមើលនៅក្នុងទីនោះចុះ ។

មួយទៀត ផលបុណ្យរបស់ព្រះនន្ទកៈ ដែលមិនបានពោលទុកសូម្បីដោយត្រង់ តែល្មមនឹងសន្និដ្ឋានបានថា នេះជាតួនាទីរបស់ព្រះអរហន្តទាំងឡាយ ដែលបានសម្រេចនូវវិជ្ជាជីវិត អ្នកមានបរិញ្ញាផ្នែកខាងសាសនា គឺវិជ្ជា ៣ បដិសម្ភិទា ៤ និងអភិញ្ញា ៦ ប្រការដូចនេះ លោកក៏មិនជាអ្នកឃើញតែសេចក្តីសុខខ្លួនឯង ដោយមានបំណងប្រាថ្នានូវប្រយោជន៍ ឲ្យដល់សង្គមជាការសំខាន់ជាង ដោយ

កាន់យកតាមគោលការណ៍ ដែលព្រះមហាវីរៈ ទ្រង់ត្រាស់អប់រំថា អ្នកទាំងឡាយ ចូរត្រាច់ទៅតាមជនបទ និងរាជធានីផ្សេងៗ ដើម្បីជាប្រយោជន៍ និងសេចក្តីសុខ ដល់ជនច្រើនផងចុះ ។

ព្រះនន្ទកត្ថេរ លោកទ្រទ្រង់អាយុសង្ខារ មកដល់កាលដ៏សមគួរហើយ លោកក៏បានរំលត់ខន្ធបរិនិព្វានទៅហោង ។

ការបរិនិព្វានរបស់លោក មិនឃើញមានសម្តែងទុកក្នុង គម្ពីរណាថា លោកបរិនិព្វានក្នុងទីណា ឬកន្លែងណាទីមួយឡើយ ។ល។

( ជីវប្រវត្តិរបស់ព្រះនន្ទកត្ថេរ ចប់ )

❊❊❊❊ ❊❊❊❊

# ✍ ជីវប្រវត្តិរបស់ព្រះហេមកត្ថេរ ✍

## " លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័កផងដែរ "

ព្រះហេមកត្ថេរ ជាព្រះអរិយសាវ័ក លោកបានសម្រេចដល់នូវដែននៃបរមសុខ នៅក្នុងសម័យបឋមពោធិកាល លោកក៏ជាអ្នកសង្គ្រោះចូលនៅក្នុងចំណោម ព្រះអសីតិមហាសាវ័កមួយរូបផងដែរ ប៉ុន្តែមុននឹងលោកមកបួស លោកក៏បានជាសិស្សរបស់អាចារ្យពាវរី ដែលជាអ្នករៀនចប់វិជ្ជាត្រៃវេទ ក្នុងលទ្ធិរបស់សាសនាព្រាហ្មណ៍ ក៏ជាអ្នកដែលមានកិត្តិយសដ៏ខ្ពង់ខ្ពស់ ដែលអាចារ្យពាវរីព្រាហ្មណ៍ ឲ្យនាំនូវបញ្ហាមកក្រាបទូលសួរព្រះសម្ពុទ្ធ ដោយរួមជាមួយនឹងមាណព ១៥ នាក់ទៀត ។

ជីវប្រវត្តិក្នុងបច្ចុប្បន្នជាតិរបស់ព្រះហេមកត្ថេរ តាមដែលមានសម្ដែងប្រាកដនៅក្នុង **គម្ពីរអដ្ឋកថាបរមត្ថជោតិកា** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីនៃព្រះបាលីក្នុង **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** នៃ

បារាយនវគ្គ និងក្នុង គម្ពីរខុទ្ទកនិកាយ ចូឡនិទ្ទេស តែក្នុងទីនេះនឹងសូមលើកយកតែសាច់រឿងក្នុងព្រះបាលីមក ដូចមានសេចក្តីថា ៈ-

ព្រះហេមកៈ ជាបុត្ររបស់ព្រាហ្មណ៍ម្នាក់ នៅក្នុងក្រុងសាវត្ថី កាលលោកចម្រើនវ័យធំដឹងក្តីឡើងហើយ បានចូលទៅថ្វាយខ្លួន ធ្វើជាកូនសិស្សរបស់អាចារ្យពាវរីព្រាហ្មណ៍ ដើម្បីសូមការសិក្សាសិល្បវិជ្ជា ។ កាលដែលហេមកមាណព ស្ម័គ្រចិត្តព្រមធ្វើជាកូនសិស្សរបស់អាចារ្យពាវរីព្រាហ្មណ៍នោះ ពីព្រោះអាចារ្យពាវរីព្រាហ្មណ៍ ជាអ្នកចេះដឹងសព្វគ្រប់ក្នុងវិជ្ជាត្រៃវេទ ជាពិសេសនោះ ក្នុងរាងកាយរបស់អាចារ្យពាវរីមានលក្ខណៈពិសេសរបស់មហាបុរស ៣ ប្រការ និងជាព្រះរាជបុរោហិត របស់ព្រះបាទបសេនទិកោសលទៀតផង ។

កាលជាខាងក្រោយមក អាចារ្យពាវរីក៏មានការនឿយណាយក្នុងភាពជាឃរាវាស ទើបក្រាបទូលលាព្រះបាទបសេនទិកោសលចេញទៅបួស ក៏បានតាំងអាស្រមនៅក្បែរឆ្នេរនៃស្ទឹងគោធាវារី ដែលជាព្រំដែននៃដែនអស្សកៈ និងដែនមូឡកៈ តាំងចិត្តបំពេញផ្នួស និង

ជាគណាចារ្យ បានបង្រៀនមន្តផ្សេងៗ ដល់កូនសិស្សទាំងឡាយ ។

ហេមកមាណព ព្រមដោយមាណពដែលជាកូនសិស្សដទៃៗ និងកូនសិស្សរបស់ខ្លួន ក៏បាននាំគ្នាចេញបួស ទៅតាមអាចារ្យពាវរី ផងដែរ ។ កាលអាចារ្យពាវរី ចូលទៅតាំងអាស្រមនៅទីកន្លែងនោះ ក្នុងស្រុក និងបរិវេណទាំងនោះ ក៏សម្បូរសប្បាយរុងរឿងឡើង ឯអាចារ្យពាវរីព្រាហ្មណ៍វិញ ក៏បានទទួលអំណោយអំពីពពួកអ្នកស្រុកទាំងនោះ ហើយក៏បានយកទៅបរិច្ចាគទាន ជាប្រចាំរៀងរាល់ឆ្នាំ ។ ថ្ងៃមួយ អាចារ្យពាវរីព្រាហ្មណ៍បានបរិច្ចាគទានរួចហើយ ក៏ត្រឡប់មកកាន់អាស្រមវិញ គ្រានោះ មានព្រាហ្មណ៍ចាស់ជរាម្នាក់ មានខ្លួនប្រឡាក់ស្រមកដោយធូលី ដើរធ្វើញ័រៗ ចូលទៅរកអាចារ្យពាវរី ហើយក៏និយាយសុំទ្រព្យ ៥០០ កហាបណៈ ។ ចំណែកអាចារ្យពាវរីព្រាហ្មណ៍ កាលបើបានឃើញព្រាហ្មណ៍នោះហើយ ក៏អញ្ជើញឲ្យអង្គុយលើអាសនៈ រួចក៏បានប្រាស្រ័យសាកសួរសុខទុក្ខ ហើយឆ្លើយប្រាប់ថា យើងអស់ទ្រព្យហើយ ពីព្រោះយើងបានបរិច្ចាគទាន

ទើបតែរួចដែរ ។ ពេលនោះ ព្រាហ្មណ៍នោះក៏ខឹងឡើង ទើបគិតក្លែងជារឿងបោកបញ្ឆោត គំរាមកំហែងឡើងថា បើអ្នកមិនឲ្យទ្រព្យដល់យើងទេ រយៈពេល ៧ ថ្ងៃទៀត ក្បាលរបស់អ្នកនឹងត្រូវបែកជា ៧ ភាគ ។ អាចារ្យពាវរីព្រាហ្មណ៍ បានស្តាប់ឮពាក្យរបស់ព្រាហ្មណ៍ចាស់នោះហើយ ក៏ភ័យខ្លាច រហូតដល់បរិភោគមិនបាន សម្រាន្តមិនលក់ ធ្វើឲ្យរាងកាយស្គាំងស្គម ។

គ្រានោះ មានទេវតាមួយអង្គ ជាអ្នកមានបំណងល្អក្នុងហេតុទាំងនោះ ទើបចូលទៅរកអាចារ្យពាវរីព្រាហ្មណ៍ ហើយពោលដាស់តឿនឲ្យមានសតិថា ព្រាហ្មណ៍ចាស់ជរានោះ ជាអ្នកពោលកុហកបោកបញ្ឆោតទេតើ គេមិនដឹងថា អ្វីជាក្បាល អ្វីជាធម៌ ដែលជាហេតុធ្វើឲ្យក្បាលបែកជា ៧ ភាគនោះទេ ។ ពេលនោះ អាចារ្យពាវរីត្រិះរិះគិតថា ទេវតានេះគង់នឹងដឹងក្នុងរឿងនេះហើយ ទើបសួរឡើងថា អ្វីជាក្បាល អ្វីដែលជាធម៌ នាំឲ្យក្បាលដាច់ធ្លាក់ចុះ ?

លំដាប់នោះ ទេវតាឆ្លើយថា សូម្បីខ្ញុំក៏មិនដឹងថា អ្វីជាក្បាល

អ្វីជាធម៌ ដែលជាហេតុធ្វើឲ្យក្បាលដាច់ធ្លាក់ចុះដូចគ្នាដែរ តែក្នុងរឿងនេះ មានតែព្រះលោកវិទូទេ ទ្រង់ជាព្រះរាជឱរសរបស់សក្យរាជនៃរាជវង្សរបស់ព្រះបាទឱក្កាករាជ ព្រះអង្គប្រាកដជាជ្រាបក្នុងរឿងនេះហើយ តែឥឡូវនេះ ព្រះពុទ្ធអង្គទ្រង់គង់ប្រថាប់នៅក្នុងរាជវាំង នៃព្រះបាទបសេនទិកោសល ក្នុងក្រុងសាវត្ថីឯណោះ ។ អាចារ្យពាវរីបានឮដូច្នោះហើយ មានចិត្តរីករាយឡើងវិញ ក៏បានរំសាយភាពកើតទុក្ខទាំងនោះ ទើបបានហៅកូនសិស្សដែលសម្រេចមន្តមកប្រាប់ឲ្យដឹងថា ឥឡូវនេះ ព្រះសម្ពុទ្ធទ្រង់ជាអ្នកខ្ពង់ខ្ពស់បំផុតជាងសព្វសត្វទាំងពួង ឥឡូវស្តេចឧប្បត្តិឡើងហើយនៅក្នុងលោក ពួកអ្នកចូរទៅស៊ើបដំណឹងឲ្យបានដឹងការពិតមើល ។ ពួកកូនសិស្សទាំងនោះ សួរអាចារ្យពាវរីថា បពិត្រលោកអាចារ្យ ពួកខ្ញុំនឹងដឹងថា ព្រះពុទ្ធដោយឧបាយយ៉ាងណាទៅ ។ អាចារ្យពាវរីក៏បានពោលពន្យល់មាណពទាំងនោះ ឲ្យមើលទៅនៅក្នុងតម្រាលក្ខណព្យាករណ៍សាស្ត្រ ពួកអ្នកនឹងដឹងថា ព្រះភគវា មានលក្ខណៈប្រកបដោយមហាបុរិសលក្ខណៈ ៣២

ប្រការ តាមដែលមានពោលទុកក្នុងមន្តទាំងឡាយ យ៉ាងជាក់ច្បាស់ហើយ ។ បើព្រះអង្គនៅគ្រប់គ្រងផ្ទះ ព្រះអង្គនឹងបានជាស្តេចចក្រពត្តិជាអ្នកឈ្នះសត្រូវក្នុងទិសទាំងពួង ទ្រង់គ្រប់គ្រងប្រកបដោយធម៌ មិនប្រើអាជ្ញា និងអាវុធ ។ បើព្រះអង្គចេញទៅបួសវិញ នឹងបានសម្រេចជាព្រះសម្មាសម្ពុទ្ធ ទ្រង់ជាសាស្តាឯកក្នុងលោក ។ ប៉ុន្តែមួយទៀត បើចង់ដឹងចូរឲ្យនឹកទូលសួរបញ្ហាដោយចិត្ត ៣ ខ ព្រះសាស្តាប្រាកដជាត្រាស់តបបញ្ហានោះដោយព្រះវាចាដ៏ស្រទន់ តាមដែលចិត្តនឹកគិតទូលសួរនោះឯង ។ ពេលដែលអាចារ្យពាវរីព្រាហ្មណ៍ពោលប្រាប់វិធីនេះ ដូច្នេះហើយ ទើបចងបញ្ហាឲ្យមាណពទាំង ១៦ នាក់នោះ ដែលបានចេញទៅស៊ើបមើលដំណឹងរកព្រះលោកនាថ កាលបើឃើញហើយ ចូរសួរបញ្ហានេះផង ។

ហេមកមាណព ជាមាណពម្នាក់ ក្នុងចំណោមមាណព ១៦ នាក់នោះ បានធ្វើដំណើរទៅស៊ើបមើលដំណឹងព្រះមានព្រះភាគ រហូតទៅដល់បាសាណកចេតិយ នៃដែនមគធៈ និងបានជាអ្នកក្រាបទូល

សួរបញ្ហាជាលំដាប់ទី ៨ កាលហេមកៈបានទទួលពុទ្ធានុញ្ញាតហើយ ទើបក្រាបទូលសួរបញ្ហាឡើងថា ៖-

( ហេមកមាណពដ៏មានអាយុ ទូលសួរថា ) ក្នុងលោកពីដើមមុនសាសនានៃព្រះគោតម អាចារ្យទាំងឡាយ បានពោលយ៉ាងជាក់ច្បាស់ថា ពាក្យនោះធ្លាប់មានមកហើយយ៉ាងនេះ ពាក្យនោះនឹងមានតទៅ ពាក្យទាំងអស់នោះ ជាពាក្យមិនជាក់ច្បាស់ ពាក្យទាំងអស់នោះ ជាគ្រឿងចម្រើននៃសេចក្តីត្រិះរិះ ( ខ្ញុំព្រះអង្គមិនទាន់ពេញចិត្តក្នុងពាក្យនោះឡើយ ) បពិត្រព្រះអង្គជាព្រះមុនី សូមព្រះអង្គសម្តែងធម៌សម្រាប់ដកចេញនូវតណ្ហា ដែលនាំឲ្យខ្ញុំព្រះអង្គដឹងច្បាស់ មានសតិឆ្លងតណ្ហាដែលផ្សាយទៅផ្សេងៗ ដល់ខ្ញុំព្រះអង្គ ?

( ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ) ម្នាលហេមកៈ ជនទាំងឡាយណា ដឹងច្បាស់នូវព្រះនិព្វាន ជាទីបន្ទោបង់នូវឆន្ទរាគៈ ជាគុណជាតមិនច្យុត ដែលបានឃើញ បានស្តាប់ បានប៉ះពាល់ ហើយចំពោះរូបជាទីស្រឡាញ់ ( ដែលគេដឹងច្បាស់ហើយ ) ជាអ្នកមានសតិ

រលត់កិលេសក្នុងបច្ចុប្បន្នហើយជនអ្នកមានសតិស្ងប់កិលេសទាំងនោះ ឈ្មោះថា ឆ្លងតណ្ហាដែលផ្សាយទៅផ្សេងៗ ក្នុងលោកបានហើយ ។

ក្នុងពេលដែលចប់នូវព្រះគាថា ដែលជាព្រះពុទ្ធតម្រាស់ត្រាស់តបបញ្ហារបស់ព្រះមានបុណ្យនោះ ធម្មចក្ខុ បានដល់ ភ្នែក គឺបញ្ញាដែលបានឃើញធម៌ទៅតាមសេចក្តីពិត បានកើតឡើងដល់ទេវតា និងមនុស្សជាច្រើន ដោយពិចារណាឃើញថា សភាវធម៌ណានីមួយមានការកើតឡើងជាធម្មតា សភាវធម៌ទាំងនោះ ក៏មានការរលត់វិញ ជាធម្មតាដែរ ព្រមទាំងមាណព ដែលជាបរិវាររបស់ហេមកៈ ដោយអំណាចការអប់រំវាសនាបារមីរួចមកហើយ ដូច្នេះ ក៏ធ្វើឲ្យចិត្តរបស់ពួកគេរួចផុតស្រឡះចាកអាសវក្កិលេសទាំងឡាយ ដោយអស់នូវការប្រកាន់មាំតទៅទៀតហើយ ។ ព្រមជាមួយគ្នានឹងការបានសម្រេចជាព្រះអរហន្តនោះ បរិក្ខាររបស់តាបស ដែលមានស្បែកខ្លាជាដើម និងពុកមាត់ពុកចង្កា ក៏បាត់ទៅមួយរំពេចពេលនោះឯង ប្រាកដឡើងនូវសំពត់កាសាវៈវិញ ហើយពោលឡើងថា បពិត្រព្រះលោកនាយក

ព្រះអង្គជាសាស្ដារបស់ខ្ញុំព្រះអង្គ ចំណែកខ្ញុំព្រះអង្គវិញ ជាសាវ័ករបស់ព្រះអង្គ ។ កាលព្រះសម្ពុទ្ធ ទ្រង់ត្រាស់តបសោឡសបញ្ហានេះចប់ហើយ ហេមកមាណពព្រមដោយមាណព ១៥ នាក់ទៀត និងបរិវារទាំងអស់ បាននាំគ្នាក្រាបទូល សូមបព្វជ្ជាឧបសម្បទានៅក្នុងព្រះពុទ្ធសាសនានេះ ព្រះពុទ្ធអង្គក៏ទ្រង់ត្រាស់អនុញ្ញាតក្នុងការបព្វជ្ជាឧបសម្បទា ដោយវិធីឯហិភិក្ខុឧបសម្បទា ។

ព្រះហេមកត្ថេរ ក្រោយអំពីលោកបានសម្រេចជាព្រះអរហន្តហើយ លោកបានពោលអំពីជីវប្រវត្តិរបស់ខ្លួនលោកទុក តាមដែលមានសម្ដែងនៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ដូចមានសេចក្ដីថា ៖-

កាលនោះ ខ្ញុំជាតាបសឈ្មោះអនោមៈ បានធ្វើអាស្រមបណ្ណសាលាដ៏វិចិត្រល្អ នៅអែបទីងចុងញកភ្នំ ខ្ញុំនោះ បានសម្រេចនូវតបកម្ម ខ្ញុំដល់នូវការសម្រេច ក្នុងកម្លាំងរបស់ខ្លួន ជាអ្នកក្លាហានក្នុងភាពនៃខ្លួនជាសមណៈ ជាអ្នកមានព្យាយាមដុតបំផ្លាញកិលេសមានប្រាជ្ញាចាស់ ជាអ្នកប្រាជ្ញ ជាអ្នកក្លៀវក្លាក្នុងលទ្ធិរបស់ខ្លួន រាង

វៃក្នុងវាទៈរបស់បុគ្គលដទៃ មួយទៀត ជាអ្នកតាំងនៅលើផែនដី និង អាកាសបាន វាងវៃក្នុងឧបាទវយធម៌ ។ ខ្ញុំប្រាសចាកសេចក្តីសោក មិនមានការប្រណាំងប្រជែង មានអាហារតិច មិនមានសេចក្តីប្រាថ្នា ជាអ្នកត្រេកអរ ដោយលាភ និងអលាភ មានឈាន ត្រេកអរ ក្នុង ឈាន ជាអ្នកប្រាជ្ញ ។ កាលនោះ ព្រះមានជោគ ព្រះនាមបិយទស្សី ជាអ្នកប្រាជ្ញដ៏ប្រសើរ ប្រកបដោយករុណា ព្រះអង្គប្រាថ្នាដើម្បីចម្លង នូវសត្វទាំងឡាយ ទ្រង់ផ្សាយព្រះទ័យករុណា ។ ព្រះមហាមុនី ព្រះ នាមបិយទស្សី ទ្រង់ឃើញនូវជនដែលគួរឲ្យត្រាស់ដឹង ព្រះអង្គ ជាអ្នក ប្រាជ្ញ ជាអ្នកឲ្យឱវាទ ស្តេចយាងទៅក្នុងចក្រវាឡ ១០០០ ។ ព្រះអង្គ មានប្រាថ្នាស្រោចស្រង់ខ្ញុំ ស្តេចយាងចូលទៅកាន់អាស្រមរបស់ខ្ញុំ ព្រះជិនស្រី ខ្ញុំមិនដែលឃើញ ទាំងមិនធ្លាប់បានឮអំពីសម្នាក់អ្នកណា មួយ ក្នុងកាលមុនឡើយ ។ ខ្ញុំបានសុបិននិមិត្តកើតឡើង លក្ខណៈ ទាំងឡាយ បានប្រកាសល្អហើយ ខ្ញុំជាអ្នកស្ថិតនៅលើផែនដី និង អាកាស ឈ្លាសវៃក្នុងបទនៃនក្ខត្តឫក្ស ។ ខ្ញុំនោះ បានស្តាប់ធម៌របស់

ព្រះពុទ្ធហើយ ក៏ញុំាងចិត្តឲ្យជ្រះថ្លាក្នុងព្រះពុទ្ធ ខ្ញុំឈរ ឬអង្គុយ តែងនឹកឃើញព្រះពុទ្ធជានិច្ច ។កាលខ្ញុំកំពុងនឹកយ៉ាងនេះ ព្រះមានព្រះភាគក៏ទ្រង់នឹកដល់ខ្ញុំដែរ ខ្ញុំកំពុងតែនឹកព្រះពុទ្ធ បីតិក៏កើតមានដល់ខ្ញុំ ក្នុងខណៈនោះ ។ ព្រះមហាមុនី ទ្រង់ចូលមករកខ្ញុំ អស់កាលម្តងទៀត កាលបើព្រះអង្គស្តេច មកដល់ហើយ ខ្ញុំឥតស្គាល់ថា ទុំះជាព្រះពុទ្ធជាអ្នកប្រាជ្ញដ៏ប្រសើរឡើយ ។ព្រះមហាមុនី ព្រះនាមបិយទស្សីប្រកបដោយករុណា ទ្រង់អនុគ្រោះខ្ញុំបានញុំាងខ្ញុំឲ្យស្គាល់ព្រះអង្គថា តថាគតជាព្រះពុទ្ធ ក្នុងលោក ព្រមទាំងទេវលោក ។ ខ្ញុំបានស្គាល់ច្បាស់នូវព្រះសម្ពុទ្ធ ព្រះនាមបិយទស្សី ជាមហាមុនី ហើយក៏ញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ក្រាបទូលពាក្យនេះថា ពួកជនទាំងអស់ តែងអង្គុយលើតាំងក្តី លើបល្ល័ង្កក្តី លើតាំងវែងក្តី ព្រះអង្គមានសេចក្តីអាណិតអាសូរដល់សត្វទាំងពួង សូមគង់លើអាសនៈដ៏រុងរឿង ។ ខ្ញុំបាននិម្មិតតាំងជាវិការនៃកែវទាំងពួង ជាអាសនៈដែលខ្ញុំនិម្មិតដោយឫទ្ធិ ថ្វាយព្រះមហាមុនី ព្រះនាមបិយទស្សី ក្នុងខណៈនោះ ។ កាលព្រះអង្គគង់លើ

តាំងកែវដែលនិម្មិតដោយឫទ្ធិ ខ្ញុំបានថ្វាយផ្លែព្រីងប៉ុនក្អម ក្នុងខណៈនោះ ។ ព្រះមហាមុនី ទ្រង់ញ៉ាំងសេចក្តីរីករាយឲ្យកើតដល់ខ្ញុំ ហើយទ្រង់សោយ ( ផ្លែព្រីងនោះ ) គ្រានោះ ខ្ញុំញ៉ាំងចិត្តឲ្យជ្រះថ្លា ហើយថ្វាយបង្គំព្រះសាស្តា ។ ចំណែកព្រះមានព្រះភាគ ព្រះនាមបិយទស្សី ព្រះអង្គប្រសើរបំផុតក្នុងលោក ប្រសើរជាងនរៈ ទ្រង់គង់លើអាសនៈកែវ ហើយត្រាស់គាថាទាំងនេះថា

បុគ្គលណា បានថ្វាយតាំងជាវិការនៃកែវ និងផ្លែព្រីងទិព្វដល់តថាគត ក្នុងកាលនោះ តថាគតនឹងសរសើរបុគ្គលនោះ អ្នកទាំងឡាយ ចូរស្តាប់តថាគតនឹងសម្តែង ដូចតទៅនេះ ។

បុគ្គលនេះ នឹងត្រេកអរក្នុងទេវលោក អស់ ៧៧ កប្ប នឹងបានជាស្តេចចក្រពត្តិ អស់ ៧៥ ដង ។ នឹងបានជាព្រះឥន្ទ្រសោយទេវរាជ្យ អស់ ៣២ ដង នឹងបានសោយប្រទេសរាជដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យកប្ប ។ បុគ្គលនោះ នឹងបាននូវបល្ល័ង្កជាវិការនៃមាសជាវិការនៃវត្ថុជាទីគាប់ចិត្ត ជាវិការនៃកែវទទឹម ជាវិការនៃកែវជាច្រើន

ដែលបុញ្ញកម្មបានតាក់តែងល្អហើយ ។ បល្ល័ង្កទាំងឡាយជាច្រើន ចោមរោមបុគ្គលនោះ អ្នកប្រកបដោយបុញ្ញកម្មនោះ សូម្បីកាលដើរទៅដើរមក សព្វៗ កាល ។ ផ្ទះមានកំពូលប្រាសាទ និងទីសម្រាប់ដេកមានតម្លៃច្រើន នឹងកើតក្នុងខណៈនោះ ព្រោះដឹងចិត្តរបស់បុគ្គលនេះ ។ ដំរី ៦០ ពាន់ ដែលគេស្អិត ស្អាងដោយគ្រឿងអលង្ការទាំងពួង ជាដំរីដ៏ប្រសើរ មានខ្សែជង្គន់មាស ប្រកបដោយគ្រឿងតាក់តែងក្បាល ជាវិការនៃមាស ។ ដំរីទាំងនោះ ដែលពួកហ្មមានដៃកាន់លំពែងស្នែងក្របី និងកង្វេរឡើងជិះហើយ នឹងបម្រើបុគ្គលនេះ នេះជាផលនៃការថ្វាយតាំងជាវិការនៃកែវ ។ សេះ ៦០ ពាន់ ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង ជាអាជានេយ្យអំពីកំណើតជាសេះសិន្ធព ជាពាហនៈដ៏លឿន ។ សេះទាំងនោះ ដែលនាយសារថី មានដៃកាន់ធ្នូ និងខែលឡើងជិះហើយ នឹងបម្រើបុគ្គលនេះ នេះជាផលនៃការថ្វាយតាំងជាវិការនៃកែវ ។ រថទាំង ៦០ ពាន់ ដែលតាក់តែងដោយគ្រឿងប្រដាប់គ្រប់យ៉ាង បិទបាំងដោយស្បែកខ្លាដំបង ខ្លាធំ ដែលគេប្រដាប់ហើយ លើកទង់ជ័យ មាន

ពួកនាយសារថី មានដៃកាន់ជួ និងខែលឡើងជិះហើយនឹងចោមរោម បុគ្គលនេះជានិច្ច នេះជាផលនៃការថ្វាយតាំង ជាវិការនៃកែវ ។ ពួកមេគោមានទឹកដោះ ៦០ ពាន់ មេគោ និងពួកគោឧសភៈដ៏ប្រសើរ នឹងញ៉ាំងកូនទាំងឡាយឲ្យកើត នេះជាផលនៃការថ្វាយតាំងជាវិការនៃកែវ ។ ពួកស្ត្រី ១៦ ពាន់ ស្អិតស្អាង ដោយគ្រឿងប្រដាប់គ្រប់យ៉ាង មានសំពត់ និងគ្រឿងអាភរណៈដ៏វិចិត្រ ពាក់កែវមុក្តា កែវមណី និងកុណ្ឌល ទាំងមានមុខទូលាយ មានមុខស្រស់ស្រាយ មានទ្រគាកសាយ ទាំងមានចង្កេះរៀវ នឹងចោមរោមបុគ្គលនេះជានិច្ច នេះជាផលនៃការថ្វាយតាំងជាវិការនៃកែវ ក្នុងកប្បទី ១.៨០០ នឹងមានព្រះពុទ្ធ ព្រះនាមគោតម មានបញ្ញាចក្ខុ ទ្រង់កម្ចាត់បង់នូវងងឹតអន្ធការ ត្រាស់ដឹងក្នុងលោក ។ បុគ្គលនេះ មានសេចក្តីខ្វល់ខ្វាយ នឹងបួសព្រោះអាស្រ័យការឃើញនូវព្រះពុទ្ធអង្គនោះ បានញ៉ាំងព្រះសាស្តាឲ្យត្រេកអរ និងរីករាយក្នុងសាសនា ។ បុគ្គលនេះ បានស្តាប់ធម៌របស់ព្រះពុទ្ធអង្គនោះហើយ នឹងដុតបំផ្លាញនូវកិលេសទាំងឡាយ កំណត់ដឹងនូវអាសវៈទាំងពួង

ជាបុគ្គលមិនមានអាសវៈ នឹងបរិនិព្វាន ។

សេចក្ដីព្យាយាមរបស់ខ្ញុំ គួរនាំទៅនូវធុរៈ ជាទីនាំមកនូវធម៌ ដ៏ក្សេមចាកយោគៈ ខ្ញុំប្រាថ្នានូវប្រយោជន៍ដ៏ឧត្ដម ក្នុងសាសនា ។ នេះ ជារាងកាយ ខាងក្រោយបំផុតរបស់ខ្ញុំ កពជាទីបំផុតរបស់ខ្ញុំ កំពុង ប្រព្រឹត្តទៅ ខ្ញុំមានអាសវៈទាំងពួង អស់រលីងហើយ ឥឡូវនេះ កពថ្មី មិនមានទៀតឡើយ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ កព ទាំងអស់ ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចដំរីដ៏ប្រសើរ កាត់ផ្ដាច់នូវទន្ទឹង ។ ឱហ្ន៎ ! ដំណើរ ដែលខ្ញុំមក ក្នុង សម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំដល់តាមលំដាប់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

មួយទៀត ជីវប្រវត្តិរបស់ព្រះហេមកត្ថេរ ដែលកើតឡើង ត្រូវនឹងពុទ្ធកាលនៃព្រះសម្មាសម្ពុទ្ធកស្សបៈនោះហើយ លោកបានធ្វើ

បុណ្យកុសលរួមជាមួយនឹងអាចារ្យពាវរី និងមាណពដទៃនោះ ដូចមានសម្តែងប្រាកដនៅក្នុង **អដ្ឋកថាបរមត្ថជោតិកា** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលីនៅក្នុង **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** នៃ **បារាយនវគ្គ** នោះ ដូចបាននាំមកពោលរួចហើយ ក្នុងជីវប្រវត្តិរបស់ព្រះអជិតត្ថេរ បើអ្នកសិក្សាចង់បាននូវសេចក្តីពិស្តារ ចូរទៅមើលនៅក្នុងទីនោះចុះ ។

ព្រះហេមកត្ថេរ លោកទ្រទ្រង់អាយុសង្ខារ មកដល់កាលដ៏សមគួរហើយ លោកក៏បានរំលត់ខន្ធបរិនិព្វានទៅហោង ។ល។

( ជីវប្រវត្តិរបស់ព្រះហេមកត្ថេរ ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះតោទេយ្យត្ថេរ ✍

## " លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័កផងដែរ "

ព្រះតោទេយ្យត្ថេរ ជាអ្នកដែលទ្រទ្រង់នូវឧត្តមគុណ ដោយបានសម្រេចដល់នូវព្រះនិព្វាន ជាព្រះមហាថេរៈមួយរូប នៅក្នុងគណៈសោឡសត្ថេរ និងបានទទួលនូវការលើកស្ទួយសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័ក ដែលជាសាវ័កធំរបស់ព្រះពុទ្ធ ៨០ រូប និងបានជាកម្លាំងដ៏សំខាន់ ក្នុងការចារិកទៅប្រកាសព្រះពុទ្ធសាសនា មុននឹងលោកចូលមកបួសជាភិក្ខុនេះ លោកក៏បានជាកូនសិស្សរបស់អាចារ្យពាវរីព្រាហ្មណ៍ ដែលមានចំណេះដឹងល្អ ក្នុងមន្តទាំងឡាយដែលមាននៅក្នុងលទ្ធិរបស់ព្រាហ្មណ៍ ទាំងខ្លួនលោកក៏មានបរិវារដែលជាកូនសិស្សរហូតដល់ទៅ ១០០០ នាក់ ថែមទាំងបាននាំគ្នាចូលមកបួសក្នុងធម្មវិន័យនេះទាំងអស់គ្នា ។

ជីវប្រវត្តិក្នុងបច្ចុប្បន្នជាតិរបស់ព្រះតោទេយ្យត្ថេរ តាមដែល

មានសម្ដែងប្រាកដនៅក្នុង **អដ្ឋកថាបរមត្ថជោតិកា** ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីព្រះបាលីនៅក្នុង **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** នៃ **បារាយនវគ្គ** និងនៅក្នុង **គម្ពីរខុទ្ទកនិកាយ ចូឡនិទ្ទេស** តែក្នុងទីនេះនឹងសូមលើកយកតែសាច់រឿងពីព្រះបាលីមក ដូចមានសេចក្ដីថា ៈ-

ព្រះតោទេយ្យត្ថេរ ជាបុត្ររបស់ព្រាហ្មណ៍ម្នាក់ នៅក្នុងក្រុងសាវត្ថី កាលលោកចម្រើនវ័យធំដឹងក្ដីឡើងហើយ បានចូលទៅថ្វាយខ្លួនធ្វើជាកូនសិស្សរបស់អាចារ្យពាវរីព្រាហ្មណ៍ ដើម្បីសូមការសិក្សាសិល្បវិជ្ជា ។ កាលដែលតោទេយ្យមាណព ស្ម័គ្រចិត្តព្រមធ្វើជាកូនសិស្សរបស់អាចារ្យពាវរីនោះ ពីព្រោះអាចារ្យពាវរី ជាអ្នកចេះដឹងសព្វគ្រប់ក្នុងវិជ្ជាត្រៃវេទ ជាពិសេសនោះ ក្នុងរាងកាយរបស់អាចារ្យពាវរីព្រាហ្មណ៍ មានលក្ខណៈពិសេសរបស់មហាបុរស ៣ ប្រការ និងជាព្រះរាជបុរោហិត របស់ព្រះបាទបសេនទិកោសលទៀតផង ។

កាលជាខាងក្រោយមក អាចារ្យពាវរីមានការនឿយណាយនៅក្នុងភាពជាយរាវាស ទើបក្រាបទូលលាព្រះបាទបសេនទិកោសល

ចេញទៅបួស បានតាំងអាស្រមនៅក្បែរឆ្នេរនៃស្ទឹងគោធាវរី ដែលជាព្រំដែននៃដែនអស្សក: និងដែនមូឡក: តាំងចិត្តបំពេញផ្នួស និងជាគណាចារ្យ បានបង្រៀនមន្តផ្សេងៗ ដល់កូនសិស្សទាំងឡាយ ។

គោទេយ្យមាណព ព្រមដោយមាណពដែលជាកូនសិស្សដទៃៗ និងកូនសិស្សរបស់ខ្លួន បាននាំគ្នាចេញបួស ទៅតាមអាចារ្យពាវរីដែរ ។ កាលអាចារ្យពាវរី ចូលទៅតាំងអាស្រមនៅទីកន្លែងនោះ ក្នុងស្រុក និងបរិវេណទាំងនោះ ក៏សម្បូរសប្បាយរុងរឿងឡើង ឯអាចារ្យពាវរីព្រាហ្មណ៍វិញ ក៏បានទទួលអំណោយអំពីពពួកអ្នកស្រុកទាំងនោះ ហើយបានយកទៅបរិច្ចាគទាន ជាប្រចាំរៀងរាល់ឆ្នាំ ៗថ្ងៃមួយ អាចារ្យពាវរីព្រាហ្មណ៍ បានបរិច្ចាគទានរួចហើយ ក៏ត្រឡប់មកកាន់អាស្រមរបស់ខ្លួនវិញ គ្រានោះ មានព្រាហ្មណ៍ចាស់ជរាម្នាក់ មានខ្លួនប្រឡាក់ស្រមកដោយធូលី ដើរធ្វើញ័រៗ ចូលទៅរកអាចារ្យពាវរី ហើយក៏និយាយសុំទ្រព្យ ៥០០ កហាបណៈ ។ ចំណែកអាចារ្យពាវរីព្រាហ្មណ៍កាលបើបានឃើញព្រាហ្មណ៍នោះហើយក៏អញ្ជើញឲ្យអង្គុយលើអាសនៈ

រួចបានប្រាស្រ័យសាកសួរសុខទុក្ខ ហើយបានឆ្លើយប្រាប់ថា យើងអស់ទ្រព្យហើយ ពីព្រោះយើងបានបរិច្ចាគទានទើបតែរួចដែរ ។ ពេលនោះព្រាហ្មណ៍នោះក៏ខឹងឡើង ទើបគិតក្លែងជារឿងបោកបញ្ឆោត គំរាមកំហែងឡើងថា បើអ្នកមិនឲ្យទ្រព្យដល់យើងទេ រយៈពេល ៧ ថ្ងៃទៀតក្បាលរបស់អ្នកត្រូវបែកជា ៧ ភាគ ។ អាចារ្យពាវរីព្រាហ្មណ៍បានស្តាប់ឮពាក្យរបស់ព្រាហ្មណ៍ចាស់នោះហើយ ក៏ភ័យខ្លាច រហូតដល់បរិភោគមិនបាន សម្រាន្តមិនលក់ ធ្វើឲ្យរាងកាយស្គាំងស្គម ។

គ្រានោះ មានទេវតាមួយអង្គ ជាអ្នកមានបំណងល្អក្នុងហេតុទាំងនោះ ទើបចូលទៅរកអាចារ្យពាវរីព្រាហ្មណ៍ ហើយពោលដាស់តឿនឲ្យមានសតិថា ព្រាហ្មណ៍ចាស់ជរានោះ ជាអ្នកពោលកុហកបោកបញ្ឆោតទេតើ គេមិនដឹងថា អ្វីជាក្បាល អ្វីជាធម៌ ដែលជាហេតុធ្វើឲ្យក្បាលបែកជា ៧ ភាគនោះទេ ។ ពេលនោះ អាចារ្យពាវរីព្រាហ្មណ៍ត្រិះរិះគិតថា ទេវតានេះគង់នឹងដឹងក្នុងរឿងនេះហើយ ទើបសួរឡើងថា អ្វីជាក្បាល អ្វីដែលជាធម៌ នាំឲ្យក្បាលដាច់ធ្លាក់ចុះ ?

លំដាប់នោះ ទេវតាឆ្លើយថា សូម្បីខ្ញុំក៏មិនដឹងថា អ្វីជា ក្បាល អ្វីជាធម៌ ដែលជាហេតុធ្វើឲ្យក្បាលដាច់ធ្លាក់ចុះដូចគ្នាដែរ តែក្នុងរឿងនេះ មានតែព្រះលោកនាយកទេ ទ្រង់ជាព្រះរាជឱរសរបស់សក្យរាជនៃរាជវង្សរបស់ព្រះបាទឱក្កាករាជ ព្រះអង្គប្រាកដជាជ្រាបក្នុងរឿងនេះហើយ តែឥឡូវនេះ ព្រះពុទ្ធអង្គទ្រង់គង់ប្រថាប់នៅក្នុងរាជវាំងនៃព្រះបាទបសេនទិកោសល នៅក្នុងក្រុងសាវត្ថីឯណោះ ។ អាចារ្យពាវរីកាលបានឮដូច្នោះហើយ មានចិត្តរីករាយឡើងវិញ ក៏បានរំសាយភាពកើតទុក្ខទាំងនោះ ទើបបានហៅកូនសិស្ស ដែលសម្រេចមន្តមកប្រាប់ឲ្យដឹងថា ឥឡូវនេះ ព្រះសម្ពុទ្ធ ទ្រង់ជាអ្នកខ្ពង់ខ្ពស់បំផុតជាងសព្វសត្វទាំងពួង ឥឡូវស្តេចទ្រង់ឧប្បត្តិឡើងហើយក្នុងលោក ពួកអ្នកចូរទៅសុំបដំណឹងឲ្យដឹងការពិតមើល ។ ពួកកូនសិស្សទាំងនោះ សួរអាចារ្យពាវរីព្រាហ្មណ៍ថា បពិត្រលោកអាចារ្យ ពួកខ្ញុំនឹងដឹងថា ព្រះពុទ្ធ ដោយឧបាយយ៉ាងណាទៅ ? អាចារ្យពាវរីព្រាហ្មណ៍ ក៏បានពោលពន្យល់មាណពទាំងនោះ ឲ្យមើលទៅនៅក្នុងតម្រាលក្ខណព្យាករណ៍សាស្ត្រ

ពួកអ្នកនឹងដឹងថា ព្រះសាស្ដា មានលក្ខណៈប្រកបដោយមហាបុរិស លក្ខណៈ ៣២ ប្រការ តាមដែលមានពោលទុកក្នុងមន្តទាំងឡាយយ៉ាង ជាក់ច្បាស់ហើយ ។ បើព្រះអង្គ នៅគ្រប់គ្រងផ្ទះ ព្រះអង្គនឹងបានជា ស្ដេចចក្រពត្តិជាអ្នកឈ្នះសត្រូវក្នុងទិសទាំងពួង ទ្រង់គ្រប់គ្រងប្រកប ដោយធម៌ មិនប្រើអាជ្ញា និងអាវុធ ។ បើព្រះអង្គចេញទៅបួសវិញ នឹងបានសម្រេចជាព្រះមានជោគ ទ្រង់ជាសាស្ដាឯកក្នុងលោក ។ ប៉ុន្តែ មួយទៀត បើចង់ដឹង ចូរនឹកទូលសួរបញ្ហាដោយចិត្ត ៣ ខ ព្រះអង្គ ប្រាកដជាត្រាស់តបបញ្ហានោះ ដោយព្រះវាចាដ៏ស្រទន់ តាមដែលចិត្ត នឹកគិតទូលសួរ ។ ពេលដែលអាចារ្យពាវរីព្រាហ្មណ៍ពោលប្រាប់វិធី នេះ ដូច្នេះហើយ ទើបចងបញ្ហាឲ្យមាណពទាំង ១៦ នាក់នោះ ដែល បានចេញទៅស៊ើបមើលដំណឹងរកព្រះលោកនាយក កាលបើឃើញ ហើយ ចូរសួរបញ្ហានេះចុះ ។

តោទេយ្យមាណព ជាមាណពម្នាក់ ក្នុងចំណោមមាណព ១៦ នាក់នោះ បានធ្វើដំណើរទៅស៊ើបមើលដំណឹងព្រះមានព្រះភាគ រហូត

ទៅដល់បាសាណកចេតិយ នៃដែនមគធៈ និងបានជាអ្នកក្រាបទូលសួរបញ្ហាជាលំដាប់ទី ៩ កាលតោទេយ្យៈបានទទួលពុទ្ធានុញ្ញាតហើយទើបក្រាបទូលសួរបញ្ហាឡើងថា ៖-

( តោទេយ្យមាណពដ៏មានអាយុ ទូលសួរថា ) កាមារម្មណ៍ទាំងឡាយ មិនមាននៅក្នុងបុគ្គលណា តណ្ហារបស់បុគ្គលណាមិនមានទាំងបុគ្គលណា ឆ្លងសេចក្តីសង្ស័យបាន វិមោក្ខធម៌ ( ការរួចផុត ) របស់បុគ្គលនោះ តើដូចម្តេច ?

( ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ) ម្នាលតោទេយ្យៈ កាមារម្មណ៍ទាំងឡាយ មិនមាននៅក្នុងបុគ្គលណា តណ្ហារបស់បុគ្គលណាមិនមាន ទាំងបុគ្គលណា ឆ្លងសេចក្តីសង្ស័យបាន វិមោក្ខធម៌របស់បុគ្គលនោះ មិនមែនទៅជាយ៉ាងដទៃទេ ។

( បុគ្គលនោះ នឹងត្រូវព្យាយាមដើម្បីធ្វើខ្លួនឲ្យរួចផុតទៅក្រៅអំពីនេះទៀតមិនមានទេ ) បុគ្គលនោះ ជាអ្នកប្រាសចាកសេចក្តីប្រាថ្នា ឬនៅប្រកបដោយសេចក្តីប្រាថ្នា ជាបុគ្គលមានប្រាជ្ញា ឬជាអ្នកគ្រាន់

តែកំណត់ថា មានបញ្ញា បពិត្រព្រះអង្គជាសក្យពង្ស ខ្ញុំព្រះអង្គគប្បីស្គាល់បាននូវមុនី ដោយប្រការដូចម្តេច បពិត្រព្រះអង្គមានបញ្ញាចក្ខុឃើញធម៌ដោយជុំវិញ សូមព្រះអង្គ ត្រាស់ប្រាប់នូវមុនីនោះ ដល់ខ្ញុំព្រះអង្គ ?

( ព្រះអង្គទ្រង់ដោះស្រាយថា ) បុគ្គលនោះប្រាសចាកសេចក្តីប្រាថ្នា ទាំងជាអ្នកប្រកបដោយសេចក្តីប្រាថ្នាក៏ទេ ជាអ្នកមានបញ្ញាទាំងជាអ្នកគ្រាន់តែកំណត់ថា មានបញ្ញាក៏ទេ ម្នាលតោទេយ្យៈ អ្នកចូរដឹងបុគ្គលនោះ ថាជាមុនី ជាអ្នកមិនមានកង្វល់ មិនជាប់នៅក្នុងកាមភព យ៉ាងនេះចុះ ។

កាលចប់នូវព្រះគាថា ដែលជាព្រះពុទ្ធតម្រាស់ត្រាស់តបបញ្ហារបស់ព្រះមានជោគនោះ ធម្មចក្ខុ បានដល់ ភ្នែក គឺបញ្ញា ដែលឃើញសភាវធម៌ទៅតាមសេចក្តីពិត បានកើតឡើងដល់ទេវតា និងមនុស្សជាច្រើន ដោយពិចារណាឃើញថា សភាវធម៌ណានីមួយ មានការកើតឡើងជាធម្មតា សភាវធម៌នោះ ក៏មានការរលត់ទៅវិញ ជាធម្មតាដែរ ។

ព្រមដោយមាណពដែលជាបរិវារ របស់គោទេយ្យមាណព ដោយអំណាចបុណ្យបារមីដែលបានសន្សំរួចមកហើយ ដូចគ្នានឹងគោទេយ្យមាណព ចិត្តក៏បានរួចផុតស្រឡះចាកអាសវក្កិលេសទាំងឡាយ ដោយការមិនមាននូវសេចក្តីប្រកាន់មាំតទៅទៀត ។

ព្រមគ្នានឹងការបានសម្រេចជាព្រះអរហន្តនោះ បរិក្ខាររបស់តាបស ដែលមានស្បែកខ្លាជាដើម និងពុកមាត់ ពុកចង្កា ក៏បាត់ទៅមួយរំពេចក្នុងពេលនោះឯង ប្រាកដឡើងនូវសំពត់កាសាវៈមកវិញ កាលមានភាវៈជាភិក្ខុហើយ ក៏ក្រាបបង្គំទូលឡើងថា បពិត្រព្រះមុនី ព្រះអង្គជាសាស្តារបស់ខ្ញុំព្រះអង្គ ចំណែកខ្ញុំព្រះអង្គវិញ ជាសាវករបស់ព្រះអង្គ ។ កាលព្រះសម្មាសម្ពុទ្ធ ត្រាស់តបសោឡសបញ្ហានោះចប់ហើយ គោទេយ្យមាណព ព្រមដោយមាណព ១៥ នាក់ទៀត និងបរិវារទាំងអស់ បានក្រាបទូលសូមបព្វជ្ជាឧបសម្បទា ក្នុងព្រះពុទ្ធសាសនានេះ ព្រះអង្គក៏ទ្រង់ត្រាស់អនុញ្ញាត ក្នុងការបព្វជ្ជាឧបសម្បទា ដោយវិធីឯហិភិក្ខុឧបសម្បទា ។

ព្រះតោទេយ្យត្ថេរ ក្រោយពីបានសម្រេចជាព្រះអរហន្តហើយ លោកក៏បានពោលតំណាលអំពីជីវប្រវត្តិរបស់ខ្លួនឯងទុក តាមដែលមានសម្តែងនៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ដូចមានសេចក្តីថា ៈ-

គ្រានោះ ក្នុងកេតុមតីបុរីដ៏ឧត្តម ព្រះរាជាព្រះនាមវិជិតជ័យជាស្តេចក្លៀវក្លា បរិបូណ៌ដោយព្យាយាម នៅគ្រប់គ្រងបុរី ។ កាលព្រះរាជាអង្គនោះ ធ្វេសប្រហែសហើយ ពួកជនជាសត្រូវ នៅក្នុងដែនឧត្តរ និងតុណ្ឌិក បង្កគ្នាឡើង លុកលុយដែនក្នុងកាលនោះ ។ កាលអ្នកបច្ចន្តគ្រាមបះបោរឡើងហើយ ព្រះរាជាទ្រង់ឲ្យប្រជុំគ្នាយ៉ាងប្រញាប់ គឺទ្រង់ញុំាងអាមាត្យ និងរាជទូតទាំងឡាយ ឲ្យសង្កត់សង្កិនសត្រូវ ក្នុងកាលនោះ ។ ពលដំរី ពលសេះ ពលពាក់គ្រឿងក្រោះ ពលកាន់ធ្នូ និងរថទាំងឡាយ សុទ្ធតែជាអ្នកក្លៀវក្លា មកប្រជុំគ្នាក្នុងកាលនោះ ។ ពួកអ្នកគ្រួ ពួកអ្នកខ្នាន់ប្រកេស ពួកអ្នកផ្ងូតទឹក ពួកអ្នកធ្វើផ្កាកម្រងទាំងអស់ សុទ្ធតែជាពួកពិជ័យសង្គ្រាមដ៏ក្លាហាន មកប្រជុំគ្នា ក្នុងកាលនោះ ។ ពួកបុរស មានដាវក្នុងដៃ មានធ្នូ និង

ខែលក្នុងដៃទាំងអស់ សុទ្ធតែជាពួកពិជ័យសង្គ្រាមដ៏កាច មកប្រជុំគ្នាក្នុងកាលនោះ ។ ពួកដំរីដ៏ប្រសើរ មានអាយុ ៦០ ឆ្នាំ មានខ្សែជង្គង់និងគ្រឿងប្រដាប់ជាវិការនៃមាស សុទ្ធតែជាដំរីចុះ ប្រេង ៣ អន្លើ ទាំងអស់មកប្រជុំគ្នាក្នុងទីនោះ ។ ក្រុមយុទ្ធនាធិការទាំងឡាយ ដែលមានការងារធ្វើហើយ ជាអ្នកអត់ធ្មត់ចំពោះត្រជាក់ ក្តៅ និងការបន្ទោបង់នូវលាមក មកប្រជុំគ្នាក្នុងកាលនោះ ។ សំឡេង ស័ង្ខ សំឡេងស្គរជាសំឡេងលាន់ឮឡើង ពួកជនទាំងអស់នោះ រីករាយដោយសំឡេងនោះ មកប្រជុំគ្នាក្នុងកាលនោះ ។ពួកជនទាំងអស់ចាក់ផ្លូលដោយច្បូកកាំបិតចៀរស្បែក ធ្នូ និងលំពែង ស្នែង ក្របី មកប្រជុំគ្នា ក្នុងកាលនោះ ។ កាលនោះ ខ្ញុំហ្នឹងឯង ជាស្តេច ឈ្មោះសង្គ្រាម ដែលគេមិនធ្លាប់ឈ្នះពាក់គ្រឿងក្រោះ បានយកដែក ស្រួចចាក់សត្វ ៦០ ពាន់ឲ្យតក់ស្លុត ។ ពួកមនុស្សបានស្រែក កងរំពងថា ឱហ្ន៎ ! ស្តេចនេះមិនប្រកបដោយធម៌ទេ កាលបើស្តេចនេះ ទៅឆេះក្នុងនរក កាលណាកាលនោះ យើងទើបនឹងមានទីបំផុតនៃទុក្ខ ។ កាលនោះ ខ្ញុំដេកលើ

ដំណាក់ ស្រាប់តែឃើញសត្វនរក ខ្ញុំដេកឥតលក់ទាំងថ្ងៃ ទាំងយប់ ពួកនិរយបាលទាំងនោះ គំរាមខ្ញុំ ដោយដែកស្រួច ។ ខ្ញុំគិតថា ប្រយោជន៍អ្វីដោយរាជ្យ ពាហនៈ និងពល ដែលអញប្រមាទហើយ រាជ្យ និងពលទាំងនោះ មិនអាចទ្រទ្រង់អញបានឡើយ មានតែញ៉ាំងអញឲ្យតក់ស្លុតសព្វៗ កាល ។ ប្រយោជន៍អ្វីដោយកូនប្រពន្ធ និងរាជ្យទាំងអស់របស់អញ បើដូច្នោះ អាត្មាអញគួរតែបួស នឹងជម្រះផ្លូវសម្រាប់ទៅកាន់ ( ព្រះនិព្វាន ) ។ ខ្ញុំឥតអាឡោះអាល័យ បានលះបង់ពួកដំរី ៦០ ពាន់ ដែលប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាង ជាដំរីដ៏ប្រសើរ មានខ្សែជង្គង់មាស ដែលពួកហ្មដំរីមានដៃកាន់លំពែងស្នែងក្របី និងកង្វេរឡើងជិះហើយ ក្នុងទីសមរភូមិ ខ្ញុំក្តៅក្រហាយសព្វ ដោយកម្មរបស់ខ្លួន ហើយចេញទៅកាន់ផ្នួស ។ ខ្ញុំលះចោលនូវសេះ ៦០ ពាន់ ដែលប្រដាប់ដោយគ្រឿងអលង្ការទាំងពួង នូវសេះអាជានេយ្យអំពីកំណើត និងសេះ សិន្ធព ជាពាហនៈដ៏លឿន ដែលពួកនាយសារថីមានធ្នូក្នុងដៃ និងពាក់គ្រឿងក្រោះឡើងជិះហើយ ទាំងអស់នោះ ហើយ

ចេញទៅកាន់ផ្នួស ។ ខ្ញុំបានលះបង់នូវរាជរថចំនួន ៦០ ពាន់ ដែលប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាង ដែលប្រកបបិទបាំង ដោយស្បែកខ្លាដំបង និងខ្លាធំ មានទង់ជ័យលើកឡើង ទាំងអស់នោះ ហើយចេញទៅកាន់ផ្នួស ។ ខ្ញុំលះបង់នូវមេគោ ដែលមានទឹកដោះ ៦០ ពាន់ និងគ្រឿងសម្រាប់ទ្រភាជន៍ទាំងអស់ ហើយចូលទៅកាន់ផ្នួស ។ ខ្ញុំលះបង់ពួកស្រី ៦០ ពាន់ ដែលស្អិតស្អាងដោយគ្រឿងអលង្ការគ្រប់យ៉ាង មានសំពត់ និងគ្រឿងអាភរណៈដ៏វិចិត្រ ពាក់កែវមណី និងកុណ្ឌល មានមុខទូលាយ មានមុខស្រស់ស្រាយ មានត្រគាកសាយមានចង្កេះ មូលរៀវ កំពុងកន្ទក់កន្ទេញទាំងនោះ ហើយចូលទៅកាន់ផ្នួស ។ខ្ញុំចេញចាកនគរហើយ ចូលទៅកាន់ព្រៃហេមពាន្ត សាងអាស្រមមួយ ទៀបភ្នំស៊ឹងភាគីរសី ។ ខ្ញុំធ្វើបណ្ណសាលា រួចហើយធ្វើរោងភ្លើង ខ្ញុំមានព្យាយាមប្រារព្ធហើយ មានចិត្តបញ្ជូនទៅហើយ ក្នុងអាស្រម ។ កាលខ្ញុំចម្រើនឈាននៅក្នុងមណ្ឌបក្តី ទៀបគល់ឈើក្តី ក្នុងផ្ទះស្ងាត់ក្តី ខ្ញុំមិនមានសេចក្តីតក់ស្លុតឡើយ ខ្ញុំមិនដែលជួបប្រទះភ័យ ដែលគួរ

ឲ្យខ្ចាចឡើយ ។ ព្រះសម្ពុទ្ធ ព្រះនាមសុមេធ ជាអ្នកប្រាជ្ញដ៏ប្រសើរ ប្រកបដោយករុណា ទ្រង់រុងរឿងដោយពន្លឺ គឺញាណកើតឡើងក្នុងលោក ក្នុងខណៈនោះឯង ។ យក្សមួយមានឫទ្ធិច្រើន នៅជិតអាស្រមរបស់ខ្ញុំ កាលព្រះពុទ្ធដ៏ប្រសើរ កើតឡើងហើយ ក៏ប្រាប់ខ្ញុំក្នុងកាលនោះថា ព្រះពុទ្ធ ព្រះនាមសុមេធ មានបញ្ញាចក្ខុ កើតឡើងហើយក្នុងលោក ទ្រង់ញុំាងប្រជុំជនទាំងអស់ ឲ្យឆ្លងហើយ ទ្រង់មុខជាចម្លងអ្នកដែរ ។ ខ្ញុំមានសេចក្តីស្ញប់ស្ញែងកើតឡើង ក្នុងខណៈនោះ ព្រោះឮពាក្យយក្សនោះ ខ្ញុំគិតថា ព្រះពុទ្ធ ព្រះពុទ្ធ ហើយរៀបចំនូវអាស្រម ។ ខ្ញុំលះបង់ឧសសម្រាប់ដុតភ្លើង រៀបចំក្រាលកម្រាល រួចថ្វាយបង្គំអាស្រម ហើយចេញអំពីព្រៃធំ ។ ខ្ញុំកាន់យកខ្លឹមចន្ទន៍ អំពីព្រៃធំនោះ ហើយចេញអំពីស្រុកមួយ ចូលទៅកាន់ស្រុកមួយ ចេញពីបុរីមួយ ចូលទៅកាន់បុរីមួយ ស្វែងរកព្រះពុទ្ធ ជាទេវតាដ៏ប្រសើរជាងទេវតា ហើយចូលគាល់ព្រះមានព្រះភាគ ។

សម័យនោះឯង ព្រះមានព្រះភាគ ព្រះនាមសុមេធ ជាលោក

នាយក ទ្រង់កំពុងប្រកាសនូវសច្ចៈ ៤ ញ៉ាំងប្រជុំជនដ៏ច្រើនទាក់ឲ្យត្រាស់ដឹង ។ ខ្ញុំផ្គងអញ្ជលីប្រណម្យលើក្បាល ថ្វាយបង្គំព្រះសម្ពុទ្ធហើយពោលនូវគាថាទាំងនេះថា កាលបើផ្កាម្លិះកំពុងរីក ក្លិននោះ ក៏ផ្សាយទៅបានតែក្នុងទីជិត កាលបើផ្កាចម្ប៉ា ផ្កាខ្ទឹង ផ្កាម្លិះ ផ្ការំដួលផ្កាការកេត និងផ្ការាំងកំពុងរីក ក្លិនក៏ផ្សាយទៅបានតែក្នុងទីបណ្តោយខ្យល់ បពិត្រព្រះអង្គជាមហាវីរបុរស ព្រះអង្គតែងផ្សាយដោយក្លិនគឺគុណធម៌ សព្វទិសទី ។ ខ្ញុំព្រះអង្គចេញចាកព្រៃហិមពាន្ត មកក្នុងទីនេះ ព្រោះបានធុំក្លិនព្រះអង្គ បពិត្រព្រះអង្គជាមហាវីរបុរស ទ្រង់ប្រសើរបំផុតក្នុងលោក មានយសច្រើន ខ្ញុំព្រះអង្គសូមបូជាចំពោះព្រះអង្គ ។ ខ្ញុំបានលាបព្រះសុមេធ ជាលោកនាយក ដោយខ្លឹមចន្ទន៍ដ៏ប្រសើរ រួចហើយញ៉ាំងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា អង្គុយស្ងៀមក្នុងខណៈនោះ ។

ព្រះមានព្រះភាគ ព្រះនាមសុមេធ ប្រសើរបំផុតក្នុងលោក ប្រសើរជាងពួកនរៈ ទ្រង់គង់ក្នុងភិក្ខុសង្ឃ ហើយត្រាស់គាថាទាំង

នេះថា បុគ្គលណា បានសរសើរគុណតថាគត ទាំងបានបូជាខ្ចឹមចន្ទន៍ ដល់តថាគត តថាគតនឹងសរសើរបុគ្គលនោះ អ្នកទាំងឡាយចូរស្តាប់ តថាគតនឹងសម្តែងចុះ ។ បុគ្គលនេះ នឹងមានពាក្យសម្តីគេគួរជឿ ជាបុគ្គលប្រសើរ មានចិត្តត្រង់ មានព្យាយាមដុតកម្តៅកិលេស មានពន្លឺ អស់ ២៥ កប្ប ។ បុគ្គលនេះ នឹងត្រេកអរក្នុងទេវលោក អស់ ២៦ រយកប្ប នឹងបានជាស្តេចចក្រពត្តិ អស់មួយពាន់ដង នឹងបានជាព្រះឥន្ទ្រ សោយរាជ្យជាស្តេចទេវតា អស់ ៣៣ ដង នឹងបានសោយប្រទេសរាជដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យកប្ប ។ មនុស្សនេះឯង លុះច្យុតចាកទីនោះមក នឹងបានទៅកើតជាមនុស្ស ប្រកបដោយបុញ្ញកម្ម នឹងមានផៅពង្សដ៏ប្រសើរ ។ ព្រាហ្មណ៍ម្នាក់ ឈ្មោះពាវរីជាអ្នកស្វាធ្យាយមន្ត ចេះចាំមន្ត ដល់នូវត្រើយនៃវេទ ទាំង ៣ បរិបូណ៌ដោយលក្ខណៈ ៣ យ៉ាង ។ បុគ្គលនេះនឹងបានជាសិស្សពាវរីព្រាហ្មណ៍នោះ ជាអ្នកដល់ត្រើយនៃមន្ត បានចូលគាល់ព្រះសម្មាសម្ពុទ្ធ ព្រះនាមគោតម ជាសក្យៈដ៏ប្រសើរ ។

ខ្ញុំបានទូលសួរនូវប្រស្នាដ៏ល្អិត ហើយញ៉ាំងចិត្តឲ្យរីករាយ កំណត់ដឹងអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ ភ្លើង ៣ យ៉ាងរបស់ខ្ញុំបានរលត់ហើយ ភពទាំងពួង ខ្ញុំបានដកចោលហើយ ខ្ញុំកំណត់នូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ កិលេសទាំងពួង ខ្ញុំបានដុតបំផ្លាញចោលហើយ ភពទាំងពួង ខ្ញុំបានដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្វីង ។ ឱហ្ន៎ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ ហ្ន៎ ! វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

រឿងនៅក្នុងគម្ពីរខុទ្ទកនិកាយ អបទាននេះ ជារឿងបង្ហាញឲ្យឃើញដល់ការកសាងសន្សំបុណ្យបារមីរបស់ព្រះតោទេយ្យត្ថេរ ដោយខ្លួនលោកតែម្នាក់ឯង ចំណែកការកសាងបុណ្យបារមី រួមជាមួយនឹងអាចារ្យពាវរីព្រាហ្មណ៍ ក្នុងជាតិដែលជាព្រះរាជាកដ្ឋវាហនៈ និងមាណព

ជទៃទៀតនោះ ដូចដែលបានពោលទុករួចមកហើយ នៅក្នុងជីវប្រវត្តិរបស់ព្រះអជិតត្ថេរនោះឯង ។

មួយវិញទៀត ក្នុងរឿងដែលទាក់ទងនឹងផលបុណ្យរបស់ព្រះតោទេយ្យត្ថេរ លោកគង់នឹងធ្វើសេចក្ដីល្អ ដូចគ្នានឹងព្រះអរហន្តសាវកអង្គដទៃទៀតដែរ ក្នុងសម័យបឋមពោធិកាលនោះ គឺធ្វើនាទីជាអ្នកជួយប្រកាសព្រះពុទ្ធសាសនា ឲ្យដល់មហាជនបានយល់ដឹងក្នុងកម្មនិងផលជាដើម ។

ព្រះតោទេយ្យត្ថេរ កាលលោកទ្រទ្រង់អាយុសង្ខារ មកដល់កាលដ៏សមគួរហើយ លោកក៏បានរំលត់ខន្ធបរិនិព្វានទៅហោង ។៚

( ជីវប្រវត្តិរបស់ព្រះតោទេយ្យត្ថេរ ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះកប្បត្ថេរ ✍

## “ លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័កផងដែរ ”

ព្រះកប្បត្ថេរ លោកតាំងនៅក្នុងលោកុត្តរធម៌ ជាព្រះមហាសាវ័ករបស់ព្រះពុទ្ធជាម្ចាស់ ហើយលោកក៏រាប់ចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័ក គឺជាសាវ័កធំរបស់ព្រះពុទ្ធ ៨០ រូប លោកក៏ធ្លាប់ជាកូនសិស្ស របស់អាចារ្យពាវរីម្នាក់ផងដែរ ក្នុងចំណោមកូនសិស្សច្បងទាំង ១៦ នាក់នោះ ដែលជាអ្នកសម្រេចមន្តក្នុងលទ្ធិនៃសាសនាព្រាហ្មណ៍ ទាំងខ្លួនលោកក៏មានកូនសិស្ស ១០០០ នាក់ដែរ និងរាប់ថាជាអ្នកមានការចេះដឹងបានល្អ ថែមទាំងជាអ្នកមានភាពអង់អាច ដោយអំណាចការអប់រំសន្សំបុណ្យបារមីរួចមកហើយ ជីវប្រវត្តិរបស់លោកមានសម្តែងទុកទាំងក្នុងអតីតជាតិ និងបច្ចុប្បន្នជាតិ ។

ជីវប្រវត្តិក្នុងអតីតជាតិរបស់ព្រះកប្បៈ តាមដែលមានសម្តែងប្រាកដនៅក្នុង **អដ្ឋកថាបរមត្ថជោតិកា** ដែលជាអដ្ឋកថាអធិប្បាយ

សេចក្តីបាលីនៅក្នុង **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** នៃ **បារាយនវគ្គ** និងក្នុង **អដ្ឋកថាមនោរថបូរណី** ដូចដែលពោលទុករួចមកហើយ នៅក្នុងជីវប្រវត្តិរបស់ព្រះមោឃរាជត្ថេរ ដូច្នេះ បើចង់បានសេចក្តីពិស្តារនោះ ចូរទៅមើលនៅក្នុងទីនោះចុះ ។

ជីវប្រវត្តិក្នុងបច្ចុប្បន្នជាតិរបស់ព្រះកប្បត្ថេរ តាមដែលមានសម្តែងនៅក្នុង **អដ្ឋកថាបរមត្ថជោតិកា** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីនៃ **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត ចូឡនិទ្ទេស** តែក្នុងទីនេះនឹងសូមលើកយកតែសាច់រឿងពីព្រះបាលីមក ដូចមានសេចក្តីថា ៈ-

ព្រះកប្បត្ថេរ ជាបុត្ររបស់ព្រាហ្មណ៍ម្នាក់ នៅក្នុងក្រុងសាវត្ថី កាលលោកចម្រើនវ័យធំដឹងក្តីឡើងហើយ បានចូលទៅថ្វាយខ្លួន ធ្វើជាកូនសិស្សរបស់អាចារ្យពាវរី ដើម្បីសូមការសិក្សាសិល្បវិជ្ជា ។ កាលដែលកប្បៈ ស្ម័គ្រចិត្តព្រមធ្វើជាកូនសិស្ស របស់អាចារ្យពាវរីនោះ ពីព្រោះអាចារ្យពាវរីព្រាហ្មណ៍ជាអ្នកចេះដឹងសព្វគ្រប់ ក្នុងវិជ្ជាត្រៃវេទ ជាពិសេសនោះ ក្នុងរាងកាយរបស់អាចារ្យពាវរីព្រាហ្មណ៍

មានលក្ខណៈពិសេស របស់មហាបុរស ៣ ប្រការ និងជាព្រះរាជ-បុរោហិត របស់ព្រះបាទបសេនទិកោសលទៀតផង ។

កាលជាខាងក្រោយមក អាចារ្យពាវរីក៏មានការនឿយណាយនៅក្នុងភាពជាឃរាវាស ទើបក្រាបទូលលាព្រះបាទបសេនទិកោសលចេញទៅបួស ក៏បានតាំងអាស្រមនៅក្បែរឆ្នេរនៃស្ទឹងគោធាវារី ដែលជាព្រំដែននៃដែនអស្សកៈ និងដែនមូឡកៈ តាំងចិត្តបំពេញផ្នួស និងជាគណាចារ្យ បានបង្រៀនមន្តផ្សេងៗ ដល់កូនសិស្សទាំងឡាយ ។

កប្បមាណព ព្រមដោយមាណពដែលជាកូនសិស្សដទៃៗ និងកូនសិស្សរបស់ខ្លួន ក៏បាននាំគ្នាចេញបួសតាមអាចារ្យពាវរីផងដែរ ។ កាលអាចារ្យពាវរី ចូលទៅតាំងអាស្រមនៅទីកន្លែងនោះ ក្នុងស្រុកនិងបរិវេណទាំងនោះ ក៏សម្បូរសប្បាយរុងរឿងឡើង ឯអាចារ្យពាវរីព្រាហ្មណ៍វិញក៏បានទទួលអំណោយអំពីពពួកអ្នកស្រុកទាំងនោះហើយបានយកទៅបរិច្ចាគទាន ជាប្រចាំរៀងរាល់ឆ្នាំ ។ ថ្ងៃមួយ អាចារ្យពាវរីបានបរិច្ចាគទានរួចហើយ ត្រឡប់មកកាន់អាស្រមវិញ គ្រានោះ

មានព្រាហ្មណ៍ចាស់ជរាម្នាក់ មានខ្លួនប្រឡាក់ស្រមកដោយធូលី ដើរធ្វើញ័រៗ ចូលទៅរកអាចារ្យពាវរី ហើយក៏និយាយសុំទ្រព្យ ៥០០ កហាបណៈ ។ ចំណែកអាចារ្យពាវរីព្រាហ្មណ៍ កាលបើបានឃើញព្រាហ្មណ៍នោះហើយក៏អញ្ជើញឲ្យអង្គុយលើអាសនៈរួចបានប្រាស្រ័យសាកសួរសុខទុក្ខ ហើយឆ្លើយប្រាប់ថា យើងអស់ទ្រព្យហើយ ពីព្រោះយើងបានបរិច្ចាគទានទើបតែរួចដែរ ។ ពេលនោះ ព្រាហ្មណ៍នោះក៏ខឹងឡើង ទើបគិតក្លែងជារឿងបោកបញ្ឆោត គំរាមកំហែងឡើងថា បើអ្នកមិនឲ្យទ្រព្យដល់យើងទេ រយៈពេល ៧ ថ្ងៃទៀត ក្បាលរបស់អ្នកត្រូវបែកជា ៧ ភាគ ។ អាចារ្យពាវរីបានស្តាប់ពាក្យរបស់ព្រាហ្មណ៍ចាស់នោះហើយ ភ័យខ្លាច រហូតដល់បរិភោគមិនបាន សម្រាន្តមិនលក់ ធ្វើឲ្យរាងកាយស្គាំងស្គម ។

គ្រានោះ មានទេវតាមួយអង្គ ជាអ្នកមានបំណងល្អក្នុងហេតុទាំងនោះ ទើបចូលទៅរកអាចារ្យពាវរីព្រាហ្មណ៍ ហើយពោលដាស់តឿនឲ្យមានសតិថា ព្រាហ្មណ៍ចាស់ជរានោះ ជាអ្នកពោលកុហកបោក

បញ្ឆោតទេតើ គេមិនដឹងថា អ្វីជាក្បាល អ្វីជាធម៌ ដែលជាហេតុធ្វើឲ្យក្បាលបែកជា ៧ ភាគនោះទេ ។ ពេលនោះ អាចារ្យពាវរីត្រិះរិះគិតថា ទេវតានេះគង់នឹងដឹង ក្នុងរឿងនេះហើយ ទើបសួរឡើងថា អ្វីជាក្បាល អ្វីដែលជាធម៌ នាំឲ្យក្បាលដាច់ធ្លាក់ចុះ ។

លំដាប់នោះ ទេវតាឆ្លើយថា សូម្បីខ្ញុំក៏មិនដឹងថា អ្វីជាក្បាល អ្វីជាធម៌ ដែលជាហេតុធ្វើឲ្យក្បាលដាច់ធ្លាក់ចុះដូចគ្នាដែរ តែក្នុងរឿងនេះ មានតែព្រះលោកនាយកទេ ទ្រង់ជាព្រះរាជឱរសរបស់សក្យរាជនៃរាជវង្សរបស់ព្រះបាទឱក្កាករាជ ព្រះអង្គប្រាកដជាជ្រាបក្នុងរឿងនេះហើយ តែឥឡូវនេះ ព្រះពុទ្ធអង្គទ្រង់គង់ប្រថាប់នៅក្នុងរាជវាំងនៃព្រះបាទបសេនទិកោសល នៅក្នុងក្រុងសាវត្ថីឯណោះ ។ អាចារ្យពាវរីបានឮដូច្នោះហើយក៏មានចិត្តរីករាយឡើងវិញ ក៏បានរំសាយភាពកើតទុក្ខទាំងនោះ ទើបបានហៅកូនសិស្សដែលសម្រេចមន្តមកប្រាប់ឲ្យដឹងថា ឥឡូវនេះ ព្រះសម្ពុទ្ធទ្រង់ជាអ្នកខ្ពង់ខ្ពស់បំផុត ជាងសព្វសត្វទាំងពួង ឥឡូវស្តេចឧប្បត្តិឡើងហើយក្នុងលោក ពួកអ្នកចូរទៅស៊ើបដំណឹង

ឲ្យដឹងការពិតមើល ។ ពួកកូនសិស្សទាំងនោះ សួរអាចារ្យពាវរីថា បពិត្រលោកអាចារ្យ ពួកខ្ញុំនឹងដឹងថា ព្រះពុទ្ធដោយឧបាយយ៉ាងណាទៅ ? អាចារ្យពាវរី ក៏បានពោលពន្យល់មាណពទាំងនោះ ឲ្យមើលទៅនៅក្នុងតម្រាលក្ខណព្យាករណ៍សាស្ត្រ ពួកអ្នកនឹងដឹងថា ព្រះសាស្តាមានលក្ខណៈប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ តាមដែលមានពោលទុកក្នុងមន្តទាំងឡាយយ៉ាងជាក់ច្បាស់ហើយ ។ បើព្រះអង្គនៅគ្រប់គ្រងផ្ទះ ព្រះអង្គនឹងបានជាស្តេចចក្រពត្តិ ជាអ្នកឈ្នះសត្រូវក្នុងទិសទាំងពួង ទ្រង់គ្រប់គ្រងប្រកបដោយធម៌ មិនប្រើអាជ្ញា និងអាវុធ ។ បើព្រះអង្គចេញទៅបួសវិញ នឹងបានសម្រេចជាព្រះសម្ពុទ្ធទ្រង់ជាសាស្តា ឯកក្នុងលោក ។ ប៉ុន្តែមួយទៀត បើចង់ដឹង ចូរនឹកទូលសួរបញ្ហាដោយចិត្ត ៣ ខ ព្រះអង្គប្រាកដជាត្រាស់តបបញ្ហានោះដោយព្រះវាចាដ៏ស្រទន់ តាមដែលចិត្តនឹកគិតទូលសួរ ។ ពេលដែលអាចារ្យពាវរីពោលប្រាប់វិធីនេះដូច្នេះហើយ ទើបចងបញ្ហាឲ្យមាណព

ទាំង ១៦ នាក់នោះ ដែលបានចេញទៅស៊ើបមើលដំណឹងរកព្រះភគវា កាលបើឃើញហើយ ចូរសួរបញ្ហានេះផង ។

កប្បមាណព ជាមាណពម្នាក់ នៅក្នុងចំណោមមាណព ១៦ នាក់នោះ បានធ្វើដំណើរទៅស៊ើបមើលដំណឹងព្រះមានព្រះភាគ រហូតទៅដល់បាសាណកចេតិយ នៃដែនមគធៈ និងបានជាអ្នកក្រាបទូលសួរបញ្ហាជាលំដាប់ទី ១០ កាលកប្បៈបានទទួលពុទ្ធានុញ្ញាត ហើយទើបក្រាបទូលសួរបញ្ហាឡើងថា

( កប្បមាណពដ៏មានអាយុទូលសួរថា ) ពួកសត្វស្ថិតនៅក្នុងកណ្តាលនៃសង្សារវដ្ត ត្រូវជរា និងមច្ចុគ្របសង្កត់ ក្នុងកាលដែលឱឃៈជាភ័យធំកើតឡើងហើយ បពិត្រព្រះអង្គនិរទុក្ខ សូមព្រះអង្គត្រាស់ប្រាប់នូវទីពឹងឲ្យទាន សេចក្តីទុក្ខក្នុងសង្សារវដ្តនេះ មិនគប្បីមានតទៅទៀតដោយប្រការណា សូមព្រះអង្គត្រាស់ប្រាប់នូវទីពឹងដល់ខ្ញុំព្រះអង្គ ( ដើម្បីវៀរចាកទុក្ខ ) ដោយប្រការនោះ ?

( ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ) ម្នាលកប្បៈ ពួក

សត្វស្ថិតនៅក្នុងកណ្តាលនៃសង្សារវដ្ត ត្រូវជរា និងមច្ចុគ្របសង្កត់ ក្នុងកាលដែលឱឃៈជាភ័យធំកើតឡើង ម្នាលកប្បៈ តថាគត នឹងសម្តែងប្រាប់នូវទីពឹងដល់អ្នក ។ ការមិនកង្វល់ ( ដោយកិលេស ) ការមិនប្រកាន់មាំនោះឯង ឈ្មោះថា ជាទីពឹងពំនាក់ មិនមានទីពឹងដទៃលើសជាងទេ តថាគតហៅទីពឹងនោះ ថាព្រះនិព្វាន ជាទីក្ស័យនៃជរា និងមច្ចុ ។ ជនទាំងឡាយណា ដឹងច្បាស់នូវព្រះនិព្វាននោះ ជាអ្នកមានសតិ រំលត់ទុក្ខក្នុងបច្ចុប្បន្ននេះ ជនទាំងនោះ ជាអ្នកមិនលុះក្នុងអំណាចនៃមារ ជនទាំងនោះ មិនដល់នូវភាពជាអ្នកបម្រើនៃមារឡើយ ។

ក្នុងពេលដែលចប់ព្រះគាថា ដែលព្រះសម្ពុទ្ធត្រាស់តបហើយ ធម្មចក្ខុ បានដល់ ភ្នែក គឺបញ្ញាដែលឃើញធម៌ទៅតាមសេចក្តីពិត បានកើតឡើងដល់ទេវតា និងមនុស្សជាច្រើន ដោយពិចារណាឃើញថា សភាវធម៌ណាមួយមានការកើតឡើងជាធម្មតា សភាវធម៌នោះក៏មានការរលត់ទៅវិញជាធម្មតាដែរ ។ គ្រានោះ ចិត្តរបស់កប្បមាណព

ក៏បានរួចផុតស្រឡះហើយ ចាកអាសវក្កិលេសទាំងឡាយ បរិក្ខាររបស់តាបស ដែលមានស្បែកខ្លាជាដើម និងពុកមាត់ ពុកចង្កាក៏បាត់ទៅមួយរំពេចពេលនោះឯង ព្រមជាមួយគ្នានឹងការបានសម្រេចជាព្រះអរហន្ត ។ កប្បមាណពបានភាវៈជាភិក្ខុ ព្រមដោយបរិក្ខារទាំង ៨ គ្រប់គ្រាន់ហើយ ក៏ប្រកាសឡើងថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គជាសាស្តាររបស់ខ្ញុំព្រះអង្គ ចំណែកខ្ញុំព្រះអង្គវិញ ជាសាវករបស់ព្រះអង្គ ។ ក្នុងទីបំផុតនៃសោឡសបញ្ហា ដែលព្រះមហាមុនីដោះស្រាយចប់នោះ កប្បមាណពព្រមដោយមាណព ១៥ នាក់ទៀត និងបរិវារទាំងអស់ បានក្រាបទូលសូមបព្វជ្ជាឧបសម្បទា នៅក្នុងធម្មវិន័យនេះ ។ ព្រះលោកនាយកក៏ទ្រង់ត្រាស់អនុញ្ញាត ឲ្យបព្វជ្ជាឧបសម្បទាជាភិក្ខុ ដោយវិធីឯហិភិក្ខុឧបសម្បទា ។

ព្រះកប្បត្ថេរ លោកបានធ្វើនូវសេចក្តីល្អជាច្រើន ដែលជាប្រយោជន៍ដល់ព្រះពុទ្ធសាសនានេះ ដោយការប្រកាសព្រះធម៌វិន័យរបស់ព្រះជិនស្រី ។

ព្រះកប្បត្ថេរ លោកទ្រទ្រង់អាយុសង្ខារ មកដល់កាលដ៏សមគួរហើយ លោកក៏បានរំលត់ខន្ធបរិនិព្វានទៅហោង ។

ការបរិនិព្វានរបស់លោក មិនឃើញមានសម្តែងទុកក្នុង **គម្ពីរ**ណាថា លោកបរិនិព្វានក្នុងទីណា ឬកន្លែងណាទីមួយនោះទេ ។l៚

( ជីវប្រវត្តិរបស់ព្រះកប្បត្ថេរ ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះជតុកណ្ណិត្ថេរ ✍

## " លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័កផងដែរ "

ព្រះជតុកណ្ណិត្ថេរ លោកមានព្រះអរហន្តធម៌ បានសម្រេចដល់សន្តិបទ ប្រាកដនៅក្នុងទំនៀមរបស់ព្រះអសីតិមហាសាវ័ក គឺជាសាវ័កធំរបស់ព្រះពុទ្ធជាម្ចាស់ ៨០ រូប មុននឹងមកបួសលោកក៏ធ្លាប់ជាអ្នករៀនចប់មន្តទាំងឡាយពីសម្នាក់របស់អាចារ្យពាវរី ទាំងខ្លួនលោក ក៏មានបរិវារ ១.០០០ នាក់ដែរ ជីវប្រវត្តិរបស់លោក ទើបគួរចាប់អារម្មណ៍យ៉ាងក្រៃលែង ដូចមានសេចក្តីខាងក្រោម ។

ជីវប្រវត្តិរបស់ជតុកណ្ណិត្ថេរ តាមដែលមានសម្តែងប្រាកដនៅក្នុង អដ្ឋកថាបរមត្ថជោតិកា ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីនៃ គម្ពីរខុទ្ទកនិកាយ សុត្តនិបាត នៃ បារាយនវគ្គ និងក្នុង គម្ពីរខុទ្ទកនិកាយ ចូឡនិទ្ទេស តែក្នុងទីនេះ នឹងសូមលើកយកតែសាច់រឿងពីព្រះបាលីមក ដូចមានសេចក្តីថា ៖-

ព្រះជតុកណ្ណិត្ថេរ ជាបុត្ររបស់ព្រាហ្មណ៍ម្នាក់ នៅក្នុងក្រុងសាវត្ថី កាលចលោកម្រើនវ័យធំដឹងក្តីឡើងហើយ បានចូលទៅថ្វាយខ្លួនធ្វើជាកូនសិស្សរបស់អាចារ្យពាវរីព្រាហ្មណ៍ ដើម្បីសូមការសិក្សាសិល្បវិជ្ជា ។ កាលដែលជតុកណ្ណី ស្ម័គ្រចិត្តព្រមធ្វើជាកូនសិស្សរបស់អាចារ្យពាវរីនោះ ពីព្រោះអាចារ្យពាវរីជាអ្នកចេះដឹងសព្វគ្រប់ក្នុងវិជ្ជាត្រៃវេទជាពិសេសនោះក្នុងរាងកាយរបស់អាចារ្យពាវរីមានលក្ខណៈពិសេសរបស់មហាបុរស ៣ ប្រការ និងជាព្រះរាជបុរោហិតរបស់ព្រះបាទបសេនទិកោសលទៀតផង ។

កាលជាខាងក្រោយមក អាចារ្យពាវរីក៏មានការនឿយណាយនៅក្នុងភាពជាយរាវាស ទើបក្រាបទូលលាព្រះបាទបសេនទិកោសលចេញទៅបួស ក៏បានតាំងអាស្រមនៅក្បែរឆ្នេរនៃស្ទឹងគោធាវារី ដែលជាព្រំដែននៃដែនអស្សកៈ និងដែនមូឡកៈ តាំងចិត្តបំពេញផ្នួស និងជាគណាចារ្យ បានបង្រៀនមន្តផ្សេងៗ ដល់កូនសិស្សទាំងឡាយ ។

ជតុកណ្ណី ព្រមដោយមាណពដែលជាកូនសិស្សដទៃៗ និង

កូនសិស្សរបស់ខ្លួន ក៏បាននាំគ្នាចេញបួសទៅតាមអាចារ្យពាវរីដែរ ។ កាលអាចារ្យពាវរី ចូលទៅតាំងអាស្រមនៅទីកន្លែងនោះ ក្នុងស្រុក និងបរិវេណទាំងនោះ ក៏សម្បូរសប្បាយរុងរឿងឡើង ឯអាចារ្យពាវរីវិញ ក៏បានទទួលអំណោយអំពីពពួកអ្នកស្រុកទាំងនោះ ហើយក៏បានយកទៅបរិច្ចាគទាន ជាប្រចាំរៀងរាល់ឆ្នាំ ។ ថ្ងៃមួយ អាចារ្យពាវរីបានបរិច្ចាគទានរួចហើយ ត្រឡប់មកកាន់អាស្រមរបស់ខ្លួនវិញ គ្រានោះមានព្រាហ្មណ៍ចាស់ជរាម្នាក់ មានខ្លួនប្រឡាក់ស្រមកដោយធូលី ដើរធ្វើញ័រៗ ចូលទៅរកពាវរីព្រាហ្មណ៍ ហើយក៏និយាយសុំទ្រព្យ ៥០០ កហាបណៈ ។ ចំណែកអាចារ្យពាវរី កាលបើបានឃើញព្រាហ្មណ៍នោះហើយ អញ្ជើញឲ្យអង្គុយលើអាសនៈ រួចក៏បានប្រាស្រ័យសាកសួរសុខទុក្ខ ហើយឆ្លើយប្រាប់ថា យើងអស់ទ្រព្យហើយ ពីព្រោះយើងបានបរិច្ចាគទានទើបតែរួចដែរ ។ ពេលនោះ ព្រាហ្មណ៍នោះក៏ខឹងឡើង ទើបគិតក្លែងជារឿងបោកបញ្ឆោតគំរាមកំហែងឡើងថា បើអ្នកមិនឲ្យទ្រព្យដល់យើងទេ រយៈពេល ៧ ថ្ងៃទៀត ក្បាលរបស់អ្នកត្រូវបែកជា ៧

ភាគ ។ អាចារ្យពាវរីបានស្តាប់ឮពាក្យរបស់ព្រាហ្មណ៍ចាស់នោះហើយ ភ័យខ្លាច រហូតដល់បរិភោគមិនបាន សម្រាន្តមិនលក់ ធ្វើឲ្យរាងកាយស្គាំងស្គម ។

គ្រានោះ មានទេវតាមួយអង្គ ជាអ្នកមានបំណងល្អក្នុងហេតុទាំងនោះ ទើបចូលទៅរកអាចារ្យពាវរីព្រាហ្មណ៍ ហើយពោលដាស់តឿនឲ្យមានសតិថា ព្រាហ្មណ៍ចាស់ជរានោះ ជាអ្នកពោលកុហកបោកបញ្ឆោតទេតើ គេមិនដឹងថា អ្វីជាក្បាល អ្វីជាធម៌ ដែលជាហេតុធ្វើឲ្យក្បាលបែកជា ៧ ភាគនោះទេ ។ ពេលនោះ អាចារ្យពាវរីត្រិះរិះគិតថា ទេវតានេះគង់នឹងដឹងក្នុងរឿងនេះហើយ ទើបសួរឡើងថា អ្វីជាក្បាល អ្វីដែលជាធម៌ នាំឲ្យក្បាលដាច់ធ្លាក់ចុះ ?

លំដាប់នោះ ទេវតាក៏ឆ្លើយថា សូម្បីខ្ញុំក៏មិនដឹងថា អ្វីជាក្បាល អ្វីជាធម៌ ដែលជាហេតុធ្វើឲ្យក្បាលដាច់ធ្លាក់ចុះដូចគ្នាដែរ តែក្នុងរឿងនេះ មានតែព្រះលោកនាយកទេ ទ្រង់ជាព្រះរាជឱរសរបស់សក្យរាជ នៃរាជវង្សរបស់ព្រះបាទឱក្កាករាជ ព្រះអង្គប្រាកដជាជ្រាប

ក្នុងរឿងនេះហើយ តែឥឡូវនេះ ព្រះពុទ្ធអង្គទ្រង់គង់ប្រថាប់នៅក្នុង រាជវាំងនៃព្រះបាទបសេនទិកោសល នៅក្នុងក្រុងសាវត្ថីឯណោះ ។ អាចារ្យពាវរីព្រាហ្មណ៍បានឮដូច្នោះហើយ មានចិត្តរីករាយឡើងវិញ ក៏បានរំសាយភាពកើតទុក្ខទាំងនោះ ទើបបានហៅកូនសិស្ស ដែល សម្រេចមន្តមកប្រាប់ឲ្យដឹងថា ឥឡូវនេះ ព្រះសម្ពុទ្ធទ្រង់ជាអ្នកខ្ពង់ ខ្ពស់បំផុត ជាងសព្វសត្វទាំងពួង ឥឡូវស្តេចឧប្បត្តិឡើងហើយក្នុង លោក ពួកអ្នកចូរទៅស៊ើបដំណឹងឲ្យដឹងការពិតមើល ។ ពួកកូន សិស្សទាំងនោះ សួរអាចារ្យពាវរីព្រាហ្មណ៍ថា បពិត្រលោកអាចារ្យ ពួកខ្ញុំនឹងដឹងថា ព្រះពុទ្ធដោយឧបាយយ៉ាងណាទៅ ? អាចារ្យពាវរី ព្រាហ្មណ៍ក៏បានពោលពន្យល់មាណពទាំងនោះ ឲ្យមើលទៅនៅក្នុង តម្រាលក្ខណព្យាករណ៍សាស្ត្រ ពួកអ្នកនឹងដឹងថា ព្រះសាស្តា មាន លក្ខណៈប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ តាមដែល មានពោលទុកក្នុងមន្តទាំងឡាយយ៉ាងជាក់ច្បាស់ហើយ ។ បើព្រះអង្គ នៅគ្រប់គ្រងផ្ទះ ព្រះអង្គនឹងបានជាស្តេចចក្រពត្តិ ជាអ្នកឈ្នះសត្រូវ

ក្នុងទិសទាំងពួង ទ្រង់គ្រប់គ្រងប្រកបដោយធម៌ មិនប្រើអាជ្ញា និងអាវុធ ។ បើព្រះអង្គចេញទៅបួសវិញ នឹងបានសម្រេចជាព្រះសម្ពុទ្ធ ទ្រង់ជាសាស្តាឯកក្នុងលោក ។ ប៉ុន្តែមួយទៀត បើចង់ដឹង ចូរឲ្យនឹកទូលសួរបញ្ហាដោយចិត្ត ៣ ខ ព្រះអង្គប្រាកដជាត្រាស់តបបញ្ហានោះ ដោយព្រះវាចាដ៏ស្រទន់ តាមដែលចិត្តនឹកគិតទូលសួរ ។ ពេលដែលអាចារ្យពាវរីព្រាហ្មណ៍ពោលប្រាប់វិធីនេះ ដូច្នេះហើយ ទើបចងបញ្ហាឲ្យមាណពទាំង ១៦ នាក់នោះ ដែលបានចេញទៅស៊ើបមើលដំណឹងរកព្រះលោកនាថ កាលបើឃើញហើយ ចូរសួរបញ្ហានេះផង ។

ជតុកណ្ណីមាណព ជាមាណពម្នាក់ នៅក្នុងចំណោមមាណព ១៦ នាក់នោះ បានធ្វើដំណើរទៅស៊ើបមើលដំណឹងព្រះមានព្រះភាគ រហូតទៅដល់បាសាណកចេតិយ នៃដែនមគធៈ និងបានជាអ្នកក្រាបទូលសួរបញ្ហាជាលំដាប់ទី ១១ កាលជតុកណ្ណីមាណព បានទទួលពុទ្ធានុញ្ញាតហើយ ទើបក្រាបទូលសួរបញ្ហាឡើងថា ៖-

( ជតុកណ្ណីមាណពដ៏មានអាយុ ទូលសួរថា ) បពិត្រព្រះ

អង្គជាវីរបុរស ខ្ញុំព្រះអង្គបានឮថា ព្រះអង្គមិនមានសេចក្តីប្រាថ្នាក្នុងកាម ឆ្លងអន្លង់ គឺកិលេសបានហើយ ទើបមកដើម្បីទូលសួរព្រះអង្គអ្នកមិនមានសេចក្តីប្រាថ្នា បពិត្រព្រះមានព្រះភាគ ព្រះអង្គមានដួងព្រះនេត្រ ឃើញនូវធម្មតាលោក ដែលកើតឡើងព្រម សូមព្រះអង្គសម្តែងនូវសន្តិបទ គឺធម៌ស្ងប់ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសម្តែងនូវសន្តិបទនោះ តាមសេចក្តីពិត ដល់ខ្ញុំព្រះអង្គឲ្យទាន ។ ព្រោះថា ព្រះមានព្រះភាគ តែងប្រព្រឹត្តគ្របសង្កត់នូវកាម ( ដូចព្រះអាទិត្យ មានតេជះ គឺរស្មីគ្របសង្កត់នូវប្រឹថពីមណ្ឌល ដោយតេជះដូច្នោះ ) បពិត្រព្រះអង្គមានបញ្ញាធំទូលាយ ដូចផ្ទៃនៃផែនដី សូមព្រះអង្គត្រាស់ប្រាប់នូវធម៌ ដែលខ្ញុំព្រះអង្គគួរដឹង ជាធម៌សម្រាប់លះជាតិ និងជរា ក្នុងអត្តភាពនេះ ដល់ខ្ញុំព្រះអង្គ ជាអ្នកមានបញ្ញាស្តួចស្តើងឲ្យទាន ។

( ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ) ម្នាលជតុកណ្ណី អ្នកចូរកម្ចាត់បង់ នូវតម្រេកក្នុងកាមទាំងឡាយចេញ ចូរឃើញនូវ

នៃកម្មះ ដោយសេចក្តីក្រេមក្បាន្ត កិលេសជាតិគ្រឿងកង្វល់ ដែលអ្នកប្រកាន់មាំ ( ដោយតណ្ហា និងទិដ្ឋិ ) ឬដែលគួរលះបង់ កុំមានដល់អ្នកឡើយ គ្រឿងខ្វល់ណាដែលមានហើយក្នុងកាលមុន អ្នកចូរឲ្យគ្រឿងខ្វល់នោះរីងស្ងួតចុះ គ្រឿងខ្វល់មានក្នុងខាងក្រោយ កុំមានដល់អ្នកឡើយ បើអ្នកមិនកាន់យកនូវគ្រឿងខ្វល់ក្នុងកណ្តាល អ្នកនឹងជាមនុស្សស្ងប់គ្រឿងខ្វល់បាន ។ ម្នាលព្រាហ្មណ៍ បុគ្គលតែងលុះក្នុងអំណាចនៃមច្ចុ ដោយអាសវៈទាំងឡាយណា អាសវៈទាំងនោះ រមែងមិនមានដល់បុគ្គល ដែលប្រាសចាកតម្រេក ក្នុងនាមរូបដោយសព្វគ្រប់ ។

ក្នុងពេលដែលចប់នូវព្រះគាថា ដែលជាព្រះពុទ្ធតម្រាស់ត្រាស់តបបញ្ហារបស់ព្រះភគវានោះ ធម្មចក្ខុ បានដល់ ភ្នែក គឺបញ្ញាដែលឃើញធម៌ទៅតាមសេចក្តីពិត បានកើតឡើងដល់មនុស្ស និងទេវតាជាច្រើន ដោយពិចារណាឃើញថា សភាវធម៌ណានីមួយ មានការកើតជាធម្មតា សភាវធម៌ទាំងនោះ ក៏មានការរលត់ទៅវិញជាធម្មតាដែរ

ព្រមទាំងមាណពដែលជាបរិវាររបស់ជតុកណ្ណីមាណព ក៏មានចិត្តរួចផុតស្រឡះ ចាកអាសវក្កិលេសទាំងឡាយ ដោយមិនមានការប្រកាន់តទៅទៀត ។

ព្រមគ្នានឹងការបានសម្រេចជាព្រះអរហន្តនោះ បរិក្ខាររបស់តាបស ដែលមានស្បែកខ្លាជាដើម និងពុកមាត់ពុកចង្កាក៏បាត់ទៅមួយរំពេចពេលនោះឯង ប្រាកដនូវគ្រឿងបរិក្ខារ មានចីវរជាដើម កើតឡើងដល់ជតុកណ្ណី កាលមានភាវៈជាភិក្ខុហើយ ក៏បានក្រាបទូលឡើងថា បពិត្រព្រះលោកនាយក ព្រះអង្គជាសាស្ដា របស់ខ្ញុំព្រះអង្គ ចំណែកខ្ញុំព្រះអង្គវិញ ជាសាវករបស់ព្រះអង្គ ។ កាលព្រះមានបុណ្យត្រាស់តបសោឡសបញ្ហាចប់ហើយ ជតុកណ្ណីមាណព ព្រមដោយមាណព ១៥ នាក់ទៀត និងបរិវារទាំងអស់ បាននាំគ្នាក្រាបទូលសូមបព្វជ្ជាឧបសម្បទា ក្នុងធម្មវិន័យនេះ ។ ព្រះមុនីក៏ទ្រង់ត្រាស់អនុញ្ញាតការបព្វជ្ជាឧបសម្បទា ដោយវិធីឯហិភិក្ខុឧបសម្បទា ។

ព្រះជតុកណ្ណិត្ថេរ ក្រោយពីបានសម្រេចជាព្រះអរហន្តហើយ

លោកបានតំណាលអំពីជីវប្រវត្តិរបស់ខ្លួនលោកទុក តាមដែលមានសម្ដែងនៅក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** ដូចមានសេចក្ដីថា ៈ-

កាលនោះ ខ្ញុំកើតជាសេដ្ឋីបុត្រ នៅក្នុងនគរហង្សវតី ជាអ្នកឆ្អែតស្កប់ស្កល់ ដោយកាមគុណទាំងឡាយ ញុំាងគេឲ្យបោមរោម ។ កាលនោះ ខ្ញុំឡើងកាន់ប្រាសាទទាំង ៣ ប្រើប្រាស់ភោគៈច្រើន ញុំាងគេឲ្យបោមរោមដោយការរាំច្រៀង ក្នុងប្រាសាទនោះ ។ តូរ្យតន្ត្រីប្រកបដោយការប្រគំដ៏ពីរោះ ដែលគេនាំមកដើម្បីខ្ញុំ ពួកស្រីទាំងអស់ កាលត្រេកអរ រមែងដឹកនាំនូវចិត្តខ្ញុំ ។ ពួកស្រីកំពុងពេញល្បែង ពួកស្រីតឿ ពួកស្រីពេញរូបរាង ពួកស្រីជំទង់ ពួកស្រីឡើងរ៉ាវ និងពួកស្រីគ្មក់ តែងបោមរោមខ្ញុំ សព្វៗ កាល ។ ពួកអ្នកប្រគំ ពួកអ្នកជំស្គរ ពួកអ្នករបាំជាច្រើនគ្នា ពួកអ្នករបាំប្រុសស្រី តែងបោមរោមខ្ញុំ សព្វៗ កាល ។ ពួកជាងកំណោរ ពួកអ្នកផុតទឹក ពួកអ្នកដាំស្ល ពួកអ្នកធ្វើកម្រងផ្កា ពួកសុបាសកជន ពួកអ្នកប្រដាល់ ពួកអ្នកចំបាប់ទាំងអស់នោះ តែងបោមរោមខ្ញុំ សព្វៗ

កាល ។ កាលពួកជនទាំងនោះ កំពុងលេង ក្នុងការបាញ់ធ្នូ ដែលសិក្សាស្ទាត់ហើយ ខ្ញុំឥតស្គាល់យប់ និងថ្ងៃឡើយ ដូចជាព្រះឥន្ទ្រស្ថិតនៅតាវត្តិង្សបុរី ។ ពួកអ្នកធ្វើផ្លូវ ពួកអ្នកកំព្រា ពួកយាចក ពួកអ្នកដើរជាច្រើនគ្នា អ្នកទាំងអស់នោះ តែងចូលទៅសុំទានក្នុងផ្ទះរបស់ខ្ញុំជានិច្ច ។ ពួកសមណៈ និងព្រាហ្មណ៍ជាបុញ្ញក្ខេត្តដ៏ប្រសើរ ញុំាងបុណ្យឲ្យចម្រើនឡើងដល់ខ្ញុំ តែងមកកាន់ផ្ទះខ្ញុំ ។ ពួកនិគ្រន្ថទាំងអស់នោះ គឺពួកបដកៈ លដុកៈ បុប្ផសាដកៈ ទណ្ឌិកៈ ឯកសិខៈ តែងមកកាន់ផ្ទះខ្ញុំ ។ ពួកអ្នកប្រព្រឹត្តចិញ្ចឹមជីវិតដោយប្រពៃ ពួកអ្នកបួន់ដណ្តើមទ្រព្យគេ ពួកអ្នកប្រព្រឹត្តធម៌ដូចគោ ពួកអ្នកប្រព្រឹត្តធម៌ដូចទេវតា ពួកអ្នកទ្រទ្រង់ល្អងធូលី ទាំងនោះ តែងមកកាន់ផ្ទះខ្ញុំ ។ ពួកអ្នកប្រព្រឹត្តធម៌ ពួកអ្នកដល់នូវការសម្រេចហេតុផ្សេងៗ ពួកអ្នកប្រជុំគ្នារម្ងាប់ការក្រោធ ពួកអ្នកមានតបៈ និងពួកអ្នកប្រព្រឹត្តនៅក្នុងព្រៃជាច្រើន តែងមកកាន់ផ្ទះខ្ញុំ ។ ពួកជនខ្វាក់ ពួកទមិឡ ពួកអ្នកដែនសាកុឡៈ ពួកអ្នកដែនមលយាលកៈ ពួកអ្នកដែនសវរៈ និងពួក

អ្នកដែនយោនកៈ តែងមកកាន់ផ្ទះខ្ញុំ ។ ពួកអ្នកដែនគន្ធកៈ ពួកអ្នកដែនមុណ្ឌកៈ ពួកអ្នកដែនកុជ្ជលៈ ពួកអ្នកដែនសានុវិន្ទកៈ ពួកអ្នកដែនអាពាពៈ និងពួកអ្នកដែនចិនៈ តែងមកកាន់ផ្ទះខ្ញុំ ។ ពួកអ្នកអាស្រ័យនៅភ្នំអលសន្ទកៈ ពួកអ្នកអាស្រ័យនៅភ្នំបល្លវៈ ពួកអ្នកឡើងកំពូលភ្នំ និងពួកបេតបុត្រ អ្នកនៅក្រៅដែន តែងមកកាន់ផ្ទះខ្ញុំ ។ ពួកជនអ្នកនៅក្នុងដែនមធុរៈ ពួកជនអ្នកនៅក្នុងដែនកោសល ពួកជនអ្នកនៅក្នុងដែនកាសី ពួកជនអ្នកនៅក្នុងដែនហត្ថិបុរី ពួកជនអ្នកនៅក្នុងដែនឥសិន្ទុៈ និងពួកជនអ្នកនៅក្នុងដែនមក្កលៈ តែងមកកាន់ផ្ទះខ្ញុំ ។ ពួកជនអ្នកនៅក្នុងដែនចេលាវកៈ ពួកជនអ្នកនៅក្នុងដែនអារម្ពៈ ពួកជនអ្នកនៅក្នុងដែនឱភាសៈ ពួកជនអ្នកនៅក្នុងដែនមេឃលៈ ពួកជនអ្នកនៅក្នុងដែនខុទ្ទកៈ និងពួកជនអ្នកនៅក្នុងដែនសុទ្ទកៈ ជាច្រើនតែងមកកាន់ផ្ទះខ្ញុំ ។ ពួកជនអ្នកនៅក្នុងដែនរោហកៈ ពួកជនអ្នកនៅក្នុងដែនសិន្ធវៈ ពួកជនអ្នកនៅក្នុងដែនចិត្តកៈ ពួកជនអ្នកនៅក្នុងដែនឯកកណ្ណិកៈ ពួកជនអ្នកនៅក្នុងដែនសុរដ្ឋៈ និងពួក

ជនអ្នកនៅក្នុងដែនអបរន្តៈ តែងមកកាន់ផ្ទះខ្ញុំ ។ ពួកកុមារនៅក្នុងដែនសុបារកៈ នៅក្នុងដែនមលយៈ នៅក្នុងសោណភូមិ នៅក្នុងដែនវិជ្ជហារ ពួកជនទាំងអស់នោះ តែងមកកាន់ផ្ទះខ្ញុំ ។ ពួកជាងផ្កាកម្រង ពួកជាងតម្បាញ ពួកជាងធ្វើស្បែក ពួកជាងចាំងឈើ ពួកអ្នកធ្វើការងារ និងពួកស្នូនថ្នាំង តែងមកកាន់ផ្ទះខ្ញុំ ។ ពួកជាងកែវមណី ពួកជាងលោហៈ ពួកជាងមាស ពួកជាងត្បាញសំពត់ និងពួកជាងសំណា ទាំងអស់នោះ តែងមកកាន់ផ្ទះខ្ញុំ ។ ពួកជាងកូនសរ ពួកជាងក្រឡឹង ពួកជាងតម្បាញ ពួកអ្នកធ្វើទឹកអប់ ពួកជាងជ្រលក់ និងជាងជួសជុល តែងមកកាន់ផ្ទះខ្ញុំ ។ ពួកអ្នកស្លប្រេង ពួកអ្នកនាំឧស ពួកអ្នកដងទឹក ពួកអ្នកបំព្រួំសាច់ ពួកអ្នកជាំស្ល និងពួកអ្នកឈ្លាសវៃក្នុងសំឡេង តែងមកកាន់ផ្ទះខ្ញុំ ។ ពួកអ្នកចាំទ្វារ ពួកអ្នករក្សាអង្គ ពួកអ្នកក្រងផ្កា ពួកអ្នកចាក់ចោលផ្កា ពួកអ្នកជិះដំរី និងពួកគង្វាលដំរី តែងមកកានផ្ទះខ្ញុំ ។ ខ្ញុំបានឲ្យសាមគ្គី ដល់ស្តេចឈ្មោះអានន្ទៈ ខ្ញុំបានបំពេញសេចក្តីខ្វះខាតដោយរតនៈ មានពណ៌ ។

ពួកជនជាច្រើនទាំងអស់ណា មានវណ្ណៈផ្សេងៗ គ្នា ដែលខ្ញុំបាន ពណ៌នារួចហើយ ខ្ញុំដឹងចិត្តនៃជននោះ ហើយឲ្យឆ្អែតស្កប់ស្កល់ដោយ រតនវត្ថុ ។ កាលបើគេនិយាយពាក្យពីរោះ កាលបើគេទូងស្គរឡើង កាលបើគេផ្លុំស័ង្ខឡើង ខ្ញុំត្រេកអរតែក្នុងផ្ទះរបស់ខ្លួន ។ សម័យនោះ ព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ ព្រមទាំងព្រះខីណាស្រពមួយ សែនអង្គ កើតមានឡើងហើយ ។ ព្រះសម្ពុទ្ធមានចក្ខុ ព្រមដោយ ភិក្ខុសង្ឃទាំងឡាយ ទ្រង់យាងទៅតាមថ្នល់ រុងរឿងដូចជាដើម ទីបព្រឹក្ស ដែលញុំាងទិសទាំងពួងឲ្យភ្លឺ ។ កាលបើព្រះលោកនាយក ស្តេចយាងទៅ ស្គរទាំងពួង ក៏លាន់ឮឡើង រស្មីរបស់ព្រះពុទ្ធ ក៏ ផ្សាយចេញទៅ ហាក់ដូចព្រះអាទិត្យទើបតែនឹងរះ ។ ខណៈនោះ ពន្លឺដ៏ធំទូលាយ ចាំងចូលទៅក្នុងផ្ទះទាំងឡាយ ដោយរស្មី ផ្សាយ ចូលទៅតាមចន្លោះសន្ទះទ្វារ ។ ខ្ញុំបានឃើញរស្មីរបស់ព្រះពុទ្ធហើយ បានប្រាប់បរិស័ទខ្ញុំថា ព្រះពុទ្ធដ៏ប្រសើរ ស្តេចយាងមកតាមថ្នល់នេះ ដោយឥតសង្ស័យ ។ ខ្ញុំបានចុះអំពីប្រាសាទដោយរហ័ស ទៅរង់ចាំ

ពាក់កណ្តាលផ្លូវ ថ្វាយបង្គំព្រះសម្ពុទ្ធ ហើយក្រាបបង្គំទូលថា សូមព្រះពុទ្ធ ព្រះនាមបទុមុត្តរៈ អនុគ្រោះដល់ខ្ញុំព្រះអង្គ ។ ព្រះពុទ្ធជាអ្នកប្រាជ្ញអង្គនោះ ទ្រង់ទទួលនិមន្ត មួយអន្លើដោយពួកភិក្ខុមួយសែនអង្គ ។ លុះខ្ញុំនិមន្តព្រះសម្ពុទ្ធរួចហើយ យាងព្រះអង្គទៅឯផ្ទះរបស់ខ្ញុំ ញ៉ាំងព្រះមហាមុនី ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយ និងទឹក ក្នុងផ្ទះនោះ ។ ខ្ញុំបានដឹងកាលដ៏គួរនៃព្រះពុទ្ធដ៏ប្រសើរ ជាតាទិបុគ្គល ទ្រង់ឆាន់រួចហើយ ក៏បម្រើព្រះពុទ្ធដ៏ប្រសើរ ដោយតូរ្យតន្ត្រី ព្រមទាំងចម្រៀង ។ ព្រះសម្ពុទ្ធ ទ្រង់ព្រះនាមបទុមុត្តរៈ ព្រះអង្គជ្រាបច្បាស់នូវលោក គួរទទួលគ្រឿងបូជា ទ្រង់គង់នៅខាងក្នុងផ្ទះ ហើយត្រាស់គាថាទាំងនេះថា

បុគ្គលណា បានបម្រើតថាគត ដោយតូរ្យតន្ត្រីផង បានថ្វាយបាយ និងទឹកផង ដល់តថាគត តថាគតនឹងសរសើរបុគ្គលនោះ អ្នកទាំងឡាយចូរស្តាប់ តថាគតនឹងសម្តែង ដូចតទៅនេះ នរៈនេះ នឹងមានគ្រឿងបរិភោគច្រើន ព្រមទាំងមាសប្រាក់ ភោជន នឹងបាន

សោយឯករាជ្យ ក្នុងទ្វីប ៤ ។ នរៈនេះ នឹងសមាទានសីល ៥ ត្រេកអរក្នុងកុសលកម្មបថ ១០ ប្រព្រឹត្តសមាទានកុសលធម៌ ហើយនឹងញ៉ាំងបរិស័ទឲ្យសិក្សា ។ តូរ្យតន្ត្រីមួយសែន និងពួកនារីមានខ្លួនប្រដាប់ប្រពៃ តែងគាល់បម្រើនរៈនេះជានិច្ច នេះជាផលនៃការបម្រើ ។ នរៈនេះ នឹងត្រេកអរក្នុងទេវលោក អស់ ៣០ ពាន់កប្ប បានជាព្រះឥន្ទ្រសោយរាជ្យ ជាស្តេចទេវតា អស់ ៦៤ ដង ។ នឹងបានជាស្តេចចក្រពត្តិ អស់ ៧៤ ដង បានសោយប្រទេសរាជដ៏ធំទូលាយ រាប់បានមួយអសង្ខេយ្យកប្ប ។ កន្លងទៅមួយសែនកប្ប នឹងមានព្រះបរមសាស្តា ព្រះនាមគោតម កើតក្នុងត្រកូល ព្រះបាទឱក្កាករាជ ត្រាស់ដឹងក្នុងលោក ។ នរៈនេះ បើចូលទៅកាន់កំណើតណា ទោះជាទេវតា ឬជាមនុស្ស នឹងជាអ្នកមានភោគៈមិនខ្វះខាត ក្នុងបច្ឆិមជាតិ នឹងបាននូវភាពជាមនុស្ស ។ ក្នុងកាលនោះ នរៈនេះជាអ្នកស្វាធ្យាយមន្ត ដល់នូវត្រើយ នៃវេទទាំង ៣ កាលស្វែងរកប្រយោជន៍ដ៏ឧត្តម នឹងត្រាច់ទៅតាមផែនដី ។ នរៈនេះ លុះកាលជា

ខាងក្រោយ ក៏ចេញបួស ត្រូវកុសលមូលជាស់តឿន នឹងត្រេកអរ ក្នុងសាសនានៃព្រះមានព្រះភាគ ព្រះនាមគោតម ។ នរៈនេះ នឹងញុំាងព្រះសម្ពុទ្ធ ព្រះនាមគោតម ជាសក្យៈដ៏ប្រសើរ ឲ្យប្រោសប្រាណ នឹងដុតកម្ដៅនូវកិលេសទាំងឡាយ ហើយបានជាព្រះអរហន្ត ។

ថ្ងៃនេះ ខ្ញុំនៅក្នុងសាសនានៃព្រះពុទ្ធជាសក្យបុត្រ ខ្ញុំឥតភ័យ ដូចជាស្ដេចខ្លាធំ ឬដូចជាកេសររាជសីហ៍ ជាស្ដេចម្រឹគនៅក្នុងព្រៃ ។ ខ្ញុំមិនដែលឃើញនូវកំណើតរបស់ខ្ញុំ ក្នុងទេវលោកកម្សត់ ឬក្នុងកំណើតមនុស្សកម្សត់ ឬក៏ក្នុងទុគ្គតិឡើយ នេះជាផលនៃការបម្រើ ។ ខ្ញុំជាអ្នកប្រកបក្នុងវិវេក ជាអ្នកមានចិត្តស្ងប់ មិនមានឧបធិ មិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរ កាត់ផ្ដាច់នូវទន្ទឹង ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំបានដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរ កាត់ផ្ដាច់នូវទន្ទឹង ។ ឱហ្ន៎! ដំណើរ ដែលខ្ញុំមកក្នុងសម្នាក់ព្រះពុទ្ធរបស់ខ្ញុំ ល្អណាស់ហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់

ហើយ ទាំងសាសនារបស់ ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយដែរ ។

រឿងក្នុងវគ្គដែលពោលមកនេះ ជារឿងដែលសម្តែងឲ្យឃើញ អំពីបុណ្យកុសលបារមីផ្ទាល់ខ្លួន របស់ព្រះជតុកណ្ណិត្ថេរ ដែលបានសន្សំទុករួចមកហើយ ដោយអស់រយៈពេលមួយសែនកប្ប ។ ចំណែកក្នុងរឿងដែលបានធ្វើបុណ្យកុសល រួមជាមួយនឹងអាចារ្យពាវរី និងមាណពដទៃទៀតនោះ នាសម័យនៃព្រះសម្មាសម្ពុទ្ធកស្សបជាម្ចាស់ ដូចដែលមានសម្តែងប្រាកដនៅក្នុង **អដ្ឋកថាបរមត្ថជោតិកា** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីនៃ **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** នៃ **បារាយនវគ្គ** ដូចដែលបានពោលរួចមកហើយ នៅក្នុងជីវប្រវត្តិរបស់ព្រះអជិតត្ថេរនោះឯង ។

បុណ្យរបស់ព្រះអរហន្តទាំងឡាយនោះ រមែងដើរទៅតាមពុទ្ធតម្រាស់ ដែលព្រះមានជោគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតរួចផុតហើយ អំពីអន្ទាក់ទាំងពួង សូម្បីអ្នកទាំងឡាយក៏ដូចគ្នា ដូច្នេះ ចូរអ្នកទាំងឡាយត្រាច់ទៅតាមជនបទ រាជធានីផ្សេងៗ ដើម្បីឲ្យបាន

ជាប្រយោជន៍ដល់មហាជនជាច្រើនផងចុះ ។ ដូច្នោះហើយ បានជាព្រះជតុកណ្ណិត្ថេរ គង់នឹងកាន់យកគោលការណ៍ទាំងនោះ ដើម្បីជាប្រយោជន៍ដល់ព្រះពុទ្ធសាសនានេះផង និងដើម្បីជាប្រយោជន៍ ដល់ពុទ្ធបរិស័ទផងដែរ ។

ព្រះជតុកណ្ណិត្ថេរ លោកទ្រទ្រង់អាយុសង្ខារ មកដល់កាលដ៏សមគួរហើយ លោកក៏បានរំលត់ខន្ធបរិនិព្វានទៅហោង ។

ការបរិនិព្វានរបស់លោក មិនឃើញមានសម្តែងទុកក្នុង **គម្ពីរ** ណាថា លោកបរិនិព្វានក្នុងទីណា ឬកន្លែងណានីមួយនោះទេ ។៚

( ជីវប្រវត្តិរបស់ព្រះជតុកណ្ណិត្ថេរ ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះភទ្រាវុធត្ថេរ ✍

## “ លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវកផងដែរ ”

ព្រះភទ្រាវុធ លោកមានអរិយធម្មសម្បត្តិថ្នាក់អសេក្ខបុគ្គល លោកក៏រាប់ចូលនៅក្នុងចំណោមព្រះអសីតិមហាសាវកផងដែរ គឺជាសាវកធំរបស់ព្រះពុទ្ធ ៨០ រូប មុននឹងលោកមកបួស លោកក៏ធ្លាប់បានជាកូនសិស្សរបស់អាចារ្យពាវរី ហើយបានរៀនចេះចប់វិជ្ជាត្រៃវេទទាំងខ្លួនលោកក៏មានបរិវារ១០០០ នាក់ ព្រះភទ្រាវុធជាព្រះមហាថេរៈដែលគួរឲ្យគោរពរាប់អាន ចំណែកជីវប្រវត្តិរបស់លោក មានសម្ដែងទុកទាំងអតីតជាតិ និងបច្ចុប្បន្នជាតិ ។

ជីវប្រវត្តិក្នុងអតីតជាតិរបស់ព្រះភទ្រាវុធត្ថេរ តាមដែលមានសម្ដែងទុកនៅក្នុង **អដ្ឋកថាបរមត្ថជោតិកា** ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីព្រះបាលីនៃ **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** នៃ **បារាយនវគ្គ** ដោយលោកធ្លាប់បានធ្វើបុណ្យកុសលធម៌ផ្សេងៗ រួមជាមួយគ្នានឹងអាចារ្យ

ពាវរី និងមាណព ១៥ នាក់ទៀត ព្រមទាំងបរិវារទាំងឡាយ របស់លោក រួចមកហើយ ក្នុងអតីតជាតិ តែក្នុងទីនេះ មិនបានលើកយកមកពោល ទៀតទេ ពីព្រោះបានពោលរួចមកហើយ នៅក្នុងជីវប្រវត្តិរបស់ព្រះ មោឃរាជត្ថេរ ដូច្នេះ បើអ្នកសិក្សាចង់ដឹងក្នុងរឿងនេះ សូមទៅមើល ក្នុងជីវប្រវត្តិព្រះមោឃរាជត្ថេរ ។

ចំណែកជីវប្រវត្តិក្នុងបច្ចុប្បន្នជាតិរបស់ព្រះភទ្រាវុធត្ថេរ តាម ដែលមានសម្ដែងប្រាកដនៅក្នុង **អដ្ឋកថាបរមត្ថជោតិកា** និងនៅក្នុង **គម្ពីរខុទ្ទកនិកាយ ចូឡនិទ្ទេស** តែក្នុងទីនេះ នឹងសូមលើកយកតែសាច់ រឿងក្នុងព្រះបាលីមក ដូចមានសេចក្ដីថា ៖-

ព្រះភទ្រាវុធត្ថេរ ជាបុត្ររបស់ព្រាហ្មណ៍ម្នាក់ នៅក្នុងក្រុង សាវត្ថី កាលលោកចម្រើនវ័យធំដឹងក្ដីឡើងហើយ បានចូលទៅថ្វាយ ខ្លួនធ្វើជាកូនសិស្សរបស់អាចារ្យពាវរីព្រាហ្មណ៍ ដើម្បីសូមការសិក្សា សិល្បវិជ្ជា ។ កាលដែលភទ្រាវុធ ស្ម័គ្រចិត្តព្រមធ្វើជាកូនសិស្ស របស់អាចារ្យពាវរីនោះ ពីព្រោះអាចារ្យពាវរី ជាអ្នកចេះដឹងសព្វគ្រប់

ក្នុងវិជ្ជាត្រៃវេទ ជាពិសេសនោះ ក្នុងរាងកាយរបស់អាចារ្យពាវរី មានលក្ខណៈពិសេស របស់ព្រះមហាបុរស ៣ ប្រការ និងជាព្រះរាជបុរោហិតរបស់ព្រះបាទបសេនទិកោសលទៀតផង ។

កាលជាខាងក្រោយមក អាចារ្យពាវរីក៏មានការនឿយណាយក្នុងភាពជាឃរាវាស ទើបក្រាបទូលលាព្រះបាទបសេនទិកោសលចេញទៅបួស បានតាំងអាស្រមនៅក្បែរឆ្នេរនៃស្ទឹងគោធាវរី ដែលជាព្រំដែននៃដែនអស្សកៈ និងដែនមូឡកៈ តាំងចិត្តបំពេញផ្នួស និងជាគណាចារ្យ បានបង្រៀនមន្តផ្សេងៗ ដល់កូនសិស្សទាំងឡាយ ។

កទ្រាវុធ ព្រមដោយមាណព ដែលជាកូនសិស្សដទៃៗ និងកូនសិស្សរបស់ខ្លួន ក៏បាននាំគ្នាចេញបួសទៅតាមអាចារ្យពាវរីដែរ ។ កាលអាចារ្យពាវរីព្រាហ្មណ៍ ចូលទៅតាំងអាស្រមនៅក្នុងទីកន្លែងនោះ ក្នុងស្រុក និងបរិវេណទាំងនោះ ក៏សម្បូរសប្បាយរុងរឿងឡើង ឯអាចារ្យពាវរីវិញ បានទទួលអំណោយអំពីពពួកអ្នកស្រុកទាំងនោះ ហើយក៏បានយកទៅបរិច្ចាគទាន ជាប្រចាំរៀងរាល់ឆ្នាំ ។ ថ្ងៃមួយ

អាចារ្យពាវរីបានបរិច្ចាគទានរួចហើយ ត្រឡប់មកកាន់អាស្រមវិញ គ្រានោះ មានព្រាហ្មណ៍ចាស់ជរាម្នាក់ មានខ្លួនប្រឡាក់ស្រមកដោយធូលី ដើរធ្វើញ័រៗ ចូលទៅរកអាចារ្យពាវរីព្រាហ្មណ៍ ហើយនិយាយសុំទ្រព្យ ៥០០កហាបណៈ ។ចំណែកអាចារ្យពាវរី កាលបើបានឃើញព្រាហ្មណ៍នោះហើយ ក៏អញ្ជើញឲ្យអង្គុយលើអាសនៈ រួចក៏បានប្រា-ស្រ័យសាកសួរសុខទុក្ខ ហើយឆ្លើយប្រាប់ថា យើងអស់ទ្រព្យហើយ ពីព្រោះយើងបានបរិច្ចាគទានទើបតែរួចដែរ ។ ពេលនោះ ព្រាហ្មណ៍នោះក៏ខឹងឡើង ទើបគិតក្លែងជារឿងបោកបញ្ឆោត គំរាមកំហែងឡើងថា បើអ្នកមិនឲ្យទ្រព្យដល់យើងទេ រយៈពេល ៧ ថ្ងៃទៀត ក្បាលរបស់អ្នកត្រូវបែកជា ៧ ភាគ ។ អាចារ្យពាវរីបានស្ដាប់ឮពាក្យរបស់ព្រាហ្មណ៍ចាស់នោះហើយ ភ័យខ្លាច រហូតដល់បរិភោគមិនបាន សម្រាន្តមិនលក់ ធ្វើឲ្យរាងកាយស្គាំងស្គម ។

គ្រានោះ មានទេវតាមួយអង្គ ជាអ្នកមានបំណងល្អនៅក្នុងហេតុទាំងនោះ ទើបចូលទៅរកអាចារ្យពាវរី ហើយពោលជាស់តឿនឲ្យមាន

សតិថា ព្រាហ្មណ៍ចាស់ជរានោះ ជាអ្នកពោលកុហកបោកបញ្ឆោត ទេតើ គេមិនដឹងថា អ្វីជាក្បាល អ្វីជាធម៌ ដែលជាហេតុធ្វើឲ្យក្បាល បែកជា ៧ ភាគនោះទេ ។ ពេលនោះ អាចារ្យពាវរីត្រិះរិះគិតថា ទេវតា នេះគង់ទឹងដឹង ក្នុងរឿងនេះហើយ ទើបសួរឡើងថា អ្វីជាក្បាល អ្វីដែល ជាធម៌ នាំឲ្យក្បាលដាច់ធ្លាក់ចុះ ?

លំដាប់នោះ ទេវតាឆ្លើយថា សូម្បីខ្ញុំក៏មិនដឹងថា អ្វីជាក្បាល អ្វីជាធម៌ ដែលជាហេតុធ្វើឲ្យក្បាលដាច់ធ្លាក់ចុះដូចគ្នាដែរ តែក្នុងរឿង នេះ មានតែព្រះលោកនាយកទេ ទ្រង់ជាព្រះរាជឱរសរបស់សក្យរាជ នៃរាជវង្សរបស់ព្រះបាទឱក្កាករាជ ព្រះអង្គប្រាកដជាជ្រាបក្នុងរឿង នេះហើយ តែឥឡូវនេះ ព្រះពុទ្ធអង្គទ្រង់គង់ប្រថាប់នៅក្នុងរាជវាំង នៃព្រះបាទបសេនទិកោសល នៅក្នុងក្រុងសាវត្ថីឯណោះ ។ អាចារ្យ ពាវរីបានឮដូច្នោះហើយ ក៏មានចិត្តរីករាយឡើងវិញ បានរំសាយភាព កើតទុក្ខទាំងនោះ ទើបបានហៅកូនសិស្សដែលសម្រេចមន្តមកប្រាប់ ឲ្យដឹងថា ឥឡូវនេះ ព្រះសម្ពុទ្ធទ្រង់ជាអ្នកខ្ពង់ខ្ពស់បំផុតជាងសព្វសត្វ

ទាំងពួង ឥឡូវស្ដេចទ្រង់ឧប្បត្តិឡើងហើយក្នុងលោក ពួកអ្នកចូរទៅ សុំបដំណឹងឲ្យដឹងការពិតមើល ។ ពួកកូនសិស្សទាំងនោះ សួរអាចារ្យ ពាវរីថា បពិត្រលោកអាចារ្យ ពួកខ្ញុំនឹងដឹងថា ព្រះពុទ្ធដោយឧបាយ យ៉ាងណាទៅ ។ អាចារ្យពាវរីបានពោលពន្យល់មាណពទាំងនោះ ឲ្យ មើលទៅនៅក្នុងតម្រាលក្ខណព្យាករណ៍សាស្ត្រ ពួកអ្នកនឹងដឹងថា ព្រះ លោកនាយក មានលក្ខណៈប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ តាមដែលមានពោលទុកក្នុងមន្តទាំងឡាយយ៉ាងជាក់ច្បាស់ ហើយ ។ បើព្រះអង្គនៅគ្រប់គ្រងផ្ទះ ព្រះអង្គនឹងបានជាស្ដេចចក្រពត្តិ ជាអ្នកឈ្នះសត្រូវ ក្នុងទិសទាំងពួង ទ្រង់គ្រប់គ្រងប្រកបដោយធម៌ មិនប្រើអាជ្ញា និងអាវុធ ។ បើព្រះអង្គចេញទៅបួសវិញ នឹងបាន សម្រេចជាព្រះសម្មាសម្ពុទ្ធ ទ្រង់ជាសាស្ដាឯកក្នុងលោក ។ ប៉ុន្តែមួយ ទៀត បើចង់ដឹង ចូរនឹកទូលសួរបញ្ហាដោយចិត្ត ៣ ខ ព្រះអង្គប្រាកដ ជាត្រាស់តបបញ្ហានោះ ដោយព្រះវាចាដ៏ស្រទន់ តាមដែលចិត្តនឹកគិត ទូលសួរ ។ ពេលដែលពាវរីពោលប្រាប់វិធីនេះ ដូច្នេះហើយ ទើបចង

បញ្ហាឲ្យមាណពទាំង ១៦ នាក់នោះ ដែលបានចេញទៅស៊ើបមើលដំណឹងរកព្រះលោកនាថ កាលបើឃើញហើយ ចូរសួរបញ្ហានេះផង ។

កទ្រាវុធមាណព ជាមាណពម្នាក់ ក្នុងចំណោមមាណព ១៦ នាក់នោះ បានធ្វើដំណើរទៅស៊ើបមើលដំណឹងព្រះមានព្រះភាគ រហូតទៅដល់បាសាណកចេតិយ នៃដែនមគធៈ និងបានជាអ្នកក្រាបទូលសួរបញ្ហាជាលំដាប់ទី ១២ កាលកទ្រាវុធ បានទទួលពុទ្ធានុញ្ញាតហើយ ទើបក្រាបទូលសួរបញ្ហាឡើងថា

( កទ្រាវុធដ៏មានអាយុទូលសួរថា ) ខ្ញុំព្រះអង្គសូមអារាធនាព្រះអង្គ អ្នកលះអាល័យ កាត់តណ្ហា មិនរំភើប ( ព្រោះលោកធម៌ ) លះសេចក្ដីត្រេកអរ ឆ្លងអន្លង់ហើយ រួចផុតស្រឡះហើយ លះធម៌គ្រឿងកំណត់ ( ដោយតណ្ហា និងទិដ្ឋិ ) ព្រះអង្គមានប្រាជ្ញាញាណបពិត្រព្រះអង្គជាវីរបុរស ពួកជនអ្នកនៅក្នុងជនបទផ្សេងៗ ចង់ស្ដាប់ព្រះវាចារបស់ព្រះអង្គ បានមកព្រមគ្នាហើយ អំពីជនបទនោះៗ បើបានស្ដាប់ព្រះវាចា របស់ព្រះអង្គហើយ នឹងត្រឡប់អំពីទីនេះវិញ

សូមព្រះអង្គទ្រង់ដោះស្រាយបញ្ហា ដើម្បីជនទាំងអម្បាលនោះ ព្រោះធម៌នោះ ព្រះអង្គបានជ្រាបហើយ ។

( ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ) ម្នាលកទ្រាវុធ បុគ្គលគួរកម្ចាត់បង់នូវតណ្ហា ជាគ្រឿងប្រកាន់មាំ ក្នុងចំណែកខាងលើ ក្នុងចំណែកខាងក្រោម និងក្នុងចំណែកទទឹង គឺត្រង់កណ្តាលឲ្យអស់ទៅ ព្រោះថា ជនទាំងអម្បាលនោះ ប្រកាន់មាំនូវរបស់ណាៗ ក្នុងលោក មាររមែងជាប់តាមសត្វ ដោយរបស់នោះៗ វិញដែរ ហេតុនោះ ភិក្ខុកាលដឹង ឃើញនូវពួកសត្វអ្នកជាប់នៅក្នុងអារម្មណ៍ផ្សេងៗ ជាទីតាំងនៃមច្ចុមារនេះថា សត្វជាប់នៅ ព្រោះសេចក្តីប្រកាន់មាំដូច្នេះ គប្បីជាអ្នកមានសតិ មិនប្រកាន់មាំ នូវគ្រឿងខ្វល់ក្នុងលោកទាំងពួង ។

ក្នុងខណៈដែលព្រះសម្ពុទ្ធត្រាស់តបបញ្ហានោះចប់ ទេវតា និងមនុស្សជាច្រើន ដោយអំណាចការអប់រំវាសនាបារមីរួមជាមួយគ្នានឹងព្រះកទ្រាវុធត្ថេរ ធម្មចក្ខុបានកើតឡើង ដោយពិចារណាឃើញទៅតាមសេចក្តីពិតថា សភាវធម៌ណានីមួយ មានការកើតឡើងជាធម្មតា

សភាវធម៌នោះ មានការរលត់ទៅវិញជាធម្មតាដែរ ។ ចំណែកព្រះកទ្រាវុធក៏មានចិត្តផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះអស់នូវការប្រកាន់ចំពោះសង្ខារ ។ គ្រានោះ បរិក្ខារផ្សេងៗ របស់តាបសដែលមានស្បែកខ្លាជាដើម និងពុកមាត់ ពុកចង្កាក៏បាត់អស់ទៅមួយរំពេចពេលនោះឯង ព្រមគ្នានឹងការបានសម្រេចព្រះអរហត្តផលនោះ បរិក្ខារទាំង ៨ បានមកប្រាកដឡើង ដូចជាព្រះថេរៈដែលមានវស្សា ១០០ ហើយដូច្នោះឯង ហើយក៏ប្រកាសឡើងថា បពិត្រព្រះសាស្តា ព្រះអង្គជាសាស្តារបស់ខ្ញុំព្រះអង្គ ចំណែកខ្ញុំព្រះអង្គវិញ ជាសាវ័ករបស់ព្រះអង្គ ។

កាលដែលព្រះមានជោគទ្រង់ដោះស្រាយសោឡសបញ្ហានោះចប់ហើយ កទ្រាវុធមាណព ព្រមដោយមាណព ១៥ នាក់ទៀត និងបរិវារទាំងអស់របស់លោក បានក្រាបទូលសូមបព្វជ្ជាឧបសម្បទា ក្នុងសាសនព្រហ្មចរិយធម៌នេះ ហើយព្រះមហាមុនីក៏ទ្រង់ត្រាស់អនុញ្ញាតឲ្យបព្វជ្ជាឧបសម្បទា ដោយវិធីឯហិភិក្ខុឧបសម្បទា ។

ទើបរាប់ថា ព្រះកង្ខារេវតត្ថេរ ជាមហាថេរៈ ពីព្រោះលោកបាន ជួយក្នុងការផ្សព្វផ្សាយព្រះធម៌វិន័យ ប្រព្រឹត្តទៅតាមកាលដ៏សមគួរ ដើម្បីជាប្រយោជន៍ ដល់ពុទ្ធបរិស័ទនាសម័យនោះ ។

ព្រះកង្ខារេវតត្ថេរ លោកទ្រទ្រង់អាយុសង្ខារ មកដល់កាល ដ៏សមគួរហើយ លោកក៏បានរំលត់ខន្ធបរិនិព្វានទៅហោង ។

ការបរិនិព្វានរបស់លោក មិនឃើញមានសម្ដែងទុកក្នុង គម្ពីរ ណាថា លោកបរិនិព្វានក្នុងទីណា ឬកន្លែងណាទីមួយនោះទេ ។ល។

( ជីវប្រវត្តិរបស់ព្រះកង្ខារេវតត្ថេរ ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះឧទយត្ថេរ ✍

## “ លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័កផងដែរ ”

ព្រះឧទយត្ថេរ លោកជាព្រះមហាថេរៈមួយរូប ជាអ្នកដល់នូវភាពខ្ពង់ខ្ពស់ក្នុងអរិយធម៌ ហើយក៏ជាអ្នកមានចំណេះចេះដឹង និងសមត្ថភាពល្អ ថែមទាំងបានទទួលនូវកិត្តិយសដ៏ខ្ពង់ខ្ពស់ គឺលោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័ក ដែលជាសាវ័កធំរបស់ព្រះពុទ្ធអង្គ ៨០ រូប ទាំងខ្លួនលោកមុននឹងមកបួស ធ្លាប់ធ្វើជាកូនសិស្សរបស់អាចារ្យពាវរី ហើយក៏ជាអ្នកទទួលនាំបញ្ហា របស់អាចារ្យពាវរីទៅក្រាបទូលសួរចំពោះព្រះមហាវីរៈ ដើម្បីពិសោធរកការពិតរបស់ព្រះអង្គថា ព្រះអង្គជាព្រះពុទ្ធមែន ឬក៏មិនមែន ទាំងជីវប្រវត្តិរបស់លោកវិញ មានសម្តែងប្រាកដទុកទាំងអតីតជាតិ និងបច្ចុប្បន្នជាតិផងដែរ ។

ការកសាងបុណ្យបារមីរបស់ព្រះឧទយៈ ដែលមានមកហើយ

ក្នុងអតីតជាតិនោះ ដោយមានពោលថា លោកក៏ធ្លាប់ធ្វើបុណ្យរួមជាមួយនឹងអាចារ្យពាវរី និងមាណព ១៥ នាក់ទៀត ព្រមទាំងបរិវាររបស់ខ្លួនផងដែរ ក្នុងរឿងទាំងអស់នោះ មានសម្តែងប្រាកដនៅក្នុង **អដ្ឋកថាបរមត្ថជោតិកា** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីព្រះបាលីនៃ **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** នៃ **បារាយនវគ្គ** ថា ៈ-

ការបំពេញសេចក្តីល្អរបស់លោក ដែលរួមជាមួយនឹងអាចារ្យពាវរី និងមិត្តធម៌នោះ ក្នុងទីនេះមិនបានលើកយកមកពិពណ៌នាតទៅទៀតទេ ពីព្រោះបានសម្តែងយ៉ាងពិស្តារហើយ នៅក្នុងជីវប្រវត្តិរបស់ព្រះមោឃរាជត្ថេរ ដូច្នេះ បើចង់បានសេចក្តីពិស្តារសូមទៅមើលក្នុងទីនោះចុះ មាននៅក្នុងជីវប្រវត្តិព្រះមោឃរាជត្ថេរ ។

ជីវប្រវត្តិរបស់ព្រះឧទយត្ថេរក្នុងបច្ចុប្បន្នជាតិ តាមដែលមានសម្តែងនៅក្នុង **អដ្ឋកថាបរមត្ថជោតិកា** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីនៃ **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** នៃ **បារាយនវគ្គ** និងនៅក្នុង **គម្ពីរខុទ្ទកនិកាយ ចូឡនិទ្ទេស** តែក្នុងទីនេះ នឹងសូមលើក

យកតែសាច់រឿងពីព្រះបាលីមក ដូចមានសេចក្តីថា ៈ-

ព្រះឧទយៈ ជាបុត្ររបស់ព្រាហ្មណ៍ម្នាក់ នៅក្នុងក្រុងសាវត្ថី កាលលោកចម្រើនវ័យធំដឹងក្តីឡើងហើយ បានចូលទៅថ្វាយខ្លួន ធ្វើជាកូនសិស្សរបស់អាចារ្យពាវរី ដើម្បីសូមការសិក្សាសិល្បវិជ្ជា ។ កាលដែលឧទយៈស្ម័គ្រចិត្តព្រមធ្វើជាកូនសិស្ស របស់អាចារ្យពាវរីនោះ ពីព្រោះអាចារ្យពាវរីជាអ្នកចេះដឹងសព្វគ្រប់ក្នុងវិជ្ជាត្រៃវេទ ជាពិសេសនោះ ក្នុងរាងកាយរបស់អាចារ្យពាវរី មានលក្ខណៈពិសេសរបស់មហាបុរស ៣ ប្រការ និងជាព្រះរាជបុរោហិតរបស់ព្រះបាទបសេនទិកោសលទៀតផង ។

កាលជាខាងក្រោយមក អាចារ្យពាវរីក៏មានការនឿយណាយនៅក្នុងភាពជាឃរាវាស ទើបក្រាបទូលលាព្រះបាទបសេនទិកោសលចេញទៅបួស បានតាំងអាស្រមនៅក្បែរឆ្នេរនៃស្ទឹងគោធាវារី ដែលជាព្រំដែននៃដែនអស្សកៈ និងដែនមូឡកៈ តាំងចិត្តបំពេញផ្នួស និងជាគណាចារ្យ បានបង្រៀនមន្តផ្សេងៗ ដល់កូនសិស្សទាំងឡាយ ។

ឧទយៈ ព្រមដោយមាណពដែលជាកូនសិស្សដទៃៗ និងកូនសិស្សរបស់ខ្លួន ក៏បាននាំគ្នាចេញបួសតាមអាចារ្យពាវរីដែរ ។ កាលអាចារ្យពាវរីព្រាហ្មណ៍ ចូលទៅតាំងអាស្រមនៅទីកន្លែងនោះ ក្នុងស្រុកនិងបរិវេណទាំងនោះ ក៏សម្បូរសប្បាយរុងរឿងឡើង ឯអាចារ្យពាវរីវិញ បានទទួលអំណោយអំពីពពួកអ្នកស្រុកទាំងនោះ ហើយក៏បានយកទៅបរិច្ចាគទាន ជាប្រចាំរៀងរាល់ឆ្នាំ ។ ថ្ងៃមួយ អាចារ្យពាវរីបានបរិច្ចាគទានរួចហើយ ត្រឡប់មកកាន់អាស្រមវិញ គ្រានោះ មានព្រាហ្មណ៍ចាស់ជរាម្នាក់ មានខ្លួនប្រឡាក់ស្រមកដោយធូលី ដើរធ្វើញ័រៗ ចូលទៅរកពាវរីព្រាហ្មណ៍ ហើយក៏និយាយសុំទ្រព្យ ៥០០ កហាបណៈ ។ ចំណែកអាចារ្យពាវរី កាលបើបានឃើញព្រាហ្មណ៍នោះហើយ អញ្ជើញឲ្យអង្គុយលើអាសនៈ រួចក៏បានប្រាស្រ័យសាកសួរសុខទុក្ខ ហើយឆ្លើយប្រាប់ថា យើងអស់ទ្រព្យហើយ ពីព្រោះយើងបានបរិច្ចាគទានទើបតែរួចដែរ ។ ពេលនោះ ព្រាហ្មណ៍នោះក៏ខឹងឡើង

ទើបគិតក្លែងជារឿងបោកបញ្ឆោត គំរាមកំហែងឡើងថា បើអ្នកមិនឲ្យទ្រព្យដល់យើងទេ រយៈពេល ៧ ថ្ងៃទៀត ក្បាលរបស់អ្នកត្រូវបែកជា ៧ ភាគ ។ អាចារ្យពាវរីបាន ស្តាប់ឮពាក្យរបស់ព្រាហ្មណ៍ចាស់នោះហើយ ភ័យខ្លាច រហូតដល់បរិភោគមិនបាន សម្រាន្តមិនលក់ធ្វើឲ្យរាងកាយស្គាំងស្គម ។

គ្រានោះ មានទេវតាមួយអង្គ ជាអ្នកមានបំណងល្អក្នុងហេតុទាំងនោះ ទើបចូលទៅរកពាវរី ហើយពោលដាស់តឿនឲ្យមានសតិថា ព្រាហ្មណ៍ចាស់ជរានោះ ជាអ្នកពោលកុហកបោកបញ្ឆោតទេតើគេមិនដឹងថា អ្វីជាក្បាល អ្វីជាធម៌ ដែលជាហេតុធ្វើឲ្យក្បាលបែកជា ៧ ភាគនោះទេ ។ ពេលនោះ ពាវរីត្រិះរិះគិតថា ទេវតានេះគង់នឹងដឹងក្នុងរឿងនេះហើយ ទើបសួរឡើងថា អ្វីជាក្បាល អ្វីដែលជាធម៌ នាំឲ្យក្បាលដាច់ធ្លាក់ចុះ ?

លំដាប់នោះ ទេវតាឆ្លើយថា សូម្បីខ្ញុំក៏មិនដឹងថា អ្វីជាក្បាល

អ្វីជាធម៌ ដែលជាហេតុធ្វើឲ្យក្បាលដាច់ធ្លាក់ចុះដូចគ្នាដែរ តែក្នុងរឿងនេះ មានតែព្រះលោកនាយកទេ ទ្រង់ជាព្រះរាជឱរសរបស់សក្យរាជនៃរាជវង្សរបស់ព្រះបាទឱក្កាករាជ ព្រះអង្គប្រាកដជាជ្រាបក្នុងរឿងនេះហើយ តែឥឡូវនេះ ព្រះពុទ្ធអង្គទ្រង់គង់ប្រថាប់នៅក្នុងរាជវាំងនៃព្រះបាទបសេនទិកោសល នៅក្នុងក្រុងសាវត្ថីឯណោះ ។ អាចារ្យពាវរីបានឮដូច្នោះហើយ ក៏មានចិត្តរីករាយឡើងវិញ បានរំសាយភាពកើតទុក្ខទាំងនោះ ទើបបានហៅកូនសិស្ស ដែលសម្រេចមន្តមកប្រាប់ឲ្យដឹងថា ឥឡូវនេះព្រះមានជោគទ្រង់ជាអ្នកខ្ពង់ខ្ពស់បំផុតជាងសព្វសត្វទាំងពួង ឥឡូវស្តេចឧប្បត្តិឡើងហើយក្នុងលោក ពួកអ្នកចូរទៅស៊ើបដំណឹង ឲ្យដឹងការពិតមើល ។ ពួកកូនសិស្សទាំងនោះ សួរអាចារ្យពាវរីថា បពិត្រលោកអាចារ្យ ពួកខ្ញុំនឹងដឹងថា ព្រះពុទ្ធ ដោយឧបាយយ៉ាងណាទៅ ? អាចារ្យពាវរី ក៏បានពោលពន្យល់មាណពទាំងនោះឲ្យមើលទៅនៅក្នុងតម្រាលក្ខណព្យាករណ៍សាស្ត្រ ពួកអ្នកនឹងដឹងថា

ព្រះលោកនាយក មានលក្ខណៈប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ តាមដែលមានពោលទុកក្នុងមន្តទាំងឡាយយ៉ាងជាក់ច្បាស់ហើយ ។ បើព្រះអង្គនៅគ្រប់គ្រងផ្ទះ ព្រះអង្គនឹងបានជាស្តេចចក្រពត្តិ ជាអ្នកឈ្នះសត្រូវក្នុងទិសទាំងពួង ទ្រង់គ្រប់គ្រងប្រកបដោយធម៌ មិនប្រើអាជ្ញា និងអាវុធ ។ បើព្រះអង្គចេញទៅបួសវិញ នឹងបានសម្រេចជាព្រះសម្មាសម្ពុទ្ធ ទ្រង់ជាសាស្តាឯកក្នុងលោក ។ ប៉ុន្តែមួយទៀត បើចង់ដឹង ចូរឲ្យនឹកទូលសួរបញ្ហាដោយចិត្ត ៣ ៖ ព្រះពុទ្ធអង្គប្រាកដជាត្រាស់តបបញ្ហានោះ ដោយព្រះវាចាដ៏ស្រទន់ តាមដែលចិត្តនឹកគិតទូលសួរ ។ ពេលដែលអាចារ្យពាវរីពោលប្រាប់វិធីនេះ ដូច្នេះហើយ ទើបចងបញ្ហាឲ្យមាណពទាំង ១៦ នាក់នោះ ដែលត្រូវចេញទៅស៊ើបមើលដំណឹងរកព្រះភគវា កាលបើឃើញហើយ ចូរសួរបញ្ហានេះផង ។

ឧទយមាណព ជាមាណពម្នាក់ ក្នុងចំណោមមាណព ១៦ នាក់នោះ បានធ្វើដំណើរទៅស៊ើបមើលដំណឹងព្រះមានព្រះភាគ រហូតទៅ

ដល់បាសាណកចេតិយ នៃដែនមគធៈ និងបានជាអ្នកក្រាបទូលសួរនូវបញ្ហាជាលំដាប់ទី ១៣ កាលឧទយៈ បានទទួលពុទ្ធានុញ្ញាតហើយ ទើបក្រាបទូលសួរបញ្ហាឡើងថា

( ឧទយមាណពដ៏មានអាយុ ទូលសួរថា ) ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយបញ្ហា ទើបមកគាល់ ( ដើម្បីសួរ ) ព្រះអង្គជាអ្នកបំពេញឈាន មានព្រះសន្តានប្រាសចាកធូលី គឺកិលេស មិនមានអាសវៈ ទ្រង់បានធ្វើកិច្ច ដែលគួរធ្វើស្រេចហើយ ដល់នូវត្រើយនៃធម៌ទាំងពួង សូមព្រះអង្គទ្រង់សម្តែងនូវវិមោក្ខធម៌ គឺព្រះអរហត្តជាគ្រឿងទម្លាយអវិជ្ជាចេញបាន ។

( ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ) ម្នាលឧទយៈ តថាគតពោលនូវការលះនូវកាមច្ឆន្ទៈ និងទោមនស្ស ទាំងពីរយ៉ាងផង ការបន្ទោបង់នូវសេចក្តីរួញរាផង ការឃាត់បង់នូវកុក្កុច្ចៈផង មានឧបេក្ខា និងសតិដ៏បរិសុទ្ធ មានសេចក្តីត្រិះរិះក្នុងធម៌ជាប្រធានថា ជា

វិមោក្ខធម៌ គឺព្រះអរហត្ត ជាគ្រឿងទម្លាយនូវអវិជ្ជាចេញបាន ។

សត្វលោក មានអ្វីជាគ្រឿងចងទុក អ្វីជាគ្រឿងសញ្ចរទៅនៃសត្វលោកនោះ លោកពោលថា និព្វានៗ ដូច្នេះ តើព្រោះលះអ្វីបាន ?

សត្វលោកមានសេចក្តីត្រេកត្រអាល ជាគ្រឿងចងទុក មានសេចក្តីគិតជញ្ជឹង ជាគ្រឿងសញ្ចរទៅនៃសត្វលោកនោះ ដែលលោកពោលថា និព្វាន ព្រោះលះតណ្ហាចេញបាន ។

កាលបុគ្គលមានសតិ ត្រាច់ទៅដូចម្តេច ទើបវិញ្ញាណរលត់ យើងខ្ញុំមកគាល់ ដើម្បីនឹងទូលសួរព្រះអង្គ និងបានស្តាប់ព្រះវាចារបស់ព្រះអង្គ ។

កាលបុគ្គលមិនត្រេកត្រអាលចំពោះវេទនា ទាំងខាងក្នុង ទាំងខាងក្រៅ មានសតិត្រាច់ទៅយ៉ាងនេះ ទើបវិញ្ញាណរលត់ទៅ ។

ក្នុងពេលដែលព្រះទសពល ត្រាស់តបបញ្ហានោះចប់ហើយ ធម្មចក្ខុបានកើតឡើងដល់មនុស្ស និងទេវតាជាច្រើន ព្រមទាំងបរិវារ

របស់ឧទយមាណព ដោយអំណាចការអប់រំវាសនាបារមី ដូចគ្នានឹងឧទយមាណព ក៏បានសម្រេចព្រះអរហត្តផល ព្រមគ្នានោះបរិក្ខាររបស់តាបស ដែលមានស្បែកខ្លាជាដើម ព្រមទាំងពុកមាត់ពុកចង្កាក៏បាត់អស់ទៅមួយរំពេចពេលនោះឯង បានប្រាកដនូវសំពត់កាសាវៈវិញ កាលមានភាវៈជាភិក្ខុហើយ បានពោលឡើងថា បពិត្រព្រះអង្គទ្រង់និរទុក្ខ ព្រះអង្គជាសាស្តារបស់ខ្ញុំព្រះអង្គ ចំណែកខ្ញុំព្រះអង្គវិញជាសាវករបស់ព្រះអង្គ ។ ក្រោយពីព្រះសម្មាសម្ពុទ្ធត្រាស់តបបញ្ហានោះចប់សព្វគ្រប់ហើយ ឧទយមាណព ព្រមដោយមាណព ១៥ នាក់ទៀត និងបរិវារទាំងអស់ បានសូមបព្វជ្ជាឧបសម្បទា ក្នុងធម្មវិន័យនេះ គ្រានោះ ព្រះសម្ពុទ្ធទ្រង់ត្រាស់អនុញ្ញាត ការបព្វជ្ជាឧបសម្បទាដោយវិធីឯហិភិក្ខុឧបសម្បទា ។

មានសេចក្តីក្នុងអដ្ឋកថាអធិប្បាយតទៅថា មាណព ១.០០០ នាក់ ដែលជាសិស្សរបស់ឧទយមាណព បានសម្រេចជាព្រះអរហន្ត

បានបួសដោយវិធីឯហិភិក្ខុឧបសម្បទា ហើយក៏បានពោលឡើងថា បពិត្រព្រះអង្គមានព្យាយាមធំ ព្រះអង្គជាសាស្តារបស់ខ្ញុំ ចំណែកខ្ញុំព្រះអង្គវិញជាសាវ័ករបស់ព្រះអង្គ ។

ព្រះឧទយត្ថេរ កាលលោកទ្រទ្រង់អាយុសង្ខារ មកដល់កាលដ៏សមគួរហើយ លោកក៏បានរំលត់ខន្ធបរិនិព្វានទៅហោង ។

ការបរិនិព្វានរបស់លោក មិនឃើញមានសម្តែងទុកក្នុង គម្ពីរណាថា លោកបរិនិព្វានក្នុងទីណា ឬកន្លែងណាទីមួយនោះទេ ៕

( ជីវប្រវត្តិរបស់ព្រះឧទយត្ថេរ ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះបោសាលត្ថេរ ✍

## “ លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័កផងដែរ ”

ព្រះបោសាលត្ថេរ លោកជាព្រះអសេក្ខបុគ្គល ដែលជាអ្នកទ្រទ្រង់គុណ គឺវុឌ្ឍិធម៌ដ៏ខ្ពង់ខ្ពស់ នៅក្នុងព្រះសាសនានេះ ទាំងខ្លួនលោកក៏មានកិត្តិយសផងដែរ ដោយបានសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវកមួយរូប ប៉ុន្តែមុននឹងលោកចូលមកបួសនៅក្នុងសាសនមណ្ឌលនេះ លោកធ្លាប់បានធ្វើជាកូនសិស្ស របស់អាចារ្យពាវរី ចំណែកជីវប្រវត្តិរបស់លោក មានសម្តែងទុកទាំងក្នុងអតីតជាតិនិងបច្ចុប្បន្នជាតិ ដែលគួរឲ្យចាប់អារម្មណ៍យ៉ាងក្រៃលែង ។

ជីវប្រវត្តិក្នុងអតីតជាតិរបស់ព្រះបោសាលត្ថេរ មានសម្តែងនៅក្នុង **អដ្ឋកថាបរមត្ថជោតិកា** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីនៃព្រះបាលីក្នុង **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** នៃ **បារាយនវគ្គ** ថាព្រះបោសាលត្ថេរ បានកសាងសន្សំបុណ្យកុសលបារមី រួមជាមួយ

*នឹងអាចារ្យពាវរី និងមាណព ១៥ នាក់ទៀត ព្រមជាមួយនឹងបរិវារ របស់ខ្លួន តែក្នុងទីនេះ មិនបានលើកយកមកទៀតទេ ពីព្រោះមាន នៅក្នុងជីវប្រវត្តិរបស់ព្រះមោឃរាជត្ថេរហើយ ដូច្នេះ បើអ្នកសិក្សា ចង់ដឹងក្នុងសេចក្តីនេះ សូមទៅមើលក្នុងទីនោះផងចុះ ។*

*ជីវប្រវត្តិក្នុងបច្ចុប្បន្នជាតិរបស់ព្រះបោសាលត្ថេរ មានសម្តែង នៅក្នុង **អដ្ឋកថាបរមត្ថជោតិកា** ដែលជាអដ្ឋកថាអធិប្បាយសេចក្តី នៃព្រះបាលីក្នុង **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** នៃ **បារាយនវគ្គ** និងក្នុង **គម្ពីរខុទ្ទកនិកាយ ចូឡនិទ្ទេស** តែក្នុងទីនេះ និងសូមលើកយកតែសាច់ រឿងពីព្រះបាលីមក ដូចមានសេចក្តីថា ៖-*

*ព្រះបោសាលត្ថេរ ជាបុត្ររបស់ព្រាហ្មណ៍ម្នាក់ នៅក្នុងក្រុង សាវត្ថី កាលលោកចម្រើនវ័យធំដឹងក្តីឡើងហើយ បានចូលទៅថ្វាយ ខ្លួនធ្វើជាកូនសិស្សរបស់អាចារ្យពាវរីព្រាហ្មណ៍ ដើម្បីសូមការសិក្សា សិល្បវិជ្ជា ។ កាលដែលបោសាលមាណព ស្ម័គ្រចិត្តព្រមធ្វើជាកូន សិស្ស របស់អាចារ្យពាវរីនោះ ពីព្រោះអាចារ្យពាវរី ជាអ្នកចេះដឹង*

សព្វគ្រប់ក្នុងវិជ្ជាត្រៃវេទ ជាពិសេសនោះ ក្នុងរាងកាយរបស់អាចារ្យពាវរី មានលក្ខណៈពិសេសរបស់មហាបុរស ៣ ប្រការ និងជាព្រះរាជបុរោហិតរបស់ព្រះបាទបសេនទិកោសលទៀតផង ។

កាលជាខាងក្រោយមក អាចារ្យពាវរីមានការនឿយណាយក្នុងភាពជាឃរាវាស ទើបក្រាបទូលលាព្រះបាទបសេនទិកោសលចេញទៅបួស បានតាំងអាស្រមនៅក្បែរឆ្នេរនៃស្ទឹងគោធាវរី ដែលជាព្រំដែននៃដែនអស្សកៈនិងដែនមូឡកៈ តាំងចិត្តបំពេញផ្នួស និងជាគណាចារ្យបានបង្រៀនមន្តផ្សេងៗ ដល់កូនសិស្សទាំងឡាយ ។

បោសាលៈ ព្រមដោយមាណពដែលជាកូនសិស្សដទៃៗ និងកូនសិស្សរបស់ខ្លួន បាននាំគ្នាចេញបួសទៅតាមអាចារ្យពាវរីដែរ ។ កាលអាចារ្យពាវរីព្រាហ្មណ៍ ចូលទៅតាំងអាស្រមនៅទីកន្លែងនោះ ក្នុងស្រុក និងបរិវេណទាំងនោះក៏សម្បូរសប្បាយរុងរឿងឡើង ឯអាចារ្យពាវរីវិញ បានទទួលអំណោយអំពីពួកអ្នកស្រុកទាំងនោះ ហើយក៏បានយកទៅបរិច្ចាគទាន ជាប្រចាំរៀងរាល់ឆ្នាំ ។ ថ្ងៃមួយ អាចារ្យពាវរី

បានបរិច្ចាគទានរួចហើយ ត្រឡប់មកកាន់អាស្រមវិញ គ្រានោះ មានព្រាហ្មណ៍ចាស់ជរាម្នាក់ មានខ្លួនប្រឡាក់ស្រមកដោយធូលី ដើរធ្វើញ័រៗ ចូលទៅរកពាវរីព្រាហ្មណ៍ ហើយក៏និយាយសុំទ្រព្យ ៥០០ កហាបណៈ ។ ចំណែកអាចារ្យពាវរីកាលបើបានឃើញព្រាហ្មណ៍នោះហើយ អញ្ជើញឲ្យអង្គុយលើអាសនៈ រួចក៏បានប្រាស្រ័យសាកសួរសុខទុក្ខ ហើយឆ្លើយប្រាប់ថា យើងអស់ទ្រព្យហើយ ពីព្រោះយើងបានបរិច្ចាគទានទើបតែរួចដែរ ។ ពេលនោះ ព្រាហ្មណ៍នោះក៏ខឹងឡើងទើបគិតក្លែងជារឿងបោកបញ្ឆោត គំរាមកំហែងឡើងថា បើអ្នកមិនឲ្យទ្រព្យដល់យើងទេ រយៈពេល ៧ ថ្ងៃទៀត ក្បាលរបស់អ្នកត្រូវបែកជា ៧ ភាគ ។ អាចារ្យពាវរីបានស្តាប់ឮពាក្យរបស់ព្រាហ្មណ៍ចាស់នោះហើយ ភ័យខ្លាច រហូតដល់បរិភោគមិនបាន សម្រាន្តមិនលក់ធ្វើឲ្យរាងកាយស្គាំងស្គម ។

គ្រានោះ មានទេវតាមួយអង្គ ជាអ្នកមានបំណងល្អក្នុងហេតុទាំងនោះ ទើបចូលទៅរកអាចារ្យពាវរី ហើយពោលជាស់តឿន ឲ្យ

មានសតិថា ព្រាហ្មណ៍ចាស់ជរានោះ គេជាអ្នកពោលពាក្យកុហក បោកបញ្ឆោតទេតើ គេមិនដឹងថា អ្វីជាក្បាល អ្វីជាធម៌ ដែលជាហេតុធ្វើឲ្យក្បាលបែកជា ៧ ភាគនោះទេ ។ ពេលនោះ អាចារ្យពាវរីត្រិះរិះគិតថា ទេវតានេះគង់នឹងដឹងក្នុងរឿងនេះហើយ ទើបសួរឡើងថា អ្វីជាក្បាល អ្វីដែលជាធម៌ នាំឲ្យក្បាលដាច់ធ្លាក់ចុះ ?

លំដាប់នោះ ទេវតាឆ្លើយថា សូម្បីខ្ញុំក៏មិនដឹងថា អ្វីជាក្បាល អ្វីជាធម៌ ដែលជាហេតុធ្វើឲ្យក្បាលដាច់ធ្លាក់ចុះដូចគ្នាដែរ តែក្នុងរឿងនេះ មានតែព្រះលោកនាយកទេ ទ្រង់ជាព្រះរាជឱរសរបស់សក្យរាជនៃរាជវង្សរបស់ព្រះបាទឱក្កាករាជ ព្រះអង្គប្រាកដជាជ្រាបក្នុងរឿងនេះហើយ តែឥឡូវនេះ ព្រះពុទ្ធអង្គទ្រង់គង់ប្រថាប់នៅក្នុងរាជវាំងនៃព្រះបាទបសេនទិកោសល នៅក្នុងក្រុងសាវត្ថីឯណោះ ។ អាចារ្យពាវរីបានឮដូច្នោះហើយ ក៏មានចិត្តរីករាយឡើងវិញ បានរំសាយភាពកើតទុក្ខទាំងនោះ ទើបបានហៅកូនសិស្សដែលសម្រេចមន្តមកប្រាប់ឲ្យដឹងថា ឥឡូវនេះ ព្រះសម្ពុទ្ធទ្រង់ជាអ្នកខ្ពង់ខ្ពស់បំផុត ជាងសព្វសត្វទាំង

ពួងឥឡូវស្ដេចឧប្បត្តិឡើងហើយក្នុងលោកពួកអ្នកចូរទៅស៊ើបដំណឹង ឲ្យដឹងការពិតមើល ។ ពួកកូនសិស្សទាំងនោះ សួរអាចារ្យពាវរីថា បពិត្រលោកអាចារ្យ ពួកខ្ញុំនឹងដឹងថា ព្រះពុទ្ធដោយឧបាយយ៉ាងណាទៅ ? អាចារ្យពាវរី ក៏បានពោលពន្យល់មាណពទាំងនោះ ឲ្យមើលទៅនៅក្នុងតម្រាលក្ខណព្យាករណ៍សាស្ត្រ ពួកអ្នកនឹងដឹងថា ព្រះមុនីមានលក្ខណៈប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ តាមដែលមានពោលទុកក្នុងមន្តទាំងឡាយយ៉ាងជាក់ច្បាស់ហើយ ។ បើព្រះអង្គនៅគ្រប់គ្រងផ្ទះ ព្រះអង្គនឹងបានជាស្ដេចចក្រពត្តិ ជាអ្នកឈ្នះសត្រូវក្នុងទិសទាំងពួង ទ្រង់គ្រប់គ្រងប្រកបដោយធម៌ មិនប្រើអាជ្ញា និងអាវុធ ។ បើព្រះអង្គចេញទៅបួសវិញ នឹងបានសម្រេចជាព្រះសម្ពុទ្ធទ្រង់ជាសាស្ដាឯកក្នុងលោក ។ ប៉ុន្តែមួយទៀត បើចង់ដឹង ចូរនឹកទូលសួរបញ្ហាដោយចិត្ត ៣ ខ ព្រះពុទ្ធអង្គប្រាកដជាត្រាស់តបបញ្ហានោះដោយព្រះវាចាដ៏ស្រទន់ តាមដែលចិត្តនឹកគិតទូលសួរ ។ពេលដែលអាចារ្យពាវរីពោលប្រាប់វិធីនេះដូច្នេះហើយ ទើបចងបញ្ហាឲ្យមាណព

ទាំង ១៦ នាក់នោះ ដែលបានចេញទៅស៊ើបមើលដំណឹងរកព្រះភគវា កាលបើឃើញហើយ ចូរសួរបញ្ហានេះផង ។

បោសាលមាណព ជាមាណពម្នាក់ក្នុងចំណោមមាណព ១៦ នាក់នោះ បានធ្វើដំណើរទៅស៊ើបមើលដំណឹងព្រះមានព្រះភាគ រហូតទៅដល់បាសាណកចេតិយ នៃដែនមគធៈ និងបានជាអ្នកក្រាបទូលសួរបញ្ហាជាលំដាប់ទី ១៤ កាលបោសាលៈ បានទទួលពុទ្ធានុញ្ញាតហើយ ទើបក្រាបទូលសួរបញ្ហាឡើងថា

( បោសាលមាណពដ៏មានអាយុទូលសួរថា ) ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយបញ្ហា ទើបមកគាល់ដើម្បីសួរ ព្រះអង្គសម្តែងព្រះប្រាជ្ញាញាណក្នុងកាលជាអតីត មិនញាប់ញ័រ ( ចំពោះសុខទុក្ខ ) មានសេចក្តីសង្ស័យកាត់បង់ហើយ ដល់នូវត្រើយនៃធម៌ទាំងពួង បពិត្រព្រះអង្គជាសក្យពង្ស ខ្ញុំព្រះអង្គសូមទូលសួរ ញាណរបស់បុគ្គលមានសេចក្តីកំណត់កត់សម្គាល់ក្នុងរូប បានជាក់ច្បាស់ ( បានសម្រេចដល់នូវរូបជ្ឈានហើយ ) លះបង់រូបារម្មណ៍ទាំងអស់បានហើយ ( កន្លងរូបជ្ឈានហើយ )

ឃើញទាំងខាងក្នុង ទាំងខាងក្រៅថា វត្ថុបន្តិចបន្តួចមិនមាន ( សម្រេចអរូបជ្ឈានដែលហៅថា អាកិញ្ចញ្ញាយតនៈ ) បុគ្គលមានសភាពដូច្នោះ តើព្រះអង្គគប្បី ប្រៀនប្រដៅដោយប្រការដូចម្តេចទៀត ?

( ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ) ម្នាលបោសាលៈ តថាគតជ្រាបវិញ្ញាណដ្ឋិតិ ( ភូមិជាទីតាំងនៃវិញ្ញាណ ) ទាំងអស់ ទើបជ្រាបបុគ្គលនោះ កំពុងស្ថិតនៅ មានចិត្តចុះស៊ប់ ក្នុង ( អាកិញ្ចញ្ញាយតនៈ ) មានអាកិញ្ចញ្ញាយតនៈនោះ ប្រព្រឹត្តទៅខាងមុខ មានអាកិញ្ចញ្ញាយតនៈជាដែនកើត មានសេចក្តីត្រេកត្រអាល ជាគ្រឿងប្រកបដូច្នេះ លុះតថាគត ជ្រាបច្បាស់យ៉ាងនេះហើយ លំដាប់អំពីអាកិញ្ចញ្ញាយតនជ្ឈាននោះ ក៏រមែងពិចារណាឃើញច្បាស់ ក្នុងសហជាតធម៌នោះ នេះឯងជាញាណ ដ៏ពិតប្រាកដ របស់ព្រាហ្មណ៍នោះ ជាអ្នកប្រព្រឹត្តចប់ព្រហ្មចរិយធម៌ ។

កាលព្រះសម្ពុទ្ធ ទ្រង់ត្រាស់តបបញ្ហានោះចប់ហើយ ធម្មចក្ខុបានដល់ ភ្នែក គឺបញ្ញាដែលឃើញធម៌ទៅតាមសេចក្តីពិត បានកើត

ឡើងដល់មនុស្ស និងទេវតាជាច្រើន ដោយពិចារណាឃើញថា សភាវធម៌ណាទីមួយ មានការកើតឡើងជាធម្មតា សភាវធម៌នោះ ក៏មានការរលត់ទៅវិញជាធម្មតាដែរ ព្រមទាំងមាណព ដែលជាបរិវាររបស់ខ្លួន ដោយការអប់រំវាសនាបារមី រួមជាមួយគ្នានឹងពោសាលៈ កាលបានសម្រេចព្រះអរហត្តផល ជាព្រះអសេក្ខបុគ្គល នៅក្នុងព្រះពុទ្ធសាសនានេះហើយ ព្រមគ្នានឹងការបានជាព្រះអរហន្តនោះ បរិក្ខាររបស់តាបស ដែលមានស្បែកខ្លាជាដើម ក៏បាត់អស់ទៅ មកប្រាកដឡើងវិញ នូវបរិក្ខារទាំង ៨ ដែលជាបរិក្ខាររបស់ភិក្ខុមកជំនួសវិញ ហើយពោលឡើងថា បពិត្រព្រះមានបុណ្យ ព្រះអង្គជាសាស្តារបស់ខ្ញុំព្រះអង្គ ចំណែកខ្ញុំព្រះអង្គវិញ ជាសាវករបស់ព្រះអង្គ ។

ក្នុងទីបំផុតនៃការត្រាស់តបសោឡសបញ្ហា របស់ព្រះជិនស្រីពោសាលមាណព ព្រមដោយមាណព ១៥ នាក់ទៀត និងបរិវារទាំងអស់ បាននាំគ្នាក្រាបទូល សូមព្រះមានជោគ ដើម្បីបព្វជ្ជា និងឧបសម្បទា ក្នុងធម្មវិន័យនេះ ។ គ្រានោះ ព្រះមានជោគ ទ្រង់ត្រាស់

អនុញ្ញាតការបព្វជ្ជាឧបសម្បទា ដោយវិធីឯហិភិក្ខុឧបសម្បទា ។

ព្រះបោសាលត្ថេរ លោកបានជាកម្លាំងដ៏សំខាន់ ក្នុងការផ្សព្វផ្សាយព្រះពុទ្ធសាសនា ពីព្រោះលោកជាព្រះមហាថេរៈ នៅក្នុងសម័យបឋមពោធិកាល ហើយបានជាប្រយោជន៍ និងសេចក្ដីសុខដល់ពុទ្ធបរិស័ទជាច្រើន ។

ព្រះបោសាលត្ថេរ លោកទ្រទ្រង់អាយុសង្ខារ មកដល់កាលដ៏សមគួរហើយ លោកក៏បានរំលត់ខន្ធបរិនិព្វានទៅហោង ។ល។

( ជីវប្រវត្តិរបស់ព្រះបោសាលត្ថេរ ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះបិង្គិយត្ថេរ ✍

## “ លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័កផងដែរ ”

ព្រះបិង្គិយត្ថេរ លោកជាព្រះខីណាស្រព ជាអ្នកប្រព្រឹត្តនូវព្រហ្មចរិយធម៌ក្នុងសាសនានេះចប់ហើយ ជាពិសេសនោះ លោកបានទទួលនូវកិត្តិយសដ៏ខ្ពង់ខ្ពស់ សង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័ក ប៉ុន្តែមុននឹងលោកមកបួស ព្រះបិង្គិយត្ថេរធ្លាប់ធ្វើជាកូនសិស្សរបស់អាចារ្យពាវរី ក្នុងឋានៈជាក្មួយប្រុសទៀតផង លោកជាសិស្សម្នាក់ ក្នុងបណ្តាសិស្សទាំងអស់ ដែលជាអ្នកនាំនូវបញ្ហាទៅក្រាបទូលសួរចំពោះព្រះមានជោគ ចំណែកជីវប្រវត្តិក៏មានសម្តែងទុកទាំងអតីតជាតិ និងបច្ចុប្បន្នជាតិផងដែរ ។

ជីវប្រវត្តិក្នុងអតីតជាតិរបស់ព្រះបិង្គិយត្ថេរ មានសម្តែងនៅក្នុងអដ្ឋកថាបរមត្ថជោតិកា ដែលជាអដ្ឋកថាអធិប្បាយសេចក្តីនៃបាលីក្នុងគម្ពីរខុទ្ទកនិកាយ សុត្តនិបាត នៃ បារាយនវគ្គ ថា ព្រះបិង្គិយត្ថេរលោក

ធ្លាប់បានសន្សំសេចក្ដីល្អផ្សេងៗ រួមជាមួយនឹងអាចារ្យពាវរី និងមាណព ១៥ នាក់ទៀត ព្រមទាំងបរិវាររបស់លោករួចមកហើយក្នុងអតីតជាតិ ប៉ុន្តែក្នុងទីនេះមិនបានលើកយកមកទៀតទេ ពីព្រោះបានសម្ដែងទុកយ៉ាងពិស្ដារនៅក្នុងជីវប្រវត្តិរបស់ព្រះមោឃរាជត្ថេរ ដូច្នេះ បើអ្នកសិក្សាចង់ដឹងក្នុងសេចក្ដីនេះ សូមទៅមើលផងចុះ ។

ជីវប្រវត្តិក្នុងបច្ចុប្បន្នជាតិរបស់ព្រះបិង្គិយត្ថេរ តាមដែលមានសម្ដែងនៅក្នុង **អដ្ឋកថាបរមត្ថជោតិកា** ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីព្រះបាលីក្នុង **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** នៃ **បារាយនវគ្គ** និងក្នុង **គម្ពីរខុទ្ទកនិកាយ ចូឡនិទ្ទេស** តែក្នុងទីនេះនឹងសូមលើកយកតែសាច់រឿងពីព្រះបាលីមក ដូចមានសេចក្ដីថា ៖-

ព្រះបិង្គិយៈ ជាបុត្ររបស់ព្រាហ្មណ៍ម្នាក់ នៅក្នុងក្រុងសាវត្ថី កាលលោកចម្រើនវ័យធំដឹងក្ដីឡើងហើយ បានចូលទៅថ្វាយខ្លួន ធ្វើជាកូនសិស្សរបស់អាចារ្យពាវរី ដើម្បីសូមការសិក្សាសិល្បវិជ្ជា ។ កាលដែលបិង្គិយមាណពស្ម័គ្រចិត្តព្រមធ្វើជាកូនសិស្ស របស់អាចារ្យ

ពាវរីនោះ ពីព្រោះអាចារ្យពាវរីជាអ្នកចេះដឹងសព្វគ្រប់ក្នុងវិជ្ជាត្រៃវេទជាពិសេសនោះ នៅក្នុងរាងកាយរបស់អាចារ្យពាវរី មានលក្ខណៈពិសេសរបស់មហាបុរស ៣ ប្រការ និងជាព្រះរាជបុរោហិតរបស់ព្រះបាទបសេនទិកោសលទៀតផង ។

កាលជាខាងក្រោយមក អាចារ្យពាវរីមានការនឿយណាយក្នុងភាពជាឃរាវាស ទើបក្រាបទូលលាព្រះបាទបសេនទិកោសលចេញទៅបួស ក៏បានតាំងអាស្រមនៅក្បែរច្នេរនៃស្ទឹងគោធាវារី ដែលជាព្រំដែននៃដែនអស្សកៈ និងដែនមូឡកៈ តាំងចិត្តបំពេញផ្នួស និងជាគណាចារ្យ បានបង្រៀនមន្តផ្សេងៗ ដល់កូនសិស្សទាំងឡាយ ។

បិង្គិយៈ ព្រមដោយមាណពដែលជាកូនសិស្សដទៃៗ និងកូនសិស្សរបស់ខ្លួន បាននាំគ្នាចេញបួស ទៅតាមអាចារ្យពាវរីដែរ ។ កាលអាចារ្យពាវរីព្រាហ្មណ៍ ចូលទៅតាំងអាស្រមនៅទីកន្លែងនោះ ក្នុងស្រុក និងបរិវេណទាំងនោះ ក៏សម្បូរសប្បាយរុងរឿងឡើង ឯអាចារ្យពាវរីវិញ បានទទួលអំណោយអំពីពពួកអ្នកស្រុកទាំងនោះ

ហើយក៏បានយកទៅបរិច្ចាគទាន ជាប្រចាំរៀងរាល់ឆ្នាំ ។ ថ្ងៃមួយ អាចារ្យពាវរីបានបរិច្ចាគទានរួចហើយ ត្រឡប់មកកាន់អាស្រមវិញ គ្រានោះ មានព្រាហ្មណ៍ចាស់ជរាម្នាក់ មានខ្លួនប្រឡាក់ស្រមកដោយធូលី ដើរធ្វើញ័រៗ ចូលទៅរកពាវរីព្រាហ្មណ៍ ហើយក៏និយាយសុំទ្រព្យ ៥០០ កហាបណៈ ។ ចំណែកអាចារ្យពាវរី កាលបើបានឃើញព្រាហ្មណ៍នោះហើយ អញ្ជើញឲ្យអង្គុយលើអាសនៈ រួចក៏បានប្រាស្រ័យសាកសួរសុខទុក្ខ ហើយឆ្លើយប្រាប់ថា យើងអស់ទ្រព្យហើយ ពីព្រោះយើងបានបរិច្ចាគទានទើបតែរួចដែរ ។ ពេលនោះ ព្រាហ្មណ៍នោះក៏ខឹងឡើង ទើបគិតក្លែងជារឿងបោកបញ្ឆោតគំរាមកំហែងឡើងថា បើអ្នកមិនឲ្យទ្រព្យដល់យើងទេ រយៈពេល ៧ ថ្ងៃទៀត ក្បាលរបស់អ្នកត្រូវបែកជា ៧ ភាគ ។ អាចារ្យពាវរីបានស្តាប់ពាក្យរបស់ព្រាហ្មណ៍ចាស់នោះហើយ ភ័យខ្លាច រហូតដល់បរិភោគមិនបាន សម្រាន្តមិនលក់ ធ្វើឲ្យរាងកាយស្គាំងស្គម ។

គ្រានោះ មានទេវតាមួយអង្គ ជាអ្នកមានបំណងល្អក្នុងហេតុ

ទាំងនោះ ទើបចូលទៅរកពាវរី ហើយពោលដាស់តឿនឲ្យមានសតិ ថា ព្រាហ្មណ៍ចាស់ជរានោះ ជាអ្នកពោលកុហកបោកបញ្ឆោតទេតើ គេមិនដឹងថា អ្វីជាក្បាល អ្វីជាធម៌ ដែលជាហេតុធ្វើឲ្យក្បាលបែកជា ៧ ភាគនោះទេ ។ ពេលនោះ អាចារ្យពាវរីត្រិះរិះគិតថា ទេវតានេះ គង់នឹងដឹងក្នុងរឿងនេះហើយ ទើបសួរឡើងថា អ្វីជាក្បាល អ្វីដែល ជាធម៌ នាំឲ្យក្បាលដាច់ធ្លាក់ចុះ ?

លំដាប់នោះ ទេវតាឆ្លើយថា សូម្បីខ្ញុំក៏មិនដឹងថា អ្វីជាក្បាល អ្វីជាធម៌ ដែលជាហេតុធ្វើឲ្យក្បាលដាច់ធ្លាក់ចុះដូចគ្នាដែរ តែក្នុងរឿង នេះ មានតែព្រះលោកនាយកទេ ទ្រង់ជាព្រះរាជឱរសរបស់សក្យរាជ នៃរាជវង្សរបស់ព្រះបាទឱក្កាករាជ ព្រះអង្គប្រាកដជាជ្រាបក្នុងរឿងនេះ ហើយ តែឥឡូវនេះ ព្រះពុទ្ធអង្គទ្រង់គង់ប្រថាប់នៅក្នុងរាជវាំងនៃព្រះ បាទបសេនទិកោសល ក្នុងក្រុងសាវត្ថីឯណោះ ។ អាចារ្យពាវរីបានឮ ដូច្នោះហើយ ក៏មានចិត្តរីករាយឡើងវិញ បានរំសាយភាពកើតទុក្ខ ទាំងនោះ ទើបបានហៅកូនសិស្ស ដែលសម្រេចមន្តមកប្រាប់ឲ្យដឹងថា

ឥឡូវនេះ ព្រះសម្ពុទ្ធទ្រង់ជាអ្នកខ្ពង់ខ្ពស់បំផុត ជាងសព្វសត្វទាំងពួង ឥឡូវស្ដេចឧប្បត្តិឡើងហើយក្នុងលោក ពួកអ្នកចូរទៅស៊ើបដំណឹងឲ្យដឹងការពិតមើល ។ ពួកកូនសិស្សទាំងនោះ សួរអាចារ្យពាវរីថា បពិត្រលោកអាចារ្យ ពួកខ្ញុំនឹងដឹងថា ព្រះពុទ្ធ ដោយឧបាយយ៉ាងណាទៅ ? អាចារ្យពាវរី ក៏បានពោលពន្យល់មាណពទាំងនោះ ឲ្យមើលទៅនៅក្នុងតម្រាលក្ខណព្យាករណ៍សាស្ត្រ ពួកអ្នកនឹងដឹងថា ព្រះមុនីមានលក្ខណៈប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ តាមដែលមានពោលទុកក្នុងមន្តទាំងឡាយយ៉ាងជាក់ច្បាស់ហើយ ។ បើព្រះអង្គនៅគ្រប់គ្រងផ្ទះ ព្រះអង្គនឹងបានជាស្ដេចចក្រពត្តិ ជាអ្នកឈ្នះសត្រូវក្នុងទិសទាំងពួង ទ្រង់គ្រប់គ្រងប្រកបដោយធម៌ មិនប្រើអាជ្ញា និងអាវុធ ។ បើព្រះអង្គចេញទៅបួសវិញ នឹងបានសម្រេចជាព្រះសម្ពុទ្ធទ្រង់ជាសាស្ដាឯកក្នុងលោក ។ ប៉ុន្តែមួយទៀត បើចង់ដឹង ចូរនឹកទូលសួរបញ្ហាដោយចិត្ត ៣ ខ ព្រះពុទ្ធអង្គប្រាកដជាត្រាស់តបបញ្ហានោះដោយព្រះវាចាដ៏ស្រទន់ តាមដែលចិត្តនឹកគិតទូលសួរ ។ ពេលដែល

អាចារ្យពាវរីពោលប្រាប់វិធីនេះ ដូច្នេះហើយ ទើបបង្គាប់ឲ្យមាណព ទាំង ១៦ នាក់នោះ ដែលបានចេញទៅស៊ើបមើលដំណឹងរកព្រះភគវា កាលបើឃើញហើយ ចូរសួរបញ្ហានេះផង ។

បង្គិយមាណព ជាមាណពម្នាក់នៅក្នុងចំណោមមាណព ១៦ នាក់នោះ បានធ្វើដំណើរទៅស៊ើបមើលដំណឹងព្រះមានព្រះភាគ រហូតទៅដល់បាសាណកចេតិយ នៃដែនមគធៈ និងបានជាអ្នកក្រាបទូលសួរនូវបញ្ហាជាលំដាប់ទី ១៦ កាលបិង្គិយៈ បានទទួលពុទ្ធានុញ្ញាតហើយ ទើបក្រាបទូលសួរបញ្ហាឡើងថា

( បិង្គិយមាណពដ៏មានអាយុទូលសួរថា ) ខ្ញុំព្រះអង្គជាមនុស្សចាស់ មិនសូវមានកម្លាំង មានពណ៌សម្បុរអាប់អន់ ភ្នែកក៏មិនសូវភ្លឺ ត្រចៀកសម្រាប់ស្តាប់ ក៏មិនសូវឮ សូមកុំឲ្យខ្ញុំព្រះអង្គវង្វេងវង្វាន់វិនាសក្នុងចន្លោះ សូមព្រះអង្គត្រាស់ប្រាប់ធម៌ ដែលខ្ញុំព្រះអង្គគួរដឹងជាគ្រឿងលះជាតិ និងជរា ក្នុងអត្តភាពនេះឲ្យទាន ?

( ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ) ម្នាលបិង្គិយៈ អ្នកចូរ

ឃើញថា ជនទាំងឡាយ ជាអ្នកប្រមាទ រមែងលំបាកព្រោះរូបជាហេតុ រមែងឈឺចាប់ក៏ព្រោះរូបជាហេតុ ម្នាលបិង្គិយៈ ព្រោះដូច្នោះ អ្នកកុំប្រមាទ ចូរលះរូបចោលចេញ ដើម្បីមិនកើតតទៅទៀត ។

ទិសទាំងឡាយនេះ គឺទិសធំ ៤ ទិសតូច ៤ ទាំងទិសខាងលើ ១ និងទិសខាងក្រោម ១ រួមត្រូវជា ១០ ទិស វត្ថុណាមួយក្នុងលោក ដែលព្រះអង្គមិនធ្លាប់ឃើញ មិនធ្លាប់ឮ មិនធ្លាប់ប៉ះពាល់ ឬមិនធ្លាប់ជ្រាប មិនមានទេ សូមព្រះអង្គត្រាស់ប្រាប់ធម៌ ដែលខ្ញុំព្រះអង្គគួរដឹងសម្រាប់លះជាតិ និងជរា ក្នុងអត្តភាពនេះ ?

( ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ) ម្នាលបិង្គិយៈ កាលបើអ្នកឃើញនូវពួកមនុស្ស ដែលត្រូវតណ្ហាកំពុងគ្របសង្កត់ ជាសត្វមានសេចក្តីក្តៅក្រហាយ កើតឡើងហើយ ត្រូវជរារួបរឹតហើយ ម្នាលបិង្គិយៈ ហេតុដូច្នោះ អ្នកកុំប្រមាទ ចូរលះតណ្ហាចោលចេញ ដើម្បីមិនឲ្យកើតតទៅទៀត ។

ក្នុងពេលចប់ព្រះពុទ្ធតម្រាស់របស់ព្រះមហេសី ធម្មចក្ខុដែល

ប្រាសចាកនូវមន្ទិល បានកើតឡើងដល់មនុស្ស និងទេវតាជាច្រើន ដោយការអប់រំវាសនាបារមីរួចមកហើយ ដូចគ្នានឹងបោសាលមាណព ដោយពិចារណាឃើញថា សភាវធម៌ណានីមួយ មានការកើតឡើងជាធម្មតា សភាវធម៌ទាំងអស់នោះ ក៏មានការរលត់ទៅវិញជាធម្មតាដែរ ។ ចំណែកបិង្គិយមាណព បានសម្រេចធម្មាភិសម័យ ថ្នាក់សេក្ខបុគ្គល (គឺបុគ្គលត្រូវមានការសិក្សាជាបន្តទៀត) ហៅថា ព្រះអនាគាមី ( អ្នកបានធម៌ថ្នាក់នេះ មិនត្រឡប់មកកាន់លោកនេះទៀតទេ) ។ហេតុដែលបិង្គិយមាណព បានសម្រេចត្រឹមតែជាព្រះអនាគាមី ពីព្រោះពេលដែលស្តាប់ព្រះលោកនាថ ទ្រង់ដោះស្រាយនូវបញ្ហានោះ ដោយមានចិត្តគិតរវើរវាយទឹកដល់អាចារ្យពាវរីថា អ៊ឺប្រុសរបស់យើងមិនមានឱកាស ដើម្បីមកស្តាប់ព្រះធម្មទេសនាដ៏ពីរោះយ៉ាងនេះសោះ ដោយអាស្រ័យទោសនៃការរវើរវាយចិត្ត ព្រោះតែសេចក្តីស្រឡាញ់ និងមានការកន្វល់ពីរឿងអាចារ្យពាវរី ទើបមិនអាចញ៉ាំងចិត្ត ឲ្យផុតស្រឡះចាកអាសវក្កិលេសបាន ។ គ្រានោះ បរិក្ខាររបស់តាបស ដែលមាន

ស្បែកខ្លាជាដើម និងពុកមាត់ពុកចង្កាក៏បាត់អស់ទៅមួយរំពេចពេលនោះឯង ព្រមគ្នានឹងការបានសម្រេចព្រះអនាគាមិផល បិង្គិយមាណពក៏មានភាវៈជាភិក្ខុឡើង ហើយក៏ប្រកាសឡើងថា បពិត្រព្រះអង្គទ្រង់និរទុក្ខ ព្រះលោកនាថជាសាស្តារបស់ខ្ញុំព្រះអង្គ ចំណែកខ្ញុំព្រះអង្គវិញជាសាវករបស់ព្រះអង្គ ។

កាលបើព្រះមុនី ទ្រង់ត្រាស់តបសោឡសបញ្ហានេះចប់ហើយ បិង្គិយមាណព ព្រមគ្នានឹងមាណព ១៥ នាក់ទៀត និងបរិវារទាំងអស់ក៏បានក្រាបទូលសូមបព្វជ្ជាឧបសម្បទា នៅក្នុងធម្មវិន័យនេះ ហើយព្រះមានព្រះភាគក៏ទ្រង់ត្រាស់អនុញ្ញាតនូវការបព្វជ្ជាឧបសម្បទានោះដោយវិធីឯហិភិក្ខុឧបសម្បទា ។ ក្រោយពីព្រះភគវា ទ្រង់ប្រទានការបព្វជ្ជាឧបសម្បទា ដល់មាណពទាំងអស់នោះរួចហើយ ក៏មានភិក្ខុប្រមាណ ១៦.០១៦ រូប និងបរិស័ទដទៃៗ ទៀត រួចហើយព្រះអង្គទ្រង់និមន្តត្រឡប់ទៅកាន់ក្រុងសាវត្ថីវិញទៅ ។

ព្រះបិង្គិយត្ថេរ បានក្រាបទូលនឹងព្រះមានជោគថា ខ្ញុំព្រះអង្គ

នឹងទៅប្រាប់នូវការកើតឡើងរបស់ព្រះពុទ្ធជាម្ចាស់ ដល់អាចារ្យពាវរី ពីព្រោះលោកបានផ្តាំហើយផ្តាំទៀត ។ គ្រានោះ កាលព្រះមានបុណ្យទ្រង់ត្រាស់អនុញ្ញាតក្នុងរឿងនោះហើយ ព្រះបិង្គិយត្ថេរ ក៏បាននិមន្តឡើងជិះយានពាហនៈ ធ្វើដំណើរទៅរហូតដល់ស្ទឹងគោធាវរី ហើយចុះចាកយាននិមន្តទៅថ្មើរជើង សំដៅទៅកាន់អាស្រម របស់អាចារ្យពាវរី ។ ខណៈនោះ អាចារ្យពាវរីក៏បានក្រឡេកឃើញព្រះបិង្គិយត្ថេរមិនមានគ្រឿងបរិក្ខាររបស់តាបសជាប់នឹងខ្លួនទៀត ដោយមានភាវៈជាភិក្ខុកំពុងនិមន្តចូលមក ទើបយល់ថា ព្រះពុទ្ធទ្រង់ឧប្បត្តិឡើងក្នុងលោកពិតប្រាកដហើយ ។ លុះព្រះបិង្គិយត្ថេរនិមន្តទៅដល់អាចារ្យពាវរីសួរឡើងថា បពិត្រលោកម្ចាស់បិង្គិយៈ ព្រះពុទ្ធអង្គទ្រង់ឧប្បត្តិឡើងក្នុងលោកពិតហើយឬ ? ព្រះបិង្គិយៈតបឡើងថា ត្រូវហើយព្រាហ្មណ៍ ព្រះពុទ្ធទ្រង់ឧប្បត្តិឡើងក្នុងលោកមែន ព្រះអង្គបានសម្តែងធម៌ឲ្យដល់ពួកអាត្មាបានស្តាប់ នៅឯបាសាណកចេតិយ ហេតុដូច្នេះអាត្មា នឹងសម្តែងធម៌ទាំងនោះ ឲ្យលោកអាចារ្យបានស្តាប់ដែរ ។

អាចារ្យពាវរី ព្រមដោយបរិវារ បានបូជាព្រះបិង្គិយត្ថេរ នូវគ្រឿងសក្ការៈរួចហើយ ក៏ឲ្យរៀបចំអាសនៈប្រគេនដល់ព្រះបិង្គិយៈៗ ឡើងគង់លើធម្មាសនៈនោះហើយ ក៏បានសម្តែងធម៌ តាមដែលព្រះមហាវីរបុរសទ្រង់សម្តែងហើយនោះ ដោយព្រះបិង្គិយត្ថេរ លើកយកសេចក្តីនៃព្រះធម៌ទាំងអស់នោះមួយមាតិកាៗ មកសម្តែងដល់អាចារ្យពាវរីបានស្តាប់ថា

ព្រះភគវា ទ្រង់សម្តែងធម៌ ដែលជាធម៌ត្រាស់ដឹងឯង ជាធម៌ដែលមិនមានកំណត់ពេល ជាធម៌ដែលអស់ទៅនូវតណ្ហា ជាធម៌ដែលមិនមានអន្តរាយដល់អាត្មា ព្រះនិព្វានមិនបានមានឧបមាក្នុងទីណាៗ ។ គ្រានោះ អាចារ្យពាវរីសួរថា បពិត្រលោកម្ចាស់បិង្គិយៈ ហេតុអ្វី បានជាលោកម្ចាស់ចេញចាកអំពីព្រះគោតមមក ព្រះអង្គជាអ្នកមានព្រះបញ្ញាដ៏ធំទូលាយ ដូចជាផែនដី ។ ព្រះបិង្គិយត្ថេរ ត្រាស់តបថា នែព្រាហ្មណ៍ អាត្មាមកនេះ មិនមែននៅប្រាសចាកព្រះគោតមទេ ដែលទ្រង់មានព្រះបញ្ញាដ៏ធំទូលាយ ដូចជាផែនដី ។ អាត្មាឃើញព្រះគោតម

ដោយចិត្តដូចឃើញដោយភ្នែក អាត្មាជាអ្នកមិនប្រមាទទាំងពេលយប់ ទាំងពេលថ្ងៃ ព្រោះដូច្នោះ ទើបអាត្មាពោលថា អាត្មាមិននៅប្រាសចាក ព្រះគោតមទេ ។ ធម៌ទាំងនោះ គឺសទ្ធា បីតិ មនៈ និងសតិរបស់អាត្មា រមែងមិនវិនាសប្រាសចាកសាសនារបស់ព្រះគោតមជាម្ចាស់ឡើយ ។ ព្រះគោតម ទ្រង់មានព្រះបញ្ញាដ៏ធំទូលាយ ដូចជាផែនដី ប្រសិនបើ ស្តេចយាងទៅកាន់ទិសណាៗ អាត្មាក៏មានចិត្តបង្អោនទៅកាន់ទិសនោះៗ ដូចគ្នាដែរ ។

កាយរបស់អាត្មាគ្រាំគ្រាហើយ មានកម្លាំងខ្សោយ មិនបានទៅ នៅក្នុងសម្នាក់ ដែលព្រះពុទ្ធអង្គគង់ប្រថាប់នៅនោះឡើយ តែអាត្មា តែងទៅដល់ជានិច្ច ដោយការត្រិះរិះ នៃព្រាហ្មណ៍ ចិត្តរបស់អាត្មា ប្រកបទៅតាមទិស ដែលព្រះពុទ្ធជាម្ចាស់គង់ប្រថាប់នៅនោះ ។ អាត្មា ដេកនៅក្នុងភក់ គឺកាម ជាអ្នកមានទូវសេចក្តីខ្វាយខ្វាល់ ( ដោយ តណ្ហា ទិដ្ឋិ កិលេស មានះ ជាដើម ) បានទៅជួបកោះ ( ទីពឹង ) កាលជាខាងក្រោយមក បានជួបព្រះសម្ពុទ្ធ ដែលទ្រង់ជាអ្នកឆ្លងឱឃះ

( អន្លង់ទឹក គឺកិលេស ) ព្រះអង្គជាអ្នកមិនមានអាសវៈ (កិលេសដែលដេកត្រាំនៅក្នុងសន្តានចិត្ត ) ។ សេចក្តីនេះ នៅក្នុង **អដ្ឋកថា** បានពោលទុកថា កាលព្រះបិង្គិយត្ថេរ សម្តែងព្រះធម៌ទេសនាឲ្យអាចារ្យពាវរីស្តាប់ចប់ ព្រះមហាវីរបុរសទ្រង់ជ្រាប ដល់ការចាស់ក្លានៃឥន្ទ្រិយរបស់ព្រះបិង្គិយត្ថេរ និងអាចារ្យពាវរី ទើបទ្រង់បញ្ចេញព្រះរស្មីពណ៌មាស ពីវត្តជេតពនមហាវិហារនាក្រុងសាវត្ថីមក ខណៈដែលព្រះបិង្គិយត្ថេរ កំពុងពណ៌នាអំពីព្រះគុណរបស់ព្រះពុទ្ធអង្គឲ្យអាចារ្យពាវរីបានស្តាប់នោះ មួយរំពេចនោះ ក៏បានក្រឡេកឃើញព្រះរស្មីរបស់ព្រះពុទ្ធ ក្នុងពេលដែលបានឃើញមុនដំបូងនោះ ក៏មិនទាន់បានជ្រាបថា ជារស្មីអ្វីដែរ ហើយពិចារណាតទៅទៀត ក៏បានឃើញព្រះមានបុណ្យ ប្រាកដដូចជាស្តេចមកប្រថាប់ឈរ នៅពីខាងមុខខ្លួន ទើបព្រះបិង្គិយត្ថេរប្រាប់ដល់អាចារ្យពាវរីថា ព្រះពុទ្ធជាម្ចាស់ស្តេចនិមន្តមកហើយ គ្រានោះ អាចារ្យពាវរី ប្រញាប់ក្រោកឡើងលើកដៃប្រណម្យក្រាបថ្វាយបង្គំព្រះមានជោគ ។

ព្រះសម្ពុទ្ធ កាលទ្រង់ផ្សាយព្រះរស្មីហើយ ទ្រង់បានបង្ហាញព្រះអង្គ ឲ្យអាចារ្យពាវរីបានឃើញ និងទ្រង់ពិចារណាដល់ធម៌ដែលជាទីសប្បាយដល់បុគ្គលទាំង ២ នេះ ហើយព្រះអង្គទ្រង់ត្រាស់ព្រះគាថា តាមដែលមានសម្តែងនៅក្នុង **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** និង **ចូឡនិទេស** ដូចមានសេចក្តីថា ៖

**វក្កលិ ១ ភទ្រាវុធ ១ និងអាឡវិគោតម ១ សុទ្ធតែជាអ្នកមានសទ្ធាចុះស៊ប់ យ៉ាងណាមិញ សូម្បីអ្នកក៏ចូរបញ្ចេញនូវសទ្ធាមកចុះ ក៏យ៉ាងនោះដែរ ម្នាលបិង្គិយៈ អ្នកនឹងដល់នូវត្រើយនៃសង្សារជាទីតាំងនៃមច្ចុមារ ។**

ក្នុងពេលចប់នូវព្រះគាថា ព្រះបិង្គិយត្ថេរ ក៏បានសម្រេចជាព្រះអរហន្ត រីឯអាចារ្យពាវរី ក៏បានសម្រេចជាព្រះអនាគាមី ចំណែកបរិវារ ៥០០ នាក់ របស់អាចារ្យពាវរីព្រាហ្មណ៍ ក៏បានសម្រេចជាព្រះសោតាបន្នបុគ្គល ។

កាលព្រះបិង្គិយៈ បានសម្តែងនូវសេចក្តីជ្រះថ្លារបស់ខ្លួន ទើប

ពោលឡើងថា ខ្ញុំព្រះអង្គបានស្តាប់ព្រះវាចារបស់ព្រះមហាមុនីហើយ ក៏មានសេចក្តីជ្រះថ្លាយ៉ាងក្រៃលែងកើតឡើង ព្រះសម្ពុទ្ធ ជាអ្នកបើកគ្រឿងប្រក់ ( បានដល់ តណ្ហា ទិដ្ឋិ កិលេស ទុច្ចរិត អវិជ្ជា ) ហើយ ទ្រង់ជាអ្នកមិនមានដែកគោល ( គឺរាគៈ ទោសៈ មោហៈ ឬការចងសេចក្តីក្រោធជាដើម ) ទ្រង់ជាអ្នកមានបដិភាណ ( បដិភាណ មាន ៣ គឺ **បរិយត្តិបដិភាណ** បានដល់ ការឆ្លាតឈ្លាស ក្នុងព្រះបរិយត្តិ ១ **បដិបុច្ឆាបដិភាណ** បានដល់ ការឆ្លាតឈ្លាស ក្នុងការសាកសួរ ១ **អធិគមបដិភាណ** បានដល់ ការឆ្លាតឈ្លាស ក្នុងការត្រាស់ដឹង ១ ) ។ ព្រះសយម្ភូ ទ្រង់ឃើញហើយ នូវធម៌ដែលធ្វើឲ្យជាអធិទេព ( ទេពដ៏ក្រៃលែង បានដល់ ទេព ៣ ប្រភេទ ) ទ្រង់ជ្រាបនូវធម៌ទាំងពួង ដែលធ្វើឲ្យព្រះអង្គ និងអ្នកដទៃប្រសើរឡើង ព្រះសាស្តាទ្រង់ធ្វើនូវចំណែកជាទីបំផុត ( ចប់ ) នៃបញ្ហាទាំងឡាយ ដល់ពួកបុគ្គលដែលមានសេចក្តីសង្ស័យ ឲ្យអស់សេចក្តីសង្ស័យបាន ។

ក្នុងទីបំផុតព្រះបិង្គិយត្ថេរ បានប្រកាសនូវការរួចផុតរបស់ខ្លួន

ដោយសទ្ធា ទើបពោលឡើងថា ព្រះនិព្វាន ដែលអ្វីៗ នាំទៅមិនបាន ( គឺមិនត្រូវរាគៈជាដើមនាំទៅ ) មិនកម្រើក ( គឺមិនប្រែប្រួល ) មិនមានឧបមាក្នុងទីណាៗ ខ្ញុំព្រះអង្គនឹងដល់ ( អនុបាទិសេសនិព្វានធាតុ ) ដោយពិត ការសង្ស័យក្នុងព្រះនិព្វាននោះ របស់ខ្ញុំព្រះអង្គមិនមានឡើយ សូមព្រះអង្គទ្រង់ចាំទុកខ្ញុំព្រះអង្គថា ជាអ្នកមានចិត្តបង្អោនទៅយ៉ាងនេះ ( មានចិត្តបង្អោនទៅកាន់ព្រះនិព្វាន ) ។

ព្រះបិង្គិយត្ថេរ លោកទ្រទ្រង់អាយុសង្ខារ មកដល់កាលដ៏សមគួរហើយ លោកក៏បានរំលត់ខន្ធបរិនិព្វានទៅហោង ។៚

( ជីវប្រវត្តិរបស់ព្រះបិង្គិយត្ថេរ ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះនាគិតត្ថេរ ✍

**“ លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័កផងដែរ ”**

*ព្រះនាគិតត្ថេរ លោកមានទ្រព្យធម្មសម្បត្តិជាព្រះអសេក្ខបុគ្គល ឬជាព្រះអរហន្ត លោកក៏ជាមហាសាវ័កមួយរូប ដែលរាប់ចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័ករបស់ព្រះពុទ្ធជាម្ចាស់ ៨០ រូប ឬហៅជាកាសាក្នុងព្រះសាសនានេះថា ព្រះអសីតិមហាសាវ័ក ទាំងជាសាវ័កដែលធ្លាប់ជាពុទ្ធុបដ្ឋាក គឺជាអ្នកធ្លាប់ចាំបម្រើព្រះពុទ្ធអង្គមុនព្រះអានន្ទត្ថេរ ដែលព្រមរ៉ាប់ខ្លួន ធ្វើជាពុទ្ធុបដ្ឋាករបស់ព្រះពុទ្ធជាស្ថាពរនោះ ទាំងនេះទើបរាប់ថា ជាកិត្តិយសដ៏សំខាន់របស់លោកមួយផងដែរ ។*

*ជីវប្រវត្តិដែលពោលដល់ខាងដើមជីវិត របស់ព្រះនាគិតត្ថេរ មានពណ៌នាទុកក្នុង **អដ្ឋកថាបរមត្ថទីបនី** ដែលជាអដ្ឋកថាអធិប្បាយសេចក្តីបាលីនៃ **គម្ពីរខុទ្ទកនិកាយ ថេរគាថា** ដូចមានសេចក្តីថា ៈ-*

ព្រះនាគិតៈ កើតឡើងក្នុងសក្យត្រកូល ក្នុងក្រុងកបិលពស្តុ មានទាមប្រាកដថា នាគិតកុមារ ។

ហេតុផលដែលនាគិតកុមារ ចូលមកបួសក្នុងព្រះពុទ្ធសាសនានេះ ព្រោះមកពីលោកកើតសទ្ធាជ្រះថ្លាយ៉ាងក្រៃលែង ពីព្រោះបានស្តាប់ **មធុបិណ្ឌិកសូត្រ** បានដល់ សូត្រដែលពោលដោយធម្មៈ ព្រះសូត្រនេះ មានសម្តែងក្នុង **គម្ពីរមជ្ឈិមនិកាយ មូលបណ្ណាសកៈ** និងសូមលើកយកមកសម្តែងទុកនៅក្នុងទីនេះ ចំពោះតែសេចក្តីដែលសំខាន់ៗ ប៉ុណ្ណោះ គឺ

សម័យមួយ ព្រះពុទ្ធជាម្ចាស់ ទ្រង់គង់ប្រថាប់នៅនិគ្រោធារាមជិតក្រុងកបិលពស្តុ នៃដែនសក្កៈ បានត្រាស់តបបញ្ហារបស់ទណ្ឌបាណិសក្យៈ ដែលបានក្រាបទូលសួរថា ព្រះអង្គមានវាទៈយ៉ាងណាត្រាស់ប្រាប់យ៉ាងណា ដោយទ្រង់បង្ហាញទៅថា ទ្រង់មានវាទៈ និងត្រាស់ប្រាប់ក្នុងផ្លូវ ដែលនឹងមិនឈ្លោះជាមួយនរណាៗ ក្នុងលោកព្រមទាំងទេវលោក និងក្នុងផ្លូវត្រង់សញ្ញា ( ការកំណត់សេចក្តីដោយ

កិលេស ហៅថា កិលេសសញ្ញា ) ឬមិនបិទបាំងខ្លួនតាម ( មិននៅដេករឿយៗ ) បុគ្គលមិនប្រកបដោយកាម អ្នកបណ្តេតបាប អ្នកអស់ការសង្ស័យ អស់ការរង្កៀស អស់ភាពកង្វល់ប្រាថ្នាចង់បានក្នុងភពតូចភពធំ ។ ដោយព្រះអង្គទ្រង់តំណាលរឿងនេះ ឲ្យភិក្ខុទាំងឡាយបានស្តាប់ កាលភិក្ខុទាំងឡាយ បានក្រាបទូលឲ្យទ្រង់សម្តែង ព្រះអង្គក៏ទ្រង់សម្តែង ដោយសេចក្តីសង្ខេប រួចក៏ទ្រង់ក្រោកចាកអាសនៈ ចៀសចេញទៅ ។ គ្រានោះ ភិក្ខុទាំងឡាយ នាំគ្នាចូលទៅរកព្រះមហាកច្ចាយនត្ថេរ ដើម្បីឲ្យព្រះមហាកច្ចាយនៈ អធិប្បាយក្នុងសេចក្តីនេះឲ្យពិស្តារ ។ ជាបឋមព្រះមហាកច្ចាយនៈ ពោលនឹងភិក្ខុទាំងនោះថា ប្រៀបដូចបុរស ដែលមានសេចក្តីត្រូវការខ្លឹមឈើ ដើរស្វែងរកខ្លឹមឈើ តែកន្លងហួសគល់ឈើ និងដើមនៃឈើដែលមានខ្លឹម ត្រឡប់មកស្វែងរកឈើនៅត្រង់មែក និងស្លឹក យ៉ាងណាមិញ សេចក្តីនេះ ក៏ដូច្នោះដែរ ។ កាលព្រះវិជិតមារ ទ្រង់គង់ប្រថាប់នៅចំពោះមុខអ្នកទាំងឡាយៗ ក៏កន្លងហួសព្រះអង្គទៅហើយៗ ក៏ត្រឡប់

មកសួរសេចក្តីនេះនឹងខ្ញុំព្រះករុណាវិញ ពិតណាស់ ព្រះសម្មាសម្ពុទ្ធ ទ្រង់ដឹង ទ្រង់ជាអ្នកមានបញ្ញាចក្ខុ ជាអ្នកឲ្យអមតធម៌ ជាព្រះតថាគត ពេលនេះ សមគួរដល់អ្នកទាំងឡាយក្រាបទូលសួរសេចក្តីនេះ ចំពោះព្រះភគវា ឲ្យព្រះអង្គទ្រង់ដោះស្រាយវិញចុះ បើព្រះអង្គដោះស្រាយយ៉ាងណា ចូរអ្នកទាំងឡាយចងចាំទុកសេចក្តីនោះ យ៉ាងនោះចុះ ។

ភិក្ខុទាំងនោះ ក៏បានពោលឡើងដូច្នេះថា ប៉ុន្តែ លោកម្ចាស់កច្ចាយនៈព្រះមានព្រះភាគ ទ្រង់លើកតម្កើងហើយ និងសព្រហ្មចារីទាំងឡាយ ក៏ពោលសរសើរហើយដែរថា លោកម្ចាស់ជាអ្នកមានចំណេះដឹង មានសមត្ថភាព ថែមទាំងភាពអង់អាច ក្នុងការពង្រីកសេចក្តីសង្ខេបឲ្យពិស្តារបាន ហេតុដូច្នេះ សូមលោកម្ចាស់ពន្យល់ឲ្យល្អិតល្អន់ហ្មត់ចត់ ក្នុងសេចក្តីនេះ ឲ្យខ្ញុំព្រះករុណាទាំងឡាយបានជ្រាបផង ។ គ្រានោះ ព្រះមហាកច្ចាយនៈ ទើបអធិប្បាយឲ្យស្តាប់ថា ចំណែកនៃសញ្ញា គឺការកំណត់កិលេសជាគ្រឿងយឺតយូរ រមែងគ្របសង្កត់បុណ្យ ព្រោះហេតុណា បើមិនកើតកើន មិនប្រកាន់ក្នុង

ហេតុ ( អាយតនៈ ១២ ) នោះឯង ទើបជាទីអស់ទៅនៃកិលេស និងអនុស័យ ។ **អនុស័យ** បានដល់ កិលេសដែលដេកត្រាំនៅក្នុងសន្តាន មាន ៧ គឺ **កាមរាគៈ** សេចក្តីត្រេកអរក្នុងវត្ថុកាម **បដិឃៈ** ការថ្នាំងថ្នាក់ ឬក្រេវក្រោធ **ទិដ្ឋិ** ការយល់ខុស **វិចិកិច្ឆា** ការស្ទាក់ស្ទើរសង្ស័យ ៨ យ៉ាង **មានៈ** ការប្រកាន់ខ្លួន ៩ យ៉ាង **ភវរាគៈ** ការត្រេកអរក្នុងភព **អវិជ្ជា** ការមិនដឹង ៤ ឬ ៨ យ៉ាង នុ៎ះឯងជាទីបំផុតនៃការចាប់កំណាត់ឈើ សស្ត្រា គឺការឈ្លោះវិវាទគ្នា ការចង្អុលមុខ ជេរទៅវិញទៅមក ការនិយាយសឹកសៀត ញុះញង់ ការនិយាយកុហក ដោយមានសេចក្តីអធិប្បាយជាលំដាប់ដូច្នេះថា

១- អាស្រ័យអាយតនៈខាងក្នុង និងអាយតនៈខាងក្រៅ កើតឡើង ការដឹងអារម្មណ៍ក៏កើតឡើង នេះហៅថា **វិញ្ញាណ** ។

២- រូបធម៌ និងនាមធម៌ ៣ ប្រការ គឺអាយតនៈខាងក្នុង ១ អាយតនៈខាងក្រៅ ១ និងវិញ្ញាណ ១ ហៅថា **ផស្សៈ** ( ការពាល់ត្រូវ ) ។

៣- ព្រោះផស្សៈជាបច្ច័យ ទើបកើតវេទនា ( គឺការដឹង ដូចជាការដឹងសុខ ទុក្ខ មិនទុក្ខ មិនសុខ ) ។

៤- ការដឹងក្នុងអារម្មណ៍ណា ក៏ចាំអារម្មណ៍នោះបាន ( កាលបើមានវេទនា ក៏មានសញ្ញា ) ។

៥- ការចាំអារម្មណ៍ណាបាន ក៏នឹកដល់អារម្មណ៍នោះ ( កាលមានសញ្ញា ក៏មានវិតក្ក គឺការនឹកគិត ) ។

៦-ការនឹកគិតក្នុងអារម្មណ៍ណា ក៏មានការយឺតយូរនៅជាមួយនឹងអារម្មណ៍នោះ ។

៧-ការយឺតយូរ នៅជាមួយនឹងអារម្មណ៍ណា ចំណែកឯសញ្ញាគឺការកំណត់កិលេស ជាហេតុឲ្យកើតការយឺតយូរ ក្នុងរូបដែលឃើញដោយភ្នែកជាដើម ទាំងដែលជាអតីត អនាគត និងបច្ចុប្បន្ន រមែងគ្របសង្កត់បាន ។

៨- កាលមានអាយតនៈខាងក្នុង មានអាយតនៈខាងក្រៅ មានវិញ្ញាណ ក៏មានឋានៈដែលនឹងបញ្ញត្តិផស្សៈបាន កាលមានការបញ្ញត្តិ

ផស្សៈបានក៏មានឋានៈដែលនឹងបញ្ញត្តិវេទនាបាន កាលមានការបញ្ញត្តិវេទនាបាន ក៏មានឋានៈដែលនឹងបញ្ញត្តិវិតក្កបាន កាលមានការបញ្ញត្តិវិតក្កបាន ក៏មានឋានៈដែលនឹងបញ្ញត្តិការគ្របសង្កត់ ចំណែកនៃវិញ្ញាណបាន គឺការកំណត់កិលេស ជាហេតុធ្វើឲ្យកើត ការយឺតយូរឡើង ។

រឿងរបស់ព្រះនាគិតត្ថេរ ក្នុង **អដ្ឋកថាបរមត្ថទីបនី** បានពោលតទៅទៀតថា កាលនាគិតកុមារ បានស្តាប់មធុបិណ្ឌិកសូត្រនេះចប់ហើយ ក៏កើតសេចក្តីជ្រះថ្លាឡើង ជាទីបំផុតក៏បានចេញបព្វជ្ជា ក្នុងព្រះពុទ្ធសាសនានេះ ។ កាលនាគិតកុមារបួសជាភិក្ខុហើយ ក៏តាំងចិត្តចម្រើនវិបស្សនាកម្មដ្ឋាន មិនយូរប៉ុន្មាន ក៏បានសម្រេចជាព្រះអរហន្ត ។ លុះព្រះនាគិតត្ថេរបានសម្រេចជាព្រះអរហន្តហើយ បានកើតបីតិសោមនស្សរីករាយ ពីព្រោះបានស្តាប់ព្រះធម៌ទេសនា ដែលព្រះលោកនាយក ទ្រង់សម្តែងឲ្យស្តាប់ និងបានឃើញយល់ថា ព្រះធម៌ទេសនានេះ ធ្វើឲ្យលោកចេញចាកភពបាន ទើបលោកបន្លឺវាចាដោយកម្លាំងបីតិ ( គឺការផ្អែតចិត្ត ) ជាព្រះគាថា ព្រះគាថាបានដល់

ពាក្យប្រព័ន្ធចងក្រងជាភាសាបាលី តាមដែលមានប្រាកដនៅក្នុងព្រះបាលី **គម្ពីរខុទ្ទកនិកាយ ថេរគាថា** ថា **ឥតោ ពហិទ្ធា បុថុអញ្ញវាទិនំ** ជាដើម ប្រែថា ព្រះមានព្រះភាគជាសាស្តាចារ្យ កាលសម្តែងដោយព្រះអង្គឯង ( ដូចផ្លែកន្ទួតព្រៃ ) ក្នុងបាតដៃ តែងប្រៀនប្រដៅសង្ឃយ៉ាងនេះថា ផ្លូវដ៏ប្រសើរនេះ ជាផ្លូវទៅកាន់ព្រះនិព្វាន មិនមែនដូចផ្លូវរបស់តិរ្ថិយ អ្នកពោលផ្សេងៗ ខាងក្រៅសាសនានេះទេ ។ ព្រះបរមសាស្តា ទ្រង់ប្រមើលមើលភិក្ខុសង្ឃដែលទ្រង់គួរណែនាំដោយព្រះអង្គឯង ដូចគ្នានឹងបុគ្គលសម្លឹងមើលផ្លែកន្ទួតព្រៃ ក្នុងបាតដៃដូច្នោះឯង គឺព្រះអង្គទ្រង់ឃើញច្បាស់ដោយព្រះអង្គឯង ។

ចំណែកឯរឿងរបស់ព្រះនាគិតត្ថេរ ដែលសម្តែងដល់ភាពជាឧបដ្ឋាករបស់ព្រះសម្ពុទ្ធ តាមដែលមានសម្តែងក្នុង **គម្ពីរអង្គុត្តរនិកាយ ឆក្កនិបាត** និង **បញ្ចកនិបាត** នៃនាគិតសូត្រ ដោយសេចក្តីនៃព្រះសូត្រទាំងពីរនេះដូចគ្នា ចំពោះអត្ថន័យខាងដើមព្រះសូត្រ តែផ្សេងគ្នាខ្លះក្នុងអត្ថន័យខាងចុងនៃព្រះសូត្រទាំងពីរនេះថា

សម័យមួយ ព្រះលោកនាយក ព្រមដោយភិក្ខុសង្ឃជាច្រើន ស្តេចយាងចារិកទៅកាន់ដែនកោសល ព្រះអង្គបានប្រថាប់គង់នៅក្នុងព្រៃ **ឥច្ឆានង្គល** ជិតគ្នានឹងស្រុកឥច្ឆានង្គល ដែលជាស្រុករបស់ពួកព្រាហ្មណ៍ ដែលតាំងនៅក្នុងដែនកោសល ។ ពួកព្រាហ្មណ៍ និងគហបតីអ្នកស្រុកឥច្ឆានង្គល បានឮដំណឹងថា ព្រះសមណគោតមស្តេចចេញចាកសក្យត្រកូលមកបួស ស្តេចបានចារិកមកដល់ស្រុកឥច្ឆានង្គល ឥឡូវនេះ ព្រះអង្គទ្រង់គង់ប្រថាប់នៅក្នុងព្រៃឥច្ឆានង្គល ជិតស្រុកឥច្ឆានង្គល ក៏កិត្តិស័ព្ទដ៏ខ្ចរខ្ចារ របស់ព្រះសមណគោតម បានផ្សព្វផ្សាយទៅយ៉ាងនេះថា **ឥតិបិ** សូម្បីព្រោះហេតុនេះៗ **សោ ភគវា** ព្រះមានព្រះភាគព្រះអង្គនោះ **អរហំ** ទ្រង់ជាព្រះអរហន្ត ( ទ្រង់មិនមានកិលេស ឬគួរដល់ការក្រាបថ្វាយបង្គំគោរពបូជា ) **សម្មាសម្ពុទ្ធោ** ទ្រង់ត្រាស់ដឹងដោយព្រះអង្គឯង ដោយប្រពៃ **វិជ្ជាចរណ-សម្បន្នោ** ទ្រង់ដល់ព្រមដោយវិជ្ជា ( វិជ្ជា ៨ ) និងចរណៈ ( ចរណៈ គឺធម៌ដែលត្រាច់ទៅកាន់ទិស ដែលមិនស្លាប់ មាន ១៥ ប្រការ ) **សុគតោ**

ទ្រង់មានដំណើរល្អហើយ (គឺព្រះនិព្វាន) **លោកវិទូ** ទ្រង់ជ្រាបច្បាស់នូវត្រៃលោក **អនុត្តរោ បុរិសទម្មសារថិ** ទ្រង់ជាអ្នកទូន្មាននូវបុរសដែលគួរទូន្មាន មិនមានអ្នកដទៃក្រៃលែងជាង **សត្ថា ទេវមនុស្សានំ** ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ **ពុទ្ធោ** ទ្រង់ដឹង ទ្រង់ភ្ញាក់ ទ្រង់រីក **ភគវា** ទ្រង់ចែកធម៌ ។

ទាំងនៅមានកិត្តិស័ព្ទ ដែលបង្ហាញឲ្យឃើញថា ទ្រង់ជាអ្នកមានភាពអង់អាច ផ្សព្វផ្សាយ ខ្ចរខ្ចាយចេញទៅទៀតថា ព្រះសមណគោតម ទ្រង់ជាអ្នកដឹងច្បាស់នូវលោកនេះ និងទេវលោក មារលោក ព្រហ្មលោក បានជាក់ច្បាស់ដោយព្រះបញ្ញាញាណ របស់ព្រះអង្គហើយ ទ្រង់ក៏ជាអ្នកប្រៀនប្រដៅដល់សព្វសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទេវតា និងមនុស្សឲ្យដឹងតាម ទ្រង់សំដែងធម៌ពីរោះបទដើម បទកណ្តាល និងបទចុង ទ្រង់ប្រកាសព្រហ្មចរិយធម៌ ព្រមទាំងអត្ថ និងព្យញ្ជនៈ ដែលបរិសុទ្ធបរិបូណ៌សព្វគ្រប់ ក៏ការបានឃើញព្រះអរហន្តទាំងឡាយ ដូចព្រះសមណគោតមនេះ រមែងជា

ការប្រសើរណាស់ ។ គ្រានោះ ព្រាហ្មណ៍ និងគហបតី អ្នកស្រុកឥច្ឆានង្គល លុះព្រឹកស្អែកឡើង បាននាំគ្នាកាន់យកខាទនីយៈ ភោជនីយាហារជាច្រើន ទៅកាន់ព្រៃឥច្ឆានង្គលនោះ ហើយបានឈរនៅខាងក្រៅខ្លោងទ្វារព្រមគ្នា ហើយបានបញ្ចេញសំឡេងគឹកកងឡើងក្នុងស្ថានទីនោះ ។ គ្រានោះ ព្រះនាគិតត្ថេរ លោកជាឧបដ្ឋាករបស់ព្រះភគវាជាម្ចាស់ បាននិមន្តតាមព្រះជិនស្រី មកកាន់ព្រៃឥច្ឆានង្គលនោះដែរ ។ កាលព្រះមានជោគ ទ្រង់បានស្តាប់ឮសំឡេងគឹកកងនោះហើយ ទើបត្រាស់សួរព្រះនាគិតត្ថេរថា ម្នាលនាគិតៈ តើសំឡេងអ្វីក៏គឹកកងម៉្លេះ ហាក់បីដូចអ្នកប្រមង់ដណ្តើមត្រីគ្នា ។

ព្រះនាគិតត្ថេរក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សំឡេងគឹកកងនោះ ជាសំឡេងរបស់ពួកព្រាហ្មណ៍ និងគហបតី អ្នកស្រុកឥច្ឆានង្គល បាននាំគ្នាយកខាទនីយៈ និងភោជនីយាហារជាច្រើន មកថ្វាយដល់ព្រះមានព្រះភាគ និងភិក្ខុសង្ឃ ហើយក៏បាននាំគ្នាឈរខាងក្រៅខ្លោងទ្វារ ព្រះអង្គ ។ ព្រះទសពល ទ្រង់ព្រះសណ្តាប់ពាក្យក្រាប

ទូលរបស់ព្រះនាគិតៈនោះហើយ ទើបត្រាស់ថា ម្នាលនាគិតៈ សូម កុំឲ្យតថាគតជាប់នៅក្នុងយសឡើយ និងកុំឲ្យយសមកជាប់តថាគត បុគ្គលណា មិនបានតាមសេចក្តីប្រាថ្នា នូវសេចក្តីសុខ ដែលកើតអំពី នេក្ខម្មៈ ( ការចេញបួស ) សេចក្តីសុខដែលកើតអំពីវិវេក សេចក្តី សុខដែលកើតអំពីសេចក្តីស្ងប់ សេចក្តីសុខដែលកើតអំពីការត្រាស់ ដឹង ( ដឹងច្បាស់ ) បានតាមបំណង បុគ្គលនោះ រមែងត្រេកអរក្នុង សេចក្តីសុខ ដែលកើតអំពីរបស់ដ៏ថោកទាប សេចក្តីសុខដែលកើត អំពីលាភសក្ការៈ កើតអំពីការសរសើរ ជាដើម ។ ព្រះនាគិតត្ថេរ ទើបក្រាបទូលឡើងថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ទទួល សូម ព្រះសុគតទ្រង់ទទួលចុះ ពេលនេះ ជាពេលដែលព្រះពុទ្ធអង្គទ្រង់គួរ ទទួល ពេលនេះ ជាពេលដែលព្រះសុគតគួរទទួល ។ ខណៈនោះ ព្រះមានជោគ ទ្រង់នឹងចារិកទៅកាន់ស្ថានទីណា ពួកព្រាហ្មណ៍ និង គហបតី អ្នកនិគម ឬអ្នកជនបទ នាំគ្នាដើរហូរហែតាមព្រះសាស្តា ទៅកាន់ស្ថានទីនោះៗ ដែរ ប្រៀបដូចមានមេឃភ្លៀងមួយមេធំបង្អុរចុះ

មក ទឹករមែងហូរទៅកាន់ទីទំនាប យ៉ាងណាមិញ ហេតុនេះក៏ដូច្នោះដែរ ពីព្រោះព្រះពុទ្ធអង្គជាបុគ្គលមានសីល និងបញ្ញា ។ គ្រានោះព្រះលោកនាយក បានត្រាស់ព្រះពុទ្ធដីកាម្តងទៀតថា ម្នាលនាគិតៈ តថាគតឃើញភិក្ខុក្នុងធម្មវិន័យនេះ ដែលភិក្ខុទាំងនោះ អាស្រ័យនៅក្នុងវិហារជិតស្រុក(សេនាសនៈជិតស្រុក) អង្គុយធ្វើសមាធិជិតស្រុក តថាគតរមែងមានការគិតយ៉ាងនេះថា ហេតុដូចម្តេច បានជាបរិស័ទ ឬសាមណេរ ធ្វើភិក្ខុរូបនេះឲ្យបន្តធ្វើសមាធិនោះបាន ឬធ្វើឲ្យភិក្ខុនោះចេញចាកសមាធិបាន ( គឺក្រោកចេញមិនធ្វើសមាធិ ) តថាគតមិនពេញចិត្ត ចំពោះការរស់នៅក្នុងវិហារជិតស្រុក របស់ភិក្ខុនោះទេ ។

មួយទៀត តថាគតឃើញភិក្ខុក្នុងធម្មវិន័យនេះ តែងតែប្រកាន់ការរស់នៅក្នុងព្រៃជាវត្ត អង្គុយងោកងក់នៅក្នុងព្រៃ តថាគតបានគិតយ៉ាងនេះថា ភិក្ខុរូបនេះនឹងបន្ទោបង់ការហត់នឿយ ដោយការសម្រាកហើយធ្វើអរញ្ញសញ្ញាទុកក្នុងចិត្តជាឯកគ្គតា ( មានចិត្តគិតតែមួយ ) ដូច្នេះ ទើបតថាគតពេញចិត្តការរស់នៅក្នុងព្រៃរបស់ភិក្ខុនោះ ។ តថាគត

ឃើញភិក្ខុក្នុងធម្មវិន័យនេះ តែងតែប្រកាន់ការរស់នៅក្នុងព្រៃជាវត្ត មិនមានចិត្តជាសមាធិ អង្គុយនៅក្នុងព្រៃ តថាគតបានគិតថា ភិក្ខុរូបនេះ នឹងតាំងចិត្ត ដែលមិនមែនជាសមាធិ ឲ្យជាសមាធិ ឬនឹងតាមរក្សាចិត្ត ដែលជាសមាធិនោះទុក ព្រោះដូច្នោះ ទើបតថាគតពេញចិត្តចំពោះការរស់នៅក្នុងព្រៃរបស់ភិក្ខុនោះ ។ តថាគតឃើញភិក្ខុក្នុងធម្មវិន័យនេះរស់នៅក្នុងព្រៃ មានចិត្តជាសមាធិ អង្គុយនៅក្នុងព្រៃ តថាគតបានគិតយ៉ាងនេះថា ភិក្ខុរូបនេះនឹងដោះចិត្ត ដែលនៅមិនទាន់ផុតស្រឡះឲ្យផុតស្រឡះ(បានដល់ ដោះចិត្តដែលនៅមិនទាន់ផុតស្រឡះ ឲ្យផុតស្រឡះ ដោយវិមុត្តិ គឺការរួចផុត ៥ ប្រការ) នឹងតាមរក្សាចិត្ត ដែលផុតស្រឡះហើយនោះទុក ទើបតថាគតពេញចិត្តចំពោះការរស់នៅក្នុងព្រៃរបស់ភិក្ខុនោះ ។ តថាគតឃើញភិក្ខុក្នុងធម្មវិន័យនេះ នៅក្នុងវិហារជិតស្រុក បានចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យ ភិក្ខុនោះជាអ្នកត្រេកអរចំពោះលាភសក្ការៈ និងការសរសើរហើយ រមែងលះបង់ចោល ការចៀសចេញចាកពួកគណៈ ដើម្បីទៅរស់នៅតែម្នាក់ឯង

លះបោលសេនាសនៈដ៏ស្ងាត់ ដែលតាំងនៅក្នុងជងព្រៃ ចូលមករួមគ្នានៅក្នុងស្រុក និគម និងរាជធានី ដូច្នេះ តថាគត ទើបមិនពេញចិត្តចំពោះការរស់នៅជិតស្រុករបស់ភិក្ខុនោះ ។ តថាគតឃើញភិក្ខុក្នុងធម្មវិន័យនេះ តែងតែប្រកាន់ការរស់នៅក្នុងព្រៃជាវត្ត បានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យ តែលោកជាអ្នកលះបង់លាភសក្ការៈ និងការសរសើរ មិនព្រមលះបង់បោលការពួនសំងំ ( គឺពេញចិត្តនៅម្នាក់ឯង ) មិនព្រមលះបង់បោលសេនាសនៈដ៏ស្ងាត់ ដែលតាំងនៅក្នុងជងព្រៃ តថាគត ទើបពេញចិត្តចំពោះការរស់នៅក្នុងព្រៃរបស់ភិក្ខុរូបនេះ ។ម្នាលនាគិតៈ ក្នុងគ្រាណា តថាគតធ្វើដំណើរផ្លូវឆ្ងាយ រមែងមិនឃើញនរណាដើរទៅខាងមុខ ឬដើរខាងក្រោយ ក្នុងគ្រានោះ តថាគតរមែងមានការសប្បាយព្រះទ័យ ។

ខ្លឹមសារធម៌ដែលមានក្នុង **គម្ពីរអង្គុត្តរនិកាយ បញ្ចកនិបាត** ដែលផ្សេងពីឆក្កនិបាតនោះ ដូចមានសេចក្ដីថា ៈ-

ម្នាលនាគិតៈ អាហារដែលស៊ី ផឹក ទំពា និងជីងរសហើយ

រមែងមានឧច្ចារៈ និងបស្សាវៈប្រាកដចេញមកមិនខាន នេះជាផលរបស់អាហារដែលបរិភោគចូលទៅហើយ ។ សេចក្ដីស្រឡាញ់មានសោកបរិទេវៈ ទុក្ខ ទោមនស្ស បានកើតឡើងព្រោះវត្ថុដែលជាទីស្រឡាញ់ប្រែប្រួលទៅជាយ៉ាងដទៃ នេះជាផលនៃសេចក្ដីស្រឡាញ់នោះ ។ ភាពជារបស់បដិកូលក្នុងអសុភនិមិត្ត រមែងតាំងនៅជាមួយនឹងភិក្ខុ ដែលខ្វល់ខ្វាយក្នុងការប្រកបតាមអសុភនិមិត្ត នេះក៏ជាផលនៃការប្រកបតាមអសុភនិមិត្តនោះ ។ ភាពជារបស់បដិកូលក្នុងផស្សៈ រមែងតាំងនៅជាមួយនឹងភិក្ខុ ដែលពិចារណាឃើញថា មិនទៀងក្នុងផស្សាយតនៈ ៦ ប្រការ នេះជាផលនៃការពិចារណាឃើញថា មិនទៀងក្នុងផស្សាយតនៈនោះ ។ ភាពជារបស់បដិកូលក្នុងឧបាទាន រមែងតាំងនៅជាមួយនឹងភិក្ខុដែលពិចារណាឃើញថា ការកើត និងការរលត់ក្នុងឧបាទានក្ខន្ធ ៥ ( រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ) នេះជាផលនៃការពិចារណាឃើញការកើត និងការរលត់ក្នុងឧបាទានក្ខន្ធនោះ ។ សេចក្ដីក្នុង **នាគិតសូត្រ** នេះ ព្រះសាស្ដាទ្រង់សរសើរការរស់នៅក្នុងសេនាសនៈ ដែល

តាំងនៅក្នុងព្រៃ ព្រោះការរស់នៅក្នុងព្រៃនោះ ធ្វើឲ្យសមាធិកើតឡើងបានឆាយ ធ្វើឲ្យការសម្រេចឈានសមាបត្តិបានឆាយដែរ ព្រោះមិនមានអារម្មណ៍ ដែលជាគ្រឿងគោងចិត្តផ្សេងៗ មកទាញចិត្តឲ្យយល់ខុសនោះឯង ។

ទំនាក់ទំនងនឹងប្រវត្តិក្នុងអតីតជាតិរបស់ព្រះនាគិតត្ថេរ បានមានរឿងតំណាលទុកក្នុង **អដ្ឋកថាបរមត្ថទីបនី** ដូចមានសេចក្តីថា ៖-

ក្នុងអតីតកាល ប្រមាណមួយសែនកប្បកន្លងមកហើយ ព្រះនាគិតត្ថេរ បានកើតជាព្រាហ្មណ៍ មាននាមថា **នារទ:** ត្រូវនឹងពុទ្ធកាលនៃព្រះបទុមុត្តរសម្ពុទ្ធជាម្ចាស់ ។ ថ្ងៃមួយ នារទព្រាហ្មណ៍ បានអង្គុយនៅក្នុងសាលាប្រជុំ របស់ពួកព្រាហ្មណ៍ បានក្រឡេកឃើញស្តេចយាងឆ្លងកាត់សាលាប្រជុំទៅ ព្រមដោយភិក្ខុសង្ឃជាច្រើន ក៏កើតមានសេចក្តីជ្រះថ្លា ទើបបានពោលសរសើរឡើងជាព្រះគាថា ៣ ព្រះគាថា ។ ដោយបុណ្យកុសល ដែលនារទព្រាហ្មណ៍បានពោលសរសើរគុណព្រះបទុមុត្តរ: និងភិក្ខុសង្ឃនោះ បានជួយឲ្យនារទ-

ព្រាហ្មណ៍ទៅកើតក្នុងទេវលោក និងក្រៅពីនោះ នារទព្រាហ្មណ៍បាន ធ្វើបុណ្យកុសលជាច្រើនយ៉ាងដទៃទៀត ។ ចាប់តាំងពីគ្រានោះមក លោកក៏បានមានការត្រាច់រង្គាត់សោយសុខ នៅក្នុងកំណើតជាទេវតា និងមនុស្ស អស់កាលដ៏យូរអង្វែង រហូតមកដល់សាសនា នៃព្រះ សមណគោតមបរមគ្រូនៃយើងនេះ លោកក៏បានមកកើត នៅក្នុង ត្រកូលសក្យរាជ ក្នុងក្រុងកបិលពស្តុ និងមានឈ្មោះថា **នាគិតៈ** ដូច ពោលរួចមកហើយ ក្នុងវគ្គខាងដើមនោះ ។

ជីវប្រវត្តិក្នុងអតីតជាតិរបស់ព្រះនាគិតត្ថេរ ក្រោយពីមានពោល ទុកក្នុង **អដ្ឋកថាបរមត្ថទីបនី** ហើយ នៅមានសម្ដែងនៅក្នុង **គម្ពីរ ខុទ្ទកនិកាយ អបទាន** ទៀតដែរ ប៉ុន្តែក្នុង **គម្ពីរខុទ្ទកនិកាយ អបទាន** នោះ ជារឿងដែលព្រះនាគិតត្ថេរ បានពោលអំពីជីវប្រវត្តិរបស់ខ្លួន លោកផ្ទាល់ ដូចមានសេចក្ដីថា ៈ-

ខ្ញុំព្រះអង្គ ( ព្រះនាគិតត្ថេរ ) ដែលបានអង្គុយនៅក្នុងសាលា ប្រជុំរបស់ពួកព្រាហ្មណ៍ បានក្រឡេកឃើញព្រះពុទ្ធអង្គជាម្ចាស់ ព្រះ

នាមបទុមុត្តរៈ ទ្រង់ជាព្រះលោកនាយក ទ្រង់សម្បូណ៌ទៅដោយព្រះខីណាស្រព ចោមរោមប្រមាណមួយសែនអង្គ ភិក្ខុសង្ឃមួយអង្គៗ សុទ្ធតែជាអ្នកបានអភិញ្ញា ៦ ។ កាលនោះ ខ្ញុំបានក្រឡេកឃើញ ក៏កើតសេចក្តីជ្រះថ្លា នរណាៗ បានជួប បានឃើញព្រះពុទ្ធហើយ នឹងមិនកើតសេចក្តីជ្រះថ្លានោះ រមែងមិនមាន បើនិយាយអំពីព្រះបញ្ញាព្រះអង្គវិញ រកទីបំផុតគ្មានឡើយ ដោយអំណាចសេចក្តីជ្រះថ្លានេះ ខ្ញុំមិនដែលស្គាល់ទុគ្គតិឡើយ អស់រយៈពេលមួយសែនកប្ប ។ លុះមកដល់កប្បទី ៣ ម៉ឺន ខ្ញុំព្រះអង្គបានជាស្តេចចក្រពត្តិ ព្រះនាមថាព្រះបាទសមិតៈ ។ លុះមកដល់ឥឡូវនេះ ខ្ញុំព្រះអង្គក៏ជាអ្នកអស់ទៅនូវអាសវក្កិលេស បានដកចោលហើយនូវភពទាំងពួង ( ភព បានដល់ កាមភព ភពជាកាមាវចរៈ គឺបុគ្គលដែលនៅជាប់ជំពាក់ក្នុងកាមសំដៅយកកាមភូមិ ១១ ជាន់ បានដល់ អបាយភូមិ ៤ មនុស្ស ១ ស្ថានសួគ៌ ៦ ជាន់ ) ។ រូបភព ( ព្រហ្មមានរូប ) ១៦ ជាន់ ។ អរូបភព បានដល់ ភពដែលជាអរូបាវចរៈ គឺបុគ្គលដែលមិនជាប់នៅ

ក្នុងរូប សំដៅយកអរូបព្រហ្ម ( ព្រហ្មមិនមានរូប ៤ ជាន់ ) ។

ជាពិសេសនោះ ខ្ញុំព្រះអង្គបានកាត់គ្រឿងចងសត្វលោកនោះបានហើយ ( គ្រឿងចង សំដៅដល់ សំយោជនៈ ) មាន ១០ ប្រការ គឺ ១ សក្កាយទិដ្ឋិ ២ វិចិកិច្ឆា ៣ សីលព្វតបរាមាស ៤ កាមរាគៈ ៥ បដិឃៈ ៦ រូបរាគៈ ៧ អរូបរាគៈ ៨ មានះ ៩ ឧទ្ធច្ចៈ ១០ អវិជ្ជា ។ មួយវិញទៀត សំយោជនកិលេសទាំងនោះ ព្រះសោតាបន្ន និងព្រះសកទាគាមី លះបាន ៣ ខ. គឺ ខ. ១-២-៣ ( តែព្រះសកទាគាមី អាចលះបង់លោភៈ ទោសៈ មោហៈ បានច្រើនជាងព្រះសោតាបន្ន ) ។ ចំណែកព្រះអនាគាមី លះបាន ៥ ខ. គឺ ខ. ១-២-៣-៤-៥ ឯព្រះអរហន្តលះបង់បានទាំង ១០ ខ.។ កាលដែលខ្ញុំមកកាន់សម្នាក់របស់ព្រះពុទ្ធនេះ ជាការមកដោយល្អ ។ វិជ្ជា ៣ ខ្ញុំបានហើយ ទាំងបដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ ខ្ញុំក៏បានធ្វើឲ្យជាក់ច្បាស់ហើយ ខ្ញុំបានកម្ចាត់បង់នូវកិលេសទាំងឡាយអស់ហើយ ខ្ញុំបានជាព្រះអរិយបុគ្គលមួយអង្គដ៏ប្រសើរនឹងគេដែរ ក្នុង

ព្រះសាសនានេះ ទាំងព្រះពុទ្ធអង្គក៏ខ្ញុំបានបម្រើហើយ ទាំងសាសនាក៏ខ្ញុំបានប្រតិបត្តិហើយដែរ ។

ចំពោះជីវប្រវត្តិរបស់ព្រះនាគិតត្ថេរ ជារឿងដែលបង្ហាញ ឲ្យឃើញអំពីអានិសង្សនៃការពោលសរសើរគុណ នៃព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដែលបុគ្គលបានសទ្ធាំហើយ ធ្វើឲ្យបុគ្គលនោះ បានទូវសម្បត្តិមនុស្ស សម្បត្តិទេវតា និងសម្បត្តិព្រះនិព្វាន យ៉ាងពិតប្រាកដ ។ បុគ្គលពោលសរសើរ បុគ្គលដែលគួរពោលសរសើរ បុគ្គលនោះ រមែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេចាប់យកទៅដាក់ បុគ្គលណា ពោលតិះដៀលបុគ្គល ដែលគួរសរសើរ បុគ្គលនោះ រមែងធ្លាក់ទៅកាន់នរក ដូចគេប្រានទម្លាក់ ។

ព្រោះដូច្នោះ បើបុគ្គលប្រាថ្នាបុណ្យ គួរតែពោលសរសើរអំពីគុណនៃព្រះរតនត្រ័យ ទើបជាការប្រសើរ ព្រោះអាចធ្វើបុគ្គលនោះឲ្យផុតភ័យទៅបាន មានតែសេចក្តីសុខ និងសេចក្តីចម្រើន ក្នុងជីវិតនៃបុគ្គលនោះតែប៉ុណ្ណោះ ទាំងក្នុងជាតិនេះ និងជាតិខាងមុខ ដូច

ព្រះនាគិតត្ថេរ បានធ្វើទុករួចមកហើយ ជាតួយ៉ាងសម្រាប់យើងទាំងអស់គ្នា បានជាបទពិចារណាក្នុងដំណើរជីវិតនេះ ។

ព្រះនាគិតត្ថេរ លោកបានធ្វើសេចក្ដីល្អជាច្រើន ក្នុងព្រះពុទ្ធសាសនានេះ ដោយលោកជួយផ្សព្វផ្សាយព្រះធម៌វិន័យ របស់ព្រះជិនស្រី ឲ្យដល់មហាជនបានយល់ដឹងក្នុងកិច្ចបដិបត្តិ ដើម្បីធ្វើនូវទីបំផុតនៃសេចក្ដីទុក្ខ ព្រោះហេតុដូច្នេះហើយ ទើបព្រះសាស្ដាសង្គ្រោះលោកចូលនៅក្នុងចំណោមព្រះអសីតិមហាសាវក ។

ព្រះនាគិតត្ថេរ លោកទ្រទ្រង់អាយុសង្ខារ មកដល់កាលដ៏សមគួរហើយ លោកក៏បានរំលត់ខន្ធបរិនិព្វានទៅហោង ។

ការបរិនិព្វានរបស់ព្រះនាគិតត្ថេរ មិនឃើញមានសម្ដែងប្រាប់ថា លោកបរិនិព្វានក្នុងទីណា ឬកន្លែងណានីមួយនោះទេ ៕

( ជីវប្រវត្តិរបស់ព្រះនាគិតត្ថេរ ចប់ )

# ✍ ជីវប្រវត្តិរបស់ព្រះនាលកត្ថេរ ✍

**“ លោកសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័កផងដែរ ”**

ព្រះនាលកត្ថេរ លោកជាព្រះអរហន្តសាវ័កមួយរូប ដែលជាអ្នកបំពេញសេចក្ដីព្យាយាម ក្នុងមោនេយ្យបដិបត្តិ យ៉ាងឧក្រិដ្ឋ ជាអ្នកបានទទួលនូវកិត្តិយសដ៏ប្រសើរពីព្រះលោកនាថ ដោយសង្គ្រោះចូលនៅក្នុងចំណោមព្រះអសីតិមហាសាវ័ក គឺជាមហាសាវ័កធំរបស់ព្រះពុទ្ធអង្គជាម្ចាស់ ៨០ រូប ទោះបីជាលោកមិនបានទទួលការលើកតម្កើងឲ្យជាអ្នកប្រសើរ តែក៏ជាអ្នកទ្រទ្រង់ **អរិយុត្តមគុណ** ដែលគួរដល់ការគោរព ធ្វើសក្ការបូជាយ៉ាងក្រៃលែង ។

ជីវប្រវត្តិរបស់ព្រះនាលកត្ថេរ មានសម្ដែងនៅក្នុង **អដ្ឋកថាបរមត្ថជោតិកា** ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីបាលីនាលកសូត្រ ក្នុង **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** ដូចមានសេចក្ដីថា ៖-

ព្រះនាលកៈ ជាកូនប្អូនស្រីរបស់ **អសិតឥសី** ឬមានឈ្មោះ

មួយទៀតថា **កាឡុទេវិលតាបស** ។ ឯការសន្សំបុណ្យកុសលក្នុងអតីតជាតិរបស់លោកវិញ មានមកតាំងពីពុទ្ធសម័យនៃព្រះបទុមុត្តរៈមកម្ល៉េះ បើរាប់រយៈកាលប្រមាណមួយសែនកប្ប ។ ហេតុដែលនឹងនាំឲ្យនាលកៈធ្វើសេចក្ដីល្អតាំងពីយូរហើយនោះ ដោយទាក់ទងមកពីក្នុងពុទ្ធសម័យនៃព្រះបទុមុត្តរសម្ពុទ្ធ ដោយលោកបានឃើញសាវ័កនៃព្រះបទុមុត្តរៈមួយរូប ជាអ្នកបដិបត្តិ១.បដិបត្តិរបស់ **មុនី** ឬហៅថា **មោនេយ្យបដិបត្តិ** ( **មោនេយ្យ** គឺភាពជាអ្នកប្រាជ្ញ ឬគុណធម៌របស់អ្នកប្រាជ្ញ ) យ៉ាងប្រសើរបំផុត ហើយក៏បានកើតសេចក្ដីជ្រះថ្លាចំពោះ១.បដិបត្តិរបស់សាវ័ករូបនោះ ក៏មានបំណងចង់បាននូវភាពប្រសើរយ៉ាងនោះដែរ ទើបតាំងចិត្តបំពេញបុណ្យបារមី តាំងពីជាតិនោះមករហូតដល់បច្ចុប្បន្ននេះ ដោយរាប់ប្រមាណមួយសែនកប្ប កន្លងរួចមកហើយ ។ កាលនាលកៈមុននឹងចូលមកបួសក្នុងព្រះសាសនានេះ លោកធ្លាប់បានបួសជាតាបសរួចមកហើយផងដែរ ។

កាលដែលលោកទៅបួសជាតាបសក្ដី ឬនឹងចូលមកបួសក្នុង

ព្រះសាសនានេះក្តី ព្រោះមកពីកាឡទេវិលតាបស ដែលជាអ៊ំប្រុស ជាអ្នកណែនាំ ឲ្យលោកចេញមកបួស ហេតុទាំងនេះ ក៏រាប់បានថា កាឡទេវិលតាបស ក៏ជាអ្នកមានគុណដល់លោកផងដែរ ។ មុននឹងតំណាលរឿងជីវប្រវត្តិរបស់ព្រះនាលកត្ថេរតទៅ នឹងសូមលើកយករឿងកាឡទេវិលតាបសមកសម្តែង ឲ្យបានជ្រាបជាមុនសិនថា ដែលពោលថា លោកជាតាបស និងជាអ្នកមានគុណចំពោះព្រះនាលកៈនោះ ដូចមានរឿងតំណាលទុកដូច្នេះថា ។ កាឡទេវិលតាបស លោកមានសម្បុរខ្មៅ កាលលោកនៅមិនទាន់មកបួសជាតាបសនោះ លោកក៏ធ្លាប់បានជាព្រះរាជបុរោហិតរបស់ព្រះបាទសីហហនុ ដែលទ្រង់ជាព្រះរាជបិតារបស់ព្រះបាទសុទ្ធោទនមហារាជ នៅពេលដែលព្រះបាទសុទ្ធោទនៈ នៅមិនទាន់បានអភិសេកជាព្រះរាជានៅឡើយ លោកក៏ធ្លាប់បានធ្វើជាអាចារ្យ បង្រៀនសិល្បវិជ្ជាផ្សេងៗ ឲ្យដល់ព្រះបាទសុទ្ធោទនកុមារ ។ ប៉ុន្តែកាលតមកព្រះបាទសុទ្ធោទនៈ បានអភិសេកជាព្រះរាជា គ្រប់គ្រងរាជសម្បត្តិ នៅក្នុងនគរកបិលពស្តុនោះហើយ

កាឡទេវិលតាបស ក៏បាននៅជាព្រះរាជបុរោហិតដូចដើមទៀត កាល អសិតព្រះរាជបុរោហិត បានចូលទៅគាល់ព្រះបាទសុទ្ធោទនៈ ទាំង ព្រឹក ទាំងល្ងាចនោះ ដូចដែលលោកធ្លាប់បដិបត្តិមកក្នុងរាជសម័យ របស់ព្រះបាទសីហហនុ ដែលជាព្រះរាជបិតា ។ ព្រះបាទសុទ្ធោទនៈ មិនបានសម្តែងនូវការគោរព ដូចដែលទ្រង់នៅជាកុមារវ័យទេ ដោយ ទ្រង់សម្តែងត្រឹមតែការកិរិយាគោរព ដោយព្រះហស្តតែប៉ុណ្ណោះ ។ មួយទៀត ការសម្តែងការគោរពដោយព្រះហស្តនោះ កាន់យកជា ទំនៀមរបស់សក្យរាជទាំងឡាយ ដែលទ្រង់បានអភិសេកជាព្រះរាជា ហើយ ។

អសិតព្រះរាជបុរោហិត បានពិចារណាការសម្តែងការគោរព នោះហើយ ក៏កើតការមិនពេញចិត្ត ទើបបានជាក្រាបទូលលាចេញពី តំណែងជាព្រះរាជបុរោហិត ដើម្បីចេញទៅបួសជាឥសី ។ ចំណែក ព្រះបាទសុទ្ធោទនៈមហារាជ ទ្រង់ជ្រាបការសម្រេចចិត្តរបស់អសិតព្រះ រាជបុរោហិតហើយ ទើបទ្រង់អនុញ្ញាត តែទ្រង់បានអង្វរថា ប្រសិនបើ

លោកអាចារ្យបព្វជ្ជាហើយ សូមឲ្យលោកអាចារ្យ អាស្រ័យនៅក្នុងព្រះរាជឧទ្យាន ទើបក្រាបបង្គំទូលទទួលព្រម ហើយក៏ក្រាបបង្គំទូលលាចេញទៅបព្វជ្ជាជាឥសី ក្រោយមក ក៏បានត្រឡប់មកអាស្រ័យនៅក្នុងព្រះរាជឧទ្យាននោះ កាលកាឡទេវិលតាបស បានទទួលការទំនុកបម្រុងអំពីព្រះបាទសុទ្ធោទនៈ ដោយសព្វគ្រប់ហើយ លោកក៏ជាអ្នកមិនមានសេចក្តីប្រមាទ ហើយក៏ខំចម្រើនកសិណ រហូតដល់បានសម្រេចអភិញ្ញា ៥ និងសមាបត្តិ ៨ ។

ចាប់តាំងពីលោក បានសម្រេចឈាន សមាបត្តិមកហើយ កាឡទេវិលតាបស នៅតែទៅចាន់ ក្នុងរាជត្រកូល ដូចសព្វដងដែរ ហើយទៅសម្រាកក្នុងពេលថ្ងៃ នាស្ថានទីផ្សេងៗ មានព្រៃហិមពាន្តស្ថានចាតុម្មហារាជិកា និងស្ថាននាគជាដើម ។ ថ្ងៃមួយ កាឡទេវិលតាបស បានឡើងទៅកាន់ស្ថានតាវត្តិង្ស ហើយចូលទៅកាន់វិមានកែវមួយ អង្គុយពែនភ្នែន នៅលើបល្ល័ង្កនោះ លុះពេលល្ងាចក៏ចេញចាកសមាធិ មកឈរនៅត្រង់ទ្វារ ហើយបានក្រឡេកមើលខាងណោះ ខាង

ណោះ ទើបបានក្រឡេកឃើញជួរទង់អណ្តែតត្រសែត ក្លឺចិញ្ចាចលើជងផ្លូវប្រមាណ ៦០ យោជន៍ ទាំងបានឃើញពួកទេវតា នៃជាន់តាវត្តិង្ស មានសក្កទេវរាជទ្រង់ជាប្រធាន បាននាំគ្នាពោលសរសើរគុណនៃព្រះបរមពោធិសត្វជាច្រើន គ្រានោះ កាឡទេវិលតាបស ក៏បានសួរដល់ទេវតាទាំងនោះ ដូចដែលបានពោលទុកក្នុងព្រះបាលីនៃនាលកសូត្រថា ព្រោះហេតុអ្វី បានជាពួកអ្នកមានសេចក្តីត្រេកអរអ្វីម៉្លេះ អ្នកទាំងអស់គ្នាលើកសំពត់ទិព្វឡើង ហើយរីករាយសប្បាយអាស្រ័យហេតុអ្វី សូម្បីក្នុងគ្រាចម្បាំងឈ្នះពួកអសុរ ការព្រឺរោម ព្រឺស្បែកដូច្នេះ ក៏មិនមាន តើគ្រានេះមានហេតុអ្វី ទើបពួកលោកនាំគ្នារីករាយ ថែមទាំងបានបន្លឺសំឡេងពោលសរសើរ ព្រមទាំងចម្រៀងប្រគំភ្លេង និងរាំនោះ ហេតុដូច្នេះ សូមអ្នកទាំងអស់គ្នា ប្រាប់សេចក្តីនេះដល់អាត្មាផង ដើម្បីឲ្យអស់ការសង្ស័យ ?

មានសំណួរដែលកាឡទេវិលតាបស សួរដល់ការត្រេកអររីករាយ របស់ពួកទេវតា ដែលជាការក្រៃលែងជាងការធ្វើសង្គ្រាម

ឈ្មោះពួកអសុរនោះទៅទៀត មានសម្ដែងក្នុង អដ្ឋកថាបរមត្ថជោតិកា ដែលជាអដ្ឋកថាអធិប្បាយសេចក្ដីព្រះបាលីនៃ នាលកសូត្រ និងក្នុង គម្ពីរខុទ្ទកនិកាយ សុត្តនិបាត និងក្នុង គម្ពីរធម្មបទ នៃ អប្បមាទវគ្គ ក្នុងរឿងស្ដេចសក្កៈ ដូចមានតំណាលថា ៖-

ក្នុងអតីតជាតិរបស់ស្ដេចសក្កទេវរាជ មុននឹងបានមកកើតជាស្ដេចសក្កទេវរាជក្នុងស្ថានតាវត្តិង្សនេះ ពីដើមធ្លាប់កើតជាមាណព ហើយបានជាប្រធាននៃមាណព ៣៣ នាក់ នៅស្រុកអចលគ្រាម ក្នុងដែនមគធៈ បានបំពេញវត្តបទ ៧ ប្រការ គឺត្រូវជាអ្នកចិញ្ចឹមមាតាបិតា អស់មួយជីវិត ១ ត្រូវគោរពបុគ្គល ជាច្បងក្នុងត្រកូល អស់មួយជីវិត ១ ត្រូវមានវាចាល្អិតទន់ អស់មួយជីវិត ១ មិនត្រូវមានវាចាញុះញង់ អស់មួយជីវិត ១ ត្រូវមានចិត្តប្រាសចាកសេចក្ដីកំណាញ់ជាមន្ទិល មានទានបរិច្ចាគហើយ មានដៃលាង (ចាំស្ទូម) ហើយត្រេកអរក្នុងការលះបង់ ជាអ្នកគួរគេសូមបាន ត្រេកអរក្នុងការឲ្យ និងការចែករំលែក នៅគ្រប់គ្រងផ្ទះអស់មួយជីវិត ១ ត្រូវមាន

សម្តីទៀងទាត់ អស់មួយជីវិត ១ មិនត្រូវមានសេចក្តីក្រោធ បើទុកជាសេចក្តីក្រោធកើតឡើង ត្រូវតែបញ្ចាប់បន្ទោបង់ នូវសេចក្តីក្រោធនោះចេញ អស់មួយជីវិត ១ ។ គោលធម៌ទាំង ៧ ប្រការនេះ លោកតែងតែប្រព្រឹត្តមិនដាច់ រហូតដល់អស់ជីវិត ថែមទាំងបានកសាងសាលា និងផ្លូវដែលជាសាធារណៈ ដើម្បីជាប្រយោជន៍ដល់មហាជន ហេតុដូច្នេះហើយ ទើបធ្វើឲ្យលោកទៅកើតក្នុងស្ថានតាវត្តិង្ស ព្រមទាំងបរិវារ ។ គ្រានោះ ពួកទេវតាដែលកើតមុន ក៏ពោលនឹងគ្នាថា មានពួកទេវបុត្រមកថ្មី ទើបនាំគ្នាត្រៀមទឹកទិព្វចាំទទួល និងបង្អោនផ្កាឈូកទិព្វបូលទៅបូជា ដោយឲ្យទ្រង់ជាព្រះរាជា គ្រប់គ្រងរាជ្យពាក់កណ្តាល ។ សក្កទេវរាជ មិនសព្វព្រះទ័យដោយលោកបានជាព្រះរាជាត្រឹមតែពាក់កណ្តាល ពេលនោះ ទើបទ្រង់ណាត់ជាមួយនឹងបរិស័ទរបស់ខ្លួនថា ពួកយើងកុំនាំគ្នាផឹកទឹកទិព្វនេះ ដោយដាក់គ្រឿងស្រវឹងក្នុងទឹកនោះ ដូច្នេះហើយ គ្រានោះ ពួកអសុរបាននាំគ្នាផឹកទឹកទិព្វនោះ រហូតដល់ស្រវឹងគ្រប់គ្នាហើយ ទើប

ព្រះអង្គឲ្យសញ្ញាដល់បរិស័ទរបស់ខ្លួន ឲ្យនាំគ្នាចាប់ពយកអសុរទាំងនោះ បោះចូលទៅក្នុងមហាសមុទ្រ ។ កាលពួកអសុរទាំងនោះ បានធ្លាក់ទៅដល់ត្រង់ជើងភ្នំសិនេរុហើយ ក្នុងបរិវេណនោះ ដោយមានប្រមាណរាប់ម៉ឺនយោជន៍ ដែលហៅថា អសុរពិភព ឬអសុរវិមានបានកើតឡើង ដើម្បីពួកអសុរទាំងនោះ ទាំងបានមានដើម ចិត្តបាតលិ ( ដើមប្រទៀង ) ដែលក្លាយជាដើម បារិច្ឆត្តកៈ ( ដើមបរិច្ឆត្រ ឬបារិជាតៈ គឺដើមរលួសផ្អុងក្នុងតាវត្តិង្សសួគ៌ ) ដុះឡើង ក្នុងបរិវេណអសុរវិមាននោះ ។ កាលបើពួកអសុរស្វាងពីស្រវឹងមានស្មារតីឡើងវិញហើយ មិនឃើញស្ថានតាវត្តិង្ស ក៏កើតការខឹងក្រោធអាក់អន់ចិត្តថា ពួកយើងវិនាសអស់ហើយ ព្រោះតែទោសនៃការផឹកទឹកស្រវឹងចាប់ពីពេលនេះតទៅ ពួកយើងកុំនាំគ្នាផឹកទឹកស្រវឹងតទៅទៀត ហេតុដែលទេវតាទាំងនោះ ឈ្មោះថា អសុរ ប្រែថា អ្នកមិនផឹកទឹកស្រវឹង ។ ចំណែកសក្កទេវរាជ ក៏បានរក្សាយ៉ាងប្រយ័ត្នប្រយែង ចំពោះស្ថានតាវត្តិង្សរបស់ព្រះអង្គ ដោយទ្រង់និម្មិតរូបសំណាករបស់ព្រះអង្គ ឲ្យ

មានកាន់វជិរាវុធ បានដល់ អាវុធ គឺផ្គេកបន្ទោរ ទុកក្នុងព្រះហស្ត ដោយទ្រង់និម្មិតទុកត្រង់ទ្វារ នៃទេវនគរទាំង ៤ ដើម្បីការពារពួកអសុរ ដែលលើកកងទ័ពមកច្បាំង តែតមក ពួកអសុរក៏បានលើកកងទ័ពមកច្បាំងមែន ប៉ុន្តែត្រូវបរាជ័យត្រឡប់ទៅវិញ ។ ពួកទេវតានៅស្ថានតាវត្តិង្សមួយអង្គៗក៏បាននាំគ្នាសម្តែងសេចក្តីត្រេកអរ ចំពោះការឈ្នះសង្គ្រាមនេះ ។ ប៉ុន្តែថា សេចក្តីត្រេកអរនៃពួកទេវតានៅស្ថានតាវត្តិង្ស ពេលនេះ ប្លែកអំពីសេចក្តីត្រេកអរកាលមុន ហេតុដូច្នេះ ទើបកាឡទេវិលតាបស បានសួរសេចក្តីនោះ ដល់ទេវតាទាំងនោះ ដូចដែលបានពោលរួច មកហើយនោះឯង ។

ពួកទេវតាទាំងនោះ បាននាំគ្នាឆ្លើយសំណួររបស់កាឡទេវិលតាបសនោះ តាមដែលមានសម្តែងប្រាកដនៅក្នុង **នាលកសូត្រ** ក្នុង **គម្ពីរខុទ្ទកនិកាយ សុត្តនិបាត** ដូចមានសេចក្តីថា ៈ-

ទេវតាទាំងនោះ បាននាំគ្នានិយាយប្រាប់អំពីព្រះពោធិសត្វថា ជារតនៈដ៏ប្រសើរ គ្មាននរណាប្រសើរដូចបាន ឥឡូវនេះ ទ្រង់បាន

កើតឡើងក្នុងលោកហើយ ដើម្បីជាប្រយោជន៍ និងសេចក្តីសុខដល់ជនច្រើន នៅឯព្រៃលុម្ពិនីវ័ន ក្នុងជនបទនៃសក្យៈឯណោះ ហេតុនេះហើយទើបពួកយើងនាំគ្នាលេងមហោស្រព យ៉ាងឱឡារិករីករាយ យ៉ាងនេះពីព្រោះព្រះពោធិសត្វនោះ ជាអគ្គបុគ្គលដ៏ខ្ពង់ខ្ពស់បំផុតជាងសព្វសត្វជាអ្នកអង់អាចជាងនរជនទាំងពួង និងបានប្រកាសព្រះធម្មចក្រ នៅក្នុងព្រៃឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ដោយកិរិយាអាការអង់អាចហាក់បីដូចជារាជសីហ៍ដែលបានបន្លឺសំឡេងឡើងនៅក្នុងព្រៃដូច្នោះដែរ ។ កាលកាឡទេវិលតាបស បានស្តាប់ដូច្នេះហើយ ទើបបានប្រញាប់ចុះ អំពីស្ថានតាវត្តិង្សមួយរំពេចនោះ ចូលទៅកាន់ទីគង់ប្រថាប់របស់ព្រះបាទសុទ្ធោទនៈ រួចហើយក៏បានអង្គុយនៅក្នុងទីដ៏សមគួរហើយបានទូលសួរព្រះបាទសុទ្ធោទនៈថា ព្រះរាជកុមារទ្រង់គង់ប្រថាប់នៅក្នុងទីណា អាត្មាចង់ឃើញ ។ លំដាប់នោះ ព្រះបាទសុទ្ធោទនៈត្រាស់ឲ្យនាំព្រះរាជកុមារមក ដោយទ្រង់មានពណ៌សម្បុរដូចជាមាស ដែលទ្រង់ជាអ្នករុងរឿងដោយសិរី ទ្រង់មានឆវីវណ្ណដ៏ល្អឥតខ្ចោះយកមក

ឲ្យកាឡទេវិលតាបសមើល ។ កាលកាឡទេវិលតាបស បានឃើញព្រះរាជកុមារ ទ្រង់រុងរឿងដូច្នេះហើយ ក៏មានចិត្តត្រេកអរខ្លាំងណាស់ក្នុងពេលដែលបានឃើញនោះ ។

កាលបើកាឡទេវិលតាបស បានឃើញព្រះរាជកុមារ ហាក់បីដូចដុំមាសនៅលើសំពត់កម្ពល និងស្វេតច្ឆត្រ ដែលបាំងនៅលើព្រះសិរសា ក៏មានចិត្តអណ្តែតឡើង សប្បាយចិត្តណាស់ ទើបទទួលព្រះរាជកុមារដោយដៃទាំងពីរ ។ ( ក្នុងវគ្គនេះ **អដ្ឋកថា** អធិប្បាយថា ក្នុងខណៈ ដែលកាឡទេវិលតាបសទទួលព្រះរាជកុមារ ដោយដៃទាំងពីរនោះ តែព្រះបាទទាំងគូរបស់ព្រះពោធិសត្វ ក៏បានត្រឡប់ឡើងទៅជាន់លើក្បាលរបស់កាឡទេវិលតាបស មុនការទទួលព្រះរាជកុមារនោះ តាបសបានឃើញភាពអស្ចារ្យដូច្នោះហើយ ក៏កើតសេចក្តីជ្រះថ្លាម្តងទៀត) ។ បន្ទាប់មក កាឡទេវិលតាបស ដែលបានរៀនចប់លក្ខណមន្តទើបពិចារណាឃើញថា ព្រះរាជកុមារនេះ ជាអ្នកប្រសើរដ៏ក្រៃលែងហើយ ក៏បានបន្លឺវាចាឡើងថា ព្រះរាជកុមារនេះ ឥតមានអ្នកដទៃណា

ក្រៃលែងជាងទេ ជាអ្នកខ្ពង់ខ្ពស់ប្រសើរបំផុតជាងសត្វជើងពីរទាំងពួង ។ ( សេចក្តីក្នុងវគ្គនេះ អដ្ឋកថាអធិប្បាយទុកថា កាលដែលកាឡទេវិលតាបសបន្ទឺវាចានោះឡើង ពីព្រោះលោកបានឃើញខ្សែកង់ចក្រ នៅត្រង់ផ្ទៃព្រះបាទរបស់ព្រះពោធិសត្វ ដែលនៅចំពីមុខរបស់ខ្លួននោះ ហើយបានពិចារណាមើលលក្ខណៈដទៃៗ ក៏ដឹងថាព្រះរាជកុមារនេះ នឹងបានត្រាស់ដឹងជាព្រះពុទ្ធយ៉ាងពិតប្រាកដ ទើបបានបន្ទឺវាចាឡើងយ៉ាងនោះ ) ។

ពេលនោះ កាឡទេវិលតាបស ក៏បានរឭកដល់ការសម្រេចអរូបជ្ឈានរបស់ខ្លួន ក៏អាក់អន់ចិត្តស្រែកយំឡើង ។ គ្រានោះ ស្តេចសក្យៈបានទតឃើញកាឡទេវិលតាបសយំហើយ ទើបត្រាស់សួរថា អន្តរាយនឹងមានដល់ព្រះរាជកុមារនេះឬ ? កាឡទេវិលតាបស បានពោលតបនឹងស្តេចសក្យៈថា ដែលអាត្មាយំនេះ អន្តរាយមិនមានដល់ព្រះរាជកុមារ និងព្រះរាជត្រកូលទេ មកពីអាត្មាមិនអាចនៅទាន់ព្រះរាជកុមារនេះ ដែលបានត្រាស់ដឹងជាព្រះពុទ្ធទេតើ ហេតុដូច្នេះ

សូមមហាបពិត្រ ទ្រង់នាំគ្នាត្រេកអរសប្បាយនៅក្នុងព្រះទ័យចុះ ព្រះរាជកុមារនេះ នឹងបានត្រាស់ដឹងជាព្រះពុទ្ធ ព្រះរាជកុមារនេះ ទ្រង់ជាអ្នកប្រាថ្នានូវប្រយោជន៍ ឲ្យដល់មហាជន ហើយទ្រង់បានប្រកាសនូវធម្មចក្រ និងព្រហ្មចរិយធម៌របស់ព្រះពុទ្ធអង្គ ផ្សព្វផ្សាយទៅដើម្បីជាប្រយោជន៍ និងសេចក្តីសុខជាច្រើន ដល់សត្វលោក តែអាយុរបស់អាត្មា មិនអាចស្ថិតនៅបានយូរដល់កាលនោះទេ អាត្មានឹងធ្វើកាលកិរិយានៅក្នុងចន្លោះនោះ និងមិនបានស្តាប់ព្រះធម៌ទេសនារបស់ព្រះរាជកុមារនេះ ដែលជាអ្នកដល់ព្រមដោយសេចក្តីព្យាយាម មិនមានបុគ្គលដទៃស្មើដូច ដោយហេតុនេះ អាត្មាជាបុគ្គលវិនាសហើយ ។

គ្រានោះ កាលកាឡទេវិលតាបស បាននូវសេចក្តីត្រេកអររីករាយជាមួយនឹងពួកសក្យៈទាំងឡាយហើយ ទើបចេញចាកអំពីព្រះរាជវាំងទៅប្រព្រឹត្តព្រហ្មចរិយធម៌ ឬនឹងទៅអនុគ្រោះដល់កូនក្មួយរបស់លោក ហើយក៏បានប្រាប់ឲ្យក្មួយប្រុស សមាទានក្នុងធម៌របស់ព្រះពុទ្ធ ដែលទ្រង់ជាអ្នកបរិបូណ៌ទៅដោយសេចក្តីព្យាយាម មិនមានបុគ្គលដទៃណា

ប្រៀបប្រដូចបាន ។

( សេចក្តីក្នុងវគ្គនេះ អដ្ឋកថាបានពោលថា កាឡទេវិលតាបស ចេញពីព្រះរាជវាំងទៅហើយនោះ ក្នុងបំណងទៅដឹកនាំដល់នាលកមាណព ដែលជាកូនប្រុសរបស់ប្អូនស្រីលោក ទាំងនេះដោយលោកយល់ឃើញថា អាយុរបស់លោកនៅតិចតួចទៀតណាស់ ប៉ុន្តែនាលកមាណពក្មួយរបស់យើងនៅវ័យក្មេង ជាអ្នកបានកសាងសន្សំបុណ្យបារមីរួចមកហើយ កាលដែលលោកឃើញដូច្នេះហើយ ក៏មានសេចក្តីអនុគ្រោះដល់កូនក្មួយ ទើបបានប្រញាប់ទៅកាន់ផ្ទះរបស់ប្អូនស្រី ហើយក៏បានសួររកនាលកៈថា នាលកៈទៅណាហើយ កាលបានជ្រាបថា នាលកៈនៅលេងខាងក្រៅផ្ទះ ក៏ឲ្យគេទៅហៅមក ហើយប្រាប់ឲ្យបួសជាតាបសក្នុងពេលនោះភ្លាមៗ ) ។ កាឡទេវិលតាបសកាលឲ្យនាលកៈបួសជាតាបសហើយ ទើបពោលប្រៀនប្រដៅថា ក្នុងកាលខាងមុខ ប្រសិនបើអ្នកបានឮដំណឹងថា **ពុទ្ធោ** ដូច្នេះនោះ គឺសំដៅដល់ ព្រះពុទ្ធ ដែលទ្រង់បានសម្រេចជាព្រះសម្មាសម្ពោធិញ្ញាណ

ហើយទ្រង់បានផ្សព្វផ្សាយនូវព្រះធម៌ ដែលល្អិតសុខុមយ៉ាងក្រៃលែង ចូរអ្នកទៅគាល់ព្រះពុទ្ធអង្គ ហើយក្រាបទូលសួរដោយខ្លួនឯង ក្នុងសម្នាក់ព្រះទសពលចុះ ចូរប្រព្រឹត្តព្រហ្មចរិយធម៌ នៅក្នុងសម្នាក់ព្រះភគវាអង្គនោះចុះ ។ កាឡទេវិលតាបស បានប្រៀនប្រដៅដល់នាលកតាបស ដែលជាកូនក្មួយដូច្នេះហើយ កាឡទេវិលតាបស ក៏បានត្រឡប់ទៅវិញទៅ ។

ចំណែកនាលកតាបស ជាអ្នកបានសន្សំបុណ្យបារមីរួចមកហើយ រក្សាឥន្ទ្រិយនៅរង់ចាំព្រះពុទ្ធ ហើយតមក បានស្តាប់សំឡេងបន្លឺកប្រកាសរបស់ទេវតាថា ព្រះលោកនាថ ទ្រង់បានប្រកាសព្រះធម្មចក្រដ៏ប្រសើរហើយ ព្រះអង្គជាព្រះសម្មាសម្ពុទ្ធ ទ្រង់បានត្រាស់ដឹងក្នុងលោកនេះហើយ លោកទើបបានចូលទៅគាល់ព្រះវិជិតមារ ដែលគង់នៅក្នុងព្រៃឥសិបតនមិគទាយវ័ន ក្នុងថ្ងៃទី ៧ រាប់ពីថ្ងៃដែលព្រះមហាមុនីទ្រង់បានសម្តែងព្រះធម្មចក្ររួចមកហើយ ក៏កើតសេចក្តីជ្រះថ្លា ហើយបានក្រាបទូលសួរបដិបទាដ៏ប្រសើររបស់មុនី នឹងព្រះ

មានជោគ ដែលទ្រង់ជាមហាមុនីដ៏ប្រសើរថា

ខ្ញុំព្រះអង្គ បានដឹងតាមការប្រាប់ របស់កាឡទេវិលតាបស ព្រោះហេតុនោះ ខ្ញុំព្រះអង្គ សូមទូលសួរថា បពិត្រព្រះគោតម ព្រះអង្គដល់ហើយនូវត្រើយនៃធម៌ទាំងពួង សូមព្រះអង្គទ្រង់ត្រាស់ប្រាប់ពាក្យថាមុនី និងបដិបទាដ៏ខ្ពង់ខ្ពស់បំផុតរបស់មុនី ដល់ខ្ញុំព្រះអង្គ ដែលជាអ្នកមិនមានផ្ទះ ហើយជាអ្នកត្រាច់ទៅដើម្បីស្វែងរកភិក្ខា ដើម្បីចិញ្ចឹមជីវិត ។ គ្រានោះ ព្រះមានជោគ ទ្រង់ត្រាស់ព្យាករថា តថាគតនឹងបញ្ញត្តបដិបទារបស់មុនី ដែលបុគ្គលធ្វើបានដោយកម្រ អ្នកចូរជាអ្នកញ៉ាំងសេចក្តីត្រេកអរឲ្យចម្រើនក្នុងការបដិបត្តិ ហើយចូរជាអ្នកគ្រប់គ្រងចិត្តចំពោះអ្នកដទៃ ដែលបានប្រព្រឹត្តធ្វើនូវអំពើមិនប្រសើរដល់ខ្លួន គប្បីរក្សាចិត្តកុំឲ្យខឹងក្រោធ ហើយជាអ្នកកុំត្រេកអរចំពោះការបូជាក្នុងត្រកូលទាំងឡាយ ។ ពីព្រោះថា ពួកស្ត្រីតែងតែលួងលោមមុនីដោយអាការផ្សេងៗ មានសើច និយាយ និងយំ ទាំងស្លៀកដណ្តប់ជាដើម ព្រោះដូច្នោះ ពួកស្ត្រីទាំងនោះ កុំជាអ្នកលួងលោមលោកបាន

ឡើយ មុនីរមែងលះបង់កាមទាំងឡាយ ទាំងល្អ ទាំងមិនល្អ ជាអ្នកវៀរចាកមេថុនធម្ម ជាអ្នកមិនត្រេកអររីករាយ ចំពោះសត្វ និងសង្ខារទាំងឡាយ ជាអ្នកមានចិត្តមិនញាប់ញ័រ និងមានចិត្តតាំងមាំ ដោយធ្វើសេចក្តីឧបមាថា យើងក៏ចង់បានសុខ សត្វដទៃក៏ចង់បានសុខដែរ ។ មុនីតែងតែលះបង់សេចក្តីប្រាថ្នាក្នុងបច្ច័យ ដែលបុថុជ្ជននៅជាប់ជំពាក់ ជាអ្នកមានចក្ខុ ( ប្រាជ្ញា គឺការដឹងសព្វគ្រប់ច្បាស់លាស់ ) គប្បីបដិបត្តិបដិបទារបស់មុនី ហើយគប្បីលះបង់នូវសេចក្តីប្រាថ្នា ក្នុងបច្ច័យដែលជាហេតុនៃមិច្ឆាជីវៈ អ្នកគប្បីដឹងថា នរក ( អដ្ឋកថាចារ្យពោលថា នរកបានដល់ តណ្ហា ដែលហៅថា តណ្ហា ជានរកនោះ ពីព្រោះថា តណ្ហានោះ ជារបស់ដែលធ្វើឲ្យពេញបានដោយកម្រដូចគ្នា ) ។

ព្រោះថា **មុនី** ជាអ្នកមានផ្ទៃខ្វះខាត (គឺមិនឃើញតែផ្ទៃ) ជាអ្នកដឹងល្មមប្រមាណ ជាអ្នកមានសេចក្តីប្រាថ្នាតិច ជាអ្នកមិនល្មម ជាអ្នកអស់ហើយនូវសេចក្តីត្រូវការ ជាអ្នករំលត់ភាពក្តៅក្រហាយបានសព្វកាល ( អដ្ឋកថាចារ្យបានអធិប្បាយសេចក្តីក្នុងគាថានេះថា មុនី កាល

បើបរិភោគអាហារ ក៏បរិភោគតិចៗ ដោយនៅសល់ ៤-៥ ម៉ាត់ទៀត នឹងឆ្អែតក៏ឈប់ ហើយក៏ផឹកទឹក ការបរិភោគអាហារយ៉ាងនេះ ទើបជាទីសប្បាយសម្រាប់ភិក្ខុ ដែលជាអ្នកមានសេចក្តីព្យាយាម ប្រសិនបើបុគ្គលបរិភោគអាហារហួសប្រមាណធ្វើឲ្យការងោកងក់កើតឡើងព្រោះស្រវឹងអាហារ អ្នកមានផ្ទៃខ្វះខាតយ៉ាងនេះហើយក្តី ជាអ្នកដឹងប្រមាណក្នុងអាហារនោះគឺត្រូវពិចារណាអាហារឲ្យឃើញគុណ និងទោសរបស់អាហារហើយ ទើបបរិភោគអាហារនោះ ទើបជាការប្រពៃទៀត ថែមទាំងជាអ្នកប្រាថ្នាតិច ឯការប្រាថ្នាតិចនោះ មាន ៤ ប្រការ គឺ ១- ប្រាថ្នាតិចក្នុងបច្ច័យ ៤ ២- ប្រាថ្នាតិចក្នុងធុតង្គ ៣- ប្រាថ្នាតិចក្នុងបរិយត្តិ (បានដល់ មិនចង់ឲ្យគេដឹងថា ខ្លួនជាពហូសូត គឺអ្នកសិក្សារៀនសូធ្យច្រើន) ៤- ប្រាថ្នាតិចក្នុងអធិគម (គឺមិនចង់ឲ្យអ្នកដទៃដឹងថា ខ្លួនបានសម្រេចគុណធម៌ថ្នាក់នេះថ្នាក់នោះឡើយ) ។ មុនីនោះ កាលបើត្រាច់ទៅបិណ្ឌបាត និងត្រឡប់មកវិញ តែងតែទៅកាន់ជាយព្រៃ អង្គុយនៅទៀបគល់ឈើ ជាអ្នកខ្វល់ខ្វាយក្នុងឈាន ជាអ្នកត្រេកអរក្នុងព្រៃ ហើយ

ជាអ្នកត្រេកអរក្នុងការសម្ងំឈាន នៅទៀបគល់ឈើនោះ កាលបើដល់ពេលភិក្ខាចារ តែងចូលទៅកាន់ស្រុក ជាអ្នកមិនត្រេកអរចំពោះភោជន ដែលនៅមិនទាន់បាន ។ មុនី កាលបើមកដល់ស្រុក ក៏មិនប្រញាប់ប្រញាល់ចូលទៅកាន់ត្រកូលនោះទេ ថែមទាំងជាអ្នកមានប្រក្រតីមិនពោលវាចាទាក់ទិននឹងអាហារ ដែលខ្លួនស្វែងរកដោយមុនីនោះគិតយ៉ាងនេះថា យើងបានវត្ថុណានីមួយ ក៏ជាការល្អ ប្រសិនបើយើងមិនបានទេ ក៏មិនជាអ្វី ជាអ្នកមានចិត្តស្មើ បុគ្គលណាមានចិត្តយ៉ាងនេះ បុគ្គលនោះ រមែងឈានកន្លងទុក្ខបាន ប្រៀបដូចបុរសដែលស្វែងរកផ្លែឈើ ចូលទៅត្រង់ដើមឈើ ហើយសូម្បីនឹងបាន ឬមិនបាន ក៏ដាក់ចិត្តជាកណ្តាល ហើយត្រឡប់មកវិញ ហេតុដូច្នោះ មុនី កាលត្រាច់ទៅបិណ្ឌបាត ធ្វើដូចជាមនុស្សគ ទាំងមិនបានមើលងាយទានរបស់គេថា បន្តិចបន្តួចឆ្ងាញ់ ឬមិនឆ្ងាញ់ ឬទាំងមិនបានមើលងាយអ្នកឲ្យទាន ជាអ្នកដល់ព្រមដោយកិច្ចបដិបត្តិ ដែលជាពាក្យប្រៀនប្រដៅរបស់ព្រះសម្ពុទ្ធ ។

មុនី តែងតែមិនទៅកាន់ព្រះនិព្វានពីរដងទេ ពីព្រោះថា ព្រះនិព្វាននោះ បុគ្គលអាចពាល់ត្រូវបានតែម្តងប៉ុណ្ណោះ ក៏ភិក្ខុមិនមានតណ្ហា ជាអ្នកកាត់ក្រសែកិលេសបានហើយ លះកិច្ចទាំងពួងអស់ហើយ រមែងមិនមានភាពក្តៅក្រហាយ ។ គ្រានោះ ព្រះសយម្ភូត្រាស់តទៅទៀតថា តថាគតនឹងប្រាប់បដិបទារបស់មុនីដល់អ្នក ភិក្ខុដែលបដិបត្តិបដិបទារបស់មុនី គួរជាអ្នកមិនឃើញតែផ្ទៃ មានចិត្តមិនរួញរា ហើយជាអ្នកមិនមានកិលេស ជាអ្នកមិនអាឡោះអាល័យចំពោះកិលេស គួរមានព្រហ្មចរិយធម៌នៅពីមុខ ( គឺមិនគួរមានកិលេស មិនគួរជាប់ទាក់ទងនឹងនរណាៗ ដោយតណ្ហា គួរជាអ្នកតាំងចិត្តប្រព្រឹត្តនៅតែក្នុងសាសនព្រហ្មចរិយធម៌នេះប៉ុណ្ណោះ ដែលរួមចុះក្នុងត្រៃសិក្ខា គឺសីល សមាធិ បញ្ញា ) គប្បីជាអ្នកសិក្សា គប្បីជាអ្នកអង្គុយនៅតែម្នាក់ឯង ( អង្គុយនៅទីស្ងាត់ ) ជាអ្នកបរិបូណ៌ដោយសេចក្តីព្យាយាមអប់រំទូន្មានចិត្ត ទាំងនេះជាបដិបទារបស់មុនីតែមួយចំណែកប៉ុណ្ណោះ ។ អដ្ឋកថាចារ្យបានអធិប្បាយថា ការអង្គុយនៅម្នាក់ឯង គឺអង្គុយក្នុងទីស្ងាត់ តែមិន

បានសំដៅដល់ការអន្ទុយតែម្យ៉ាងទេ គឺសំដៅយកឥរិយាបថទាំង ៤ ។ ទិសទាំង ១០ រមែងប្រាកដដោយសំឡេងសរសើររបស់អ្នកប្រាជ្ញទាំងឡាយ ដែលជាអ្នកប្រព្រឹត្តបដិបទារបស់មុនី ហើយបានលះបង់កាមារម្មណ៍ទាំងនោះចេញទៀត កាលបើដូច្នេះ អ្នកនឹងបានជាសាវករបស់តថាគត ។សមណៈណាពោលពាក្យជាច្រើន ដែលជាហេតុនាំចូលទៅរកប្រយោជន៍ ឬប្រកបដោយប្រយោជន៍ ដឹងនូវពាក្យទាំងនោះ ហើយសម្ដែងប្រាប់សមណៈនោះ ឈ្មោះថា ជាអ្នកប្រសើរ ។

សមណៈណា ជាអ្នកចេះដឹងច្រើន ជាអ្នកដល់ព្រមដោយការសង្រួម ជាអ្នកដឹងហេតុដែលមិននាំមកនូវប្រយោជន៍ និងសេចក្ដីសុខឲ្យដល់សត្វលោកនោះ សមណៈនោះ រមែងមិនពោលឡើយ សមណៈនោះឯងជាមុនី ថែមទាំងជាអ្នកប្រព្រឹត្តនូវបដិបទារបស់មុនី ឬសមណៈនោះបានដល់ធម៌ ដើម្បីភាពជាមុនីហើយ ។ អដ្ឋកថាចារ្យបានពោលអធិប្បាយក្នុងវគ្គនេះថា ព្រះមានជោគ ទ្រង់ប្រកបដោយព្រះសព្វញ្ញុតញ្ញាណ កាលដឹង ទើបទ្រង់សម្ដែងធម៌ កាលដឹង ទើបទ្រង់ពោល ។

ចំណែកបុគ្គលណាដឹងនូវធម៌របស់ព្រះសម្ពុទ្ធនោះ ដែលទ្រង់សម្តែងទុកល្អហើយនោះ ដោយការយល់ដឹង ជាចំណែកនៃការនឿយណាយ ឬការសង្រួម គឺការគ្រប់គ្រងចិត្ត ពាក្យណា មិននាំមកនូវប្រយោជន៍ និងសេចក្តីសុខដល់សត្វទាំងឡាយ ការដឹងនូវពាក្យនោះហើយក៏មិននិយាយ បុគ្គលដូច្នេះ រមែងសមគួរហៅថា មុនី បុគ្គលបដិបត្តិដើម្បីមុនី ដូច្នោះ ឬសមគួរដល់ខ.បដិបត្តិរបស់មុនី និងមិនមែនត្រឹមតែសមគួរតែម្យ៉ាងប៉ុណ្ណោះទេ ជាអ្នកធ្វើឲ្យដល់ភាពជាមុនី គឺបានសម្រេចអរហត្តមគ្គញាណ (ការដឹងក្នុងផ្លូវបដិបត្តិដើម្បីសម្រេចព្រះអរហត្ត ) ។ សរុបខ.បដិបត្តិរបស់ភិក្ខុ ដែលជាអ្នកប្រព្រឹត្តមោនេយ្យប្បដិបត្តិតាមព្រះពុទ្ធវចនៈនោះ អ្នកគប្បីញ៉ាំងចិត្តឲ្យស្មើគ្នា ទាំងក្នុងសត្វ និងបុគ្គលទាំងពួង កុំជ្រើសរើសរកបុគ្គល ព្រោះតែសេចក្តីស្រឡាញ់ ឬស្អប់ក្នុងគោចរគ្រាម ដែលអ្នកត្រាច់ទៅបិណ្ឌបាតនោះ ។

សូម្បីនរណានឹងជេរ ឬតវ៉ាត្អូញត្អែរ ចំអក បញ្ឈឺអ្នក អ្នកកុំខឹង កុំទោមនស្ស កុំស្អប់គេឡើយ ។ សូម្បីនរណាគោរព សំពះ

ដោយយកចិត្តទុកដាក់យ៉ាងណាក៏ដោយ អ្នកកុំស្រឡាញ់ អ្នកចូរធ្វើទុកក្នុងចិត្តឲ្យស្មើ អ្នកគប្បីរក្សាចិត្តឲ្យប្រាសចាកទោសៈ ( ការគិតប្រទូសរ៉ាយ ឬការក្រេវក្រោធ ) ។ អ្នកកុំជាអ្នកមានអស្មិមានះ ( ការប្រកាន់ខ្លួនថាពិសេសជាងគេ ការប្រកាន់ថាយើង ថាគេ ) កាលបើអ្នកនឹងត្រាច់ទៅក្នុងស្ថានទីណាៗ ចូរញ៉ាំងចិត្តឲ្យផុតអំពីមានះ ។ អ្នកកុំជាមនុស្សក្រអឺតក្រទម កិរិយាក្រអឺតក្រអោង ក្រអឺតក្រទមឡើងនោះ ចូរអ្នកកម្ចាត់ចេញអំពីខន្ធសន្តាន ។ គ្រានោះ នាលកតាបសបានស្តាប់អំពីបដិបទារបស់មុនី ឬមោនេយ្យប្បដិបត្តិហើយ ទើបកើតសេចក្តីជ្រះថ្លាឡើង ហើយក៏ក្រាបទូលសូមព្រះមានជោគដើម្បីបព្វជ្ជាឧបសម្បទា ក្នុងព្រះសាសនានេះ លុះលោកឧបសម្បទារួចហើយ ក៏ជាបុគ្គលមានប្រក្រតីប្រាថ្នាតិច ៣ យ៉ាង ១- ប្រាថ្នាតិចក្នុងការឃើញ ២- ប្រាថ្នាតិចក្នុងការស្តាប់ ៣- ប្រាថ្នាតិចក្នុងការសាកសួរ ។

កាលព្រះសយម្ភូ ទ្រង់ត្រាស់សម្តែងព្រះធម៌ចប់ហើយ ព្រះ

នាលកត្ថេរ ក៏មានចិត្តជូរជង់ ប្រាសចាកនូវមន្ទិល ហើយបានក្រាបថ្វាយបង្គំព្រះលោកនាយក រួចក៏ពោលឡើងថា ខ្ញុំព្រះអង្គចូលទៅកាន់ព្រៃហើយ សូមឲ្យឃើញព្រះពុទ្ធអង្គទៀត នេះហៅថា ការប្រាថ្នាតិចក្នុងការឃើញ ។ ព្រះនាលកត្ថេរ បានពោលតទៅទៀតថា សូមឲ្យខ្ញុំព្រះអង្គបានស្តាប់ព្រះធម៌ទេសនាទៀត នេះហៅថា ការប្រាថ្នាតិចក្នុងការស្តាប់ ។ ព្រះនាលកត្ថេរ ពោលបន្តទៅទៀតថា សូមឲ្យខ្ញុំព្រះអង្គបានក្រាបទូលសួរបដិបទារបស់មុនីទៀត នេះហៅថា ប្រាថ្នាតិចក្នុងការសាកសួរ ។ ព្រះនាលកត្ថេរ លោកជាអ្នកប្រាថ្នាតិចយ៉ាងនេះ ហើយក៏បានចូលទៅកាន់ញកភ្នំ ថែមទាំងជាអ្នកមានប្រក្រតីនៅកន្លែងមួយមិនដល់ពីរថ្ងៃឡើយ ទាំងមិនអង្គុយនៅត្រង់គល់ឈើមួយដើមដល់ពីរថ្ងៃដែរ មិនចូលទៅបិណ្ឌបាតក្នុងស្រុកនីមួយៗ ដល់ពីរថ្ងៃ គឺបានចេញពីព្រៃនេះ ទៅកាន់ព្រៃនោះ លោកជាអ្នកមានឧស្សាហ៍ព្យាយាមបដិបត្តិនៅក្នុងបដិបទារបស់មុនី ក្នុងមោនេយ្យប្បដិបត្តិយ៉ាងឧក្រិដ្ឋ ហើយបានសម្រេចអរិយផលដ៏ប្រសើរ ជាព្រះអរិយបុគ្គល

ថ្នាក់ខ្ពស់បំផុតក្នុងព្រះសាសនានេះ គឺបានជាព្រះអរហន្ត ។

មួយវិញទៀត លោកតែងតែពេញចិត្ត ក្នុងបដិបទារបស់មុនី ឬនៅក្នុងមោនេយ្យប្បដិបត្តិយ៉ាងឧក្រិដ្ឋនេះ ដោយថា បុគ្គលដែលប្រព្រឹត្តបែបនេះ នឹងមានជីវិតរស់នៅបានត្រឹមតែ ៧ ខែប៉ុណ្ណោះ ចំណែកឯថ្នាក់កណ្ដាលអាចមានជីវិតរស់នៅបាន ៧ ឆ្នាំ ឯថ្នាក់ទាបវិញ អាចមានជីវិតរស់នៅបាន ១៦ ឆ្នាំ ។ ព្រះនាលកៈ ដែលលោកបានព្យាយាមបដិបត្តិក្នុងបដិបទារបស់មុនី ឬមោនេយ្យប្បដិបត្តិថ្នាក់យ៉ាងឧក្រិដ្ឋនោះ ព្រោះដូច្នោះ ទើបលោកអាចមានជីវិតរស់នៅបានត្រឹម ៧ ខែប៉ុណ្ណោះ កាលបើដល់ ៧ ខែហើយ លោកក៏ដឹងខ្លួនថាអាយុសង្ខាររបស់ខ្លួន ដល់នូវទីបំផុតហើយ ទើបបានស្រង់ទឹកជម្រះកាយ និងគ្រងចីវរឲ្យជាបរិមណ្ឌល ហើយបែរមុខឆ្ពោះទៅរកព្រះមុនីដែលទ្រង់គង់ប្រថាប់ទិសនោះ ដោយការក្រាបថ្វាយបង្គំប្រកបដោយបញ្ចង្គប្រតិស្ឋាន បានដល់ការក្រាបថ្វាយបង្គំប្រកបដោយអង្គ ៥ ចុះទៅផ្ទៃដី គឺថ្ងាសមួយ ដៃទាំងពីរ ក្បាលជង្គង់ទាំងពីរ ហើយក្រោក

ឡើងឈរប្រណម្យដៃ រួចលោកក៏បានរំលត់ខន្ធបរិនិព្វាន ដោយឈរផ្អែកទីផភ្នំហិង្គុលបព៌ត ។

គ្រានោះ ព្រះលោកនាយក ទ្រង់ជ្រាបដោយពុទ្ធញាណ ទើបស្តេចព្រមដោយភិក្ខុសង្ឃ ដែលជាសាវកទៅកាន់ភ្នំហិង្គុលបព៌តនោះ ដោយទ្រង់ធ្វើឈាបនកិច្ចសរីរសោកសព របស់ព្រះនាលកត្ថេរ រួចស្រេចហើយ ក៏ឲ្យកសាងព្រះចេតិយបញ្ចុះព្រះធាតុរបស់ព្រះនាលកៈនៅទីផជើងភ្នំ ដែលជាស្ថានទីបរិនិព្វានរបស់លោក ។ គួរឲ្យយើងជ្រះថ្លានោះ ពីព្រោះថា ក្នុងព្រះសាសនាព្រះពុទ្ធមួយអង្គៗ គឺមានសាវក ដែលជាអ្នកព្យាយាម បំពេញនូវមោនេយ្យប្បដិបត្តិបែបនេះតែមួយអង្គប៉ុណ្ណោះ ។

សេចក្តីនេះមិនមែនថា មោនេយ្យប្បដិបត្តិនេះ បដិបត្តិបានត្រឹមតែមួយរូប ឬម្នាក់ អ្នកដទៃៗ បដិបត្តិមិនបាននោះ មិនមែនដូច្នោះទេ ពីព្រោះពាក្យប្រៀនប្រដៅរបស់ព្រះសក្យមុនី ទ្រង់មិនបានប្រៀនប្រដៅឲ្យប្រព្រឹត្តជាច់មុខចំពោះធម៌អ្នកណាមួយឡើយ តែព្រះពុទ្ធតែងតែ

ប្រៀនប្រដៅដល់សព្វសត្វទាំងអស់ឲ្យមានសទ្ធាជ្រះថ្លា បើបុគ្គលណា ដែលជាអ្នកប្រព្រឹត្តប្រតិបត្តិ ទៅតាមពាក្យប្រៀនប្រដៅនោះ នឹងធ្វើឲ្យ បុគ្គលនោះ បានទទួលនូវគុណតម្លៃ ដែលមានព្រះនិព្វានជាទីអវសាន ដូចក្នុងមោនេយ្យប្បដិបត្តិនេះជាដើម ដែលបុគ្គលបានប្រព្រឹត្តនៅជា រឿយៗក្នុងជីវិតប្រចាំថ្ងៃ តែងតែធ្វើឲ្យបុគ្គលនោះដុតកម្ដៅនូវកិលេស ដែលជារបស់មិនស្អាត ឬធ្វើឲ្យបុគ្គលនោះបានចូលដល់នូវអចលនបទ ថែមទាំងធ្វើឲ្យសង្គមបានទទួលសេចក្ដីសុខ និងសេចក្ដីចម្រើនជាដើម ទៀតផង ។៚

( ជីវប្រវត្តិរបស់ព្រះនាលកត្ថេរ ចប់ )

អាស្រមព្រះគន្ធកុដិ ថ្ងៃ ៨ កើត ខែពិសាខ ព.ស. ២៥៥៥

**ដោយប្រធានសមាគមធម្មទានអរិយធន៍ខ្សាយចំស្វាត**

## ឈ្មោះសប្បុរសប្រគេនសម្ភារៈ មានត្រៃចីវរជាដើម
## ក្នុងកិច្ចការទារជាធម្មទាន

✵ឧបាសិកា ហម យិម

ឧបាសក អ៊ឹង ប៊ុនហួរ ឧបាសិកា បួ ម៉ាឡា ព្រមទាំងកូនចៅ

ឧបាសក បួ ស៊ុប៊ូ ឧបាសិកា ថៃ ស៊ីវន ព្រមទាំងបុត្រ

ឧបាសិកា បួ ចន្ធា និងស្វាមី ព្រមទាំងបុត្រ

កញ្ញា បួ ដាវី កញ្ញា អ៊ឹង មុយហៀក

✵លោកម្ចាស់ សោម ហួន

លោកគ្រូធម្មាចារ្យ អៀ សៅ ( ទក្ខប្បញ្ញោ )

ឧបាសក ប៊ូ ហោនាង ឧបាសិកា អ៊ឹង រិទ្ធារី ព្រមទាំងបុត្រធីតា

ឧបាសក យឹម សំណាង ឧបាសិកា យឹម ច័ន្ទបូ(LAURA)+បុត្រធីតា

ឧបាសិកា លីប៉ុលីន ស៊ីមប៉ូ កូនក្មួយ ប៊ុន ឡុង,សេង ឈិនដានេត

លោកអាចារ្យ ផាត សាវឿយ ឧបាសិកា រ៉ាត់ អម +បុត្រធីតា

ឧបាសក សៅ ហ៊ាន ឧបាសិកា មាស មូនីកា +បុត្រធីតា

ឧបាសក សួស ចាន់ធី ឧបាសិកា ឡុង សេង +បុត្រធីតា

ឧបាសក ម៉ៅ វង្ស ឧបាសិកា ឆាន់ កាន់ជួន +បុត្រធីតា

ឧបាសក ម៉ៅ ផុន+សាបូរ៉ាក់ សុខ( SABOREAK SOK )

ឧបាសក យក់ ស៊ីមូរ៉ា ឧបាសិកា តាន់ រ៉ាណា

ឧបាសក អ៊ឹង រិទ្ធី ឧបាសិកា ជូធារី

ឧបាសក មាស សារ៉េត

ឧបាសក លឹម ស៊ាង

ឧបាសក ឈុន គឹមអេង

❃ឧបាសក ឈុំ គឹម គឹមហោ ឧបាសិកា គួ ប៊ុនគាង

ឧបាសក សោម សាខន ឧបាសិកា ឈុំ សុជា (ហៅអាហ្មួយ)

ឧបាសក សារុន សេងហួរ ឧបាសិកា ឈុំ សុរីណែត

ឧបាសក ឈុំ សុរិណា (ហៅប៊ុន ឃឹម) ឧបាសិកា ណៃ គឹមហុង

ឧបាសក ឈុំ សុបូរី ឧបាសិកា កើត កុលាប

❃ឧបាសិកា ច័ន្ទ បុប្ផាណា

ឧបាសក ស្ងួន សុធីរ

ឧបាសិកា ស្ងួន កល្យាណ

ឧបាសិកា ស្ងួន ចរណៃ

ឧបាសិកា សួន កញ្ញារ័ត្ន

✵ឧបាសិកា ម៉ក់ នាង ព្រមទាំងកូនចៅ

ឧបាសក តាំង គឹមប៉ៃ និងភរិយា ព្រមទាំងកូនចៅ

ឧបាសក តាំង គឹមលន់ និងភរិយា ព្រមទាំងកូនចៅ

ឧបាសិកា តាំង លាងងិម និងស្វាមី ព្រមទាំងកូនចៅ

✵ពុទ្ធសាសនបណ្ឌិត្យ អ្នកគ្រូ ម៉ម សុខហេង+ពុទ្ធបរិស័ទ+សៀមរាប

ឧបាសក រស់ សុខ ឧបាសិកា សោម ផាន

ឧបាសិកា នួង ឈុំ សោភ័ណ រស្មី

ឧបាសក ជោគ ឌី ឧបាសិកា ដុះ ចំណាន

ឧបាសិកា វិញ ពូន

✵ឧបាសក ឡាំ ធៀន ឧបាសិកា ស៊ឹន ចន្ទា

ឧបាសក លឹម សេងយូ ឧបាសិកា ឡាំ ចាន់សុភី

ឧបាសក ឡាំ ចាន់ណា ឧបាសិកា ទុច ចាន់សាក់គ្រីយ៉ា

ឧបាសក ឡាំ ដាវណ្ណ ឧបាសិកា ឡាំ ចាន់វ៉ារី

✵ឧបាសក ជុំ លាង ឧបាសិកា ចៀម អ៊ូន ព្រមទាំងបុត្រ

ញោម ឥម្មទ្ទីនិងធូ ញោម ហាន ញោម វ៉ន ញោម ភ័ណ្ឌ ញោម

សុមនា ញោម ជោត ញោម មាស សុភា ញោម ឡៃ លី កញ្ញា នា ញោម ឆាង ញោម ជឹង ឡេង ញោម អៀម ញោម ភួង ញោម អុំភា ញោម សុភា ញោម វល័ក្ខ ញោម ឆាលី លីណា ញោម ថាក ញោម ផារិន ញោម ឈឿន ញោម ឡាង ញោម ស៊ិន ញោម ភាព សាវឿន ញោម ហ៊ន ញោម ប៊ូ សៀកលីវ ញោម យក់ វ៉ាន់ថា ។

✵ឧបាសិកា អ៊ុន ខាត់ណា ឧបាសិកា អ៊ុន ញ៉ាណ ឧបាសក អ៊ុន សេរី

លោក ជែង វស្នូ និងអ្នកស្រី ជុង កុយយ៉ា ព្រមទាំងបុត្រ

✵ឧបាសក អ៊ឹង ហេ្គចឡេង ឧបាសិកា តាំង ប៉ោជីង ព្រមទាំងបុត្រ

លោក ធៃ ហេង អ្នកស្រី អ៊ឹង ស៊ីវគៀង ព្រមទាំងបុត្រ

លោក ភួ ពុយ អ្នកស្រី អ៊ឹង ណាងពិន ព្រមទាំងបុត្រ

លោក អ៊ឹង វណ្ណម៉ៅ អ្នកស្រី ហេង ហ៊ុយទៀង ព្រមទាំងបុត្រ

លោក ប៊ុ ទី អ្នកស្រី តាំង ប៉ោគិម ព្រមទាំងបុត្រ

ឧបាសិកា ជា នាងនិងស្វាមី ព្រមទាំងបុត្រ

✵ឧបាសិកា ង៉ែត យូអេង ព្រមទាំងបុត្រ

ឧបាសិកា គង់ ង៉ោ និងស្វាមី ព្រមទាំងបុត្រ

ឧបាសិកា ច័ន្ទនី និងស្វាមី ព្រមទាំងបុត្រ

✵ឧបាសិកា សាម៉ុល គឹមធន និងអ្នកម្ដាយ

ឧបាសិកា គី វណ្ណហាក់ ព្រមទាំងបុត្រ

លោក សេង យុវនាថ ឧបាសិកា គុជ ឡាំងអេង

ឧបាសិកា ឈន សុភនី ឧបាសក ជីវ និងភរិយា

ឧបាសក សុខ សំ និងភរិយា ព្រមទាំងបុត្រ

ឧបាសក នុត កុសល និងភរិយា ព្រមទាំងបុត្រ

ឧបាសិកា អឿន ភី + អ៊ុំ សុភាព + ឈិត ស្រស់ + សឹម ឡាយ

ញោម ហ៊ឺ ជាង + ជាមុយហាង + គុយ លឹម + សេង មុយនី

ញោម ចៅ ជីវ ស៊ុយលៀប+ថៃ អេង+គឹម ធី+ខៀវ វ៉ន+ គឹម

ញោម នឿង+យាយ ធឹង+គួង កាង+សើន គា+សឿង+គឹម អាង

ញោម សេង ឆេង+ផាន់ វ៉ាន់+យាយ រុ+ឡាំម៉ាលី+ជាន សុផាត

យាយ ម៉ៅ + ពៅ + ឈួន+ ក. កាក់ឡែន+ ហ៊ុង+ ថៃ ង៉ា+ រី រុត្ន

ញោមអ្នកគ្រូ វ៉ាន់ + យុវសិស្ស អ៊ុំ រតនា + សាមណេរ អ៊ុំ វិរៈ

ញោមថៃ ង៉ាថ្មគោល+អ្នកស្រី លេង យ៉ុង+តី លី+នាង ឈៀត

ញោម ហ៊ុង+នាង មឿន+អូនប៉ុប+ ឡាត វ៉ាន់យិន+ ម៉ម សុខហេង

ញោម គឹម ឡេង+តាំង វេន+ យុន+ យាយ ធុច + យាយ យន ញោម ហ៊ន ស៊ម ញោម អឿន ភី+វ៉ាន់ ស៊ុនឡាយ+ផល្លី+សវ៉ាមី ញោម ឡុង សាវី+ជា សុខហ៊ាង+គុយ លឹម+សេង ទូច+ស៊ីវ ទី ញោម ណៃ ហ្គេចណៃ+វ៉ាន់ សុផានី+សា វឿន+សំ គី+ចាន់ ណារ៉ា ញោម ធារ៉ា+យឿត និងស្វាមី+ហួត អេង+អាវ សុវណ្ណី+ណា ស៊ី ញោម យាយ នៅ+ឈុន គាវ+ យាយ ឌី+ សំ វ៉ាន់នី+ គឹម អ៊ី ញោម អៀប សាន្ទួន+ យាយ ហឿន+យាយ ឡាំ+កេន សេងម៉ុំ ស ខាន់ថង+ស៊ី ណាត+យឿន+ចាន់ នី+ផន សារ៉ែន+កោ ហុង ។

# នាមពុទ្ធបរិស័ទនៅសហរដ្ឋអាមេរិកមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

លោកម្ចាស់ សោម ហួន

លោកគ្រូធម្មបណ្ឌិត ( ទក្ខប្បញ្ញោ ) អឿ សៅ

ឧបាសិកា ធឹក ស្រ៊ិន ព្រមទាំងកូនប្រុស អ៊ុង រិទ្ធី និងភរិយា

ឧបាសក ប៊ូហោ នាង ឧបាសិកា អ៊ឹង រិទ្ធារី ព្រមទាំងបុត្រធីតា

ឧបាសក យេមសំណាង ឧបាសិកា យេម ឡារ៉ា ព្រមទាំងបុត្រ

ឧបាសក សៅ ហ៊ាន ឧបាសិកា មាស ម៉ូនីកា ព្រមទាំងបុត្រ

ឧបាសក ឈៀងសារឿន ឧបាសិកា ឈុំ ធដា ព្រមទាំងបុត្រធីតា

ឧបាសក ម៉ៅ វង្ស ឧបាសិកា ធាន់ កាន់ជួង ព្រមទាំងបុត្រ

ឧបាសក និន ហាក់ ឧបាសិកា លុយ ចាន់ថន ព្រមទាំងបុត្រ

ឧបាសិកា ម៉ី ចាន់រ៉ាវី ព្រមទាំងបុត្រធីតា

ឧបាសិកា យ៉ក់ ស៊ីមូរ៉ា ព្រមទាំងបុត្រ

ឧបាសិកា វាន់ចាន់ ព្រមទាំងបុត្រធីតា

ឧបាសិកា ខៀវ ណាត ព្រមទាំងបុត្រធីតា

# នាមពុទ្ធបរិស័ទនៅសហរដ្ឋអាមេរិកមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ឆាយ អ៊ីវស៊ាង ឧបាសិកា ហុង គឹមសែ កូន+ចៅ

ឧបាសិកា យូ ស៊ាងនន្ទលី ព្រមទាំងកូនចៅ

# នាមពុទ្ធបរិស័ទនៅអូស្ត្រាលីមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ប៊ុន ហេង ឧបាសិកា ជុំ សុខុម

ឧបាសិកា ហេង ស្រីជា ឧបាសិកា ហេង ស្រីចន្ទ

ឧបាសិកា ហេង គន្ធា ឧបាសក ហេង សុកត្រ័

# នាមពុទ្ធបរិស័ទនៅខេត្តបាត់ដំបងមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក អ៊ឹង ហ្គិចឡេង ឧបាសិកា តាំង ប៉េងជីង ព្រមទាំងកូនចៅ

ឧបាសក វៀម ឈឺន ឧបាសិកា ប៊ូ ម៉ុន ព្រមទាំងកូនចៅ

ឧបាសក ញ៉ែម មឿន ឧបាសិកា វៀម ផុល ព្រមទាំងកូនចៅ

ឧបាសក អ៊ុំង ប៊ុនហួរ ឧបាសិកា បួ ម៉ាឡា ព្រមទាំងកូនចៅ

ឧបាសក ឈុំ គឹមហោ ឧបាសិកា គួ ប៊ុនគាង ព្រមទាំងកូនចៅ

ឧបាសក សោម សាខន ឧបាសិកា ឈុំ សុផា ព្រមទាំងកូន

ឧបាសក នាង រ៉ា ឧបាសិកា តែម ផារីម ព្រមទាំងកូនចៅ

ឧបាសក សៅ ស៊ិន្ទូរា ឧបាសិកា ប៊ុន មុំ ព្រមទាំងកូនចៅ

ឧបាសក ណូ ស្វែង ឧបាសិកា សោម គឹមលួន ព្រមទាំងកូនចៅ

ឧបាសិកា ង៉ិន យ៉ុន ឧបាសិកា សួស សុខា ព្រមទាំងកូនចៅ

ឧបាសិកា សោម គឹមលៀម និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា គឹម ធវី និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា ទាវ គឹមយក់ ឧបាសិកា អ៊ឹម គឹមជីវ

ឧបាសិកា គី វណ្ណហាក់ ឧបាសិកា ឡាំ ម៉ាលី

ឧបាសិកា ហួត អេង ឧបាសិកា ឡោ សាយហ៊ួច

ឧបាសិកា ង៉ែត យូអេង ព្រមទាំងកូនក្មួយ

ឧបាសិកា ហោ ភាព ព្រមទាំងកូនក្មួយ

ឧបាសិកា អ៊ុក នៅ ព្រមទាំងបុត្រ

ឧបាសិកា សៀង ព្រមទាំងបុត្រ

# នាមពុទ្ធបរិស័ទនៅស្ទឹងមានជ័យភ្នំពេញមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសិកា ឆេង ស៊ីម ព្រមទាំងកូនចៅ

លោក លី ហុង លោកស្រី ជា ណារី ព្រមទាំងបុត្រ ធីតា

លោក ផូ ចាន់ថន លោកស្រី ជា ណាវី ព្រមទាំងបុត្រ ធីតា

លោក លឹម ចាន់ឌី លោកស្រី ទេព ចិន្តា ព្រមទាំងបុត្រ ធីតា

កញ្ញា ហុង លីដា

លោក ហុង សុវណ្ណតារា និងភរិយា លឹម ចាន់មុនីរ័ត្ន

ឧបាសក ហុង សុវណ្ណរិទ្ធ

ឧបាសក ហុង សុវណ្ណរ៉េត

យុវជន ហុង ប៊ុនឡុង

ឧបាសក ហ៊ុន ហេងគង់ ឧបាសិកា ទូច សារុន ព្រមទាំងកូនចៅ

ឧបាសិកា ធុយ ឈីវអួន ព្រមទាំងកូនចៅ

ឧបាសក យ៉ែម យ៉ន ឧបាសិកា យ៉ង់ ទូច ព្រមទាំងកូនចៅ

ឧបាសក មិន ម៉ាង ឧបាសិកា ឈិន គីមហ៊ាន ព្រមទាំងកូនចៅ

ឧបាសិកា ជា សុផល ព្រមទាំងកូនចៅ

ឧបាសិកា មៀច យ៉ន ព្រមទាំងកូនចៅ

ឧបាសិកា មុំ សុន ព្រមទាំងកូនចៅ

លោក លន់ វ៉ាន់ថា លោកស្រី មុំ ដាន់ ព្រមទាំងបុត្រ ធីតា

លោក ចាប សោភ័គ លោកស្រី មុំ ដា ព្រមទាំងបុត្រ ធីតា

លោក ឈឹន សាគឹម លោកស្រី ខឹម អូន ព្រមទាំងបុត្រ ធីតា

លោក រស់ ប៊ុនឡេង លោកស្រី ឡេង ស៊ីនី ព្រមទាំងបុត្រ ធីតា

ឧបាសិកា ឈួន សុ ព្រមទាំងកូនចៅ

ឧបាសិកា ថ្វាង តាំងគៀន ព្រមទាំងកូនចៅ

ឧបាសិកា ប៉ែន នាង ព្រមទាំងកូនចៅ

ឧបាសិកា អៀវ ងីម និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា ហ៊ុន ដារ៉ុង ព្រមទាំងកូនចៅ

ឧបាសិកា គីម សេង ព្រមទាំងកូនចៅ

ឧបាសិកា ហួយ ជន ព្រមទាំងកូនចៅ

ឧបាសិកា រ័ត្ន សុផល ព្រមទាំងកូនចៅ

លោកស្រី ជុន បូណ៌មី និងស្វាមី ព្រមទាំងបុត្រ

ឧបាសិកា ជា ព្រមទាំងកូនក្មួយ

ឧបាសិកា គឹម អាន់ ព្រមទាំងកូនចៅ

ឧបាសិកា ជាវ ស៊ីយន ព្រមទាំងកូនចៅ

លោក កេត ចាន់តារា

លោក កេត សំបូរ និង កុមារី សុជាតា

ឧបាសិកា ជា រួចទៀង ព្រមទាំងកូនចៅ

ឧបាសក ជឹ សុខអៀម ឧបាសិកា តាំង ស៊ូអេង ព្រមទាំងកូនចៅ

ឧបាសិកា តាំង ស៊ូហៀង ព្រមទាំងកូនចៅ

ឧបាសិកា ជឹ ញ៉េ ព្រមទាំងកូនចៅ

ឧបាសិកា ខៀវ សុធី ហៅ អ៊ុំម៉ៅ ព្រមទាំងកូនចៅ

ឧបាសិកា ទូច ព្រមទាំងកូនចៅ

ឧបាសក ឡាយ ឧបាសិកា លន់ ព្រមទាំងកូនចៅ

ឧបាសិកា ជាវ ហ៊ិន ព្រមទាំងកូនចៅ

ឧបាសិកា មិល មម ព្រមទាំងកូនចៅ

ឧបាសក រស់ ស្រេង ឧបាសិកា ឡា ហ៊ុយឡេង ព្រមទាំងកូនចៅ

ឧបាសិកា ឡា ស៊ីវឡេង ព្រមទាំងកូនចៅ

ឧបាសិកា គី បួយ ព្រមទាំងកូនចៅ

លោក យឹម សារ៉ាវិទ្ធ លោកស្រី រស់ ចិន្តា ព្រមទាំងបុត្រ

កុមារា យាន ពិសិដ្ឋ

ឧបាសិកា យន សាក ព្រមទាំងកូនចៅ

ឧបាសិកា ហោ យិចឡាំង ព្រមទាំងកូនចៅ

ឧបាសិកា ហ៊ុន ចាន់ថា ព្រមទាំងកូនចៅ

ឧបាសិកា ជី ជុន ព្រមទាំងកូនចៅ

ឧបាសិកា លឹម ម៉ាលី (គីម ហ៊ួយ) និងស្វាមី ព្រមទាំងបុត្រ ធីតា

ឧបាសិកា ស៊ុន ឡាប ព្រមទាំងក្រុមគ្រួសារ

ឧបាសក ប៊ុន បួន ឧបាសិកា យុត សួគ៌ ព្រមទាំងកូនចៅ

លោក ផាន សុបិន អ្នកស្រី សំ សុវណ្ណមល្លិកា ព្រមទាំងបុត្រ

បងស្រី ណៅ សុភី និង ប្អូនស្រី ណៅ សុផល

ឧបាសិកា ឈឹន សុន ព្រមទាំងកូនចៅ

លោក ម៉ាន់ រិទ្ធី និង អ្នកស្រី អ៊ួន សារ៉េត ព្រមទាំងបុត្រ

លោក ឱម ឡូត លោកស្រី ស៊ុំ ស្រីពៅ ព្រមទាំងបុត្រ

លោក ម៉ាន់ សារឿន លោកស្រី ម៉ម សុជា ព្រមទាំងបុត្រ

លោក ស៊ឹម សារ៉ាន់ លោកស្រី លី សុខរ៉េត ព្រមទាំងបុត្រ

ឧបាសក ទិត្យ លី ឧបាសិកា ហេង វណ្ណា ព្រមទាំងកូនចៅ

ឧបាសិកា ថោង គីមលន់ ព្រមទាំងកូនចៅ

ឧបាសិកា ប៉ូ ប៉ុក ព្រមទាំងកូនចៅ

ឧបាសិកា សោម សូត្រ ព្រមទាំងកូនចៅ

ឧបាសិកា ឈឹន សង់ ព្រមទាំងកូនចៅ

លោក ឈឹន ចំរើន លោកស្រី ហោ វាសនា ព្រមទាំងបុត្រធីតា

ឧបាសិកា ប៉េ សារ៉ា(ម្តាយ) ឧបាសក ម៉ុី ធារី

ឧបាសិកា ម៉ៅ ណារី ព្រមទាំងកូនចៅ

ឧបាសក ប៉ែ ស៊ីថា ឧបាសិកា ង៉ួន សាលីន ព្រមទាំងកូនចៅ

ឧបាសិកា ប៉ូច សាមុត ព្រមទាំងកូនចៅ

ឧបាសិកា មាស អួន ព្រមទាំងកូនចៅ

ឧបាសក សៅ ម៉េង ឧបាសិកា ថោង វង្ស ព្រមទាំងកូនចៅ

ឧបាសិកា ថោង វ៉េត ព្រមទាំងកូនចៅ

ឧបាសក ជូ ប៊ូរិន ឧបាសិកា ហែម យ៉ានី ព្រមទាំងកូនចៅ

អ្នកគ្រូ ឱម សុផាត ព្រមទាំងកូនចៅ

ឧបាសក ធីង ផាត់ ឧបាសិកា ណុប សៀងហេង ព្រមទាំងកូនចៅ

លោក អ៊ិត សារឿន លោកស្រី ញឹក សោភ័ណ ព្រមទាំងបុត្រ

# នាមពុទ្ធបរិស័ទរួមមានឧបការៈក្នុងការទោរធម្មទាន

១- ឧបាសិកា ប៉េង តាំង ឧបាសិកា ហ៊ូ គឹមឡៀក

២- ឧបាសក ស្រេង ស្រ៊ាង ឧបាសិកា គិម ចន្ថា

៣- ឧបាសក ឡាយ សុខុម ឧបាសិកា គី គឹមហាប់

៤- ឧបាសិកា បួ ម៉ាឡា កញ្ញា បួ ដាវី

៥- ឧបាសិកា ង៉ែង យូអេង កញ្ញា អ៊ុឹង មុយហៀក

៦- ឧបាសក លឹម ខូង ឧបាសិកា កែវ អុន

៧- ឧបាសិកា កែវ កល្យាណ ឧបាសិកា សុខ សុទ្ធី

៨- ឧបាសិកា សឹន ចន្ថា លោក ឡាំ ដាវណ្ណ

៩- ឧបាសិកា គួ ប៊ុនគាង ឧបាសិកា ឈុំ សុធា

១០- ឧបាសិកា នេត្រ នរិន្ទ ឧបាសិកា ទន់

១១-ឧបាសិកា ឱម លក្ខណា ឧបាសិកា ហេង ច័ន្ទបុញ្ញវន្តី

១២-ឧបាសិកា គី យក់បួយ ឧបាសិកា ឈុន ណាត

១៣-ឧបាសិកា អ៊ុឹង រិទ្ធារី ឧបាសក អ៊ុន សេរី

១៤-ឧបាសិកា វៀម ថុល ឧបាសិកា ម៉ៅ នី

១៥-ឧបាសិកា សន ឈៀត ឧបាសក ឡាន សុខុម

១៦-ឧបាសិកា គី វណ្ណហាក់ ឧបាសិកា ប៉ាន ណាម

១៧-ឧបាសិកា ស្ងួន កល្យាណ ឧបាសិកា ភយង់ កក្តី

១៨-ឧបាសក អ៊ឹង វ៉ៃយ៉ា ឧបាសក កុយ សាមន

១៩-ឧបាសក ហុង សុវណ្ណារិទ្ធ ឧបាសក ហុង សុវណ្ណារ៉េត

ខ្ញុំព្រះករុណា អាត្មាភាពមានបំណងនឹងបោះពុម្ពសៀវភៅព្រះធម៌ជាច្រើនមុខទៀត ដើម្បីចែកជាធម្មទាន បើញាតិញោមពុទ្ធបរិស័ទ មានបំណងចង់ចូលរួមបោះពុម្ពសៀវភៅជាធម្មទាននោះ សូមទំនាក់ទំនងតាមរយៈលេខទូរស័ព្ទនេះ ០១២ ៣០៥ ៧៦៦, ០៨ ៨៨ ៧៧ ៩៩ ៦៦ ០៧៧ ៦៦ ៦៦ ៣៨ ចំពោះសៀវភៅដែលត្រូវបោះពុម្ពនោះ ដូចមានខាងក្រោមនេះ គឺ

**-ជីវប្រវត្តិពុទ្ធឧបាសក** មាន ៥ ភាគ ដែលជាភាគបញ្ចប់ ហើយសព្វថ្ងៃនេះ ក៏បានធ្វើចប់រួចអស់ហើយដែរ ទាំង ៥ ភាគ នៅតែមានការបោះពុម្ពជាបន្តបន្ទាប់ទៀតតែប៉ុណ្ណោះ ។

**-ជីវប្រវត្តិពុទ្ធឧបាសិកា** មាន ៤ ភាគ ដែលជាភាគបញ្ចប់ ហើយ

សព្វថ្ងៃនេះ ក៏បានធ្វើចប់រួចអស់ហើយដែរ ទាំង ៤ ភាគ នៅតែមានការបោះពុម្ពជាបន្តបន្ទាប់ទៀតតែប៉ុណ្ណោះ ។

-**វចនានុក្រមព្រះអភិធម្ម ៧ គម្ពីរ** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់ រហូតទៅដល់ ៨៣៣ ទំព័រ ។

-**វិសុទ្ធិមគ្គ** និង **បរមត្ថមញ្ជូសាមហាដីកា បញ្ញានិទ្ទេស** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេចដែរ ដែលមាន ៣ ភាគ ។

-**គម្ពីរសារត្ថសង្គហៈ** ហើយសព្វថ្ងៃនេះ បានធ្វើរួចជាស្ថាពរ គឺវាយកុំព្យូទ័ររួចជាស្រេចអស់ហើយទាំង ២ ភាគ ដែលមានកម្រាស់ រហូតទៅដល់ ៦០០ ទំព័រជាង ។

-**គម្ពីរអភិធម្មត្ថសង្គហៈ** និង **វិភាវិនីដីកា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់ រហូតទៅដល់ ៦៥០ ទំព័រជាង ។

-**អភិធម្មត្ថសង្គហៈ** និង **បរមត្ថទីបនីដីកា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់

រហូតទៅដល់ ៩៨៩ ទំព័រជាង ។

-គម្ពីរអភិធម្មាវតា សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៥៩៧ ទំព័រ ។

-មិលិន្ទបញ្ហា សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៥០០ ទំព័រ ។

-រឿងរ៉ាវដែលទាកទង់ នឹងពុទ្ធស្ថាន បានធ្វើសម្រេចជាស្ថាពរហើយ ដែលមានចំនួន ៥ ភាគ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៦០០-៧០០ ទំព័រជាងក៏មាន ។

-ខ្ញុំព្រះករុណា អាត្មាភាព មានបំណងនឹងរាបចំធ្វើ គម្ពីរព្រះត្រៃបិដក និងគម្ពីរព្រះអដ្ឋកថា បញ្ចូលជាមួយគ្នា ដោយដាក់ព្រះត្រៃបិដកហើយ ដាក់ព្រះអដ្ឋកថាពីខាងក្រោមព្រះត្រៃបិដក ក្នុងការបញ្ចូលគម្ពីរព្រះត្រៃបិដក និងគម្ពីរព្រះអដ្ឋកថាជាមួយគ្នានោះ ព្រះត្រៃបិដកយកតាមបិដកខ្មែរយើង ដែលមាន ១១០ ក្បាល ។

-ព្រះត្រៃបិដកខ្មែរយើងដែលមាន ១១០ ក្បាល បានវាយកុំព្យូទ័រចប់ហើយ ( ០១.០៥.២០១០, ២៧.០៣.២០១១ ) ។

-ការដាក់ព្រះត្រៃបិដក និងអដ្ឋកថាបញ្ចូលជាមួយគ្នានោះ ដែលធ្វើសម្រេចជាស្ថាពរនោះ មានដូចខាងក្រោមនេះ គឺ

-គម្ពីរវិន័យបិដក បានធ្វើរួចជាស្រេចហើយ មានចំនួន ១៤ភាគ

-គម្ពីរទីឃនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ៦ ភាគ

-គម្ពីរមជ្ឈិមនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ៩ ភាគ

-គម្ពីរសំយុត្តនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ១១ ភាគ

-គម្ពីរអង្គុត្តរនិកាយ កំពុងតែប្រែជិតចប់ហើយដែរ

-គម្ពីរខុទ្ទកនិកាយ ប្រែបាន ៦ ភាគហើយ

សរុបការប្រែព្រះត្រៃបិដក និងអដ្ឋកថាបញ្ចូលជាមួយគ្នានោះ សព្វថ្ងៃនេះ បានចំនួន ៥០ ក្បាលជាងហើយ ។

# សៀវភៅដែលប្រមូលរៀបរៀង និងបោះពុម្ពហើយដោយ
# ខ្ញុំព្រះករុណា អាត្មាភាព
# ✍ យង់ សុផាត ✍

-ជីវប្រវត្តិព្រះអសីតិមហាសាវក មាន ៨ ភាគ ពីភាគ ១ ដល់ភាគ ៨

-ជីវប្រវត្តិព្រះពុទ្ធសាវិកា មាន ៤ ភាគ ពីភាគ ១ ដល់ភាគ ៤

-ជីវប្រវត្តិព្រះពុទ្ធឧបាសក មាន ៥ ភាគ ពីភាគ ១ ដល់ភាគ ៥

-រឿងរ៉ាវដែលទាក់ទងនឹងពុទ្ធស្ថាន មាន ៥ ភាគ ពីភាគ ១ ដល់ភាគ ៥

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា សីលនិទ្ទេស មួយភាគ ១

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា សមាធិនិទ្ទេស មាន ៤ ភាគ

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា បញ្ញានិទ្ទេស ភាគ ១

-ធម៌សូធ្យនមស្ការបែបសម័យទំនើប

-គម្ពីរមហាសតិប្បដ្ឋានភាវនា

-គម្ពីរសារត្ថសង្គហៈ ភាគ ១

-ពុទ្ធប្បវត្តិ

សូមអនុមោទនាធម្មទាន !!!






# នឹកឃើញស្រុកព្រះ

នឹកឃើញស្រុកព្រះ  បានក្រាបសំពះ  អង្គព្រះសាស្ដា<br>
សិរសាលំទោន  ទុកដូចឈូកផ្កា  បូជាសាស្ដា<br>
ជ្រះថ្លាក្រៃលែង ។<br>
៦៥ អង្គា  គាល់ព្រះភគវា  ៥១ កន្លែង<br>
នៅស្រុកឥណ្ឌា  ចង់ចាំមិនលែង  សោមនស្សពន់ពេក<br>
ក្នុង ព.ស.២៥៥០ ។